ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សន្និបាត



## បូកសរុបលទ្ធផលការងារ

## អប់រំ យុវជន និងកីឡា

## ឆ្នាំសិក្សា២០១៩ - ២០២០ និងទិសដៅ

## ឆ្នាំសិក្សា២០២០ - ២០២១

ថ្ងៃទី២៨ -២៩ ខែមេសា ឆ្នាំ២០២១

| មាតិកា | ទំព័រ |
|---|---|
| **ផ្នែកទី១ ៖ លទ្ធផល និងទិសដៅ** | |
| **១. សេចក្តីផ្តើម** | ១ |
| **២. វឌ្ឍនភាព** | ១ |
| **២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា** | ១ |
| ២.១.១ វឌ្ឍនភាពនៃការសម្រេចបានសូចនាករពិនិត្យតាមដានរួមគ្នា | ១ |
| ២.១.២ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល | ២ |
| ២.១.៣ វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាផ្អែកលើសសរស្តម្ភទាំង៥ | ៤ |
| ២.១.៤ វឌ្ឍនភាពនៃការគ្រប់គ្រងនិងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ | ៩ |
| ២.១.៤.១ វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការ ស្ថិតិ និងការពិនិត្យតាមដាននិងវាយតម្លៃ | ៩ |
| ២.១.៤.២ វឌ្ឍនភាពនៃការអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ | ១០ |
| ២.១.៤.៣ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ច្បាប់ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ២០ |
| ២.១.៤.៤ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ | ២៣ |
| ២.១.៤.៥ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ២៥ |
| ២.១.៥ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ ថ្នាក់ជាតិ | ៣២ |
| ២.១.៦ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៩-២០២០ ថ្នាក់ជាតិ | ៣៥ |
| ២.១.៧ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០២០ | ៣៧ |
| ២.១.៨ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំសិក្សា២០១៩-២០២០ រាជធានី ខេត្ត | ៣៨ |
| **២.២ លទ្ធផលតាមអនុវិស័យ** | ៤០ |
| ២.២.១ អនុវិស័យ ការអប់រំកុមារតូច | ៤០ |
| ២.២.២ អនុវិស័យ ការអប់រំបឋមសិក្សា | ៥០ |
| ២.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ៧៥ |
| ២.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា | ១០០ |
| ២.២.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ១១៥ |
| ២.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន | ១៣១ |
| ២.២.៧ អនុវិស័យ ការអប់រំកាយ និងកីឡា | ១៣៨ |
| **៣. ទិសដៅឆ្នាំសិក្សា ២០២០-២០២១** | ១៤៦ |
| **៣.១ ទិសដៅតាមអនុវិស័យ** | ១៤៦ |
| ៣.១.១ អនុវិស័យ ការអប់រំកុមារតូច | ១៤៦ |
| ៣.១.២ អនុវិស័យ ការអប់រំបឋមសិក្សា | ១៤៦ |
| ៣.១.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ១៤៧ |
| ៣.១.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា | ១៤៧ |
| ៣.១.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ១៤៨ |
| ៣.១.៦ អនុវិស័យ ការអភិវឌ្ឍយុវជន | ១៤៨ |
| ៣.១.៧ អនុវិស័យ ការអប់រំកាយ និងកីឡា | ១៤៨ |
| **៣.២ បញ្ហាប្រឈម និងទិសដៅកំណែទម្រង់ឆ្លងអនុវិស័យ** | ១៤៩ |
| ៣.២.១ ការពង្រឹងការងារគោលនយោបាយ ផែនការ ស្ថិតិ និងការពិនិត្យតាមដាននិងវាយតម្លៃ | ១៤៩ |
| ៣.២.២ ការងារវិមជ្ឈការ និងវិសហមជ្ឈការ | ១៤៩ |
| ៣.២.៣ ការងារគ្រប់គ្រងបុគ្គលិក | ១៥០ |
| ៣.២.៤ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១៥០ |
| ៣.២.៥ ការងារកិច្ចលទ្ធកម្ម | ១៥១ |
| ៣.២.៦ ការងារបណ្តុះបណ្តាល និងក្រឹតការ | ១៥២ |

| | |
|---|---|
| ៣.២.៧ ការងារអភិវឌ្ឍន៍កម្មវិធីសិក្សា | ១៥៣ |
| ៣.២.៨ ការងាររដ្ឋបាល | ១៥៣ |
| ៣.២.៩ ការងារសំណង់សិក្សា | ១៥៣ |
| ៣.២.១០ ការងារបោះពុម្ព និងចែកផ្សាយ | ១៥៤ |
| ៣.២.១១ ការងារអធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | ១៥៤ |
| ៣.២.១២ ការងារសវនកម្មផ្ទៃក្នុង | ១៥៤ |
| ៣.២.១៣ ការងារធានាគុណភាពអប់រំ | ១៥៥ |
| ៣.២.១៤ ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ១៥៦ |
| **៤. សេចក្តីសន្និដ្ឋាន** | ១៥៦ |
| **ផ្នែកទី២ ៖ ឧបសម្ព័ន្ធ** | |
| ឧបសម្ព័ន្ធទី១៖ ចំនួនសកម្មភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ ថ្នាក់ជាតិ | ១៥៩ |
| ឧបសម្ព័ន្ធទី២៖ ចំនួនសកម្មភាពនៃទិសដៅសន្និបាតអប់រំឆ្នាំសិក្សា២០១៩-២០២០ ថ្នាក់ជាតិ | ១៦១ |
| ឧបសម្ព័ន្ធទី៣៖ ចំនួនសកម្មភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ រាជធានី ខេត្ត | ១៦២ |
| ឧបសម្ព័ន្ធទី៤៖ ចំនួនសកម្មភាពនៃទិសដៅសន្និបាតអប់រំឆ្នាំសិក្សា២០១៩-២០២០ រាជធានី ខេត្ត | ១៦៣ |
| ឧបសម្ព័ន្ធទី៥៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៩-២០២០ កំណែទម្រង់សំខាន់ៗ និងឆ្លងអនុវិស័យ | ១៦៤ |
| ឧបសម្ព័ន្ធទី៦៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា២០១៩-២០២០ តាមអនុវិស័យ | ១៧៤ |
| ឧបសម្ព័ន្ធទី៧៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០២០ | ១៨១ |
| ឧបសម្ព័ន្ធទី៨៖ វឌ្ឍនភាពការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ ថ្នាក់ជាតិ | ១៨៧ |
| **ផ្នែកទី៣ ៖ ប្រធានបទពិភាក្សា** | |
| ប្រធានបទពិភាក្សា | ២៤៣ |

# ផ្នែកទី១

# លទ្ធផល និងទិសដៅ

## ១. សេចក្តីផ្តើម

ឆ្នាំសិក្សា២០១៩-២០២០ ជាឆ្នាំទី២ ដែលក្រសួងអប់រំ យុវជន និងកីឡា អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា និងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីជាអាទិភាព ស្របតាមក្របខណ្ឌផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ សំដៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០។

តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ និងយុទ្ធសាស្ត្រកំណែទម្រង់ ដោយរំពឹងថា នៅពេលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹង ស្របតាមស្តង់ដាមួយ ព្រមទាំងអាច ប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ ការអនុវត្តការងារតាមអនុវិស័យ និងការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ បានឆ្លុះបញ្ចាំងនៅក្នុងខ្លឹមសារនៃរបាយការណ៍សន្និបាតអប់រំ ដើម្បីជាមូលដ្ឋានសម្រាប់ ពិនិត្យឡើងវិញពីសកម្មភាព និងចំណុចដៅរបស់សូចនាករបំពេញការងារគន្លឹះ។ ទោះបីមានផលប៉ះពាល់ ដោយសារ ជំងឺរាតត្បាតកូវីដ-១៩ក្តី ក៏វិស័យអប់រំ យុវជន និងកីឡា ដោយមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន នៅតែដំណើរការសិក្សារៀនសូត្រ ដោយបានជំរុញឱ្យមានការសិក្សាតាមអនឡាញ ឬតាមវិធីចម្រុះ។

របាយការណ៍សន្និបាតអប់រំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍រួមរបស់ក្រសួង និងតាមអនុវិស័យ ទាំង៧ រួមមាន៖ ការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា។ លទ្ធផលសន្និបាតអប់រំនឹងក្លាយជាមូលដ្ឋានដ៏មាន សារៈសំខាន់ ក្នុងការពិនិត្យឡើងវិញគោលនយោបាយអប់រំ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិ ប្រចាំឆ្នាំ។

ក្នុងឆ្នាំសិក្សា២០១៩-២០២០កន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចលទ្ធផលធំៗដូចតទៅ ៖

## ២. វឌ្ឍនភាព

### ២.១ លទ្ធផលរួមរបស់វិស័យអប់រំ យុវជន និងកីឡា

### ២.១.១ វឌ្ឍនភាពនៃការសម្រេចបានសូចនាករពិនិត្យតាមដានរួមគ្នា

ក្រសួងបានសម្រេចគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាពជាអាទិភាព តាមរយៈសូចនាករ ពិនិត្យតាមដានរួមគ្នាដូចខាងក្រោម៖

**តារាងទី១ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករពិនិត្យតាមដានរួមគ្នា**

| លទ្ធផល ២០១៨-២០១៩ | សូចនាករ លទ្ធផល | ជាក់ស្តែង ២០១៨-១៩ | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| ផលសម្រេច ២០១៩-២០២៣ ៖ អត្រាបញ្ចប់ការសិក្សានៅអប់រំមូលដ្ឋាន កើនឡើងជាមួយនឹងលទ្ធផលសិក្សាល្អប្រសើរ | | | | | | |
| ១. អត្រាត្រួតថ្នាក់នៅបឋមសិក្សាថយចុះ ពិសេសនៅថ្នាក់ដំបូង | ១. អត្រាត្រួតថ្នាក់នៅបឋមសិក្សាថយចុះពី ៦,២% (ប្រុស ៧,៧% ស្រី ៤,៧%) ក្នុងឆ្នាំសិក្សា ២០១៧-១៨ ដល់ ៥,៧% (ប្រុស ៦,៨% ស្រី ៤,១%) ក្នុងឆ្នាំសិក្សា ២០១៩-២០ | សរុប ៦,២% (ប្រុស ៧,៧% ស្រី ៤,៧%) (២០១៧-១៨) | សរុប ៦,៣% (ប្រុស ៧,៨% ស្រី ៤,៧%) (២០១៨-១៩) | សរុប ៥,៧% (ប្រុស ៦,៨% ស្រី ៤,១%) (២០១៩-២០) | សរុប ៧,០% (ប្រុស ៨,៧% ស្រី ៥,៣%) (២០១៩-២០) | ↓ |

| | | | | | | |
|---|---|---|---|---|---|---|
| ២. លទ្ធផលសិក្សារបស់សិស្សនៅបឋមសិក្សាកើនឡើង (អំណាន និងគណិតវិទ្យាថ្នាក់ទី៣ - ការសរសេរ និងគណិតវិទ្យាថ្នាក់ទី៦) | ២.១. ភាគរយសិស្សសម្រេចបាន "លទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋាន" **នៅថ្នាក់ទី៣៖**<br>-អំណាន៖ ថយចុះពី ៥២,៦% ក្នុងឆ្នាំសិក្សា២០១៤-១៥ ដល់ ៤៦,៦% ឆ្នាំសិក្សា២០១៩-២០<br>-គណិតវិទ្យា៖ ថយចុះពី ៤៤,៩% ឆ្នាំសិក្សា២០១៤-១៥ ដល់ ៣៨,៩% ក្នុងឆ្នាំសិក្សា ២០១៩-២០ | | អំណាន<br>៥០,៥%<br>(២០១៨-១៩)<br><br>គណិតវិទ្យា<br>៤០,៩%<br>(២០១៨-១៩) | អំណាន<br>៤៦,៦%<br>(២០១៩-២០)<br><br>គណិតវិទ្យា<br>៣៨,៩%<br>(២០១៩-២០) | អនុវត្តនៅឆ្នាំ ២០២៣-២៤ | |
| | ២.២. ភាគរយសិស្សសម្រេចបាន "លទ្ធផលសិក្សាក្រោមកម្រិតមូលដ្ឋាន" **នៅថ្នាក់ទី៦៖**<br>-ការសរសេរ៖ ថយចុះពី ៣៩,៦% ក្នុងឆ្នាំសិក្សា ២០១៥-១៦ ដល់ ៣៣,៦% ក្នុងឆ្នាំសិក្សា ២០២០-២១<br>- គណិតវិទ្យា៖ ថយចុះពី ៥៣,២% ឆ្នាំសិក្សា២០១៥-១៦ ដល់ ៤៧,២% ក្នុងឆ្នាំសិក្សា ២០២០-២១ | | | សរសេរ<br>៣៣,៦%<br>(២០២០-២១)<br><br>គណិតវិទ្យា<br>៤៧,២%<br>(២០២០-២១) | អនុវត្តនៅឆ្នាំ ២០២១-២២ | |
| ៣. អត្រានៃការសិក្សាកើនឡើង និងអត្រាបោះបង់ថយចុះនៅមធ្យមសិក្សាបឋមភូមិ | ៣.១. អត្រាសរុបនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (GER) កើនពី៥៩,១% (ប្រុស៥៤,៩% ស្រី ៦៣,៨%) ឆ្នាំសិក្សា ២០១៨-១៩ដល់ ៦២,២% (ប្រុស ៥៩,១% ស្រី ៦៦,៨%) ឆ្នាំសិក្សា ២០១៩-២០ | ៥៩,១%<br>(ប្រុស ៥៤,៩%<br>ស្រី ៦៣,៨%) | ៥៩,៩%<br>(ប្រុស ៥៥,១%<br>ស្រី ៦៥,១%) | ៦៣,៧%<br>(ប្រុស៦៦,១%<br>ស្រី ៦៨,៦%) | ៦០,៧%<br>(ប្រុស៥៥,៣%<br>ស្រី ៦៦,៦%) | → |
| | ៣.២. អត្រាបោះបង់នៅមធ្យមសិក្សាបឋមភូមិថយចុះពី ១៥,៨% (ប្រុស ១៧,៦% ស្រី ១៤,២%) ឆ្នាំសិក្សា ២០១៧-១៨ ដល់ ១២,៨% (ប្រុស១៣,៨% ស្រី១១,៧%) ឆ្នាំសិក្សា២០១៩-២០។ | ១៥,៨%<br>(ប្រុស១៧,៦%<br>ស្រី ១៤,២%)<br>(២០១៧-១៨) | ១៨,៦%<br>(ប្រុស២០,០%<br>ស្រី១៧,៤%<br>(២០១៨-១៩) | ១២,៨%<br>(ប្រុស១៣,៨%<br>ស្រី១១,៧%<br>(២០១៩-២០) | ១៨,២%<br>(ប្រុស១៩,៦%<br>ស្រី១៦,៩%<br>(២០១៩-២០) | ↓ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

តារាងទី១៖ បង្ហាញថា ការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិមានការកើនឡើងដោយជិតសម្រេចបានតាមចំណុចដៅ (៦៣,៧ភាគរយ)។ អត្រាលំហូរសិស្សនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិមិនសម្រេចបានតាមចំណុចដៅ។ លទ្ធផលវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ពន្យាពេលអនុវត្តដល់ឆ្នាំសិក្សា២០២១-២០២២។

## ២.១.២ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

ក្រសួងបានសម្រេចគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាពជាអាទិភាព តាមរយៈសូចនាករស្នូលដូចខាងក្រោម៖

## តារាងទី២ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| | សូចនាករស្នូល | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| ១. | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ (ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៦២,៩ | ៦១,៩ | ៦១,១ | ↓ |
| | *ប្រុស* | % | ៦២,០ | ៦១,៣ | ៥៨,៦ | ↓ |
| | *ស្រី* | % | ៦៣,៦ | ៦២,៧ | ៦២,៣ | ↓ |
| ២. | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨៨,២* | ៨៤,៨ | ៨៧,៤* | ↑ |
| | *ប្រុស* | % | ៨៤,១* | ៨២,៦ | ៨៣,៤* | ↑ |
| | *ស្រី* | % | ៩២,៧* | ៨៩,២ | ៩១,៦* | ↑ |
| ៣. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៤៧,៣* | ៥០,២ | ៤៨,១* | ↓ |
| | *ប្រុស* | % | ៤២,៤* | ៤៦,៩ | ៤៣,១* | ↓ |
| | *ស្រី* | % | ៥២,៥* | ៥៤,២ | ៥៣,៤* | ↓ |
| ៤. | ភាគរយសិស្សសម្រេចបានកម្រិតសមត្ថភាពក្រោមកម្រិតមូលដ្ឋាន មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា | | | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៣* | % | ៥០,៥% (២០១៨-១៩) | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២៣-២៤ | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៣* | % | ៦២,១ (២០១៨-១៩) | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២៣-២៤ | |
| | *គណិតវិទ្យាថ្នាក់ទី៣* | % | ៤០,៩% (២០១៨-១៩) | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២៣-២៤ | |
| | *ការអានភាសាខ្មែរថ្នាក់ទី៦* | % | មិនទាន់អនុវត្ត | ២៥,៥ | អនុវត្តនៅឆ្នាំ ២០២០-២១ | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៦* | % | មិនទាន់អនុវត្ត | ៣៣,៦ | អនុវត្តនៅឆ្នាំ ២០២០-២១ | |
| | *គណិតវិទ្យាថ្នាក់ទី៦* | % | មិនទាន់អនុវត្ត | ៤៧,២ | អនុវត្តនៅឆ្នាំ ២០២០-២១ | |
| | *ការអានភាសាខ្មែរថ្នាក់ទី៨* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២១-២២ | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៨* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២១-២២ | | |
| | *គណិតវិទ្យាថ្នាក់ទី៨* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២១-២២ | | |
| | *រូបវិទ្យាថ្នាក់ទី៨* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២១-២២ | | |
| | *ការអានភាសាខ្មែរថ្នាក់ទី១១* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២២-២៣ | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី១១* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២២-២៣ | | |
| | *គណិតវិទ្យាថ្នាក់ទី១១* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២២-២៣ | | |
| | *រូបវិទ្យាថ្នាក់ទី១១* | % | មិនទាន់អនុវត្ត | អនុវត្តនៅឆ្នាំ ២០២២-២៣ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥. | ភាគរយគ្រូបង្រៀនបឋមសិក្សាមានគុណវុឌ្ឍិតាមស្តង់ដាជាតិ | % | ៧៩,០ | ៧៦,០ | ៧៥,០ | ↓ |
| ៦. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា | % | ១១,៦ ** | ១៤,២ | ១៣,៣ *** | → |
| | *ប្រុស* | % | ១២,២ ** | ១៦,៦ | ១៥,៥ *** | → |
| | *ស្រី* | % | ១១,៨ ** | ១២,៣ | ១១,៩ *** | ↓ |
| ៧. | អត្រាអក្ខរកម្មជនពេញវ័យ(អាយុ ១៥ឆ្នាំឡើង) | % | ៨២,៥ | ៨៥,៨ | ៨៧,៨ **** | ↑ |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| ៨. | នាយកសាលាបឋមសិក្សា និងមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៦៩១ | ៧០០ | ៦៣០ | ↓ |

សម្គាល់៖ ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

* *គិតទាំងសាលាឯកជន* **ទិន្នន័យឆ្នាំសិក្សា២០១៨-១៩ (គិតទាំងឯកជន) *** ទិន្នន័យឆ្នាំសិក្សា២០១៩-២០(គិតទាំងឯកជន)

*ប្រភព៖ **** ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជាឆ្នាំ ២០១៩/២០, វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ*

អត្រាចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ ជិតសម្រេចចំណុចដៅ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា និងអត្រាអក្ខរកម្មជនពេញវ័យ(អាយុ ១៥ឆ្នាំឡើង) មានការកើនឡើងលើសចំណុចដៅ។ សូចនាករស្នូលផ្សេងទៀតមិនសម្រេចបានតាមចំណុចដៅដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងពីគ្រប់តួអង្គពាក់ព័ន្ធ។

## ២.១.៣ វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាផ្តែកលើសសរស្តម្ភទាំង៥

វឌ្ឍនភាពរយៈពេលមួយឆ្នាំកន្លងមកនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ មានដូចខាងក្រោម៖

### *សសរស្តម្ភទី១ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន*

- ការអនុម័តក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន និងសេចក្តីណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន
- ការអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុងនៅវិទ្យាស្ថានគរុកោសល្យ
- ការរៀបចំមេរៀនបង្រៀនតាមអនឡាញសម្រាប់គរុសិស្ស និស្សិត នៅតាមគ្រឹះស្ថានបណ្តុះបណ្តាល
- ការរៀបចំសៀវភៅណែនាំស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការរៀបចំប្រព័ន្ធក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការរៀបចំប្រព័ន្ធទទួលស្គាល់អ្នកផ្តល់សេវានៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពី ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់នាយកសាលានិងគ្រូបង្រៀន
- ការរៀបចំសេចក្តីព្រាងក្របខណ្ឌស្តីពី គុណសម្បទាសតវត្សរ៍ទី២១ របស់គ្រូឧទ្ទេស
- ការបង្កើតប្រព័ន្ធ HRMIS សម្រាប់កត់ត្រាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន
- ការបន្ថែមក្រេឌីតអំណានថ្នាក់ដំបូងក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សាមុខវិជ្ជាភាសាខ្មែរតាមប្រព័ន្ធ ១២+២
- ការបន្ថែម ៣ក្រេឌីតទៀតក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ដើម្បីសិក្សាពីចម្ងាយ
- ការបន្សុីគ្នារវាងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធក្រេឌីតនៃក្របខណ្ឌការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការបង្កើតការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការរៀបចំផែនការរយៈពេលមធ្យមស្តីពី ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនទៅកម្រិតបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន

- ការបញ្ចូលបំណិនរកចំណូលក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន
- ការសិក្សាស្រាវជ្រាវស្តីពី គុណសម្បទាសតវត្សរ៍ទី២១ សម្រាប់គ្រូឧទ្ទេសតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ការជំរុញការរៀន និងបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិកនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩
- ការរៀបចំវគ្គសុក្រឹតការគ្រូឧទ្ទេសថ្នាក់ជាតិតាមប្រព័ន្ធអនឡាញ ៩០នាក់
- ការបំប៉នសមត្ថភាពគ្រូឧទ្ទេស ២៥០នាក់ គ្រូមធ្យមសិក្សាទុតិយភូមិ ៨ ៤៣៤នាក់ លើមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា និងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងណែនាំអាជីព ១៣ ៣០០នាក់
- ការបង្កើតគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន
- ការដាក់សាលាគរុកោសល្យគ្រប់ប្រភេទ និងសាលាអនុវត្តឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង។

***សសរស្តម្ភទី២ ៖ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា***

***ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល***

- ការរៀបចំប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោលជូនសាលារៀនឱ្យមានប្រសិទ្ធភាព(TnT)
- ការកែលម្អឯកសារជំនួយការបង្រៀននិងរៀនអក្សរសិល្ប៍បរទេស
- ការពិនិត្យនិងកែលម្អកម្មវិធីសិក្សាថ្មីលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា
- ការពង្រឹងការអនុវត្តកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាសម្រាប់សាលារៀនឯកជនចំណេះទូទៅ
- ការអនុម័តគោលការណ៍នៃការរៀបចំមេរៀនតាមអនឡាញសម្រាប់គរុសិស្ស និស្សិតនៅគ្រឹះស្ថានបណ្តុះបណ្តាល
- ការបញ្ចូលកញ្ចប់កម្មវិធីអំណានថ្នាក់ដំបូងភាសាខ្មែរក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សានៅសាលគរុកោសល្យ និងវិក្រឹតការខេត្ត
- ការអភិវឌ្ឍឯកសារជំនួយការរៀននិងបង្រៀនមុខវិជ្ជាសិក្សាសង្គមថ្នាក់ទី៣ និងទី៦
- ការអភិវឌ្ឍឯកសារជំនួយការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ -៦ ចំនួន ១ច្បាប់
- ការអភិវឌ្ឍឯកសារជំនួយការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងកម្មវិធីសិក្សាបឋមសិក្សាថ្នាក់ទី៤ ទី៥ និងទី៦ ចំនួន ៣ច្បាប់
- ការអភិវឌ្ឍសៀវភៅសិក្សាគោលអប់រំសិល្បៈសម្រាប់សិស្សនិងគ្រូបង្រៀនថ្នាក់ទី១ ដល់ទី៣ ចំនួន ៣ច្បាប់
- ការអភិវឌ្ឍឯកសារជំនួយការរៀន និងបង្រៀនមុខវិជ្ជាសិក្សាសង្គមកម្រិតបឋមសិក្សា ថ្នាក់ទី៣-៦ ចំនួន ១ច្បាប់
- ការអភិវឌ្ឍឯកសារវាយតម្លៃកម្មវិធីសិក្សាកម្រិតសាលារៀន
- ការអភិវឌ្ឍឯកសារជំនួយការរៀន និងបង្រៀនមុខវិជ្ជាគណិតវិទ្យាតាមគោលវិធីស្វែមមធ្យមបឋមភូមិ ១ច្បាប់
- ការកែលម្អឯកសារជំនួយការបង្រៀន និងរៀនអក្សរសិល្ប៍បរទេសរឿងរ៉ូម៉េអូហ្ស៊ូលីយ៉េត ហាំលែត និងទុគ៌តជន
- ការអភិវឌ្ឍឯកសារជំនួយការរៀននិងបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមគោលវិធីស្វែមថ្នាក់ទី១០-១២
- ការអភិវឌ្ឍឯកសារសេចក្តីណែនាំការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន និងឯកសារណែនាំការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន ១ច្បាប់
- ការរៀបចំឯកសារស្តីពី ការអនុវត្តកម្មវិធីសិក្សានៅក្នុងដំណាក់កាលជំងឺកូវីដ-១៩ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាអង់គ្លេស
- ការអភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាផ្នែកមត្តេយ្យសិក្សា
- ការកែសម្រួលកម្មវិធីសិក្សាលម្អិតនិងការអភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាសម្រាប់មត្តេយ្យសិក្សាសហគមន៍

- ការចងក្រងសៀវភៅជំនួយគ្រូស្តីពី ការសិក្សាចិត្តសង្គមនៅមត្តេយ្យសិក្សា
- ការកែសម្រួលកម្មវិធីបណ្តុះបណ្តាលក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនក្នុងបរិបទកូវីដ-១៩
- ការបោះពុម្ពសៀវភៅសម្រាប់គ្រូថ្នាក់ទី១២ ចំនួន ២១ ០០០ក្បាល (១១មុខវិជ្ជា) និងផ្តល់ដល់គ្រូថ្នាក់ទី១២ នៅខេត្តគោលដៅទាំង៧ ចំនួន ៣ ០០០នាក់ សហការជាមួយគម្រោងកម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិទី១
- ការផ្តល់សៀវភៅសិក្សាគោលថ្នាក់ទី១២ ចំនួន ៦ ០៣៨ឈុត មាន ១២មុខវិជ្ជា ដល់សិស្សថ្នាក់ទី១២ នៅខេត្តគោលដៅទាំង៧ មានសិស្ស ៦ ៨៨៣នាក់ ស្រី ៣ ៤៣៥នាក់ ដោយសិស្សម្នាក់ៗបានទទួលសៀវភៅសិក្សាគោល ១ឈុត សហការជាមួយគម្រោងកម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិទី១
- ការកែលម្អកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ឱ្យដល់កម្រិតស្តង់ដាតំបន់ និងកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ សហការជាមួយគម្រោងកម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិទី១
- ការរៀបចំវីដេអូឃ្លីបដើម្បីគាំទ្រការរៀន និងបង្រៀនស្តីពី កម្រិតសំណួរក្នុងដំណើរការរៀននិងបង្រៀន
- ការនិពន្ធសៀវភៅស្តីពី វិធីសាស្ត្របង្រៀនប្រវត្តិវិទ្យា
- ការអភិវឌ្ឍសៀវភៅសិក្សាគោលភាសាខ្មែរពីសខ្មៅទៅពណ៌មាន ៤ ចំណងជើងថ្នាក់ទី៤, ៥, ៦, ៧
- ការអភិវឌ្ឍសៀវភៅអំណានបន្ថែម ១០ចំណងជើងសម្រាប់បឋមសិក្សា
- ការអភិវឌ្ឍសៀវភៅហ្វឹកហាត់លើមុខវិជ្ជាវិទ្យាសាស្ត្រមាន ៩ចំណងជើងសម្រាប់មធ្យមសិក្សា
- ការទទួលបានលេខសៀវភៅស្តង់ដាអន្តរជាតិ(ISBN)ពីបណ្ណាល័យជាតិមានសៀវភៅសម្រាប់គ្រូ ៣២ចំណងជើង
- ការទទួលបានវិញ្ញាបនបត្រចុះបញ្ជីការពារស្នាដៃសិទ្ធិអ្នកនិពន្ធ ៤០ចំណងជើងពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ការបោះពុម្ពសៀវភៅសិក្សាគោល សៀវភៅអំណានបន្ថែម និងសៀវភៅហ្វឹកហាត់ ៣ ៧៦៤ ០៦០ច្បាប់
- ការដឹកជញ្ជូនសៀវភៅសិក្សាគោលជូនរាជធានី ខេត្ត ដោយប្រើប្រាស់ថវិកាកម្មវិធី២០១៩ (PB-២០១៩) បាន ២ ៥៣០ ០០០ច្បាប់ និងថវិកាកម្មវិធី២០២០ (PB-២០២០) បាន ១ ៤៥០ ០០០ច្បាប់
- ការចុះឈ្មោះសាលារៀនក្នុងប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោលជូនសាលារៀន(TnT)បាន ៩ ០៧០ សាលារៀន។

***ការកែលម្អបរិស្ថានសិក្សា***

- ការកែលម្អបណ្ណាល័យឱ្យស្របតាមស្តង់ដាបណ្ណាល័យសតវត្សរ៍ទី២១ ចំនួន ៩ សាលារួមមាន ទី១.វិទ្យាល័យព្រះស៊ីសុវត្ថិ ទី២. វិទ្យាល័យព្រះយុគន្ធរ ទី៣. វិទ្យាល័យព្រែកលៀប ទី៤. វិទ្យាល័យព្រែកអញ្ចាញនៅរាជធានី ទី៥. វិទ្យាល័យ **ហ៊ុន សែន** ពងជីកង ទី៦. វិទ្យាល័យ **ហ៊ុន សែន** កំពង់ចាម (ក្នុងនោះមានសាលាបឋមសិក្សាអនុវត្ត) ទី៧. សាលាបឋមសិក្សាអង្គរបាន ខេត្តកំពង់ចាម ទី៨. វិទ្យាល័យគោកព្រីង (ក្នុងនោះមានសាលាបឋមសិក្សាស្វាយព្រហូត) ខេត្តស្វាយរៀង និងទី៩. សាលាបឋមសិក្សា**សម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនីនាថសីហនុ** ខេត្តកំពង់ស្ពឺ
- ការធ្វើបច្ចុប្បន្នកម្មស្ថិតិបណ្ណាល័យ ១៨ខេត្ត រាជធានី សាលារៀនដែលមានបណ្ណាល័យ ៥ ៧៤០ ក្នុងនោះ សាលាបឋមសិក្សា ៤ ៤៨៨ អនុវិទ្យាល័យ ៧៦៨ និងវិទ្យាល័យ ៤៨៤
- ការជួសជុលកែលម្អអគារសិក្សា ៧ខ្នង ស្មើ ៤១បន្ទប់ មជ្ឈមណ្ឌលជាតិយុវជនខេត្តសៀមរាប ១កន្លែង និង ថែទាំទីលានបាល់ទាត់ គាំទ្រដោយថវិការាជរដ្ឋាភិបាល

- ការជួសជុលកែលម្អអគារសិក្សា ១៣ខ្នង ៩៨បន្ទប់ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង គាំទ្រដោយថវិការាជរដ្ឋាភិបាល
- ការកែលម្អអគារសិក្សា ១ខ្នង សម្រាប់ការងារពិសោធន៍និងការអប់រំ និងអន្តេវាសិកដ្ឋាន ១ខ្នង នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សហការជាមួយគម្រោងកែលម្អការអប់រំឧត្តមសិក្សា
- ការសាងសង់អគារមជ្ឈមណ្ឌលបណ្តុះបណ្តាលពន្លកអាជីវកម្ម និងអន្តេវាសិកដ្ឋាន ១ខ្នង និងជួសជុលបន្ទប់ពិសោធន៍ ៣៩បន្ទប់ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សហការជាមួយគម្រោងកែលម្អការអប់រំឧត្តមសិក្សា
- ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតជាពិសេសនារី ២ខ្នង អគារពហុបំណងសម្រាប់ជាការិយាល័យ ជាបន្ទប់ពិសោធន៍ និងជាថ្នាក់រៀន នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សហការជាមួយគម្រោងកែលម្អការអប់រំឧត្តមសិក្សា
- ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតជាពិសេសនារី ១ខ្នង និងអគារវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ១ខ្នង នៅសាកលវិទ្យាល័យជាតិបាត់ដំបង សហការជាមួយគម្រោងកែលម្អការអប់រំឧត្តមសិក្សា
- ការសាងសង់អគារសិក្សាថ្មី ១ខ្នង និងពង្រីកស្ថានីយ៍កសិកម្ម នៅសាកលវិទ្យាល័យស្វាយរៀង សហការជាមួយគម្រោងកែលម្អការអប់រំឧត្តមសិក្សា
- ការជួសជុលកែលម្អសាលាគរុកោសល្យខេត្ត ១១ មាន ៦៣ខ្នង ៣៤៨បន្ទប់ បង្គន់អនាម័យ ១៤ខ្នង ៣១៤បន្ទប់ ដោយបំពាក់គ្រឿងសង្ហារិមការិយាល័យ អន្តេវាសិកដ្ឋាន និងសម្ភារឧបករណ៍ពិសោធន៍ សហការជាមួយគម្រោងមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ-ពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា(GPE-STEPCam)
- ការសាងសង់អគារសិក្សាថ្មី ៣ខ្នង ៩បន្ទប់ ដោយគម្រោងអង្គការជំនួយជប៉ុន (JRfC-WAfC)
- ការសាងសង់អគារសិក្សាថ្មី ២ខ្នង ១០បន្ទប់ ក្រោមជំនួយអង្គការមូលនិធិអេស៊ីលីជា-ចារឌីនសម្រាប់ការអប់រំ(AJF)
- ការសាងសង់អគារសិក្សាថ្មី ១ខ្នង ៥បន្ទប់ ដោយស្ថានទូតជប៉ុនគម្រោងខ្នាតតូចសន្តិសុខមនុស្សជាតិ
- ការសាងសង់អគារសិក្សា និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ១ខ្នង កម្ពស់ ២ជាន់ ស្មើ ៨បន្ទប់ អគាររដ្ឋបាល ១ខ្នង ៣ជាន់ ស្មើ ១៦បន្ទប់ អគារបណ្ណាល័យ ១ខ្នង ២ជាន់ ស្មើ ៨បន្ទប់ និងសាលប្រជុំ ១ខ្នង នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- ការសាងសង់អគារសិក្សា និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ១ខ្នង កម្ពស់ ៣ជាន់ ស្មើ ២៩បន្ទប់ អគាររដ្ឋបាល ១ខ្នង កម្ពស់ ២ជាន់ ស្មើ ២៩បន្ទប់ អគារបណ្ណាល័យ ១ខ្នង ស្មើ ៩បន្ទប់ សាលប្រជុំធំ ១ខ្នង និងអន្តេវាសិកដ្ឋាន ១ខ្នង កម្ពស់ ៣ជាន់ ស្មើ ២៤បន្ទប់ នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- ការជួសជុលអគារសិក្សា ២ខ្នង ស្មើ ៨បន្ទប់ សង់អគារការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុក ១ខ្នង សាងសង់អគារសិក្សា ២ខ្នង ស្មើ ១០បន្ទប់ និងសាងសង់អគារសិក្សាកម្ពស់ ២ជាន់ ៥ខ្នង ស្មើ ៥២បន្ទប់ នៅខេត្តកណ្តាល ស្វាយរៀង កំពង់ចាម និងរាជធានី សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គិតមកត្រឹមខែមីនា ឆ្នាំ២០២១ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មាន ៤ ៤៣៥ខ្នង ស្មើ ២៨ ២១៨បន្ទប់។

### *សសរស្តម្ភទី៣ ៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធអធិការកិច្ច*

- ការពិនិត្យតាមដានការធ្វើអធិការកិច្ចតាមកាលកំណត់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចស្តីពី ការវាយតម្លៃសាលារៀនតាមប្រព័ន្ធអេឡិចត្រូនិក

- ការបង្កើតបណ្ដាញចំណេះដឹងមេរៀន និងតេស្តវាយតម្លៃ ៦មុខវិជ្ជា នៅកម្រិតមធ្យមសិក្សាបឋមភូមិ
- ការពង្រឹងសមត្ថភាពគ្រូបង្គោល និងមន្ត្រីបង្គោលថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ក្នុងការពិនិត្យតាមដានផលសម្រេចនៅសាលារៀនដោយប្រើប្រាស់ស្តង់ដាទាំង ៩ នៃស្តង់ដាសាលារៀនមានប្រសិទ្ធភាព
- ការកែលម្អសៀវភៅជំនួយស្មារតីអធិការកិច្ចសាលារៀនតាមកាលកំណត់
- ការធ្វើសុខដុមនីយកម្មឧបករណ៍អធិការកិច្ចសាលារៀនតាមកាលកំណត់ជាមួយនឹងឧបករណ៍ការគ្រប់គ្រងតាមសាលារៀន កម្មវិធីសាលាកុមារមេត្រី និងស្តង់ដាសាលារៀនមានប្រសិទ្ធភាព
- ការបូកសរុបលទ្ធផលអធិការកិច្ចសាលារៀនតាមកាលកំណត់ និងអធិការកិច្ចតាមប្រធានបទ
- ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចក្នុងការធ្វើអធិការកិច្ច និងការសរសេររបាយការណ៍
- ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចស្តីពី ការប្រើប្រាស់កម្មវិធីពិនិត្យតាមដាន និងវាយតម្លៃសាលាកុមារមេត្រីតាមឧបករណ៍ចល័ត និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន តាមប្រព័ន្ធអ៊ីនធឺណិត
- ការធ្វើអធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ២៣៨អង្គភាព។

### *សសរស្តម្ភទី៤ ៖ ការពង្រឹងវង្វាយតម្លៃសិក្សាមានរូបភាពផ្សេងៗដូចជា ការប្រឡង ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ*

- ការវាយតម្លៃការរៀន បង្រៀន និងការអនុវត្តស្វែមនៅបឋមសិក្សា មធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- ការផ្សព្វផ្សាយក្របខណ្ឌវង្វាយតម្លៃលទ្ធផលសិក្សា និងការតាក់តែងសំណួរតេស្តស្តង់ដាកម្រិតសាលារៀន
- ការពង្រឹងការអនុវត្តវង្វាយតម្លៃលទ្ធផលសិក្សានៅតាមសាលារៀន
- ការពិនិត្យ និងការកែសម្រួលឯកសារតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៦
- ការរៀបចំឯកសារកម្មវិធីអន្តរជាតិស្តីពី តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA)
- ការអភិវឌ្ឍវិញ្ញាសាប្រឡងឆមាសសម្រាប់មធ្យមសិក្សាបឋមភូមិលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យាសម្រាប់ថ្នាក់ទី៧ ទី៨ និងទី៩
- ការអភិវឌ្ឍវិញ្ញាសាប្រឡងប្រចាំខែនៅកម្រិតបឋមសិក្សា
- ការផ្តល់ឯកសារជំនួយស្មារតីស្តីពី គំរូវិញ្ញាសាប្រឡងឆមាសទី១ និងឆមាសទី២ ជូនមន្ទីរអប់រំ យុវជន និងកីឡា ១៧ និងសាលារៀន ៣៨
- ការណែនាំបច្ចេកទេស និងបញ្ចូលទិន្នន័យតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី១១ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា
- ការពិគ្រោះយោបល់ស្តីពី លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា
- ការផ្សព្វផ្សាយលទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិថ្នាក់ទី១១
- ការផ្សព្វផ្សាយលទ្ធផលកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

### *សសរស្តម្ភទី៥ ៖ ការកែទម្រង់ឧត្តមសិក្សា*

- ការរៀបចំនីតិវិធីស្តីពីការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ៤ ឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ សាកលវិទ្យាល័យស្វាយរៀង និងសាកលវិទ្យាល័យជាតិបាត់ដំបង
- ការរៀបចំមជ្ឈមណ្ឌលឧត្តមភាពនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

- ការបញ្ចប់យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ និងយុទ្ធសាស្ត្រគ្រឹះស្ថានឧត្តមសិក្សា២០២១-២០៣០ ចំនួន ៥
- ការផ្តល់គម្រោងស្រាវជ្រាវ ៥៣ ដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ៥ ក្នុងនោះ ៤៥គម្រោងបានផ្សារភ្ជាប់ទៅនឹងឧស្សាហកម្ម ដែលដឹកនាំនិងសហដឹកនាំដោយស្ត្រី ២២គម្រោង
- ការរៀបចំកម្មវិធីភាពជាដៃគូការអប់រំស្វែមរវាងគ្រឹះស្ថានឧត្តមសិក្សា និងសាលារៀនមធ្យមសិក្សាតាមរយៈគម្រោងកែលម្អការអប់រំឧត្តមសិក្សា និងគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា
- ការរៀបចំគោលការណ៍ណែនាំស្តីពី មជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ការកែលម្អសមត្ថភាពបង្រៀននិងរៀនតាមកម្មវិធីភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាក្នុង និងក្រៅប្រទេស
- ការបញ្ចប់សេចក្តីព្រាងគោលនយោបាយស្តីពី ការស្រាវជ្រាវ និងការអភិវឌ្ឍនៅឧត្តមសិក្សា
- ការរៀបចំនីតិវិធីអនុវត្តប្រកាសស្តីពី ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ
- ការរៀបចំគោលការណ៍ណែនាំស្តីពី ការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងធនធានមនុស្សសម្រាប់ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល
- ការរៀបចំគោលការណ៍ណែនាំស្តីពី ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- ការរៀបចំគោលការណ៍ណែនាំស្តីពី ការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ការរៀបចំផែនការមេសម្រាប់អភិវឌ្ឍធនធានមនុស្សនៅឧត្តមសិក្សា
- ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ និងការសិក្សាស្រាវជ្រាវ។

## ២.១.៤ វឌ្ឍនភាពនៃការគ្រប់គ្រង និងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

### ២.១.៤.១ វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ផែនការ ស្ថិតិ និងការពិនិត្យតាមដាននិងវាយតម្លៃ

ក្រសួងបាន៖

- អនុម័តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- អនុម័ត និងផ្សព្វផ្សាយផែនការឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩
- អនុម័ត និងផ្សព្វផ្សាយផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ២០២០-២០២៤
- អនុម័ត និងផ្សព្វផ្សាយផែនការប្រតិបត្តិប្រចាំ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុម័ត និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រថវិកា២០២១-២០២៣
- អនុម័តសូចនាករថវិកាកម្មវិធីឆ្នាំ២០២១ និងសូចនាករសមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០
- អនុម័តសៀវភៅស្តីពី បច្ចេកទេសគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិសម្រាប់បុគ្គលិកអប់រំ
- ព្រាងផែនទីចង្អុលផ្លូវឆ្នាំ២០៣០ ការអប់រំនៅមធ្យមសិក្សា
- ព្រាងផែនការមេអភិវឌ្ឍសមត្ថភាពពិនិត្យតាមដាននិងវាយតម្លៃ
- ព្រាងក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃអនុវិស័យយុវជន និងអនុវិស័យកីឡា
- រៀបចំរបាយការណ៍សមិទ្ធកម្មស្តីពី ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០
- អនុម័ត និងផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវស្តីពីស្ថានភាពអប់រំក្នុងដំណាក់កាលកូវីដ-១៩
- រៀបចំរបាយការណ៍ស្តីពី ប្រសិទ្ធភាពនៃការប្រើប្រាស់ក្របខណ្ឌនិងឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃរបស់វិទ្យាល័យធនធាន
- រៀបចំឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃក្នុងវិស័យអប់រំក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩

- សិក្សាស្រាវជ្រាវស្តីពី កាតព្វកិច្ចសិក្សានៅបឋមសិក្សានៅកម្ពុជា
- សិក្សាស្រាវជ្រាវស្តីពី តំបន់ជួបការលំបាកក្នុងវិស័យអប់រំ
- សិក្សាស្រាវជ្រាវស្តីពី លទ្ធភាពនៃការបញ្ចូលភាសាចារាយក្នុងកម្មវិធីអប់រំពហុភាសា និងការប្រែក្លាយសាលាមត្តេយ្យសិក្សាពហុភាសាសហគមន៍ទៅជាសាលាមត្តេយ្យសិក្សាសាធារណៈ
- សិក្សាស្រាវជ្រាវស្តីពី បញ្ហាប្រឈម និងឱកាសរបស់និស្សិតនារីកម្រិតឧត្តមសិក្សា
- សិក្សាស្រាវជ្រាវស្តីពី ការអនុវត្តការគ្រប់គ្រងតាមសាលារៀន
- សិក្សាស្រាវជ្រាវស្តីពី ការអប់រំ STEM តាមរយៈការវិភាគទីតាំងភូមិសាស្ត្រសាលាមធ្យមសិក្សាធនធាន
- សិក្សាស្រាវជ្រាវស្តីពី គោលនយោបាយអប់រំក្នុងតំបន់ និងក្នុងពិភពលោក
- ដាក់ឱ្យដំណើរការប្រព័ន្ធប្រមូលទិន្នន័យអប់រំពីសាលារៀនតាមអនឡាញ
- ផលិតសៀវភៅស្ថិតិ និងសូចនាករអប់រំថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត (រដ្ឋ ឯកជន មត្តេយ្យសិក្សាសហគមន៍ បណ្ណផ្ទត់ ស្ថិតិកម្រងសាលារៀន និងបណ្ណទិន្នន័យសាលារៀន)។

### ២.១.៤.២ វឌ្ឍនភាពនៃការអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ

### កម្មវិធីវិនិយោគសាធារណៈ

ក្រសួងបានរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០២១-២០២៣ មាន ៣៦ គម្រោង ក្នុងនោះ គម្រោងកំពុងដំណើរការ ៣៤ គម្រោង និងគម្រោងសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២គម្រោង មានថវិកាសរុប ២៥៧ ៤៩៧ លានដុល្លារអាមេរិក។

តារាងទី៣ ៖ កម្មវិធីវិនិយោគសាធារណៈ(PIP) ៥ឆ្នាំចុងក្រោយពីឆ្នាំ២០១៧-២០១៩ ដល់ឆ្នាំ ២០២១-២០២៣
(គិតជាពាន់ដុល្លារអាមេរិក)

| ឆ្នាំ | សរុបគម្រោងជំនួយ | | គម្រោងកំពុងដំណើរការ | | | | គម្រោងសម្រាប់អនុវត្តផយអជ | |
|---|---|---|---|---|---|---|---|---|
| | គម្រោង | ថវិកា | គម្រោងវិនិយោគជាទុន | | គម្រោងជំនួយបច្ចេកទេស | | ចំនួនគម្រោង | ថវិកាគ្រោង |
| | | | គម្រោង | ថវិកា | គម្រោង | ថវិកា | | |
| ២០១៧-២០១៩ | ២៧ | ២០៨ ៤៨១ | ១៤ | ១៥៧ ០៥៥ | ៧ | ៥ ៥៤០ | ៦ | ៤៥ ៨៨៥ |
| ២០១៨-២០២០ | ៣០ | ៣៩០ ៣០៦ | ១២ | ១៣៩ ៣៧៤ | ៩ | ៨ ៨០៩ | ៩ | ២៤២ ១២៣ |
| ២០១៩-២០២១ | ២៣ | ៣៩៥ ៤១៩ | ១២ | ២៧៩ ៨៩៩ | ៨ | ៧៦ ៨៣១ | ៣ | ៣៨ ៦៨៨ |
| ២០២០-២០២២ | ២៨ | ៣៤៥ ៩៧៧ | ១២ | ២១៩ ២៣៧ | ១១ | ៩៨ ៦៩០ | ៥ | ២៨ ០៥០ |
| ២០២១-២០២៣ | ៣៦ | ២៥៧ ៤៩៧ | ៩ | ១០៧ ៤៦៣ | ២៥ | ១៤១ ៦៩៤ | ២ | ៨ ៣៤០ |

តារាងខាងលើបង្ហាញថា ចំនួនគម្រោងនៃកម្មវិធីវិនិយោគសាធារណៈនៅឆ្នាំ២០២១-២០២៣ កើន ៨ គម្រោង គម្រោងជំនួយបច្ចេកទេសកើន ១៤ គម្រោង ប៉ុន្តែគម្រោងវិនិយោគជាទុនថយ ៣ គម្រោង បើធៀបទៅនឹងឆ្នាំ២០២០-២០២២ ។

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំឆ្នាំ២០២០ មានថវិកាសរុបជាង ១៩៨ លានដុល្លារអាមេរិក បានថយចុះបើធៀបនឹងឆ្នាំ២០១៩។ ក្នុងចំណោមដៃគូអភិវឌ្ឍទាំង១០ សហភាពអឺរ៉ុបបានចំណាយថវិកាច្រើនជាងគេ បន្ទាប់ពីនេះមានគម្រោងគាំទ្រដោយធនាគារពិភពលោក និងអង្គការយូនីសេហ្វ។

ភ្នាក់ងារផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់វិស័យអប់រំ ១០ ដែលស្ថិតនៅក្នុងលំដាប់ខ្ពស់ជាងគេក្នុងឆ្នាំ ២០២០ មានបង្ហាញនៅក្នុងតារាងខាងក្រោម៖

**តារាងទី៤ ៖ ដៃគូអភិវឌ្ឍចំនួន១០ មានហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រវិស័យអប់រំច្រើនជាងគេក្នុងឆ្នាំ២០២០ (ឯកតា: ពាន់ដុល្លារអាមេរិក)**

| លរ | អ្នកផ្តល់ជំនួយ | ចំណាយជាក់ស្តែង ២០១៨ | ចំណាយជាក់ស្តែង ២០១៩ | ចំណាយជាក់ស្តែង ២០២០ | ផែនការ ឆ្នាំ២០២១ | ផែនការ ឆ្នាំ២០២២ |
|---|---|---|---|---|---|---|
| ១ | សហភាពអឺរ៉ុប | ២០ ០៧៨ | ២៦ ៤៦២ | ២៥ ៧៩៦ | ៣៨ ១០៩ | ៥ ០៣៨ |
| ២ | ធនាគារពិភពលោក | ៣ ១៦០ | ១៥ ៦៦៩ | ១៦ ៨៦៨ | ២២ ៤០០ | ២៤ ២០០ |
| ៣ | អង្គការយូនីសែហ្វ | ៦ ៥៦៨ | ១២ ០២២ | ១៣ ៣៧២ | ២០ ៨០៤ | ៥ ៨៣៥ |
| ៤ | ធនាគារអភិវឌ្ឍអាស៊ី | ១៨ ៧៥៥ | ២៧ ០៣០ | ៩ ៣៦១ | ១៦ ០២១ | ១២ ២៨៣ |
| ៥ | ប្រទេសជប៉ុន | ១៩ ០៣៨ | ៩ ០០៥ | ៨ ៨៣៦ | ៨ ១៩២ | ៧ ៣១៥ |
| ៦ | ប្រទេសស៊ុយអែត | ៥ ៨៨៤ | ៨ ៦១៣ | ៨ ៤៤៦ | ៧ ៦៣៧ | ១ ៥៥២ |
| ៧ | សាធារណរដ្ឋប្រជាមានិតចិន | N/A | ៣ ៨៧៩ | ៤ ៨១៩ | ៨ ២៤៧ | ៣ ០៩២ |
| ៨ | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ | ៨ ៨៩៣ | ៩ ៥១៧ | ៤ ៥០៩ | ៣ ៩៥១ | ៣០០ |
| ៩ | ប្រទេសអូស្ត្រាលី | ៦ ៨៦២ | ៥ ៩០៦ | ៤ ១១៥ | ៦ ៤៨៨ | N/A |
| ១០ | អង្គការយូណេស្កូ | ៨០៩ | ៤ ៣៣៦ | ៣ ៣០០ | ២ ៧២៦ | ២៣៥ |
| | សរុបថវិការបស់ដៃគូទាំង១០ | **៩០ ០៤៧** | **១២២ ៤៣៩** | **៩៩ ៤២២** | **១៣៤ ៥៧៥** | **៥៩ ៨៥០** |
| | សរុបថវិការបស់ដៃគូផ្សេងៗទៀត | **៥៣ ៣០២** | **៧៤ ០៤១** | **៤៥ ៨៧៨** | **៤៥ ១០៨** | **៣៩ ៧៧០** |
| | សរុបថវិការបស់អង្គការក្រៅរដ្ឋាភិបាល | **៦៧ ១៦៥** | **៦១ ៧៦៩** | **៥៣ ០៧០** | **៣២ ១១០** | **៧ ៩៦៤** |
| | សរុបទាំងអស់ | ***២១០ ៥១៤*** | ***២៥៨ ២៤៩*** | ***១៩៨ ៣៧០*** | ***២១១ ៧៩៣*** | ***១០៧ ៥៨៤*** |

*(ប្រភព CDC: ដកស្រង់ចេញពីទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០២១)*

## វឌ្ឍនភាពនៃការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ

ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ និងយុទ្ធសាស្ត្រកំណែទម្រង់ ក្រសួងបាន និងកំពុងអនុវត្តគម្រោងមួយចំនួនដូចខាងក្រោម៖

១. **កម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ (USESDP1)** ជាឥណទានកម្ចីរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានថវិកា ៤៨ លានដុល្លារអាមេរិក (៤៥ លានដុល្លារអាមេរិក គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ៣ លានដុល្លារអាមេរិក គាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា) មានរយៈពេលអនុវត្តពីឆ្នាំ ២០១៧ ដល់ឆ្នាំ២០២១ ដើម្បីបង្កើនគុណភាពសេវាអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ គម្រោងនេះបានផ្តោតលើ ១).ការបង្កើនការចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ២).ការបង្កើនគុណភាពនិងភាពឆ្លើយតបនៃការអប់រំនៅមធ្យមសិក្សាទុតិយភូមិ ៣).ការពង្រឹងសមត្ថភាពស្ថាប័នក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងការផ្តល់សេវាអប់រំ។ វឌ្ឍនភាពសំខាន់ៗរួមមាន៖

- ការផ្តល់សម្ភារបរិក្ខារជាអគារសិក្សា ផ្ទះគ្រូ និងជួសជុលអគារសិក្សា ៨៤កន្លែង រួមមានសង់អគារធនធានថ្មី ១៤ ខ្នងសង់អគារសិក្សាថ្មី ៥ខ្នង (១ជាន់ ៥បន្ទប់) ដែលពង្រីកពីអនុវិទ្យាល័យទៅវិទ្យាល័យ សង់អគារសិក្សាថ្មី

១០ខ្នង(២ជាន់ ១០បន្ទប់) ដល់វិទ្យាល័យដែលមានសិស្សច្រើន សង់ផ្ទះគ្រូថ្មី ៤៤ខ្នង ក្នុងនោះសង់រួច ២០ខ្នង កំពុងសាងសង់ ២៤ខ្នង និងកំពុងជួសជុលអគារសិក្សាវិទ្យាល័យ ១១ខ្នង

- ការផ្តល់កុំព្យូទ័របន្ទះ ២៤ឈុត ដល់វិទ្យាល័យធនធានថ្មី ២៤
- ការផ្តល់សម្ភារបរិក្ខារបន្ថែមដល់នាយកដ្ឋាននិងអង្គភាពបង្កើតថ្មី៖ នាយកដ្ឋានកិច្ចការប្រឡង នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នាយកដ្ឋានគោលនយោបាយ និងក្រុមប្រឹក្សាស្រាវជ្រាវអប់រំ
- ការផ្តល់អាហារូបករណ៍ដល់សិស្ស ៤ ៣១៤នាក់ ស្រី ២ ៥៧៨នាក់ ស្មើ ៧២,២៣ភាគរយ ក្នុងនោះសិស្សជនជាតិដើមភាគតិច ៣៥នាក់ ស្រី ១៣នាក់ (ចំណុចដៅ ៦ ០០០នាក់)
- ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ២០ដុល្លារ ក្នុងមួយខែដល់គ្រូមុខវិជ្ជា STEM ៤៤៦នាក់ ស្រី ១៩០នាក់ (គ្រូនារីទាំងអស់ត្រូវបានផ្តល់ជូន) និងលើកទឹកចិត្តពួកគាត់ឱ្យបន្តស្នាក់នៅ និងបង្រៀនក្នុងតំបន់ជួបការលំបាកដែលខ្វះគ្រូបង្រៀន(ចំណុចដៅ ៩៣៨នាក់)
- ការផ្តល់អាហារូបករណ៍ដល់គរុនិស្សិត ២៩៨នាក់ ស្រី ១១៨នាក់ ស្មើ ៥៩,៦០ភាគរយ (ចំណុចដៅ ៥០០នាក់)នៅវិទ្យាស្ថានជាតិអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ ៨០ ដុល្លារក្នុងមួយខែសម្រាប់រយៈពេល ១០ខែ
- ការផ្តល់សៀវភៅសិក្សាគោលថ្នាក់ទី១២ ចំនួន ៦ ០៣៨ឈុត មាន ១២មុខវិជ្ជា ដល់សិស្សថ្នាក់ទី១២ នៅខេត្តគោលដៅទាំង៧ មានសិស្ស ៦ ៨៨៣នាក់ ស្រី ៣ ៤៣៥នាក់ ដោយសិស្សម្នាក់ៗបានទទួលសៀវភៅសិក្សាគោល ១ឈុត
- ការបោះពុម្ពសៀវភៅសិក្សាគ្រូថ្នាក់ទី១២ ចំនួន ២១ ០០០ក្បាល (១១ មុខវិជ្ជា) និងផ្តល់ដល់គ្រូថ្នាក់ទី១២ នៅខេត្តគោលដៅទាំង៧ ចំនួន ៣ ០០០នាក់។
- ការកែលម្អកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា និងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍(ICT) ឱ្យដល់កម្រិតស្តង់ដាតំបន់/អន្តរជាតិ និងកម្មវិធីបណ្តុះបណ្តាល និងក្រឹតការគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ
- ការបំប៉នសមត្ថភាពគ្រូមធ្យមសិក្សាទុតិភូមិមុខវិជ្ជាស្នែម ១ ០០៧នាក់ ស្រី ២៧៩នាក់ (ចំណុចដៅ ៨ ៤៣៤នាក់) និងណែនាំអាជីព ៨៣៨នាក់ ស្រី ២៤៦នាក់ (ចំណុចដៅ ១៣ ៣០០នាក់)
- ការផ្តល់មូលនិធិកែលម្អសាលារៀន (SIF) ៥០០ដុល្លារ ក្នុងមួយឆ្នាំ ដល់វិទ្យាល័យធនធាន ៥០ (ចំណុចដៅ ៤៨សាលា) និងសាលាបណ្តាញ ២៤៧ (ចំណុចដៅ ២៤០សាលា)។

**២. កម្មវិធីអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិជំហានទី២ (USESDP2)** ជាឥណទានកម្ចីរបស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានថវិកា ៥៣,៥ លានដុល្លារអាមេរិក (៥០ លានដុល្លារអាមេរិក គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ៣,៥ លានដុល្លារអាមេរិក ជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា) មានរយៈពេលអនុវត្តពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤។ គម្រោងនេះផ្តោតលើ ១).ការលើកកម្ពស់គុណភាពគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ២).ការលើកកម្ពស់គុណភាពនិងការឆ្លើយតបទីផ្សារការងារនៃការអប់រំមធ្យមសិក្សាទុតិយភូមិ និង ៣). ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការធ្វើផែនការ ការគ្រប់គ្រង និងការផ្តល់សេវាអប់រំ។ វឌ្ឍនភាពសំខាន់ៗរួមមាន៖

- ការអនុម័ត និងផ្សព្វផ្សាយក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន និងសេចក្តីណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន
- ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិអប់រំសម្រាប់ដាក់ស្នើទៅក្រសួងមុខងារសាធារណៈ
- ការរៀបចំផែនការមេសម្រាប់អភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ រួមទាំងការរចនាប្លង់សម្រាប់សាងសង់បណ្ណាល័យសតវត្សរ៍ទី២១ និងការជួសជុលអគារ

- ការធ្វើលទ្ធកម្មលើសម្ភារៈសម្រាប់បំពាក់នៅសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញ រួមទាំងសម្ភារៈផ្នែកស្នែម និងបណ្ណាល័យ
- ការបំពាក់សម្ភារបរិក្ខារបច្ចេកវិទ្យាសារគមនាគមន៍ទាំងផ្នែករឹង និងផ្នែកទន់នៅវិទ្យាស្ថានជាតិអប់រំ រួមមានកុំព្យូទ័រយួរដៃសម្រាប់បន្ទប់បង្រៀន និងបន្ទប់សន្និសីទពីចម្ងាយ (video conference system)
- ការរៀបចំសិក្ខាសាលាស្តីពី ជំនាញស្រាវជ្រាវបែបបរិមាណវិស័យ-គុណវិស័យ កាស្រាវជ្រាវប្រតិបត្តិ ការបង្កើតគម្រោងស្រាវជ្រាវនិងស្នើសុំមូលនីធិស្រាវជ្រាវ ការសរសេរនិងបោះពុម្ពអត្ថបទស្រាវជ្រាវ ដល់គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ ២៣នាក់ ស្រី ៥នាក់
- ការបង្កើតគណៈកម្មការជ្រើសរើសគ្រូឧទ្ទេសពីវិទ្យាស្ថានជាតិអប់រំ ដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រគ្រប់គ្រងបណ្ណាល័យ ២រូប និងថ្នាក់បណ្ឌិត ផ្នែកស្នែម កម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ៧រូបតាមរយៈការផ្តល់អាហារូបករណ៍គម្រោងទៅសិក្សានៅក្រៅប្រទេស
- ការរៀបចំបញ្ជីសម្ភារៈតម្រូវការមុខវិជ្ជាស្នែម សម្រាប់ដំណើរការរៀននិងបង្រៀននៅវិទ្យាស្ថានជាតិអប់រំ
- ការផ្សព្វផ្សាយការដេញថ្លៃការងារសំណង់ រួមមានការដេញថ្លៃលើ (១).ការធ្វើឱ្យប្រសើរឡើង និងបំពាក់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រនៅវិទ្យាល័យធនធាន៣៦ (២).ការកែលម្អនូវបន្ទប់រៀនទៅជាបន្ទប់ពិសោធន៍ និងបណ្ណាល័យនៅសាលាបណ្តាញ (៣).ការដំឡើងបន្ទប់ពហុបំណងបំណិនជីវិតនៅវិទ្យាល័យធនធាន ២៥ (៤).ការបំពាក់នូវប្រព័ន្ធទឹកស្អាត និងបរិក្ខាអនាម័យនៅវិទ្យាល័យធនធាន១៨ និង (៥) ការដំឡើងប្រព័ន្ធថាមពលដើរដោយពន្លឺព្រះអាទិត្យនៅវិទ្យាល័យធនធាន ២០ និងសាលាបណ្តាញ ៣០
- ការកែសម្រួលកម្មវិធីសិក្សាផ្នែកស្នែម ដែលគ្រោងនឹងបណ្តុះបណ្តាលលើកម្មវិធីអប់រំអាជីព ស្នែមនិងបំណិនជីវិតដល់គ្រូបង្គោល ១៥៣នាក់ ស្រី ៥៤នាក់ តារយៈសកម្មភាពបង្វឹកនិងហ្វឹកហាត់
- ការអនុម័តឧបករណ៍សម្រាប់ពិនិត្យតាមដាន ការហ្វឹកហាត់ និងបង្វឹកនៅវិទ្យាល័យធនធាន និងបណ្តុះបណ្តាលស្តីពីសៀវភៅណែនាំ ដល់នាយកវិទ្យាល័យធនធាន ១៦ និងមន្ត្រីតំបន់ទាំង៥
- ការបញ្ចប់សេចក្តីណែនាំស្តីពី ការគ្រប់គ្រង និងដំណើរការប្រតិបត្តិលើការផ្តល់សេវាបណ្តុះបណ្តាលជំនាញបន្ថែម ស្នែមសម្រាប់មធ្យមសិក្សាទុតិយភូមិ
- ការរៀបចំបញ្ជីតម្រូវការសម្ភារៈជំនួយសម្រាប់ការរៀននិងបង្រៀននៅវិទ្យាល័យធនធាន និងសាលាបណ្តាញ រួមមាន ពិសោធន៍វិទ្យាសាស្ត្រ ថ្នាក់ ICT ថ្នាក់រៀនបែបវិទ្យាសាស្ត្រ បណ្ណាល័យ និងថ្នាក់ជំនាញបំណិនជីវិតផ្អែកលើគម្រោង
- ការអនុម័តនូវផែនការរួមគ្នាសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដែលមានការចូលរួមពីគម្រោង USESD P2, STEPCam/GPE3 និង CDPF ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០
- ការធ្វើកិច្ចសន្យាក្រុមហ៊ុនទីប្រឹក្សាមួយ សម្រាប់អភិវឌ្ឍវិបសាយក្រសួងអប់រំ យុវជន និងកីឡា និងបានបន្តការរចនាវិបសាយ
- ការរៀបចំបង្កើតក្របខណ្ឌនិងសៀវភៅណែនាំ ដើម្បីពន្លឿនដល់ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅតាមវិទ្យាល័យធនធានគោលដៅ
- ការប្រគល់កិច្ចសន្យាលើទំនិញ ៩កញ្ចប់តម្លៃ ០,៤៨៦ លានដុល្លារ និងសេវាប្រឹក្សាយោបល់ ១៩កញ្ចប់ តម្លៃ ៤,៧២ លានដុល្លា។ នៅសល់កញ្ចប់ទំនិញនិងសម្ភារៈ ១៧កញ្ចប់តម្លៃ ៦,៤៣ លានដុល្លារ ព្រមទាំងការងារសំណង់ ១១កញ្ចប់តម្លៃ ១០,២៤ លានដុល្លារ ដែលនឹងត្រូវប្រគល់កិច្ចសន្យានៅក្នុងឆ្នាំ២០២១ និង២០២២។

៣. **គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (SEIP)** មានថវិកាសរុប ៤០ លានដុល្លារអាមេរិក គាំទ្រដោយធនាគារពិភពលោក មានរយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២។ គម្រោងនេះបានផ្តោតលើការពង្រឹងការ

គ្រប់គ្រងសាលារៀន (SBM) តាមរយៈការផ្ដល់មូលនិធិកែលម្អសាលារៀន ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀននៅមធ្យមសិក្សាបឋមភូមិ និងការកែលម្អបរិក្ខារសាលារៀន ដោយបាននឹងកំពុងអនុវត្តក្នុងសាលារៀនមធ្យមសិក្សាគោលដៅ ១០០ ទាំង ២៥ខេត្ត រាជធានី។ វឌ្ឍនភាពសំខាន់ៗ រួមមាន៖

- គ្រូបង្គោលថ្នាក់ជាតិ ៥៧នាក់ បានទទួលការបណ្តុះបណ្តាលបំប៉នចំណេះដឹងបន្ថែម ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចុះជួយ និងគាំទ្រដល់បុគ្គលិកថ្នាក់ក្រោមជាតិ និងសាលារៀនគោលដៅ ដើម្បីឱ្យសាលារៀនគោលដៅទាំងអស់នោះសម្រេចបានស្តង់ដាប្រសិទ្ធភាព
- គ្រប់សាលារៀនគោលដៅទាំងអស់ បានអនុវត្តកម្មវិធីធ្វើតេស្តស្តង់ដាកំណត់លទ្ធផលសិក្សារបស់សិស្ស និងការជួយសិស្សរៀនយឺត រៀបចំផែនការអភិវឌ្ឍន៍សាលារៀន បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន រៀបចំកិច្ចព្រមព្រៀងរបស់គ្រូ និងគណៈគ្រប់គ្រង ប្រជុំ ពិនិត្យតាមដានជាប្រចាំការអនុវត្តផែនការ កែលម្អវិធីសាស្ត្របង្រៀន និងរៀន កៀរគរការចូលរួមរបស់សហគមន៍ មាតាបិតា និងអាជ្ញាធរមូលដ្ឋាននិងរៀបចំស្វ័យវាយតម្លៃ (កម្រិតសាលា)វាយតម្លៃផ្ទៃក្នុង(កម្រិតអន្តរនាយកដ្ឋាន)និងវាយតម្លៃផ្ទៃក្រៅ(ពីធនាគារពិភពលោក)។ ជាលទ្ធផលក្នុងឆ្នាំសិក្សា២០១៩-២០២០ សាលារៀនគោលដៅ ៣៦ បានជាប់ជាសាលារៀនស្តង់ដាប្រសិទ្ធភាព។ ចំនួននេះជាចំនួនលើសពីការផែនការគ្រោងទុកប្រចាំឆ្នាំរបស់គម្រោងដែលមានត្រឹមតែ ២០សាលា
- ក្នុងអំឡុងពេលនៃការបង្ការ និងទប់ស្កាត់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានផលិតសន្លឹកកិច្ចការ វីដេអូថ្នាក់ទី៧ ដល់ទី១២ លើមុខវិជ្ជាគោល៦ សម្រាប់រៀន និងបង្រៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងចែកជូនទៅដល់សាលារៀន សិស្ស គ្រូបង្រៀន ព្រមទាំងមានការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ និងការផ្សាយតាមទូរទស្សន៍ជាតិ
- សហការជាមួយគម្រោងកែលម្អការអប់រំនៅឧត្តមសិក្សាដោយសហការជាមួយសាកលវិទ្យាល័យរដ្ឋ៦ លើកម្មវិធីបំណិនកសិកម្ម និងកម្មវិធីរកប្រាក់ចំណូល ដើម្បីផ្សារភ្ជាប់មធ្យមសិក្សានិងឧត្តមសិក្សាក្នុងគោលបំណង ១). សិស្សត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់បន្តការសិក្សានៅឧត្តមសិក្សា ២).សិស្សសម្រួចជំនាញទៅតាមឧប្បនិស្ស័យ ៣).សិស្សមានជីវភាពរស់នៅសមរម្យប្រចាំថ្ងៃ និង ៤).សិស្សមានលទ្ធភាពថវិកាគ្រប់គ្រាន់ដើម្បីបន្តការសិក្សានៅកម្រិតឧត្តមសិក្សា
- គរុនិស្សិតជាគ្រូបង្រៀនបានចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជំនាន់ទី១ ទី២ និងទី៣ កើនដល់ ២ ២៧៧នាក់ ក្នុងនោះគរុនិស្សិតស្ត្រី ៩៦០នាក់។ ចំនួនបានកើនឡើងលើសផែនការដែលបានគ្រោងទុកត្រឹមតែ ២២០០នាក់ តែប៉ុណ្ណោះ។ រហូតមកដល់ដំណាច់ឆ្នាំ២០២០នេះ មានគរុនិស្សិតបានបញ្ចប់វគ្គសិក្សាទាំងពីរជំនាន់ ៨៥៥នាក់ ស្រី ៣៤៨នាក់
- គរុនិស្សិតជានាយក នាយករងសាលារៀន និងមន្ត្រីការិយាល័យអប់រំក្រុង ស្រុកបានចុះឈ្មោះចូលរៀននៅជំនាន់ទី ១ និងទី២ ចំនួន ៦០៥នាក់ ស្រី ៧៨នាក់ បានចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គរុនិស្សិតជំនាន់ទី១ បានប្រឡងបញ្ចប់ ១៥០នាក់ ស្រី ១០នាក់។ គរុនិស្សិតជំនាន់ទី២ នឹងបញ្ចប់នៅខែឧសភាឆ្នាំ២០២២
- ការសាងសង់អគារសិក្សា ៣៨ខ្នង ស្មើ ១៩៥បន្ទប់ (៣០ លើទីតាំងថ្មីមិនមែនជាសាលាគោលដៅ ១០០របស់គម្រោង និង ៨ លើទីតាំងសាលារៀនគោលដៅទាំង ១០០)
- ការសាងសង់អគារផ្ទះស្នាក់នៅគ្រូបង្រៀន ៣០ខ្នង ស្មើ ៩០បន្ទប់
- ការជួសជុល និងបំពាក់សម្ភារពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា) ចំនួន ៩២ទីតាំង ស្មើ ៤៣៧បន្ទប់)

- ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនសាលាគោលដៅស្ដីពី "លទ្ធផលកម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ (PISA-D) ដល់សាលារៀនគោលដៅ មន្ទីរអប់រំ យុវជន និងកីឡា គ្រូបង្គោលថ្នាក់ជាតិ គ្រូឧទ្ទេស គណៈគ្រប់គ្រងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ១៦២នាក់ ស្រី ១៩នាក់
- ការពិនិត្យតាមដាន និងជួយពង្រឹងការអនុវត្តវង្វាយតម្លៃលទ្ធផលសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកឱ្យឆ្លើយតបនឹងកម្មវិធីអន្តរជាតិស្ដីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ១១ ខេត្ត រួមមានខេត្តបាត់ដំបង បន្ទាយមានជ័យ មណ្ឌលគិរី ស្ទឹងត្រែង សៀមរាប ព្រះសីហនុ កោះកុង ពោធិ៍សាត់ កំពត ប៉ៃលិន និងព្រះវិហារ។

៤. មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំទី៣ (GPE3) មានថវិកា ២០,៦ លានដុល្លារអាមេរិក ផ្ដោតលើការអភិវឌ្ឍសមត្ថភាព និងកម្មវិធីអប់រំគ្រូបង្រៀន មានរយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។ គម្រោងនេះ បានផ្ដោតលើការពង្រឹងការគ្រប់គ្រងតាមសាលារៀន (SBM) ការអនុវត្តអំណានថ្នាក់ដំបូង (EGRA) និងគណិតវិទ្យាថ្នាក់ដំបូង (EGMA) និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ១១។ វឌ្ឍនភាពសំខាន់ៗនៃផ្នែកថេរ (ការពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា) មានទឹកប្រាក់ ១៤,៤ លានដុល្លារអាមេរិក (ដោយឡែកលទ្ធផលផ្នែកអថេរមាននៅក្នុងការអនុវត្ត CDPF)។ វឌ្ឍនភាពសំខាន់ៗរួមមាន៖

- ការរៀបចំប្រព័ន្ធក្រឌីតអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងបានធ្វើសមាហរណ័កម្មជាមួយនឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ព្រមទាំងកំពុងរៀបចំសៀវភៅការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD handbook)
- ការរៀបចំ និងផ្សព្វផ្សាយគោលនយោបាយស្ដីពីគន្លងអាជីពគ្រូបង្រៀន និងសេចក្ដីណែនាំប្រតិបត្តិស្ដីពីគន្លងអាជីព
- ការរៀនកម្រិតថ្នាក់បរិញ្ញាបត្រអប់រំឆ្នាំដំបូងដោយផ្ទាល់ ត្រូវបានបញ្ចប់ដោយជោគជ័យ។ ការស្រាវជ្រាវប្រតិបត្តិ និងការរៀនដោយផ្ទាល់ឆ្នាំទី២ ត្រូវបានពន្យាពេលដល់ឆ្នាំ ២០២១ ដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩
- ការបណ្ដុះបណ្ដាលគ្រូបង្រៀនអំពីវិធីសាស្ត្របង្រៀនអំណានថ្នាក់ដំបូងសម្រាប់ថ្នាក់ទី១ ចំនួន ១ ១៨៩នាក់ ស្រី ៨៦៣នាក់ នៅ ៤ខេត្ត (មិនរាប់បញ្ចូលខេត្តសៀមរាប) និងថ្នាក់ទី២ ចំនួន ២ ០២៧នាក់ ស្រី ១ ៣៩៣នាក់ នៅខេត្តក្រចេះ សៀមរាប ស្ទឹងត្រែង ឧត្ដរមានជ័យ និងព្រះវិហារ
- ការបណ្ដុះបណ្ដាលគ្រូបង្រៀនអំពីវិធីសាស្ត្របង្រៀនគណិតវិទ្យាថ្នាក់ដំបូងថ្នាក់ទី១ ចំនួន ២ ០៣៣នាក់ ស្រី ១ ៣៩០នាក់ នៅ ៥ខេត្ត (ខេត្តសៀមរាប ក្រចេះ ស្ទឹងត្រែង ឧត្ដរមានជ័យ និងព្រះវិហារ) និងថ្នាក់ទី២ ចំនួន ៨២៧នាក់ ស្រី ៦៣៧នាក់ នៅខេត្តសៀមរាប
- ការបោះពុម្ពសៀវភៅណែនាំគ្រូ ២ ១៣០ក្បាល និងសៀវភៅជំនួយសិស្ស ៣ ៤០០សំណុំ សម្រាប់ការសិក្សាភាសាខ្មែរថ្នាក់ទី២។ បោះពុម្ពសៀវភៅជំនួយសិស្ស ៧៧ ០០០ក្បាល។ បោះពុម្ពឯកសាររៀនបង្រៀន ១ ៤៧០ សំណុំ សៀវភៅលំហាត់ ២៤ ៥៤៦ក្បាល សន្លឹកកិច្ចការ ៨០ ៥០០ សម្រាប់គណិតវិទ្យាថ្នាក់ទី១។ បោះពុម្ពសៀវភៅណែនាំគ្រូ ១ ៨៦៣ក្បាល ឯកសាររៀនបង្រៀន ១ ០៨០សំណុំ សៀវភៅលំហាត់ ៩ ៦១៤ក្បាល សៀវភៅជំនួយសិស្ស ៣៨ ៤៥៦ក្បាល សម្រាប់គណិតវិទ្យាថ្នាក់ទី២
- ការដាក់ឱ្យប្រើប្រាស់កញ្ចប់សម្ភារៈបង្រៀន និងរៀនអក្សរសាស្ត្រខ្មែរថ្នាក់ទី១ នៅខេត្តចំនួន ៤ និងថ្នាក់ទី២ នៅខេត្តសៀមរាប។ គណិតវិទ្យាថ្នាក់ដំបូង ក៏ត្រូវបានសាកល្បងនៅខេត្តសៀមរាបផងដែរ
- ការជួសជុលសាលាគរុកោសល្យនិងវិក្រឹតការខេត្ត១១ ក្នុងនោះបានបញ្ចប់ការជួសជុសនៅខេត្តកំពត កំពង់ស្ពឺ កំពង់ធំ ពោធិ៍សាត់ បន្ទាយមានជ័យ ក្រចេះ និងកំពុងជួសជុលនៅខេត្តកំពង់ឆ្នាំង ស្វាយរៀង ព្រះវិហារ ព្រះសីហនុ និងស្ទឹងត្រែង

- ការបញ្ចប់ការអនុវត្តសាកល្បងប្រព័ន្ធទិន្នន័យតាមដានសិស្ស (STS) នៅសាលាបឋមសិក្សា និងមធ្យមសិក្សា ក្នុងស្រុកពួក ខេត្តសៀមរាប
- ការបញ្ចប់ការធ្វើតេស្តវង្វាយតម្លៃដើមគ្រា (Baseline) លើអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង (EGRA& EGMA) នៅតាមសាលារៀន ៣៤០ ក្នុង៩ខេត្តគោលដៅ បានការគាំទ្របច្ចេកទេសពីអង្គការ KAPE លើការ សរសេររបាយការណ៍
- ថវិកាសរុបដែលបានបែងចែកនៅក្នុងកិច្ចព្រមព្រៀងដៃគូសម្រាប់អនុវត្ត និងចុះហត្ថលេខាចាប់តាំងពីការចាប់ផ្តើមគម្រោងរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ចំនួន ១០ ៥៨៧ ៧៤១,១០ ដុល្លារអាមេរិក ក្នុងនោះទឹកប្រាក់ចំនួន ៥ ៤០៣ ៩៣៥,៨៧ ដុល្លារអាមេរិក ត្រូវបានផ្ទេរទៅក្នុងគណនីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការចំណាយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ អនុវត្តបាន ៤ ៩០៩ ០៦០,៦២ ដុល្លារអាមេរិក ស្មើ ៤៦,៣៧ ភាគរយ។ អត្រាការប្រើប្រាស់ទាបដោយសារសកម្មភាពមួយចំនួន ដូចជា សិក្ខាសាលា បណ្តុះបណ្តាល និងពិគ្រោះយោបល់ត្រូវបានលុបចោល ឬពន្យារពេល នៅពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩ ។

**៥. មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពដំណាក់កាលទី៣ (CDPF 3)** មានថវិកា ៣២ លានដុល្លារអាមេរិក គាំទ្រដោយសហភាពអឺរ៉ុប រដ្ឋាភិបាលស៊ុយអែត អង្គការយូនីសេហ្វ មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ (ផ្នែកអថេរដែលមានទឹកប្រាក់ ៦,២ លានដុល្លារអាមេរិក) និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ មានរយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៣។ មូលនិធិនេះសម្រាប់ពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការ ការពិនិត្យតាមដាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយ និងកំណែទម្រង់។ ក្នុងឆ្នាំ២០២០ មូលនិធិនេះ គាំទ្រសង្គ្រោះបន្ទាន់ដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការឆ្លើយតបនឹងជំងឺរីករាលដាលកូវីដ-១៩។ ការគាំទ្រទូទាំងប្រទេសនេះ បានផ្តល់មធ្យោបាយដល់កុមារក្នុងការបន្តការសិក្សាកំឡុងពេលបិទសាលារៀន ជំនួយដល់ការបើកសាលារៀនឡើងវិញប្រកបសុវត្ថិភាពក្នុងបរិបទកូវីដ-១៩។ វឌ្ឍនភាពសំខាន់ៗរួមមាន៖

- ការបញ្ចប់ការពិនិត្យឡើងវិញទៅលើមុខងាររបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលជាការងារមួយមានវិសាលភាពធំ និងម៉ត់ចត់ ដោយបានផ្តល់អនុសាសន៍គន្លឹះ និងជាក់លាក់ដល់ក្រសួងក្នុងការពង្រឹងការអភិវឌ្ឍនៅកម្រិតស្ថានប័នឱ្យមានប្រសិទ្ធភាពបន្ថែមទៀត
- ផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពឆ្នាំ២០២០-២០២៤ គ្រោងនឹងបញ្ចប់នៅដើមឆ្នាំ២០២១។ ឯកសារនេះនឹងផ្តល់ជាក្របខណ្ឌសម្រាប់គាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីឆ្ពោះទៅសម្រេចវត្ថុបំណងគោលនយោបាយ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ការគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីបន្តផលិតឯកសារសម្រាប់ការសិក្សាពីចម្ងាយប្រកបដោយបរិយាបន្នតាមរយៈការផលិតវីដេអូមេរៀន និងមេរៀនអេឡិចត្រូនិក ដើម្បីឆ្លើយតបនឹងជំងឺរីករាលដាលកូវីដ-១៩។ ដោយសារផលប៉ះពាល់របស់ជំងឺនេះនៅប្រទេសកម្ពុជាកាន់តែខ្លាំង ធនធានរបស់មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ ត្រូវបានប្រើដើម្បីគាំទ្រដល់ការចូលរៀនវិញ គាំទ្រលើការរក្សាសុវត្ថិភាព អនាម័យមូលដ្ឋានដល់សាលារៀនរដ្ឋ ១៣ ៤៨២ និងគាំទ្រការបើកដំណើរការសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាព និងមានផាសុខភាព ព្រមទាំងយុទ្ធនាការជំរុញឱ្យមានអនាម័យស្អាត និងវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩
- ការវាយតម្លៃរួមគ្នាស្តីពី តម្រូវការសម្រាប់វិស័យអប់រំនៃផលប៉ះពាល់ពីជំងឺរីករាលដាលកូវីដ-១៩ ទៅលើកុមារដោយផ្តោតលើការចូលរៀន គុណភាពនិងប្រសិទ្ធភាពនៃការសិក្សាពីចម្ងាយ និងតម្រូវការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន មានអ្នកចូលរួមឆ្លើយក្នុងការវាយតម្លៃនេះ ១៥ ០០០នាក់ នៅទូទាំងប្រទេស

- ជំងឺរីករាលដាលកូវីដ-១៩ បានធ្វើឱ្យប្រែប្រួល និងពន្យាពេលអនុវត្តផែនការសកម្មភាពខ្លះ ប៉ុន្តែវឌ្ឍនភាពការងារនៅតែបន្តទៅមុខ តាមរយៈការគាំទ្រដល់នាយកដ្ឋានជំនាញឬស្ថាប័នអប់រំ ២២ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ២ (VSO និងអង្គការសង្គ្រោះកុមារ) ដៃគូអង្គការសហប្រជាជាតិ ១ (IIEP) និងអ្នកជំនួយការបច្ចេកទេសអន្តរជាតិ(បុគ្គល និងស្ថាប័ន) ៣៤។ ក្រុមបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ១៤ បានគាំទ្រដល់ការងារវាយតម្លៃពីផលប៉ះពាល់ដោយសារជំងឺរីករាលដាលកូវីដ-១៩
- ក្របខណ្ឌថវិកា GPE3 ផ្នែកអថេរមិនសម្រេចបានតាមចំណុចដៅទៅតាមពេលវេលាកំណត់ទេ ដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ-១៩ ដែលសកម្មភាពគាំទ្រត្រូវបានពន្យាពេលអនុវត្ត និងមានការឯកភាពពីក្រុមប្រឹក្សាមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ។

ជារួម មូលនិធិនេះបានគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីក្រសួង មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន ១២ ៧៥០នាក់ ដែលស្ថិតក្នុងចំណុចផលសម្រេចជាយុទ្ធសាស្ត្រទាំង៦ របស់មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ។ ៧២ភាគរយ នៃថវិកានេះបានផ្តល់ផលប្រយោជន៍ទៅដល់បុគ្គលិកអប់រំនៅថ្នាក់ក្រោមជាតិ ទាំងផ្ទាល់និងប្រយោល។ មានត្រឹមតែ ៣០ភាគរយ នៃបុគ្គលិកអប់រំទាំងអស់ជាស្ត្រីដែលនឹងត្រូវបានបន្តគាំទ្រដោយផ្តោតលើការបញ្ជ្រាបយេនឌ័រ និងការគាំទ្រដល់ថ្នាក់ដឹកនាំជាស្ត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡានៅគ្រប់កម្រិត។ បានប្រើប្រាស់ថវិកាសរុបប្រមាណ ៥,៥ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២០។

**៦. គម្រោងបង្កើតវិទ្យាស្ថានគរុកោសល្យនៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង (E-TECs)** មានថវិកា ៣៧ លានដុល្លារអាមេរិក គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានរយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀនថ្មីនៅកម្ពុជា។ វឌ្ឍនភាពសំខាន់ៗរួមមាន៖

**ការលើកកម្ពស់សមត្ថភាព៖**

- ការបញ្ជូនគ្រូឧទ្ទេស ៥នាក់ ស្រី ១នាក់ ទៅបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ស្តីពីការកែលម្អគុណភាពការអប់រំមូលដ្ឋាន នៅប្រទេសជប៉ុន ឆ្នាំ២០២០-២០២២
- ការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់គ្រប់មុខវិជ្ជា នៃកម្មវិធីអប់រំគ្រូបង្រៀនកម្រិតបឋមសិក្សា និងមុខវិជ្ជាវិធីសាស្ត្របង្រៀនសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ
- ការបំប៉នសមត្ថភាពគ្រូឧទ្ទេសស្តីពី ការរៀបចំកម្មវិធីសិក្សាលម្អិត ការសរសេរកិច្ចតែងការបង្រៀន តាមរយៈការអនុវត្តវិធីសាស្ត្របង្រៀនគាំទ្រជំនាញសតវត្សរ៍ទី២១
- ការបំប៉ន និងគាំទ្រសមត្ថភាពគ្រូឧទ្ទេសលើជំនាញស្រាវជ្រាវប្រតិបត្តិ(អប់រំ)
- ការកសាងសមត្ថភាពដឹកនាំគ្រប់គ្រង និងវាយតម្លៃ ដល់គណៈគ្រប់គ្រង និងគ្រូឧទ្ទេស

**ការសាងសង់ និងបំពាក់សម្ភារៈ៖** ការងារសាងសង់ និងបំពាក់សម្ភារៈសម្រេចបាន ១០០ភាគរយ និងលទ្ធផលនៅវិទ្យាស្ថានគរុកោសល្យមានដូចខាងក្រោម៖

**វិទ្យាស្ថានគរុកោសល្យបាត់ដំបង៖**

- ការសាងសង់អគាររដ្ឋបាល ១ខ្នង ៣ជាន់ ស្មើ ២៩បន្ទប់ ដោយមានបំពាក់សម្ភារៈការិយាល័យដូចជា តុ ទូ កៅអី ម៉ាស៊ីនត្រជាក់ និងកុំព្យូទ័រ
- ការសាងសង់អគារសិក្សា ១ខ្នង ៣ជាន់ ស្មើ ២៩បន្ទប់ ក្នុងនោះមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់សិល្បៈ បន្ទប់តន្ត្រី និងបន្ទប់គេហកិច្ច
- ការសាងសង់អគារបណ្ណាល័យមាន ៣ជាន់ រួមមានបណ្ណាល័យ បន្ទប់ស្វ័យសិក្សា សាលសហសិក្សា ២បន្ទប់ និងបន្ទប់កុំព្យូទ័រ ៤បន្ទប់

- ការសាងសង់អគារពហុមុខងារ ១ជាន់ ដែលអាចប្រើជាសាលប្រជុំ កីឡា និងសិល្បៈ
- ការសាងសង់អគារអន្តេវាសិកដ្ឋាន ១ខ្នង ៤ជាន់ ស្មើ ២២បន្ទប់ ក្នុងនោះបន្ទប់គេង ១៧ ក្នុង ១បន្ទប់មានគ្រែពីរជាន់ ៨ និងតុវែង ១ និងកៅអី ៨។ ចំណែក ៥បន្ទប់ទៀតរួមមាន បន្ទប់ផ្ទះបាយ ១ បន្ទប់បោកគក់ ១ បន្ទប់ងូតទឹក ១ បន្ទប់បង្គន់អនាម័យ ១ និងបន្ទប់ស្នាក់នៅរបស់គ្រូ ១
- ការបំពាក់កុំព្យូទ័រ ៣២គ្រឿង ក្នុង ១បន្ទប់
- ការបំពាក់សម្ភារៈ និងឧបករណ៍នៅតាមបន្ទប់ពិសោធន៍ បន្ទប់សិល្បៈ តន្ត្រី និងបន្ទប់គេហកិច្ច
- ការផ្តល់សៀវភៅអានសម្រាប់បណ្ណាល័យ។

**វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ៖**

- ការសាងសង់អគាររដ្ឋបាល ១ខ្នង ៣ជាន់ ស្មើ ១៦ បន្ទប់ ដោយមានបំពាក់សម្ភារៈការិយាល័យដូចជា តុ ទូ កៅអី ម៉ាស៊ីនត្រជាក់ និងកុំព្យូទ័រ
- ការសាងសង់អគារសិក្សា ១ខ្នង ២ជាន់ ស្មើ ៧បន្ទប់ ក្នុងនោះមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់សិល្បៈ និងបន្ទប់គេហកិច្ច
- ការសាងសង់អគារបណ្ណាល័យមាន ២ ជាន់ រួមមាន សាលសៀវភៅ សាលអាន និងបន្ទប់ កុំព្យូទ័រចំនួន ៤
- ការសាងសង់អគារពហុមុខងារ ១ជាន់ផ្ទាល់ដី ដែលអាចប្រើប្រាសបានជាសាលប្រជុំ កីឡា និងសិល្បៈ
- ការបំពាក់កុំព្យូទ័រ ៣២គ្រឿង ក្នុង ១បន្ទប់
- ការបំពាក់សម្ភារៈ និងឧបករណ៍នៅតាមបន្ទប់ពិសោធន៍ បន្ទប់សិល្បៈ តន្ត្រី និងបន្ទប់គេហកិច្ច
- ការផ្តល់សៀវភៅអានសម្រាប់បណ្ណាល័យ។

**៧. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការផ្គត់ផ្គង់សម្ភារបរិក្ខារអប់រំនៅកម្ពុជា** មានថវិកា ២០ លានដុល្លារ អាមេរិក គាំទ្រដោយសាធារណរដ្ឋប្រជាមានិតចិន មានរយៈពេលអនុវត្តពីឆ្នាំ២០១៩ ដល់២០២១។ វឌ្ឍនភាពសំខាន់ៗរួមមាន៖ សាងសង់អគារសិក្សា ២៧កន្លែងនៅតាមរាជធានី ខេត្ត ៣ រួមមាន៖ ខេត្តកណ្តាល ១១ ខេត្តកំពង់ចាម 10 និងរាជធានី ៦។ គម្រោងនេះគ្របដណ្តប់លើវិទ្យាល័យ ២៦ និងមជ្ឈមណ្ឌលគរុកោសល្យនិងវិក្រឹតការ ១ ក្នុងនោះសង់អគារសិក្សា ២៣ខ្នង ស្មើ ២៩៩បន្ទប់ អគារធនធាន ១៧កន្លែង អន្តេវាសិកដ្ឋាន ១ខ្នង ផ្ទះគ្រូ ៥កន្លែង ទីលានបាល់ទាត់ ៨ ទីលានបាល់បោះ ១៥ បង្គន់អនាម័យ ៣២ អណ្តូងទឹក ២៣ របងប្រវែង ៦៤0ម៉ែត្រ ផ្លូវនិងលូបង្ហូរទឹកបេតុងប្រវែង ៧៥0ម៉ែត្រ ឧបករណ៍បង្រៀន គ្រឿងសង្ហារិម និងបរិក្ខារផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់។ មកដល់បច្ចុប្បន្ននេះការអនុវត្តគម្រោងសម្រេចបាន ២៦,៨៤ភាគរយ។

**៨. គម្រោងកែលម្អការអប់រំនៅឧត្តមសិក្សា (HEIP)** មានថវិកា ៩២,៥ លានដុល្លារអាមេរិក (៩0 លានដុល្លារអាមេរិក គាំទ្រដោយធនាគារពិភពលោក និង ២,៥ លានដុល្លារអាមេរិក ជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា) មានរយៈពេលអនុវត្តពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៤។ គោលបំណងនៃគម្រោងនេះគឺការកែលម្អសមត្ថភាពនៃការរៀន និងបង្រៀន និងការស្រាវជ្រាវដោយផ្តោតលើស្ទែម កសិកម្ម និងការពង្រឹងប្រព័ន្ធអភិបាលកិច្ចអនុវិស័យឧត្តមសិក្សា។ គម្រោងនេះផ្តល់ការគាំទ្រដល់៖ គ្រឹះស្ថានឧត្តមសិក្សាគោលដៅ៥ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យស្វាយរៀង និងសាកលវិទ្យាល័យជាតិបាត់ដំបង) គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា អគ្គនាយកដ្ឋានឧត្តមសិក្សាក្នុងការពង្រឹងសមត្ថភាពនៃប្រព័ន្ធអភិបាលកិច្ចរបស់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់។ គម្រោងនេះក៏ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាឯកជនគោលដៅក្នុងការកែលម្អសមត្ថភាពរៀននិងបង្រៀន និងប្រព័ន្ធអភិបាលកិច្ច។ វឌ្ឍនភាពសំខាន់ៗរួមមាន៖

- គម្រោងនេះមានកិច្ចព្រមព្រៀងភាពជាដៃគូ ៣១។ កិច្ចព្រមព្រៀងភាពជាដៃគូ ១៥ បានចុះហត្ថលេខា និង ១៦ ទៀតគ្រោងនឹងចុះហត្ថលេខានៅដើមឆ្នាំ២០២១ ហើយក្នុងនោះ ២៨កិច្ចព្រមព្រៀងជាមួយដៃគូបរទេស និង ៣ទៀតជាមួយដៃគូក្នុងស្រុក។ ដៃគូអន្តរជាតិ ១២ ដែលបានចុះហត្ថលេខារួចហើយមាន ៤ជាមួយថៃ ២ជាមួយបារាំង ២ជាមួយហ្វីលីពីន និង ១ជាមួយអូស្ត្រាលី សហរដ្ឋអាមេរិក ជប៉ុន និងហុងកុង។ កិច្ចព្រមព្រៀងភាពជាដៃគូក្នុងស្រុក ៣ ត្រូវបានចុះហត្ថលេខាផងដែរគឺ ២ជាមួយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និង ១ទៀតជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- កិច្ចព្រមព្រៀងភាពជាដៃគូអន្តរជាតិ ១៦ ដែលកំពុងដំណើរការមាន ៣ជាមួយអូស្ត្រាលី ៣ជាមួយកូរ៉េ ២ជាមួយហុងកុង ២ជាមួយថៃ និង១ជាមួយបារាំង ឥណ្ឌូណេស៊ី ជប៉ុន ហ្វីលីពីន សហរដ្ឋអាមេរិក និងស៊ុយអែត
- ការផ្តល់គម្រោងស្រាវជ្រាវ ៥៣ ដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ៥ ក្នុងនោះ ៤៥គម្រោងបានផ្សារភ្ជាប់ទៅនឹងឧស្សាហកម្ម ដែលដឹកនាំនិងសហដឹកនាំដោយស្ត្រី ២២គម្រោង
- គ្រឹះស្ថានឧត្តមសិក្សាគោលដៅទាំងអស់បានបង្កើតគណៈកម្មាធិការប្រឹក្សាឧស្សាហកម្ម
- គ្រឹះស្ថានឧត្តមសិក្សាគោលដៅទាំងអស់បានបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំអំពី ដំណើរការបណ្តឹងតវ៉ារបស់សិស្ស ការប្រមូលមតិយោបល់ពីសិស្ស និងបានបញ្ជូនរបាយការណ៍ទៅនាយកដ្ឋានឧត្តមសិក្សា
- គ្រឹះស្ថានឧត្តមសិក្សាគោលដៅទាំងអស់បានបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំអំពី ការតាមដានការសិក្សា
- គ្រឹះស្ថានឧត្តមសិក្សាឯកជន ៨ ត្រូវបានជ្រើសរើស ដើម្បីផ្តល់ហិរញ្ញប្បទានឥតសំណងនៅដំណាក់កាលទី១
- ការផលិតវីដេអូឃ្លីបជាង ២ ៥០០ ដែលជាផ្នែកមួយនៃកម្មវិធីរៀនតាមប្រព័ន្ធអេឡិកត្រូនិក ដើម្បីជួយកាត់បន្ថយ និងប្រឆាំងនឹងការបិទស្ថាប័នអប់រំក្នុងកំឡុងពេលជំងឺរាតត្បាតកូវីដ-១៩
- គ្រឹះស្ថានឧត្តមសិក្សា ១០ ត្រូវបានទទួលស្គាល់គុណភាពអប់រំពេញលេញ
- ការរៀបចំគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង និងការគ្រប់គ្រងធនធានមនុស្សសម្រាប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាលត្រូវបានអភិវឌ្ឍ
- ការគ្រប់គ្រឹះស្ថានឧត្តមសិក្សាគោលដៅទាំងអស់ បាននឹងកំពុងរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំអំពីប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និងអគ្គនាយកដ្ឋានឧត្តមសិក្សាកំពុងរៀបចំគោលការណ៍ណែនាំទូទៅអំពីប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងសម្រាប់អនុវិស័យឧត្តមសិក្សា
- ការព្រាងសូចនាករថ្មី២៦ ដើម្បីលើកកម្ពស់ស្តង់ដាគុណភាពកម្រិតកម្មវិធីសម្រាប់ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង
- ការផ្សព្វផ្សាយសៀវភៅណែនាំស្តីពីដំណើរការ និងនីតិវិធីនៃការវាយតម្លៃក្នុងការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាសម្រាប់មន្ត្រីវាយតម្លៃ
- ការបញ្ចប់យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ និងយុទ្ធសាស្ត្រគ្រឹះស្ថានឧត្តមសិក្សា២០២១-២០៣០ ចំនួន ៥
- ការរៀបចំកម្មវិធីភាពជាដៃគូការអប់រំស្វែមរវាងគ្រឹះស្ថានឧត្តមសិក្សា និងសាលារៀនមធ្យមសិក្សាតាមរយៈគម្រោងកែលម្អការអប់រំឧត្តមសិក្សា និងគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា។

## ទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិបំពេញការងារនៅតាមអង្គភាពក្រោមឱវាទក្រសួង និងថ្នាក់ក្រោមជាតិ

ក្រសួងបានប្រមូល និងរៀបចំចងក្រងព័ត៌មានស្តីពីទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិដែលបានបំពេញការងារនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីពិនិត្យតាមដានអំពីវឌ្ឍនភាពនៃការបំពេញការងាររបស់ទីប្រឹក្សាបច្ចេកទេស។ នៅឆ្នាំ២០២០ ទីប្រឹក្សាបច្ចេកទេសសរុប ២៤ នាក់ ស្រី ៣នាក់ បម្រើការងារនៅអង្គភាពក្រោមឱវាទក្រសួង ក្នុងនោះទីប្រឹក្សាជាតិ ១១នាក់ និងអន្តរជាតិ ១៣នាក់។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានជំនួយការបច្ចេកទេស ១៨នាក់ ស្រី ៩នាក់ ភាគច្រើនជាអ្នកស្ម័គ្រចិត្ត។

ជារួម ចំនួនទីប្រឹក្សាបច្ចេកទេសបម្រើការងារនៅក្នុងក្រសួង មានការថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ស្របទៅនឹងគោលការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ។

### លទ្ធផលការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ

នៅឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ បានរៀបចំកិច្ចប្រជុំ ២ដង ដើម្បីពិភាក្សា និងដោះស្រាយ ការអនុវត្តគោលនយោបាយ កំណែទម្រង់វិស័យអប់រំ ការពង្រឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងការបង្ហាញពីវឌ្ឍនភាពសំខាន់ៗ រួមទាំងការពិនិត្យតាមដាន។ ក្រុមការងារនេះបានផ្តោតការយកចិត្តទុកដាក់លើសកម្មភាពពាក់ព័ន្ធនឹងនិរន្តរភាពនៃការសិក្សារបស់សិស្សានុសិស្ស ទាក់ទងនឹងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការគៀរគរធនធានសម្រាប់ការសិក្សាក្នុងបរិបទកូវីដ-១៩។ កម្ពុជាទទួលបានហិរញ្ញប្បទានឥតសំណង ៧ លានដុល្លារអាមេរិក សម្រាប់ដោះស្រាយការរៀនសូត្រក្នុងបរិបទកូវីដ-១៩ និង ១០លានដុល្លារអាមេរិក ផ្សេងទៀតសម្រាប់ការអភិវឌ្ឍវិស័យអប់រំ ពីមូលនិធិសកលសម្រាប់ការអប់រំ។

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី ខេត្ត ១១ ស្មើ ៤៤ភាគរយ បានធ្វើបច្ចុប្បន្នកម្មសមាសភាពក្រុមការងារ ។ ២២ ខេត្ត រាជធានី បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០២០ និង ១០ខេត្ត បានដំណើរការកិច្ចប្រជុំតាមត្រីមាស។ ក្រុមការងារថ្នាក់ខេត្តនេះបានប្រជុំពិភាក្សាអំពីការពង្រឹងការសិក្សាតាមអនឡាញ និងការបើកសាលារៀនឡើងវិញ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងការរៀបចំផែនការអប់រំឆ្លើយតបទៅនឹងផលប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ-១៩។

### ២.១.៤.៣ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ច្បាប់ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

#### ការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រអនុវិស័យឱ្យឆ្លើយតបទៅនឹងច្បាប់ស្តីពីការអប់រំ និងកំណែទម្រង់វិស័យអប់រំ

ក្រសួងបានរៀបចំ៖

- ព្រះរាជក្រឹត្យលេខ នស/រកត/០៨២០/ ៩២៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត
- អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានរៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា និងមជ្ឈមណ្ឌលជាតិព័ត៌មាននិងស្ថិតិកីឡាចំណុះអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា
- អនុក្រឹត្យលេខ ២០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការប្តូរឈ្មោះសាកលវិទ្យាល័យបាត់ដំបងមកជាសាកលវិទ្យាល័យជាតិបាត់ដំបង
- អនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការប្តូរឈ្មោះសាកលវិទ្យាល័យមានជ័យមកជាសាកលវិទ្យាល័យជាតិមានជ័យ
- អនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា
- អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន ៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត ១៥ និងសាលាអនុវត្តន៍ ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រកាសលេខ ១៦៤១ អយក.ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍កីឡា និងមជ្ឈមណ្ឌលព័ត៌មាននិងស្ថិតិកីឡា
- ប្រកាសលេខ ៣៨២ អយក.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតមូលនិធិស្រាវជ្រាវគំនិតច្នៃប្រឌិត និងនវានុវត្តន៍នៃក្រសួងអប់រំ យុវជន និងកីឡា

- ប្រកាសលេខ ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំ
- សេចក្តីសម្រេចលេខ ៤៥ អយក.សសរ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជាសម្រាប់អាណត្តិទី៤
- សេចក្តីសម្រេចលេខ ៥៥ អយក.សសរ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា
- សេចក្តីសម្រេចលេខ ៥៦ អយក.សសរ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងសាកលវិទ្យាល័យជាតិបាត់ដំបង
- សេចក្តីសម្រេចលេខ ៧១ អយក.សសរ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍធនធានគ្រូបង្រៀន
- ប្រកាសលេខ ១៨៨៧ អយក.ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការគ្រប់គ្រងអនុវិទ្យាល័យអនុវត្តន៍និងបឋមសិក្សាអនុវត្តន៍នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបងមកស្ថិតក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានគរុកោសល្យបាត់ដំបង
- ប្រកាសលេខ ៣០៦ អយក.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការលើកកម្ពស់អ្នកសិក្សាពូកែដែលមានទេពកោសល្យ ឬ បញ្ញាខ្ពស់
- ប្រកាសលេខ ៦៤២ អយក.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាលម្អិតជំនាញកែច្នៃអាហារកម្រិតមធ្យមសិក្សាទុតិយភូមិផ្នែកអប់រំបច្ចេកទេស
- ប្រកាសលេខ ៦៤៣ អយក.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការកំណត់វិញ្ញាបនបត្របច្ចេកទេសនិងវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ
- ប្រកាសលេខ ១៨៨៦ អយក.ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការគ្រប់គ្រងអនុវិទ្យាល័យអនុវត្តន៍ និងបឋមសិក្សាអនុវត្តន៍នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញមកស្ថិតក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
- ប្រកាសលេខ ២៩៥៤ អយក.ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ស្តីពីយន្តការនិងនីតិវិធីនៃការគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- សេចក្តីសម្រេចលេខ ៥៤ អយក.សសរ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ស្តីពីគណៈកម្មការរៀបចំ និងអភិវឌ្ឍផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០២១-២០២៥) របស់មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស(SEAMEO TED)
- សេចក្តីណែនាំលេខ ០១ អយក.សណន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ស្តីពីការពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន
- សេចក្តីណែនាំលេខ ៤៦ អយក.សណន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការអនុវត្តតួនាទីភារកិច្ចរបស់គណៈអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ខណ្ឌក្នុងដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ចូលរួមពិនិត្យទុនគ្រាដំបូងរបស់សាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ សាកលវិទ្យាល័យស្វាយរៀង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិបាត់ដំបង ដើម្បីជាមូលដ្ឋានក្នុងការរៀបចំលិខិតបទដ្ឋានប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបាន៖

- រៀបចំនីតិវិធីស្តង់ដានៃការអនុវត្តមុខងារវិស័យអប់រំ និងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារផ្តល់សេវាអប់រំ
- ព្រាងស្តង់ដាអប្បបរមានៃការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចុះសិក្សាទិន្នន័យដើមគ្រាអំពីមុខងារវិស័យអប់រំដែលបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
- ព្រាងសេចក្តីណែនាំស្តីពី នីតិវិធី បែបបទ ក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ព្រាងប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងគោលការណ៍ណែនាំនានាគាំទ្រអនុក្រឹត្យលេខ ១៨២, ១៨៣, ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌ
- ផ្សព្វផ្សាយអនុក្រឹត្យលេខ ១៨២, ១៨៣, ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពី មុខងារនិងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌ ដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ១០០នាក់ ស្រី ២០នាក់ និងថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ១៥៦នាក់ ស្រី ២៧នាក់
- រៀបចំក្រុមការងារអន្តរក្រសួងដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាមួយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.)និងសាលាជាតិរដ្ឋបាលមូលដ្ឋាន
- ព្រាងឯកសារសម្រាប់បណ្តុះបណ្តាលស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ការពង្រឹងការអនុវត្តគោលការណ៍អភិបាលកិច្ចល្អវិស័យអប់រំ និងគណនេយ្យភាពសង្គម

ក្រសួងបាន ៖

- កែសម្រួលឡើងវិញឯកសារតម្រង់ទិសលើការងារគ្រប់គ្រងតាមគោលការណ៍អភិបាលកិច្ចល្អ
- រៀបចំផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមលើការងារអភិបាលកិច្ចល្អ
- កែសម្រួលឡើងវិញសូចនាករ ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) ក្នុងវិស័យអប់រំ
- ផ្តល់សេវាជូនអតិថិជនលើការស្នើសុំអាជ្ញាបណ្ណទទួលស្គាល់ការបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនគ្រប់កម្រិត ១១៤ និងគ្រឹះស្ថានឧត្តមសិក្សា ៥
- ផ្តល់សេវាជូនអតិថិជនលើការស្នើសុំបន្តសុពលភាព ប្តូរឈ្មោះនាយក និងប្តូរទីតាំងសាលា ២៧គ្រឹះស្ថានសិក្សាឯកជន។

## ការពង្រឹងសមត្ថភាពលើការប្រមូលព័ត៌មានស្តីពីផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត

ក្រសួងបាន ៖

- រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពស្តីពី ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអប់រំដល់បុគ្គលិកអប់រំថ្នាក់ក្រោមជាតិ មានអ្នកចូលរួម ៩៦នាក់ ស្រី ១២នាក់ នៅខេត្តកំពង់ធំ
- ពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី ការកំណត់តួនាទីភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានអ្នកចូលរួម ៣៧នាក់ ស្រី ៥នាក់ នៅខេត្តកំពង់ចាម កំពង់ឆ្នាំង និងបាត់ដំបង
- រៀបចំសៀវភៅស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

### ២.១.៨.៨ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ
### ស្ថានភាពបុគ្គលិកអប់រំ

បុគ្គលិកអប់រំគ្រប់ប្រភេទក្របខណ្ឌ ១២៣ ២៥០នាក់ ស្រី ៥៧ ៣៦៣នាក់ ត្រូវជា ៤៦,៥៥ភាគរយ ក្នុងនោះនៅថ្នាក់ជាតិ ៣ ៧៨៦នាក់ ស្រី ១ ០៥៧នាក់ និងថ្នាក់ក្រោមជាតិ ១១៩ ៤៦៤នាក់ ស្រី ៥៦ ៣០៦នាក់។ គ្រូមត្តេយ្យសិក្សា ៣ ៨២០នាក់ ស្រី ៣ ៧១៨នាក់ គ្រូបឋមសិក្សា ៥៣ ២៦៣នាក់ ស្រី ២៧ ៨៨២នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋាន (ចំណេះទូទៅ) ៤៣ ៥០៨នាក់ ស្រី ១៨ ៨៥៥នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋាន(អប់រំកាយនិងកីឡា) ២ ៥០៣នាក់ ស្រី ៥២៥នាក់ គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅវិទ្យាល័យ) ១៨ ២២៤នាក់ ស្រី ៥ ៩៥០នាក់ គ្រូបង្រៀនកម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ១ ៦៦២នាក់ ស្រី ៣៩៤នាក់ អធិការបឋម ៤០នាក់ ស្រី ៦នាក់ និងអធិការមធ្យម ២៣០នាក់ ស្រី ៣៣នាក់។

ក្រសួងបានៈ

- ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ៧០៤នាក់ ស្រី ២៧២នាក់ ក្នុងនោះថ្នាក់ជាតិ ៤៥០នាក់ ស្រី ១៦៦នាក់ និងថ្នាក់ក្រោមជាតិ ២៥៤នាក់ ស្រី ១០៦នាក់
- ប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ១៣ ៩៤១នាក់ ស្រី ៧ ៨០៧នាក់ ក្នុងនោះ គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ ១១ ២៩១នាក់ ស្រី ៦ ៩៣៦នាក់ និងគ្រូអក្ខរកម្មជាប់កិច្ចសន្យា ២ ៤៧២នាក់ ស្រី ៨២១នាក់ និងកិច្ចសន្យាខ្មែរឥស្លាម ១៧៨នាក់ ស្រី ៥០នាក់
- ប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរពេល ១០ ២០០នាក់ ស្រី ៤ ៧៧២នាក់ គ្រូបង្រៀនថ្នាក់គួបពីរកម្រិត ២ ៦៦១នាក់ ស្រី ៩២០ នាក់ និងគ្រូបង្រៀនថ្នាក់គួបបីកម្រិត ៩៤នាក់ ស្រី ១៣នាក់
- ដាក់ឱ្យអនុវត្តបន្តគោលការណ៍ស្តីពី ការជ្រើសរើសគ្រូថ្មីដោយតម្រូវឱ្យបេក្ខជនមានទិដ្ឋាការពីនាយកគ្រឹះស្ថានសិក្សានិងអង្គភាពដែលខ្វះគ្រូ មុននឹងដាក់ពាក្យប្រឡងចូលធ្វើជាគ្រូបង្រួបង្រៀនគ្រប់កម្រិត
- ពង្រាយគ្រូចេញពីសាលាលើសគ្រូ ទៅសាលាខ្វះគ្រូគ្រប់កម្រិត ១៨នាក់ ស្រី ១៣នាក់
- ប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ១ ១៨៦នាក់ ស្រី ៦១០នាក់ ក្នុងនោះចូលនិវត្តន៍មុនកំណត់ ១៧៧នាក់ ស្រី ៨៨នាក់ គ្រប់រាជធានី ខេត្ត
- ស្នើសុំកែតម្រូវសលាកបត្រចូលនិវត្តន៍ ៣៨៤នាក់ ស្រី ១៩៣នាក់
- ស្នើសុំគោលការណ៍បោះពុម្ពសលាកបត្រចូលនិវត្តន៍ឆ្នាំ ២០១៩ -២០២០ ចំនួន ១៩៩នាក់ ស្រី ៩៤នាក់
- ប្រកាសផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់មន្ត្រីរាជការ ៥០នាក់ ស្រី ១៦នាក់
- ប្រកាសផ្ទេរក្របខណ្ឌបុគ្គលិកអប់រំទៅក្រសួងស្ថាប័ននានា ៤១នាក់ ស្រី ១២នាក់ ក្នុងនោះក្របខណ្ឌបឋមសិក្សា ៨នាក់ ស្រី ២នាក់ ក្របខណ្ឌមូលដ្ឋាន ១៦នាក់ ស្រី ៦នាក់ និងក្របខណ្ឌឧត្តម ១៧នាក់ ស្រី ៤នាក់
- ប្រកាសទទួលក្របខណ្ឌពីក្រសួងស្ថាប័ននានា ១៤នាក់ ស្រី ៤នាក់ ក្នុងនោះក្របខណ្ឌឧត្តម ១៣នាក់ ស្រី ៣នាក់ និងក្របខណ្ឌបឋមសិក្សា ១នាក់ ស្រី ១នាក់
- ប្រកាសបុគ្គលិកអប់រំចូលបម្រើការងារក្នុងក្របខណ្ឌដើម ៣នាក់ ស្រី ៣នាក់
- ប្រកាសអនុញ្ញាតច្បាប់ក្រោម ១៥ថ្ងៃ ដល់បុគ្គលិកអប់រំ ១នាក់ ស្រី ១នាក់
- ប្រកាសលុបឈ្មោះបុគ្គលិកអប់រំ ២៧៦នាក់ស្រី ៧៨នាក់
- ប្រកាសដាក់បុគ្គលិកអប់រំឱ្យនៅទំនេរគ្មានបៀវត្ស ១៦៩នាក់ ស្រី ៧០នាក់
- ប្រកាសអនុញ្ញាតឱ្យបុគ្គលិកអប់រំចូលបម្រើការងារវិញ ៦៩នាក់ ស្រី ២៦នាក់
- ប្រកាសអនុញ្ញាតច្បាប់ឱ្យបុគ្គលិកអប់រំព្យាបាលជំងឺ ៤៦នាក់ ស្រី ២៧នាក់
- ប្រកាសអនុញ្ញាតច្បាប់ឱ្យបុគ្គលិកអប់រំឈប់សម្រាកដោយមានការកិច្ចផ្ទាល់ខ្លួន ៩នាក់ ស្រី ៥នាក់

- ប្រកាសអនុញ្ញតច្បាប់ឱ្យបុគ្គលិកអប់រំលំហែមាតុភាព ២៦នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំទៅបម្រើការងារនៅសាលាជំនាន់ថ្មី ៤នាក់ ស្រី ២នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំចូលបម្រើការងារនៅអង្គភាពដើមសាលាជំនាន់ថ្មី ១៣នាក់ ស្រី ៥នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំឱ្យទៅបម្រើការងារជាមួយអង្គការម៉ារីណុល ៤នាក់ ស្រី ៣នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំទៅបម្រើការងារនៅគណៈកម្មាធិការរៀបចំការបោះឆ្នោត ៤៨៣នាក់ ស្រី ៣៨នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំ បន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសប្រឹក្សាគរុកោសល្យឆ្នាំសិក្សា ២០១៩-២០២០ រយៈពេល ១ឆ្នាំនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៃវិទ្យាស្ថានជាតិអប់រំ ៣២នាក់ ស្រី ១៣នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំ បន្តការសិក្សាជាអធិការអេប់រំជំនាន់ទី៥ នៅវិទ្យាស្ថានជាតិអប់រំ ៥២នាក់ ស្រី១១នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំ បន្តការសិក្សាក្រៅប្រទេស ៨៦នាក់ ស្រី ២២នាក់ ក្នុងនោះក្រោយបណ្ឌិត ១នាក់ បណ្ឌិត ២១នាក់ ស្រី ៦នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ៥៧នាក់ ស្រី ១៤នាក់ និងបរិញ្ញាបត្រ ៨នាក់ ស្រី ២នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំ បន្តការសិក្សានៅក្នុងប្រទេស ១១៧នាក់ ស្រី ២០នាក់
- ឧទ្ទេសនាមបុគ្គលិកអប់រំដែលបញ្ចប់ការសិក្សាក្នុងប្រទេសចូលបម្រើការងារវិញ ១០៧នាក់ ស្រី ១៥នាក់ ក្នុងនោះអធិការអេប់រំជំនាន់ទី៣ ចំនួន ៤០នាក់ ស្រី ៤នាក់ និងមន្ត្រីភូមិន្ទរដ្ឋបាល ៦៧នាក់ ស្រី ១១នាក់។

## ការជ្រើសរើសបុគ្គលិកអប់រំ

ក្រសួងបាន៖

- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅមធ្យមសិក្សាទុតិយភូមិ (បរិញ្ញាបត្រ+១) ៩៩៤នាក់ ស្រី ៤៥៨នាក់
- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន (អប់រំកាយនិងកីឡា ១២+២) ជំនាន់ទី២៨ ចំនួន ១៤៨នាក់ ស្រី ១១នាក់
- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ជំនាន់ទី២៩ ចំនួន ៤៧១នាក់ ស្រី ២៤៩ នាក់
- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា១២+២ ជំនាន់ទី៣៧ ចំនួន ១ ៣៤៧នាក់ ស្រី ៩២៩នាក់
- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា ១២+២ ជំនាន់ទី៣២ ចំនួន ២០០នាក់ ស្រី ១៩១នាក់។

## ការលើកទឹកចិត្តបុគ្គលិកអប់រំ

ក្រសួងបាន៖

- ប្រកាសតែងតាំងមន្ត្រីគ្រប់គ្រង ៨៨នាក់ ស្រី ១៦នាក់
- ប្រកាសតែងតាំងកម្មសិក្សាគ្រូចេញថ្មីគ្រប់កម្រិត ២ ៨៦៥នាក់ ស្រី ១ ៧២៤នាក់
- ប្រកាសតែងតាំងអធិការអេប់រំជំនាន់ទី៥ ចំនួន ៤៩នាក់ ស្រី ១០នាក់
- ស្នើតាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនបង្រៀនកម្រិតឧត្តម ៦១៣នាក់ ស្រី ៣១១នាក់
- ស្នើតាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនបង្រៀនកម្រិតមូលដ្ឋាន ៧៥៣នាក់ ស្រី ៣៧០នាក់
- ស្នើតាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនកម្រិតបឋមសិក្សា-មត្តេយ្យសិក្សា ១ ៨១៣នាក់ ស្រី ១ ២៤៣នាក់
- ស្នើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនបុគ្គលិកអប់រំតាមសញ្ញាបត្រ ១ ១៦១នាក់ ស្រី ៥៣៦នាក់
- ស្នើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនបុគ្គលិកអប់រំតាមវេនជ្រើសរើស ៩៤ ២១៣នាក់ ស្រី ៤២ ១៨៦នាក់
- បំពាក់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំ ៨១៩នាក់ ស្រី ២០៧នាក់

- ផ្តល់បណ្ណសរសើរជូនបុគ្គលិកអប់រំចូលនិវត្តន៍ឆ្នាំ២០២០ ចំនួន ១ ០១០នាក់ ស្រី ៥០៧នាក់
- ផ្តល់បណ្ណសរសើរជូនគរុសិស្ស គរុនិស្សិតដែលបានបំពេញការកិច្ចជាជំនួយការអប្បមាទ សម័យប្រឡង៖១៩ សីហា ២០១៩ ចំនួន ៤៧៥នាក់ ស្រី ២៦០នាក់
- ផ្តល់លិខិតថ្លែងអំណរគុណជូនលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី៩ និងទី១២ ចំនួន ១៣នាក់ ស្រី ៥នាក់ ដែលស្ម័គ្រចិត្តបង្រៀនក្នុងកម្មវិធីតាមប្រព័ន្ធអេឡិចត្រូនិក និងបុគ្គលិកអប់រំ ៤នាក់ និងគរុសិស្ស ៤៩នាក់ ស្រី ៣៤ នាក់នៅសាលាមធ្យមសិក្សាគរុកោសលមត្តេយ្យមជ្ឈិម និង ៧៦នាក់ដែលបានចូលរួមវិភាគទានឧបត្ថម្ភកងពលតូចផ័ត្រយោង ៩១១ និងសប្បុរសជន អង្គការ និងវាគ្មិនកិត្តិយស ៤៤នាក់
- លើកសំណើសុំគ្រឿងឥស្សរិយយសការងារជូនសប្បុរសជន និងដៃគូអភិវឌ្ឍ ៤៥នាក់ និងបណ្ណសរសើរជូនដល់អង្គការក្រៅរដ្ឋាភិបាល ៣០សន្លឹក
- លើកសំណើសុំគ្រឿងឥស្សរិយយសការងារឆ្នាំសិក្សា២០១៩-២០២០ ជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិសរុប ៩ ២៨២នាក់ ស្រី ៣ ៧៧៧នាក់ ស្មើ ៤០,៩ភាគរយ ប័ណ្ណសរសើរ ៥០៦អង្គភាព និងទង់ជ័យលាភីលេខ១ ចំនួន ១២៣ និងលេខ២ ចំនួន ១៤៧។

### ២.១.៤.៥ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ការងារហិរញ្ញកិច្ច

ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡាបានចំណាយថវិកាកម្មវិធី ដោយបោះផ្សាយអាណត្តិបើកប្រាក់បាន ៩៤,៣ភាគរយ ធៀបនឹងច្បាប់ថវិកា និង ៩៦,២ភាគរយ ធៀបនឹងឥណទានក្រោយវិចារណកម្មចំណាយ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបាន ៧៥,២ភាគរយ ធៀបនឹងច្បាប់ថវិកា និង ៨៣,០ភាគរយ ធៀបនឹងឥណទានក្រោយវិចារណកម្មចំណាយ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តអនុវត្តបាន ៩៨,១ភាគរយ ធៀបនឹងច្បាប់ថវិកា និង ៩៨,៥ភាគរយ ធៀបនឹងឥណទានក្រោយវិចារណកម្មចំណាយ។

ក្រសួងបាន៖

- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន
- ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) នៅអគ្គនាយកដ្ឋានកីឡា អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ខេត្តកណ្តាល កែប កំពត ស្វាយរៀង និងត្បូងឃ្មុំ
- ផ្តល់មូលនិធិដំណើរការសាលារៀនចំនួន ១៤០ ១៥៨,៣ លានរៀល ដោយបង្កើនចំនួន ១លានរៀល/សាលា លើលិខិត ៨០១៥ សហវ និងចំនួន ៤ ០៦៥ លានរៀល សម្រាប់ផ្តល់ជូនសាលារៀនអាទិភាពក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សា
- ពន្លឿនការផ្ទេរមូលនិធិកែលម្អសាលារៀនដែលជាជំនួយរបស់ស៊ុយអែត ២២ ៥០៣,៩ លានរៀល ជូនសាលារៀនសាធារណៈទូទាំងប្រទេស
- ផ្តល់អាហារូបត្ថម្ភដល់សិស្សនៅបឋមសិក្សាដែលស្ថិតក្នុង ៦ ខេត្ត ២០៥សាលា មានសិស្ស ៥០ ៣៦០នាក់ ទឹកប្រាក់ ៧ ០៧២,៤ លានរៀល
- ផ្តល់ថវិកាសម្រាប់ទិញសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាជូនសាលារៀនដែលបានបង្កើតថ្មី ៦៤ រួមមានកុំព្យូទ័រ ៦៤គ្រឿង និងម៉ាស៊ីនបោះពុម្ព ៦៤គ្រឿង
- បង្កើនចំនួនសិស្សអាហារូបករណ៍សិស្សបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ២០ ១៤១នាក់ ស្មើនឹងឥណទានថវិកា ៤ ៨៣៣,៨ លានរៀល
- បង្កើនអង្គភាពថវិកាពី ៦២ ទៅ ៦៣អង្គភាព

- បង្កើនសិទ្ធិសម្រេចជូនអង្គភាពថវិកាសម្រាប់ការចំណាយ និងទូទាត់ប្រាក់រដ្ឋទេយ្យបុរេប្រទាន
- បង្កើនថវិកាសាងសង់បង្គន់អនាម័យនិងប្រព័ន្ធទឹកស្អាត ១៤៤បង្គន់ ចំណាយថវិកា ២ ០០០លានរៀល
- បង្កើតក្រុមការងារសម្រាប់ជួយដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (Help Desk)
- បង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២១-២០២៣ និងគម្រោងថវិកាប្រចាំឆ្នាំ២០២១ តាមលិខិតលេខ ២៥២៥ អយក.ឧទន ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០
- បូកសរុបគម្រោងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈទូទាំងប្រទេសតាមប្រព័ន្ធព័ត៌មានវិទ្យា
- បូកសរុបគម្រោងថវិកាប្រចាំឆ្នាំ២០២១ របស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស និងមុខងារទាំង ៣ (អប់រំកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ) នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ព្រមទាំងបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាន់ពេលវេលា
- បូកសរុបគម្រោងថវិកាប្រចាំឆ្នាំ២០២១ របស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ ព្រមទាំងបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាន់ពេលវេលា
- ធ្វើបច្ចុប្បន្នកម្ម និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈអនុលោមតាមលិខិតលេខ ៨០១៥ សហវ.អថ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១៩ និងបន្ថែមមុខងារការគ្រោងថវិកាដៃគូលម្អិតតាមគម្រោងដៃគូនីមួយៗ និងព័ត៌មានអគារសិក្សារបស់សាលារៀនសាធារណៈ
- ធ្វើបច្ចុប្បន្នកម្មវីដេអូមេរៀន ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រោងនិងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈជូនមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនសាធារណៈទូទាំងប្រទេស
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាលើរបាយការណ៍ហិរញ្ញវត្ថុ និងការរៀបចំគម្រោងថវិកាបន្ទុកបុគ្គលិក (ជំពូក ៦៤)
- ធ្វើបច្ចុប្បន្នកម្ម និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធរបាយការណ៍ដែលផ្សារភ្ជាប់ទៅនឹង ESP, AOP និងរបាយការណ៍សមិទ្ធកម្មជូនអង្គភាពថ្នាក់កណ្តាល
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាគ្រោងថវិកា និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ឱ្យស្របតាមស្មារតីនៃលិខិតលេខ ៨០១៥ សហវ.អថ ចុះថ្ងៃ១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការរៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីនិងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាជូនអង្គភាពរដ្ឋបាលកណ្តាល ដោយអនុលោមតាមប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើសុខដុមនីយកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំតាមប្រព័ន្ធព័ត៌មានវិទ្យា ដោយបន្សុីជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ សហការជាមួយអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- ចងក្រងសៀវភៅគោលការណ៍ណែនាំ ស្តីពីនីតិវិធីនៃការអនុវត្តថវិកាផ្ទៃក្នុងក្រសួងសម្រាប់អង្គភាពថ្នាក់រដ្ឋបាលកណ្តាល
- អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងរដ្ឋទេយ្យបុរេប្រទានសម្រាប់អង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងបានរៀបចំសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធ EFMS មុខងារគ្រប់គ្រងរដ្ឋទេយ្យបុរេប្រទាន

- រៀបចំនិតីវិធីនៃការផ្ទេរថវិកាបេសកកម្មតាមប្រព័ន្ធធនាគារអេស៊ីលីដាសម្រាប់អង្គភាពថ្នាក់រដ្ឋបាលកណ្តាល
- រៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តផែនការសកម្មភាពរួមអន្តរកាលឆ្នាំ២០២១ (MAP-២០២១) ដើម្បីចូលរួមគាំទ្រកម្មវិធីកំណែទម្រង់សាធារណៈ
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមអនុវិស័យដោយផ្សារភ្ជាប់ជាមួយកម្មវិធីចំណាយ នឹងផ្ទុះបញ្ចាំងជាមួយរបាយការណ៍សមិទ្ធកម្ម ជូនអង្គភាពរដ្ឋបាលកណ្តាល
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងការចុះបំពេញបេសកកម្មក្នុងប្រទេស និងក្រៅប្រទេសជូនអង្គភាព រដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- រៀបចំលំហូរនីតិវិធីនៃការអនុវត្តថវិកា និងកែសម្រួលរំហូរពីគ្រប់អង្គភាពថវិកា
- ព្រាងសៀវភៅនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុស្តង់ដាសម្រាប់គម្រោង (ការគ្រោង ការអនុវត្ត និងរបាយការណ៍)
- រៀបចំលិខិតលេខ ៣១៣ អយក.ហវ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីករណីអនុញ្ញាតជាគោលការណ៍ ផ្តល់សិទ្ធិសម្រេចជូនប្រធានអង្គភាពថវិកាសម្រាប់ការចំណាយនិងទូទាត់ប្រាក់រង្វាន់ទេយ្យបុរេប្រទាន
- រៀបចំលិខិតលេខ ៥៤៣ អយក.ហវ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីសំណើសុំអនុញ្ញាតជាគោលការណ៍ បន្តនិរន្តភាពនៃលិខិតលេខ ២៨៧ សហវ.ហក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥
- រៀបចំលិខិតលេខ ៧៦៣ អយក.ហវ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ លើករណីសុំពន្លឿនការអនុវត្តថវិកា កម្មវិធីពេញលេញរបស់អង្គភាពនៅក្រោមទីស្តីការក្រសួងអប់រំ យុវជន និងកីឡានៅថ្នាក់រដ្ឋបាលកណ្តាលក្នុងឆ្នាំ ២០២០ និងបណ្តាឆ្នាំបន្ទាប់
- រៀបចំលិខិតលេខ ៨៤៧ អយក.ហវ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីសំណើសុំអនុញ្ញាតជាគោលការណ៍ និងផ្តល់ប្រាក់ឧបត្ថម្ភជូននិស្សិតអាហារូបករណ៍កម្ពុជា ២៣រូប ចាប់ពីខែមករា ឆ្នាំ២០២០ តទៅដែលកំពុងស្នាក់ នៅទីក្រុងអ៊ូហាន ខេត្តហ្វូប៉ី សាធារណរដ្ឋប្រជាមានិតចិន និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈលិខិតលេខ ១២៣៩ សហវ.អថ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០
- រៀបចំសេចក្តីសម្រេចលេខ ១២ អយក.សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតនិងការប្រព្រឹត្ត ទៅរបស់ក្រុមការងាររៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS)
- រៀបចំលិខិតលេខ ១៦៥៣ អយក.ហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការត្រៀមកញ្ចប់ឥណទានថវិកា សម្រាប់ចំណាយទិញសម្ភារៈប្រើប្រាស់ក្នុងការបង្ការនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០
- រៀបចំលិខិតលេខ ១៧១២ អយក.ហវ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ស្តីពី ការធ្វើវិចារណកម្មនិងការពង្រឹង ប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ របស់អង្គភាពក្រោមឱវាទ ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំលិខិតលេខ ១៩៧០ អយក.ហវ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការធ្វើវិចារណកម្មនិងការពង្រឹង ប្រសិទ្ធភាពចំណាយលើកទី២ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ របស់អង្គភាព ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំលិខិតលេខ ១៩៨២ អយក.ហវ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ស្តីពីសំណើសុំអនុញ្ញាតជាគោលការណ៍ ដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងឆ្នាំបន្ត បន្ទាប់នៅក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈ លិខិតលេខ ៥៥៥៩ សហវ.អថ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០
- រៀបចំលិខិតលេខ ២៣៩៩ អយក.ហវ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ស្តីពីការស្នើសុំអនុញ្ញាតជាគោល ការណ៍លើកលែងការកាត់សន្សំឥណទាន ១ ១៩៣,៣ លានរៀល សម្រាប់ចំណាយលើសកម្មភាពអាទិភាព និង

ទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈលិខិតលេខ ៦៩០៧ សហវ.អថ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០

- រៀបចំលិខិតលេខ ៣៨១៥ អយក.ហវ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការសុំអនុញ្ញាតជាគោលការណ៍បញ្ចូលឥណទានថវិកា ២៨ ២២៦លានរៀល ក្នុងគម្រោងថវិកាឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំលិខិតលេខ ៤២៣៧ អយក.ហវ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីសំណើសុំជំរុញការទូទាត់ថវិកាពេញលេញសម្រាប់ឆ្នាំ២០២០ របស់អង្គភាពថវិកានៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំលិខិតលេខ ៤៥១៤ អយក.ហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីសំណើសុំពន្យារពេលនៃការបិទបញ្ជីចំណាយថវិកាបុរេប្រទានសម្រាប់ចំណាយលើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈលិខិតលេខ ១០២២៥ សហវ.អថ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០
- រៀបចំលិខិតលេខ ៤៦២៨ អយក.ហវ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡាបានបើកប្រាក់ទិញសម្ភារអនាម័យជូនប្រធានមណ្ឌលសំណេរ មណ្ឌលកំណៃ និងមណ្ឌលបូកស្រង់ពិន្ទុដោយកុំព្យូទ័រសម្រាប់ប្រើប្រាស់ក្នុងកិច្ចដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈលិខិតលេខ ៩០២០ សហវ.អថ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០
- រៀបចំលិខិតលេខ ៥៤៦៩ អយក.ហវ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ ស្តីពីសំណើសុំអនុញ្ញាតជាគោលការណ៍ប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យ និងសម្រេចផ្តល់ទិដ្ឋាការលើមុខសញ្ញាចំណាយមួយចំនួនដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យ និងវិក្រឹតការ និងសាលាអនុវត្តន៍ ចាប់ពីឆ្នាំ២០២១ តទៅ
- រៀបចំលិខិតលេខ ៥៨៤៧ អយក.ហវ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ស្តីពីករណីសុំកែសម្រួលអង្គភាពថវិកាថ្នាក់រដ្ឋបាលកណ្តាលសម្រាប់ការអនុវត្តឆ្នាំ២០២០តទៅ នៅក្រសួងអប់រំ យុវជន និងកីឡា ឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំលិខិតលេខ ៥៩៤០ អយក.ហវ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីករណីបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីពេញលេញរបស់អង្គភាពនៅរដ្ឋបាលកណ្តាលក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២០
- រៀបចំលិខិតលេខ ៧១០០ អយក.ហវ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីករណីសំណើសុំផ្ទេរឥណទានថវិការបស់អង្គភាពថវិកាអគ្គនាយកដ្ឋានយុវជន និងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រមកអង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រហិរញ្ញវត្ថុក្នុងឆ្នាំ២០២០ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈលិខិតលេខ ៥៨៨ សហវ.អថ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១
- រៀបចំលិខិតលេខ ៧១០១ អយក.ហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីអនុញ្ញាតជាគោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភក្នុងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអប់រំចាប់ពីឆ្នាំ២០២០តទៅ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលិខិតលេខ ២៧៣២ សហវ.អថ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២០
- រៀបចំលិខិតលេខ ៧០៩៥ អយក.ហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីសំណើសុំអនុញ្ញាតផ្តល់ប្រាក់ឧបត្ថម្ភជូនសាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ និងស្រាវជ្រាវចំនួន ៤លានរៀល/ម្នាក់ សម្រាប់បណ្តុះបណ្តាលនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមលិខិតលេខ ៥៨៦៤ សហវ.អថ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០

- រៀបចំលិខិតលេខ ៦៨៩០ អយក.ហវ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ថវិកាបុរេប្រទានសម្រាប់ចំណាយលើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ ដើម្បីចំណាយលើកិច្ចដំណើរការ និងឧបត្ថម្ភជូនគណៈកម្មការចេញសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈលិខិតលេខ ១១៣៤២ សហវ.អថ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០
- ផ្សព្វផ្សាយសារាចរលេខ ០៣ សរណន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២១-២០២៣ ជូនគ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងប្រមូល និងបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាន់ពេលវេលា
- ផ្សព្វផ្សាយសារាចរលេខ ០៤ សរណន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ជូនគ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងបានប្រមូល និងបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាន់ពេលវេលា
- ផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ ០៩៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកានៅក្រសួងអប់រំ យុវជន និងកីឡា
- ផ្សព្វផ្សាយអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល
- ផ្សព្វផ្សាយប្រកាសលេខ ០៩០ (ស្ហន) សហវ.ប្រក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍
- ផ្សព្វផ្សាយអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំនិងតារាងភាគនៃប្រាក់ជាប់ពន្ធប្រចាំខែ
- ផ្សព្វផ្សាយសារាចរណែនាំលេខ ០០១ សហវ.អថ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- ផ្សព្វផ្សាយសារាចរណែនាំលេខ ០០៣ សហវ. ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយលើកទី២ សម្រាប់អនុវត្តច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- ផ្សព្វផ្សាយលិខិតលេខ ៣៥៥៤ សហវ.អរតន ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០២០ ស្តីពីករណីការជំរុញការកែសម្រួលតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ឆ្នាំ២០២០
- ផ្សព្វផ្សាយលិខិតលេខ ០៣ សរណន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣
- ផ្សព្វផ្សាយសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- ផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយរដ្ឋទេយ្យបុរេប្រទានរដ្ឋបាលថ្នាក់ជាតិ ជូនអង្គភាពថវិកាក្រោមឱវាទក្រសួង
- សម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបន្ថែមឥណទាន ១ ៦១១,៣ លានរៀល សម្រាប់ប្រាក់ឧត្ថម្ភអាហារូបករណ៍សិស្សក្រីក្របឋមសិក្សាថ្នាក់ទី១ ដល់ទី៦ និងមធ្យមសិក្សាថ្នាក់ទី៧ ចំនួន ១លើកក្នុងឆ្នាំ២០២០
- សហការរៀបចំប្រកាសអន្តរក្រសួងលេខ ៥២១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុលក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌឱ្យរដ្ឋបាលក្រុង

ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបងសម្រាប់ការអនុវត្តមុខងារគ្រប់គ្រងអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ព្រមទាំងបានផ្សព្វផ្សាយជូនអង្គភាពក្រោមឱវាទក្រសួង

- ពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅតាមអង្គភាពក្រោមឱវាទក្រសួង ស្តីពីការតម្រង់ទិសសកម្មភាព ចង្អោមសកម្មភាពរបស់អនុកម្មវិធីនីមួយៗឱ្យស្របទៅនឹងគោលបំណង និងគោលនយោបាយរបស់ក្រសួង
- បណ្តុះបណ្តាលប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដល់មន្ត្រីជំនាញមន្ទីរ និងមន្ត្រីជំនាញការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៤៥៦នាក់ នាយកសាលា និងហេរញ្ញិក ២ ៥០០នាក់
- បណ្តុះបណ្តាល និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ ដោយផ្សារភ្ជាប់ទៅនឹង ESP BSP ABP AOP និងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស និងប្រចាំឆ្នាំ ដល់ថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅថ្នាក់កណ្តាល ១៨០នាក់
- បណ្តុះបណ្តាល និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រោងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ ដល់ថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅមន្ទីររាជធានី ខេត្ត ១០០នាក់។

## ការងារកិច្ចលទ្ធកម្ម

ក្រសួងបាន៖

- ធ្វើលិខិតប្រកាសស្តីពីការកែសម្រួលសមាសភាព និងតួនាទីក្រុមលទ្ធកម្មថ្មី ០៤ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្នុងចំណោមក្រុមលទ្ធកម្ម ៣៣
- អនុវត្តកិច្ចលទ្ធកម្មមានទឹកប្រាក់ ២៦១ ៤៧៤ ០៤១,៤៨ លានរៀល ស្មើ ៩៩ភាគរយ៖
  - អនុវត្តកិច្ចលទ្ធកម្មទំនិញនិងសំណង់ជូនអង្គភាពថ្នាក់កណ្តាល ២៥គម្រោង មានទឹកប្រាក់ ៤៤ ៧១១៤,៨ លានរៀល ក្នុងនោះលទ្ធកម្មទំនិញ ២០គម្រោង មានទឹកប្រាក់ ៣៣ ០៣៨,៥៤ លានរៀល និងលទ្ធកម្មសំណង់ ៥គម្រោង មានទឹកប្រាក់ ១១ ៦៧២,៩៤ លានរៀល
  - អនុវត្តកិច្ចលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ដោយក្រុមលទ្ធកម្ម ២៣៣គម្រោង មានទឹកប្រាក់ ២៦១ ៤២៩ ៣៣០ លានរៀល ក្នុងនោះលទ្ធកម្មទំនិញ ១៥៤គម្រោង មានទឹកប្រាក់ ២៦ ៤៦៤,៥១ លានរៀល លទ្ធកម្មសំណង់ ៦៧គម្រោង មានទឹកប្រាក់ ៣៧ ៦៣៤,៨២ លានរៀល និងលទ្ធកម្មសេវាកម្ម ៥ គម្រោង មានទឹកប្រាក់ ១៩៧ ៣៣០ លានរៀល ។

## ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

ក្រសួងបាន៖

- បញ្ចប់សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ និងដាក់ជូននាយកដ្ឋាននីតិកម្មបន្តពិនិត្យទិដ្ឋភាពច្បាប់
- ផ្គត់ផ្គង់សម្ភារបរិក្ខារសម្រាប់ការងាររដ្ឋបាលសាលារៀន ១៤២សាលា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ២៦ និងកុំព្យូទ័រសម្រាប់សិស្សរៀន ៩សាលា (កុំព្យូទ័រសម្រាប់រដ្ឋបាលសាលារៀន ៨៥គ្រឿង កុំព្យូទ័រសម្រាប់សិស្សរៀន ៧៥គ្រឿង ព្រីនធ័រ ១៤៩គ្រឿង ម៉ាស៊ីនថតចម្លង ៥០គ្រឿង និងទូរឯកសារគ្រូ ២២១គ្រឿង)
- សម្របសម្រួលបែបបទនាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ៦៣ករណី
- បំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុកការងារទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត ២៣៧នាក់ ស្រី ៤៣នាក់

- ចុះពិនិត្យ និងវាយតម្លៃការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋគ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់សាលារៀន ២២៥ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ស្រុកឆ្លូង ខេត្តក្រចេះ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ក្រុងបានលុង ខេត្តរតនគិរី និងស្រុកតាំងគោក ខេត្តកំពង់ធំ
- ជម្រះសម្ភារៈសង្ហារិមចាស់ៗ ១៤ ៣៥៧ ឯកតា ចេញពីបញ្ជីសារពើភណ្ឌ
- បង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្ដាល
- ធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ រួចរាល់ ៣១ អង្គភាព (ថ្នាក់កណ្ដាល២៦ និង ៥ខេត្ត រាជធានី)
- ធ្វើបច្ចុប្បន្នកម្មទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ២៧ ទូទាំងប្រទេស និងវិទ្យាល័យធនធាន ៥០
- ធ្វើបច្ចុប្បន្នកម្មទិន្នន័យយានយន្តរបស់ក្រសួងរួមមានរថយន្ត ៤២៧គ្រឿង ម៉ូតូ ១៩៩៥គ្រឿង ម៉ាស៊ីនភ្លើង ២៨៦ គ្រឿង ម៉ាស៊ីនបូមទឹក ១២៧គ្រឿង គោយន្ត ១៣គ្រឿង អេឡេវ៉ាទ័រ ១៤គ្រឿង កាណូត ៣៤គ្រឿង ត្រាក់ទ័រ ៨ គ្រឿង ម៉ាស៊ីនកាត់ស្មៅ ៣៣គ្រឿង ម៉ាស៊ីនបោះពុម្ព និងម៉ាស៊ីនកាត់ ១៦គ្រឿង
- ប្រមូលចំណូលបង់ចូលថវិការដ្ឋបាន ៣១៦ ៥៨៤ ដុល្លារអាមេរិក និង ១៥ ៩៦៤ ៧០០ រៀល
- បញ្ចេញប្រេងសាំង និងម៉ាហ្ស៊ូតសរុប ១២៥ ០០០លីត្រ។

## ការពង្រឹងការងារសវនកម្មផ្ទៃក្នុង

ក្រសួងបាន៖

- ធ្វើសវនកម្មនៅតាមសវនដ្ឋាន ១៩៦ ដោយធ្វើការវាយតម្លៃនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួមមាន៖
    - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៤
    - សាលាគរុកោសល្យនិងវិក្រឹតការខេត្ត ៣
    - ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៣៨
    - សាលារៀនចំណេះទូទៅ ១៥១
- ធ្វើសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បងលើប្រព័ន្ធគ្រប់គ្រងបេសកកម្ម ដែលទទួលការគាំទ្របច្ចេកទេសដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើសវនកម្មផ្ទៃក្នុងសម្រង់ព័ត៌មានដើម្បីស្វែងយល់ពីបរិស្ថាននៃសវនដ្ឋាន នៅវិទ្យាស្ថានបច្ចេកទេស ១
- បញ្ចប់សេចក្ដីព្រាង និងកំពុងរៀបចំសំណើសុំអនុម័ត ដើម្បីដាក់ឱ្យអនុវត្ត
- ធ្វើសវនកម្មសាកល្បង ដោយប្រើប្រាស់ឧបករណ៍សវនកម្មដែលរៀបចំដោយទីប្រឹក្សាបច្ចេកទេសក្នុងស្រុក នៅមន្ទីរអប់រំ យុវជន និងកីឡា ១ និងសាលារៀនចំណេះទូទៅ ៦
- សវនកម្មសាកល្បងផ្ទាល់ជាមួយទីប្រឹក្សាបច្ចេកទេសក្នុងស្រុកនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងវិទ្យាល័យជប់វារី
- បណ្ដុះបណ្ដាលសវនករផ្ទៃក្នុង ៨រូប ស្ដីពីសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៅវិទ្យាស្ថានតិចឡាយកម្ពុជា
- ពិនិត្យតាមដាន និងកែលម្អអនុសាសន៍ ១៩សវនដ្ឋាន ក្នុងនោះការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៣ និងសាលាចំណេះទូទៅ ១៦ ដែលសវនករផ្ទៃក្នុងបានផ្ដល់អនុសាសន៍សរុប ១៧៨ ក្នុងនោះអនុវត្តពេញលេញ ៥៧ភាគរយ។

### ការងារអធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ

ក្រសួងបាន៖

- អភិវឌ្ឍស្តង់ដាអធិការកិច្ចប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិវិធីអធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ
- ទទួលពាក្យបណ្តឹងតវ៉ាប្រមាណជា ៣០ភាគរយ
- ធ្វើអធិការកិច្ចការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នៅអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ២៣៨អង្គភាព រួមមានសាកលវិទ្យាល័យ ២ មន្ទីរអប់រំ យុវជន និងកីឡា៩ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៤០ វិទ្យាល័យ ៦០ អនុវិទ្យាល័យ ៣៣ និង សាលាបឋមសិក្សា ៩៩
- ត្រួតពិនិត្យវឌ្ឍនភាពលើការកែលម្អតាមអនុសាសន៍នៅអង្គភាពថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ ៨៩អង្គភាព រួមមានមន្ទីរអប់រំ យុវជន និងកីឡា ៤ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ១៧ វិទ្យាល័យ ២០ អនុវិទ្យាល័យ ១៦ និងសាលាបឋមសិក្សា ៣២
- ចុះស្រាវជ្រាវពាក្យបណ្តឹង ឬបាតុភាពមិនប្រក្រតីពាក់ព័ន្ធវិស័យអប់រំ ៨ករណី តាមរយៈពាក្យបណ្តឹង និងការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

## ២.១.៥ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ ថ្នាក់ជាតិ

ក្រសួងបានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ មានសកម្មភាព ១ ១៦៧ ត្រូវអនុវត្ត ធៀបទៅនឹងឆ្នាំ ២០១៩ កើន ១៩០ ក្នុងនោះអនុវត្តចប់ ៧០០ ស្មើ ៦០ភាគរយ កំពុងអនុវត្ត ២៣៧ ស្មើ ២០,៣ភាគរយ និងមិនបានអនុវត្ត ២៣០ ស្មើ ១៩,៧ភាគរយ (ឧបសម្ព័ន្ធទី១)។

រូបភាពទី១ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០




បើពិនិត្យតាមកម្មវិធីនីមួយៗបង្ហាញថា **កម្មវិធីទី១** មានសកម្មភាព ២៥៧ ក្នុងនោះអនុវត្តចប់ ៦៤,៦ភាគរយ កំពុងអនុវត្ត ១៩,៨ភាគរយ មិនបានអនុវត្ត ១៥,៦ភាគរយ។ **កម្មវិធីទី២** មានសកម្មភាព ៣៤៧ ក្នុងនោះអនុវត្តចប់ ៦៤,៣ភាគរយ កំពុងអនុវត្ត ២០,២ភាគរយ មិនបានអនុវត្ត ១៥,៦ភាគរយ។ **កម្មវិធីទី៣** មានសកម្មភាព ៨៥ ក្នុងនោះអនុវត្តចប់ ៦០ភាគរយ កំពុងអនុវត្ត ១៦,៥ភាគរយ មិនបានអនុវត្ត ២៣,៥ភាគរយ។ **កម្មវិធីទី៤** មានសកម្មភាព ៤៥ ក្នុងនោះអនុវត្តចប់ ៥៥,៦ភាគរយ កំពុងអនុវត្ត ៤,៤ភាគរយ មិនបានអនុវត្ត ៤០ភាគរយ។ **កម្មវិធីទី៥** មានសកម្មភាព ៤២៩ ក្នុងនោះអនុវត្តចប់ ៥៣,៨ភាគរយ កំពុងអនុវត្ត ២៣,៣ភាគរយ មិនបានអនុវត្ត ២២,៨ភាគរយ។ កម្មវិធីផ្សេងៗ មានសកម្មភាព ៤ ក្នុងនោះអនុវត្តចប់ ១០០ភាគរយ។

## រូបភាពទី២ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ (តាមកម្មវិធី)




បើពិនិត្យតាមអង្គភាពនៃកម្មវិធីនីមួយៗបានបង្ហាញថា៖

**កម្មវិធីទី១៖** ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការមាន ៩អង្គភាព បានគ្រោងសកម្មភាព ២៥៧ ក្នុងនោះសកម្មភាពអនុវត្តចប់ ១៦៦ ស្មើ ៦៤,៦ភាគរយ កំពុងអនុវត្ត ៥១ ស្មើ ១៩,៨ភាគរយ និងមិនបានអនុវត្ត ៤០ ស្មើ ១៥,៦ភាគរយ។ អង្គភាពដែលអនុវត្តសកម្មភាពចប់ចាប់ពី ៩០ភាគរយឡើងទៅ មាននាយកដ្ឋានសុខភាពសិក្សា។

## រូបភាពទី៣ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ របស់កម្មវិធីទី១




**កម្មវិធីទី២៖** ការអភិវឌ្ឍឧត្តមសិក្សា និងស្រាវជ្រាវ មាន ១៦ អង្គភាព បានគ្រោងសកម្មភាព ៣៤៧ ក្នុងនោះ អនុវត្តចប់ ២២៣ ស្មើ ៦៤,៣ភាគរយ កំពុងអនុវត្ត ៧០ ស្មើ ២០,២ភាគរយ និងមិនបានអនុវត្ត ៥៤ ស្មើ ១៥,៦ ភាគរយ។ សាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា អនុវត្តចប់ ១០០ភាគរយ។

## រូបភាពទី៤ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ របស់កម្មវិធីទី២




**កម្មវិធីទី៣៖** ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា មាន ៤ អង្គភាព បានគ្រោងសកម្មភាព ៨៥ ក្នុងនោះអនុវត្តចប់ ៥១ ស្មើ ៦០ភាគរយ កំពុងអនុវត្ត ១៤ ស្មើ ១៦,៥ភាគរយ និងមិនបានអនុវត្ត ២០ ស្មើ ២៣,៥ភាគរយ។

### រូបភាពទី៥ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ របស់កម្មវិធីទី៣




**កម្មវិធីទី៤៖** ការអភិវឌ្ឍជំនាញទន់ បច្ចេកទេស និងជំនាញទន់សម្រាប់យុវជនមាន ៣អង្គភាព បានគ្រោងសកម្មភាព ៤៥ ក្នុងនោះអនុវត្តចប់ ២៥ ស្មើ ៥៥,៦ភាគរយ កំពុងអនុវត្ត ២ ស្មើ ៤,៤ភាគរយ និងមិនបានអនុវត្ត ១៨ ស្មើ ៤០ភាគរយ។

### រូបភាពទី៦ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ របស់កម្មវិធីទី៤




**កម្មវិធីទី៥៖** ការគាំទ្រសេវាអប់រំនិងអភិបាលកិច្ចល្អ មាន ២៤អង្គភាព បានគ្រោងសកម្មភាព ៤២៩ ក្នុងនោះអនុវត្តចប់ ២៣២ ស្មើ ៥៣,៨ភាគរយ កំពុងអនុវត្ត ១០០ ស្មើ ២៣,៣ភាគរយ និងមិនបានអនុវត្ត ៩៨ ស្មើ ២២,៨ ភាគរយ។ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ បានអនុវត្តចប់ ១០០ភាគរយ។

### រូបភាពទី៧៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ របស់កម្មវិធីទី៥




**កម្មវិធីផ្សេងៗ៖** កម្មវិធីផ្សេងៗមានសកម្មភាព ៤ អនុវត្តចប់ ១០០ភាគរយ។ ការងារកំណែទម្រង់វិស័យអប់រំ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ និងការពិនិត្យតាមដាននិងវាយតម្លៃអនុវត្តបាន ១០០ភាគរយ។

រូបភាពទី៨ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២០ កម្មវិធីផ្សេងៗ




## ២.១.៦ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៩- ២០២០ ថ្នាក់ជាតិ

សន្និបាតអប់រំឆ្នាំ ២០២០ បានលើកទិសដៅ ១៨២ ក្នុងនោះទិសដៅកំណែទម្រង់សំខាន់ៗ ៥១ ទិសដៅ អនុវិស័យ ៧៦ និងទិសដៅឆ្លងអនុវិស័យ ៥៥។ ទិសដៅអនុវត្តចប់ ៨៦ ស្មើ ៤៧,៣ភាគរយ កំពុងអនុវត្ត ៧៧ ស្មើ ៤២,៣ភាគរយ និងមិនបានអនុវត្ត ១៩ ស្មើ ១០,៤ភាគរយ។

ទិសដៅកំណែទម្រង់សំខាន់ៗមាន ២៥ ស្មើ ៤៩ភាគរយ ទិសដៅអនុវិស័យ ២៧ ស្មើ ៣៥,៥ភាគរយ និង ទិសដៅឆ្លងអនុវិស័យ ៣៤ ស្មើ ៦១,៨ភាគរយ អនុវត្តចប់។ ទិសដៅកំណែទម្រង់សំខាន់ៗ ២១ ស្មើ ៤១,២ភាគរយ ទិសដៅអនុវិស័យ ៤២ ស្មើ ៥៥,៣ភាគរយ និងទិសដៅឆ្លងអនុវិស័យ ១៥ ស្មើ ២៥,៥ភាគរយ កំពុងអនុវត្ត។ ទិសដៅ កំណែទម្រង់សំខាន់ៗ ៥ ស្មើ ៩,៨ភាគរយ ទិសដៅអនុវិស័យ ៧ ស្មើ ៩,២ភាគរយ ទិសដៅឆ្លងអនុវិស័យ ៧ ស្មើ ១២,៧ភាគរយ មិនបានអនុវត្ត (ឧបសម្ព័ន្ធទី២, ៣, ៤ និងទី៥)។

រូបភាពទី៩ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ ២០២០ ថ្នាក់ជាតិ
(កំណែទម្រង់សំខាន់ៗ អនុវិស័យ និងឆ្លងអនុវិស័យ)




### វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតតាមកំណែទម្រង់សំខាន់ៗ

ទិសដៅកំណែទម្រង់ ៥១ ក្នុងនោះការពង្រឹងប្រព័ន្ធផែនការ ៧ ការងារវិមជ្ឈការនិងវិសហមជ្ឈការ ៦ ការងារគ្រប់គ្រងបុគ្គលិក ៧ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០ ការងារបណ្តុះបណ្តាលនិងវិក្រឹតការ ១១។ ការងារវិមជ្ឈការ និងវិសហមជ្ឈការ និងការគ្រប់គ្រងបុគ្គលិក អនុវត្តទិសដៅបាន ៨៥,៧ភាគរយ ខ្ពស់ជាងគេ(ឧបសម្ព័ន្ធទី២ និងទី៣)។

រូបភាពទី១០ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតតាមកំណែទម្រង់ ឆ្នាំ២០២០




### វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតតាមអនុវិស័យ

ជារួម ទិសដៅអនុវិស័យ ៧៦ ក្នុងនោះអនុវត្តចប់ ២៧ ស្មើ ៣៥,៥ភាគរយ កំពុងអនុវត្ត ៤២ ស្មើ ៥៤,៣ភាគរយ និងមិនបានអនុវត្ត ៧ ស្មើ ៩,២ភាគរយ។

អនុវិស័យការអប់រំកុមារតូច ៩ ក្នុងនោះអនុវត្តចប់ ៣ ស្មើ ៣៣,៣ភាគរយ កំពុងអនុវត្ត ៦ ស្មើ ៦៦,៧ភាគរយ។ អនុវិស័យការអប់រំបឋមសិក្សា ១៣ ក្នុងនោះអនុវត្តចប់ ៤ ស្មើ ៣០,៨ភាគរយ កំពុងអនុវត្ត ៨ ស្មើ ៦១,៥ភាគរយ មិនបានអនុវត្ត ១ ស្មើ ៧,៧ភាគរយ។ អនុវិស័យការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស ១៣ ក្នុងនោះអនុវត្តចប់ ៨ ស្មើ ៦១,៥ភាគរយ កំពុងអនុវត្ត ៤ ស្មើ ៣០,៨ភាគរយ មិនបានអនុវត្ត ១ ស្មើ ៧,៧ភាគរយ។ អនុវិស័យការអប់រំឧត្តមសិក្សា ១២ ក្នុងនោះអនុវត្តចប់ ៤ ស្មើ ៣៣,៣ភាគរយ កំពុងអនុវត្ត ៥ ស្មើ ៤១,៧ភាគរយ មិនបានអនុវត្ត ៣ ស្មើ ២៥ ភាគរយ។ អនុវិស័យការអប់រំក្រៅប្រព័ន្ធ ៨ ក្នុងនោះអនុវត្តចប់ ៣ ស្មើ ៣៧,៥ភាគរយ កំពុងអនុវត្ត ៤ ស្មើ ៥០ភាគរយ មិនបានអនុវត្ត ១ ស្មើ ១២,៥ភាគរយ។ អនុវិស័យការអភិវឌ្ឍយុវជន ១០ ក្នុងនោះអនុវត្តចប់ ១ ស្មើ ៩,១ភាគរយ កំពុងអនុវត្ត ៩ ស្មើ ៨១,៨ភាគរយ មិនបានអនុវត្ត ១ ស្មើ ៩,១ភាគរយ។ អនុវិស័យការអប់រំកាយនិងកីឡា ១០ ក្នុងនោះ អនុវត្តចប់ ៤ ស្មើ ៤០ភាគរយ កំពុងអនុវត្ត ៦ ស្មើ ៦០ភាគរយ( ឧបសម្ព័ន្ធទី២ និងទី៤)។

រូបភាពទី១១ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅអនុវិស័យ ឆ្នាំ២០២០




## វឌ្ឍនភាពនៃការអនុវត្តទិសដៅឆ្លងអនុវិស័យ

ជារួម ទិសដៅឆ្លងអនុវិស័យ ៥៥ ក្នុងនោះអនុវត្តចប់ ៣៤ ស្មើ ៦១,៨ភាគរយ កំពុងអនុវត្ត ១៤ ស្មើ ២៥,៥ ភាគរយ និងមិនបានអនុវត្ត ៧ ស្មើ ១២,៧ភាគរយ។

ការអភិវឌ្ឍកម្មវិធីសិក្សា ១៣ ការងាររដ្ឋបាល ៥ ការងារសំណង់សិក្សា ៣ ការងារបោះពុម្ពនិងចែកផ្សាយ ៥ ការងារអធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ៧ ការងារសវនកម្មផ្ទៃក្នុង ៧ ការងារធានាគុណភាពអប់រំ ៤ និងការងារគ្រប់គ្រងសម្ភារៈទ្រព្យសម្បត្តិរដ្ឋ ៦ និងការងារកិច្ចលទ្ធកម្ម ៥។ អង្គភាពដែលបានអនុវត្តទិសដៅចប់ ១០០ភាគរយ រួមមាន លទ្ធកម្ម ធានាគុណភាព បោះពុម្ពនិងចែកផ្សាយ និងសំណង់។ អង្គភាពអភិវឌ្ឍកម្មវិធីសិក្សាអនុវត្តទិសដៅចប់បានតិចជាងគេ ១៥,៤ភាគរយ។ ( ឧបសម្ព័ន្ធទី២ និងទី៥ )។

រូបភាពទី១២ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅឆ្លងអនុវិស័យ ឆ្នាំ២០២០



## ២.១.៧ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ ២០២០

ក្រសួងបានគ្រោងរៀបចំសកម្មភាពគោលនយោបាយសម្រាប់ឆ្នាំ ២០២០ សរុប ៥៧ ក្នុងនោះគោលនយោបាយទី១ មាន ៤១ សកម្មភាព និងគោលនយោបាយទី២ មាន ១៦ សកម្មភាព។ សកម្មភាពគោលនយោបាយរៀបចំចប់ ៦ ស្មើ ១០,៥ភាគរយ កំពុងរៀបចំ ៤១ ស្មើ ៧១,៩ភាគរយ និងមិនទាន់រៀបចំ ១០ ស្មើ ១៧,៥ភាគរយ។

គោលនយោបាយទី១ មាន ៤១ ក្នុងនោះរៀបចំចប់ ៥ ស្មើ ១២,២ភាគរយ កំពុងរៀបចំ ៣០ ស្មើ ៧៣,២ ភាគរយ និងមិនទាន់រៀបចំ ៦ ស្មើ ១៤,៦ភាគរយ។ គោលនយោបាយទី២ មាន ១៦ ក្នុងនោះរៀបចំចប់ ១ ស្មើ ៦,៣ ភាគរយ និង កំពុងរៀបចំ ១១ ស្មើ ៦៨,៨ភាគរយ និងមិនទាន់រៀបចំ ៤ ស្មើ ២៥ភាគរយ។

រូបភាពទី១៣ ៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០២០




### សកម្មភាពគោលនយោបាយតាមអនុវិស័យ៖

អនុវិស័យការអប់រំកុមារតូចមាន ៨ ក្នុងនោះកំពុងរៀបចំ ៧ ស្មើ ៨៧,៥ភាគរយ មិនទាន់រៀបចំ ១ ស្មើ ១២,៥ ភាគរយ។ អនុវិស័យការអប់រំបឋមសិក្សាមាន ១៧ ក្នុងនោះរៀបចំចប់ ៣ ស្មើ ១៧,៦ភាគរយ កំពុងរៀបចំ ៩ ស្មើ ៥២,៩ភាគរយ និងមិនទាន់រៀបចំ ៥ ស្មើ ២៩,៤ភាគរយ។ អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស មាន ១៣ ក្នុងនោះរៀបចំចប់ ១ ស្មើ ៧,៧ភាគរយ និងកំពុងរៀបចំ ១០ ស្មើ ៧៦,៩ភាគរយ និងមិនទាន់រៀបចំ ២ ស្មើ ១៥,៤ភាគរយ។ អនុវិស័យការអប់រំឧត្តមសិក្សាមាន ៣ ក្នុងនោះកំពុងរៀបចំ ២ ស្មើ ៦៦,៣ភាគរយ និងមិនទាន់រៀបចំ ១ ស្មើ ៣៣,៣ភាគរយ។ អនុវិស័យការអប់រំក្រៅប្រព័ន្ធមាន ៨ ក្នុងនោះរៀបចំចប់ ១ ស្មើ ១២,៥ភាគរយ កំពុងរៀបចំ ៦ ស្មើ ៧៥ភាគរយ និងមិនទាន់រៀបចំ ១ ស្មើ ១២,៥ភាគរយ។ អនុវិស័យយុវជនមាន ៦ ក្នុងនោះរៀបចំចប់ ១ ស្មើ ១៦,៧ភាគរយ កំពុងរៀបចំ ៥ ស្មើ ៨៣,៣ភាគរយ។ អនុវិស័យការអប់រំកាយនិងកីឡាមាន ២ កំពុងរៀបចំ ២ ស្មើ ១០០ភាគរយ។

រូបភាពទី១៤ ៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយឆ្នាំ២០២០ (តាមអនុវិស័យ)




### សកម្មភាពគោលនយោបាយបានរៀបចំចប់សព្វគ្រប់រួមមាន៖

- ការអនុម័តក្របខណ្ឌអាហារូបករណ៍ផ្ដោតលើគោលការណ៍សមធម៌នៅកម្រិតបឋមសិក្សា
- ការរៀបចំសេចក្ដីណែនាំស្ដីពីការបង្រៀននិងរៀនពេញមួយថ្ងៃនៅសាលាបឋមសិក្សា
- ការអនុម័តគោលនយោបាយស្ដីពីគន្លងអាជីពគ្រូបង្រៀន
- ការរៀបចំសេចក្ដីណែនាំប្រតិបត្តិក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

- ការរៀបចំផែនការអនុវត្តសាកល្បងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀននៅសាលាគោលដៅ ២៥០ ទូទាំងប្រទេស ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣
- ការអភិវឌ្ឍឯកសារជំនួយការរៀន និងបង្រៀនតាមបែបបញ្ញត្តិ
- ការចេញសេចក្តីណែនាំ ស្តីពីការរៀបចំបណ្ណាល័យ និងបណ្ណាល័យចល័ត
- ការរៀបចំផែនការសកម្មភាពជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២១-២០២៥ ទទួលបានការឯកភាពពីទីស្តីការគណៈរដ្ឋមន្ត្រី។

## ២.១.៨ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំសិក្សា២០១៩-២០២០ រាជធានី ខេត្ត

### វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ របស់រាជធានី ខេត្ត

ឆ្នាំ២០២០ គ្រប់រាជធានី ខេត្ត បានគ្រោងសកម្មភាពសរុប ៤ ០៧៣ ថយ ២៨០ ក្នុងនោះអនុវត្តចប់ ៣ ៤០០ ស្មើ ៨៣,៤ភាគរយ ថយ ៨,១ភាគរយ កំពុងអនុវត្ត ១១៧ ស្មើ ២,៩ភាគរយ កើន ០,៤ភាគរយ និងមិនបានអនុវត្ត ៥៥៦ ស្មើ ១៣,៧ ភាគរយ កើន ៧,៧ភាគរយ។

រូបភាពទី១៥៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ របស់រាជធានី ខេត្ត




ពិនិត្យតាមរាជធានី ខេត្តបង្ហាញថា ៣ខេត្ត អនុវត្តចប់ ១០០ភាគរយ រួមមានខេត្តព្រះវិហារ ព្រៃវែង និងកំពត។ ៦ ខេត្ត រាជធានី អនុវត្តចប់លើស ៩០ភាគរយ រួមមានខេត្តតាកែវ កំពង់ចាម ព្រះសីហនុ ប៉ៃលិន សៀមរាប និងរាជធានី។ ដោយឡែកខេត្តកោះកុងអនុវត្តចប់បាន ៦៦,០ភាគរយ និងមិនបានអនុវត្ត ៣៤,០ភាគរយ។

រូបភាពទី១៦៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ របស់រាជធានី ខេត្ត



## វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៩-២០២០ រាជធានី ខេត្ត

ឆ្នាំសិក្សា ២០១៩-២០២០ គ្រប់រាជធានី ខេត្ត បានលើកទិសដៅសម្រាប់អនុវត្ត ២ ១៤៣ ក្នុងនោះទិសដៅអនុវត្តចប់ ១៧០៥ ស្មើ ៧៩,៦ភាគរយ កំពុងអនុវត្ត ១៧៩ ស្មើ ៨,៤ភាគរយ និងមិនបានអនុវត្ត ២៥៩ ស្មើ ១២,១ភាគរយ។

រូបភាពទី១៧៖វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំរាជធានី ខេត្ត




ពិនិត្យតាមរាជធានី ខេត្តឃើញថាមាន ៣ ខេត្ត រាជធានី អនុវត្តចប់លើស ៩០ភាគរយ រួមមាន ខេត្តកំពង់ធំ ព្រះសីហនុ និងរាជធានី។ ដោយឡែកខេត្តពោធិ៍សាត់ អនុវត្តចប់តែ ៥៩,៤ភាគរយ និងខេត្តបាត់ដំបង អនុវត្តចប់តិចជាងគេ ៥៤,៨ភាគរយ។

រូបភាពទី១៨៖វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំរាជធានី ខេត្ត



# ២.២ លទ្ធផលតាមអនុវិស័យ

## ២.២.១ អនុវិស័យ ការអប់រំកុមារតូច

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា២០២០-២០២១ សាលាមត្តេយ្យសិក្សាគ្រប់រូបភាពមាន ៨ ០១២ សាលា/កន្លែង ថយ ៥៥ ក្នុងនោះ សាលាមត្តេយ្យសិក្សារដ្ឋមាន ៤ ៤៩៣ កើន ៨៤ (សាលាមត្តេយ្យសិក្សាដាច់ដោយឡែក ២១១ ថយ ២) មត្តេយ្យសិក្សាឯកជន ៥១៩ ថយ ៧៥ និងមត្តេយ្យសិក្សាសហគមន៍ ៣ ០០០កន្លែង ថយ ៦៤កន្លែង ដែលមានទីតាំង ១ ០៣៥ ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៤៦ ឃុំ សង្កាត់។

ថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាពមាន ១៤ ០២៤ កើន ៤៧០។ ថ្នាក់មត្តេយ្យសិក្សាសាធារណៈ ៨ ៨៣០ កើន ១ ០៦៩ មត្តេយ្យសិក្សាសហគមន៍ ៣ ១៤៥ ថយ ៥២ ក្នុងនោះថ្នាក់មត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដា ១ ០៥០ថ្នាក់ និងមត្តេយ្យសិក្សាឯកជន ២ ០៤៩ ថយ ៥២៩។

កុមារទទួលបានសេវាអប់រំមាន ៣៣៨ ៣០៧នាក់ ស្រី ១៧០ ៦៥៧នាក់ ស្មើ ៥០,៤៤ភាគរយ។ កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំមាន ៣៦ ៤៤៩នាក់ ស្មើ ១២,០៧ភាគរយ នៃចំនួនប្រជាជនអាយុ ៣ឆ្នាំ ស្រី ១៩ ១៣៧នាក់ ស្មើ ១២,៨៨ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំមាន ៩៩ ៦២៤នាក់ ស្មើ ៣២,៦៤ភាគរយ នៃចំនួនប្រជាជនអាយុ ៤ឆ្នាំ ស្រី ៥០ ៩៨០នាក់ ស្មើ ៣៤,១០ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ១៩១ ២៨២នាក់ ស្មើ ៦១,០៨ភាគរយ នៃចំនួនប្រជាជនអាយុ ៥ឆ្នាំ (ចំណុចដៅ ESP ៦១,៩ភាគរយ) ស្រី ៩៥ ០៤៣នាក់ ស្មើ ៦២,៣៣ ភាគរយ។

អត្រារួមនៃការសិក្សា (មត្តេយ្យសិក្សាសាធារណៈ សហគមន៍ និងឯកជន) ៣៤,៧៦ភាគរយ ប្រុស ៣៣,១២ ភាគរយ ស្រី ៣៥,៩២ភាគរយ ។

**រូបភាព១៩ ៖ ភាគរយកុមារតូចទទួលបានការអប់រំធៀបនឹងចំណុចដៅ ESP**




*កុមារអាយុ ៥ឆ្នាំ ទទួលបានសេវាអប់រំកុមារតូចគ្រប់រូបភាពមានការកើនឡើងគួរឱ្យកត់សម្គាល់។ ប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញថា សេវាអប់រំកុមារតូចបានឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ប្រកបដោយសមធម៌ និងត្រៀមលក្ខណៈពេញលេញ ដើម្បីទទួលការអប់រំនៅកម្រិតបឋមសិក្សា។*

បុគ្គលិកអប់រំផ្នែកអប់រំកុមារតូច ១២ ៨៤២នាក់ ថយ ១ ៣០៤នាក់ ស្រី ៩០,៦៩ភាគរយ ក្នុងនោះបុគ្គលិកបង្រៀន ១០ ៩២៩នាក់ ថយ ២៩៨នាក់ ស្រី ៩៣,៥៦ភាគរយ និងបុគ្គលិកមិនបង្រៀនមាន ១ ៩១៣នាក់ កើន ១៤៣នាក់ ស្រី ៧៤,២៨ភាគរយ។

បុគ្គលិកមត្តេយ្យសិក្សាសាធារណៈ ៥ ៧១៧នាក់ កើន ៣៩នាក់ ស្រី ៩៤,៧៨ភាគរយ ក្នុងនោះបុគ្គលិកបង្រៀន ៥ ៤៥០នាក់ កើន ១១៥នាក់ ស្រី ៩៤,៩៩ភាគរយ។ បុគ្គលិកមត្តេយ្យសិក្សាសហគមន៍ ៣ ២០២នាក់ ស្រី ៩៤,៦០ភាគរយ។ បុគ្គលិកមត្តេយ្យសិក្សាឯកជន ៣ ៩២៣នាក់ ថយ ១ ២៨៦នាក់ ស្រី ៨១,៥២ភាគរយ ក្នុងនោះបុគ្គលិកបង្រៀន ២ ៣១៨នាក់ ថយ ៤២២នាក់ ស្រី ៨៨,៥៦ភាគរយ។

### *មត្តេយ្យសិក្សាសាធារណៈ*

កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំ ១៥ ៤៣៥នាក់ ស្មើ ៤,៧១ភាគរយ ស្រី ៨ ១០៩នាក់ ស្មើ ៥,០៧ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ ៦២ ៦៦៦នាក់ ស្មើ ១៩,៧៧ភាគរយ ស្រី ៣១ ៩៨៦នាក់ ស្មើ ២០,៦០ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ១៤៨ ៨៧៨នាក់ ស្មើ ៤៧,៩៣ភាគរយ ស្រី ៧៣ ៨៨៣នាក់ ស្មើ ៤៨,៩៤ភាគរយ។

### *មត្តេយ្យសិក្សាឯកជន*

កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំ ៦ ៤០៩នាក់ ស្មើ ១,៩៥ភាគរយ ស្រី ៣ ២១៩នាក់ ស្មើ ២,០១ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ ១០ ៦៧៤នាក់ ស្មើ ៣,៣៧ភាគរយ ស្រី ៥ ៣៩៦នាក់ ស្មើ ៣,៥០ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ១៥ ៣៦២នាក់ ស្មើ ៤,៩៥ភាគរយ ស្រី ៧ ៥៣៤នាក់ ស្មើ ៤,៩៩ភាគរយ។

### *មត្តេយ្យសិក្សាសហគមន៍*

កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំ ១៤ ៦០៥នាក់ ស្មើ ៤,៥០ភាគរយ ស្រី ៧ ៨០៩នាក់ ស្មើ ៤,៨៨ភាគរយ។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ ២៦ ២៨៤នាក់ ស្មើ ៨,២៩ភាគរយ ស្រី ១៣ ៥៩៨នាក់ ស្មើ ៨,៨០ភាគរយ។ កុមារអាយុ ៥ឆ្នាំ បានទទួលសេវាអប់រំ ២៧ ០៤២នាក់ ស្មើ ៨,៧០ភាគរយ ស្រី ១៣ ៦២៦នាក់ ស្មើ ៩,០២ភាគរយ។

### ការអនុវត្តកម្មវិធី និងសកម្មភាពនានា

### *ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ*

ក្រសួងបានផ្តល់មូលនិធិដំណើរការសាលារៀនសាធារណៈដល់សាលាមត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក ២១៣ មានទឹកប្រាក់សរុប ២ ៤៧០ ២១៣ ៥០០រៀល ក្នុងនោះ៖

- ថវិការដ្ឋ ១ ៩៩៤ ៣៨៥ ៥០០រៀល អនុវត្តបាន ១ ៩៨០ ០១៥ ៦០០ រៀល ស្មើ ៩៩,២៨ភាគរយ
- មូលនិធិដំណើរការសាលារៀនសាធារណៈ(ថវិកាកែលម្អសាលារៀនរបស់ដៃគូអភិវឌ្ឍ) ៤៧៥ ៨២៨ ០០០រៀល អនុវត្តបាន ១០០ភាគរយ។

ក្រសួងបានបើកផ្តល់ថវិកាឧបត្ថម្ភគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដា ១ ០៥០នាក់ ស្រី ១ ០០៤នាក់ តាមប្រព័ន្ធធនាគារ មានទឹកប្រាក់សរុប ៨ ៤៤០ ០០០ ០០០រៀល និងថវិកាសម្រាប់កិច្ចដំណើរការអភិវឌ្ឍថ្នាក់រៀន មានទឹកប្រាក់សរុប ៥២៥ ០០០ ០០០រៀល។

### ការគ្រប់គ្រងតាមសាលារៀន

ក្រសួងបានពង្រឹងយន្តការអនុវត្តការអប់រំតាមគន្លងថ្មី នៃការគ្រប់គ្រងតាមសាលារៀននៅកម្រិតមត្តេយ្យសិក្សា ក្នុងបរិការណ៍ការរាតត្បាតជាសកលជំងឺកូវីដ-១៩ ចំនួន ៣១សាលា នៅ ២៥ ក្រុង ស្រុក ខណ្ឌ នៃ ១៩ ខេត្ត និងរាជធានី និងបានបំពាក់ទូរទស្សន៍វៃឆ្លាត ៣១គ្រឿង ដល់សាលាមត្តេយ្យសិក្សាគោលដៅ ៣១សាលា សម្រាប់ការអនុវត្តកម្មវិធីការរៀន និងបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក។

### កម្មវិធីអប់រំមាតាបិតា

ក្រសួងបាន៖

- អនុវត្តកម្មវិធីអប់រំមាតាបិតា អ្នកអាណាព្យាបាល នៅតាមសាលារៀនមត្តេយ្យសិក្សាសាធារណៈគោលដៅនៃការគ្រប់គ្រងតាមសាលារៀន ៣១សាលា ដើម្បីជួយបង្រៀនកូននៅតាមផ្ទះក្នុងការគាំទ្រការអនុវត្តការសិក្សាពីចម្ងាយ ក្នុងដំណាក់កាលនៃការីករាលដាលជាសកលជំងឺកូវីដ-១៩
- អនុវត្តកម្មវិធីការអប់រំមាតាបិតាផ្សារភ្ជាប់ថ្នាក់មត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដា ១ ០៥០កន្លែង កើន ២០០កន្លែង
- ពង្រឹងការអនុវត្តការងារប្រឹក្សាយោបល់ជាមួយមាតាបិតាស្តីពី ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដល់គ្រូបង្គោល ៣០០សាលា។

### ការអប់រំពហុភាសា និងមត្តេយ្យសិក្សាចល័ត

ក្រសួងបាន៖

- អនុវត្តកម្មវិធីការអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិចក្នុង ១៩ក្រុង ស្រុក ក្នុងខេត្តគោលដៅ ៥ មានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ព្រះវិហារ និងក្រចេះ។ កម្មវិធីនេះបានអនុវត្តនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ ៨កន្លែង កើន១ មានកុមារ ១១៩នាក់ ស្រី ៦៣នាក់ កើន ៨នាក់ ស្រី ៨នាក់ និងមត្តេយ្យសិក្សាសហគមន៍ ១១៩កន្លែង កើន ៦កន្លែង មានកុមារ ២ ២១០នាក់ ស្រី ១ ១៣៨នាក់ កើន ៦៣នាក់ ស្រី ៥០នាក់។ ភាសាដែលបានប្រើប្រាស់រួមមាន ភាសាទំពួន គ្រឹង ព្នង កួយ ក្រោល ការ៉ែត ព្រៅ ចារ៉ាយ និងកាចក់។
- សហការអនុវត្តកម្មវិធីមត្តេយ្យសិក្សាចល័តតាមរដូវកាល ៥កន្លែង ជួយកុមារអាយុពី ៣ ទៅ ៥ឆ្នាំ ទទួលសេវា ១៣២នាក់ ស្រី ៧០នាក់ រស់នៅតំបន់ជនជាតិដើមភាគតិចដែលមានគ្រួសារបម្លាស់ទីលំនៅទៅតាមរដូវកាល និងមានចម្ងាយឆ្ងាយពីសាលាមត្តេយ្យសិក្សាសាធារណៈ ឬមត្តេយ្យសិក្សាសហគមន៍។ កម្មវិធីនេះអនុវត្តតាមរយៈការចល័តដោយប្រើយានជំនិះផ្សេងៗ និងចល័តតាមរដូវកាលនៅឃុំតាវែងក្រោម ឃុំតាវែងលើ ស្រុកតាវែង ឃុំកោះពាក្យ ស្រុកវើនសៃ និងឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី និងឃុំស្រែសម្បូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

### ការអប់រំបរិយាបន្ន

ក្រសួងបាន៖

- អនុវត្តកម្មវិធីការអប់រំបរិយាបន្នសម្រាប់មត្តេយ្យសិក្សាសាធារណៈ ៨៥១សាលា កើន ៣០៦សាលា ក្នុងនោះកុមារមានពិការភាព ៤៤៦នាក់ កើន ៤៧នាក់ ស្រី ១៧១នាក់ និងមត្តេយ្យសិក្សាសហគមន៍ ៣១១កន្លែង ក្នុងនោះកុមារមានពិការភាព ២០៧នាក់ កើន ៤០នាក់ ស្រី ១៥៤នាក់ នៅខេត្តសៀមរាប កំពង់ធំ រតនគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រៃវែង ព្រះសីហនុ ឧត្តរមានជ័យ និងរាជធានី
- បំប៉នសមត្ថភាពស្តីពី ការអប់រំបរិយាបន្ន និងវិធីព្យាបាល ការប្រាស្រ័យទាក់ទងសម្រាប់កុមារតូចក្នុងថ្នាក់អប់រំបរិយាបន្នដល់គ្រូមត្តេយ្យសិក្សាសាធារណៈ ៥៨៤នាក់ ស្រី ៥៦៤នាក់ និងគ្រូមត្តេយ្យសិក្សាសហគមន៍ ៦១នាក់

ស្រី ៥៨នាក់ នៅខេត្តព្រៃវែង បាត់ដំបង សៀមរាប កំពង់ធំ ឧត្តរមានជ័យ បន្ទាយមានជ័យ និងរាជធានី សហការជាមួយដៃគូអភិវឌ្ឍ។

*ការអនុវត្តកម្មវិធីនិងសកម្មភាពនានា បានផ្តល់ការគាំទ្រសម្រាប់អនុវិស័យការអប់រំកុមារតូច ដើម្បីធានាបាននូវប្រក្រតីភាពក្នុងការរៀននិងបង្រៀន ក្នុងបរិបទការរីករាលដាលជាសកលជំងឺកូវីដ-១៩ ។*

## លទ្ធផលនៃការសិក្សា

### *ការអនុវត្តកម្មវិធីសិក្សាលម្អិតនិងវិធីសាស្ត្របង្រៀនថ្មី*

ក្រសួងបាន៖

- អនុម័តជាផ្លូវការឯកសារស្តីពី សិក្សាចិត្តសាស្ត្រសង្គមនៅមត្តេយ្យសិក្សា
- ព្រាងចុងក្រោយសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាសម្រាប់មត្តេយ្យសិក្សា
- ព្រាងចុងក្រោយកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍
- បំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ ២០០នាក់ ស្រី ១៩២នាក់ ស្តីពីការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍ ៨តំបន់ លើកទី១ មានខេត្តស្វាយរៀង កំពង់ចាម កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ សៀមរាប រតនគិរី និងបាត់ដំបង
- បំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ ២០០នាក់ ស្រី ១៩២នាក់ ស្តីពីការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍ ៨តំបន់ លើកទី២ មានខេត្តព្រៃវែង កណ្តាល កំពត តាកែវ ស្ទឹងត្រែង ឧត្តរមានជ័យ ត្បូងឃ្មុំ និងពោធិ៍សាត់។

### *លទ្ធផលសិក្សាកម្រិតមត្តេយ្យសិក្សា*

កុមារអាយុ ៦ឆ្នាំ ចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាបានឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់រូបភាព ៧៤,៤៥ ភាគរយ កើន ៣,១៥ភាគរយ។ អត្រាកុមារអាយុ ៦ឆ្នាំ បានឆ្លងកាត់សេវាអប់រំកុមារតូចមានការកើនឡើងជាលំដាប់ អាស្រ័យដោយមានការកើនឡើងថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា និងថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

### ការលើកកម្ពស់សុខភាពសិក្សា

ក្រសួងបាន៖

- ពិនិត្យសុខភាព និងកាយសម្បទាដល់កុមារនៅសាលាមត្តេយ្យសិក្សាសហគមន៍ ៣២៧នាក់ ស្រី ៤៨,៩២ភាគរយ នៅខេត្តពោធិ៍សាត់ សហការជាមួយដៃគូអភិវឌ្ឍ
- ផ្តល់ប្រអប់សង្គ្រោះបឋមដល់មត្តេយ្យសិក្សាសហគមន៍ ២១៦ប្រអប់ នៅខេត្តសៀមរាប ស្ទឹងត្រែង ពោធិ៍សាត់ និង រតនគិរី សហការជាមួយដៃគូអភិវឌ្ឍ
- រៀបចំសិក្ខាសាលាអភិវឌ្ឍសមត្ថភាពស្តីពីគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បរមាស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន ដល់នាយក នាយិកាសាលាមត្តេយ្យជាច់ដោយឡែក ៥៥នាក់ ស្រី ៩២,៧ភាគរយ ក្នុងខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង សៀមរាប ព្រះវិហារ និងបន្ទាយមានជ័យ
- រៀបចំបង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងបណ្តាញទឹកស្អាត ៨២សាលា នៅតាមរាជធានី ខេត្ត គាំទ្រដោយថវិការាជរដ្ឋាភិបាល
- ចែកផ្សាយសៀវភៅណែនាំ ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ ដល់គ្រប់សាលាមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសហគមន៍ទូទាំងប្រទេស ៥០ ៨១៦ក្បាល សហការជាមួយដៃគូអភិវឌ្ឍ

- ផ្តល់ឧបករណ៍លាងសម្អាតដៃ ដល់គ្រប់សាលាមត្តេយ្យសិក្សាសាធារណៈទាំងអស់ទូទាំងប្រទេស ៤ ៤០៩គ្រឿង ធុងទឹកសម្រាប់លាងដៃចំណុះ ២០លីត្រ ១៦ ៩៧៥ធុង ចំណុះ ១៤លីត្រ ៨ ១៥៧ធុង សាប៊ូដុំ ៧៥មីលីក្រាម ៥០ ៦០៥ដុំ កញ្ចប់សម្ភារៈអនាម័យនិងម្ងាប់មេរោគ ១១មុខផ្សេងទៀតសម្រាប់ប្រើប្រាស់រយៈពេល១ខែ និងខិតបណ្ណស្តីពីពិធីសារម្ងាប់មេរោគនៅតាមសាលារៀន ៤ ៤០៩សន្លឹក សហការជាមួយដៃគូអភិវឌ្ឍ
- ផ្តល់ឧបករណ៍លាងសម្អាតដៃ ដល់គ្រប់សាលាមត្តេយ្យសិក្សាសហគមន៍ទាំងអស់ទូទាំងប្រទេស ៣ ០៦៤គ្រឿង ធុងចម្រោះទឹកស្អាតសម្រាប់ទទួលទាន ៣ ០៦៤គ្រឿង ធុងទឹកសម្រាប់លាងដៃចំណុះ ២០លីត្រ ៦ ១២៨ធុង ចំណុះ ១៤លីត្រ ៣ ០៦៤ធុង សាប៊ូដុំ ៧៥មីលីក្រាម ២១ ៤៤៨ដុំ កញ្ចប់សម្ភារៈអនាម័យនិងម្ងាប់មេរោគ ១១មុខផ្សេងទៀតសម្រាប់ប្រើប្រាស់រយៈពេល១ខែ ព្រមទាំងប្រអប់រៀននិងបង្រៀន ៣ ០៩៥ប្រអប់ និងខិតបណ្ណស្តីពីពិធិសារម្ងាប់មេរោគនៅតាមសាលារៀន ៣ ២៨៦សន្លឹក សហការជាមួយដៃគូអភិវឌ្ឍ
- ផ្តល់ផ្ទាំងរូបភាពស្តីពីការចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលនិងស្អូចដល់គ្រប់សាលាមត្តេយ្យសិក្សាសាធារណៈ ១៩៣ ៦៤១សន្លឹក និងដល់គ្រប់មត្តេយ្យសិក្សាសហគមន៍ទូទាំងប្រទេស ៧៤ ៥៤៥សន្លឹក សហការជាមួយដៃគូអភិវឌ្ឍ
- ផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន ដល់សិស្សានុសិស្សសាលាមត្តេយ្យសិក្សាសាធារណៈលើកទី១ ចំនួន ១៦៨ ០៨២នាក់ ស្មើ ៧២,៣៨ភាគរយ ស្រី ៨១ ៩៧៨នាក់ ស្មើ ៧០,៨៩ភាគរយ និងលើកទី២ ចំនួន ៨៧ ៥៦០នាក់ ស្មើ ៣៧,៧០ភាគរយ ស្រី ៤៣ ៥៩១នាក់ ស្មើ ៣៧,៧០ភាគរយ សាលាមត្តេយ្យសិក្សាសាធារណៈដាច់ដោយឡែកមានប្រអប់សង្គ្រោះបឋម ១៤៣សាលា ស្មើ ៦៧,១៣ភាគរយ កើន ៣៤,៧៣ភាគរយ មានបន្ទប់សុខភាព ៦សាលា ស្មើ ២,៨២ ភាគរយ កើន ២,៨២ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ សហការជាមួយក្រសួងសុខាភិបាល
- ចែកសន្លឹកកិច្ចការ និងចុះជួយកុមារមត្តេយ្យសិក្សាអប់រំពហុភាសាដល់សហគមន៍ក្នុងអំឡុងពេលទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ នៅខេត្តស្ទឹងត្រែង។

## ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការផ្គត់ផ្គង់

ក្រសួងបាន៖

- ជួសជុល រៀបចំថ្នាក់រៀន តាមរយៈការលេង និងបរិស្ថាន ផ្អែកលើកម្មវិធីមត្តេយ្យសិក្សាសាធារណៈក្នុងសាលាបឋមសិក្សាគោលដៅ ៥១សាលា នៅខេត្តបាត់ដំបង
- កែលម្អទីធ្លា និងល្បែងលេងក្នុងនិងក្រៅថ្នាក់នៅតាមសាលាមត្តេយ្យសិក្សាគោលដៅអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន ១៤សាលា នៅខេត្តតាកែវ បន្ទាយមានជ័យ កំពង់ចាម ស្ទឹងត្រែង បាត់ដំបង ស្វាយរៀង ព្រៃវែង សៀមរាប កំពត និងរតនគិរី។

## ការពិនិត្យតាមដាន និងការវាយតម្លៃ

ក្រសួងបាន៖

- ពិនិត្យតាមដានស្តីពី ការអនុវត្តការងារអប់រំកុមារតូច នៅខេត្តស្ទឹងត្រែង កំពង់ឆ្នាំង រតនគិរី មណ្ឌលគិរី ពោធិ៍សាត់ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពង់ស្ពឺ
- ពិនិត្យតាមដានស្តីពី ការអនុវត្តកម្មវិធីប្រឹក្សាយោបល់ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅខេត្តកំពង់ចាម ព្រៃវែង ក្រចេះ កណ្តាល តាកែវ ព្រះសីហនុ បាត់ដំបង និងសៀមរាប
- ចុះប្រមូលទិន្នន័យព័ត៌មានស្តីពី ការអនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចនៅកម្ពុជា តាមរយៈការជួបសម្ភាសន៍ឪពុកម្តាយ និងធ្វើតេស្តកុមារក្នុងតំបន់គោលដៅនៅខេត្តរតនគិរី
- ពិនិត្យតាមដានការងារកម្មវិធីអប់រំមាតាបិតា នៅខេត្តកំពង់ចាម និងស្ទឹងត្រែង

- ពិនិត្យប្រមូលព័ត៌មានស្តីពី ស្ថានភាពគ្រឹះស្ថានមត្តេយ្យសិក្សានិងសេវាអប់រំកុមារតូចខេត្តបាត់ដំបង តាកែវ កែប ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ ព្រះសីហនុ កោះកុង កំពត ព្រៃវែង ស្វាយរៀង កណ្តាល កំពង់ធំ ប៉ៃលិន សៀមរាប ព្រះវិហារ បន្ទាយមានជ័យ និងឧត្តរមានជ័យ
- ពិនិត្យតាមដាន និងវាយតម្លៃស្ថានភាពរបស់គ្រឹះស្ថានសិក្សាឯកជនស្តីពី ការអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ ដំណាក់កាលទី២ នៅរាជធានី
- ពិនិត្យតាមដានការអនុវត្តដំណើរការមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ២០០កន្លែង នៅតាម រាជធានី ខេត្ត
- ចុះពិនិត្យតាមដានការបង្រៀន និងរៀនថ្នាក់អប់រំពហុភាសាកម្រិតមត្តេយ្យសិក្សា ១៦សាលា ក្នុង ១២ស្រុក នៃ ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ។

*សកម្មភាពពិនិត្យតាមដាននិងវាយតម្លៃបានជួយជំរុញនិងពង្រឹងការអនុវត្តកម្មវិធីអប់រំកុមារតូចឱ្យមានគុណភាព។*

## ក.២. ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### យន្តការគាំទ្រសេវាអប់រំកុមារតូច

ក្រសួងបាន៖

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលទិន្នន័យព័ត៌មានស្តីពី ការរៀបចំសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា សម្រាប់មត្តេយ្យសិក្សាដល់មន្ត្រីទទួលបន្ទុកអប់រំកុមារតូចថ្នាក់ជាតិ ក្រោមជាតិ នាយក នាយិកា គ្រូមត្តេយ្យសិក្សា ១២៥នាក់ ស្រី ៩៨នាក់ នៅតាមសាលារៀនគោលដៅការគ្រប់គ្រងសាលារៀន នៃខេត្តកំពង់ចាម សៀមរាប បាត់ដំបង ព្រៃវែង និងកំពត
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំចងក្រងសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាសម្រាប់មត្តេយ្យ សិក្សាសាធារណៈ ដល់មន្ត្រីទទួលបន្ទុកអប់រំកុមារតូចថ្នាក់ជាតិ ក្រោមជាតិ នាយក នាយិកា គ្រូមត្តេយ្យសិក្សា ១៥០នាក់ ស្រី ១២៤នាក់ នៅខេត្តកោះកុង
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយស្តីពី ការរៀបចំចងក្រងសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាសម្រាប់ សាលាមត្តេយ្យសិក្សាសាធារណៈ ដល់មន្ត្រីទទួលបន្ទុកអប់រំកុមារតូចថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ នាយក នាយិកា គ្រូមត្តេយ្យសិក្សា ៩០នាក់ ស្រី ៧៣នាក់ នៅខេត្តកំពង់ចាម
- រៀបចំសិក្ខាសាលាប្រកាសដាក់ឱ្យដំណើរការគម្រោងស្តីពី ការគាំទ្រអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងសហគមន៍ ក្នុងការបញ្ជ្រាបសមភាពយេនឌ័រ មានអ្នកចូលរួម ៥៨នាក់ ស្រី ៣៤នាក់ នៅរាជធានី
- រៀបចំសិក្ខាសាលាប្រកាសដាក់ឱ្យដំណើរការគម្រោងស្តីពី ការបង្កើតទារកដ្ឋានប្រចាំសហគមន៍សម្រាប់កូនកម្មករ កម្មការិនីតាមរោងចក្រ មានអ្នកចូលរួម ៦៧នាក់ ស្រី ៣១នាក់ នៅរាជធានី
- រៀបចំសិក្ខាសាលាប្រកាសដាក់ឱ្យអនុវត្តគម្រោងស្តីពី ការកសាងមូលដ្ឋានគ្រឹះនៃការអនុវត្តទ្រឹស្តីរៀនតាមរយៈការ លេងនិងបរិស្ថាន ផ្តែកលើកម្មវិធីមត្តេយ្យសិក្សាសាធារណៈ មានអ្នកចូលរួម ១៦៥នាក់ ស្រី ៨៥នាក់ នៅខេត្ត បាត់ដំបង
- កសាងនិងផ្សព្វផ្សាយឯកសារជំនួយការកំណត់អត្តសញ្ញាណកុមារមានពិការភាពអាយុក្រោម ៦ឆ្នាំ មានអ្នកចូលរួម ១២៥នាក់ ស្រី ៥២នាក់ នៅរាជធានី
- ផលិតខ្សែវីដេអូក្លីប ៣៨ ស្តីពីលំនាំការបង្រៀនមុខវិជ្ជាចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និង ភាសាខ្មែរ
- ផ្សព្វផ្សាយវីដេអូក្លីបស្តីពី លំនាំបង្រៀនសម្រាប់មត្តេយ្យសិក្សាតាមកញ្ចក់ទូរទស្សន៍ជាតិ២ (TVK2) និងបណ្តាញ សង្គមផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

- រៀបរៀងនិងផលិតរឿងអប់រំខ្លី ១៥រឿង ស្តីពីកម្មវិធីអប់រំមាតាបិតា និងចាក់ផ្សាយតាមស្ថានីយ៍វិទ្យុជាតិកម្ពុជា FM 69 $MH_z$ នៃក្រសួងព័ត៌មាន និងបណ្តាញសង្គមផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច
- ថតវីដេអូល្បែងសិក្សាការអប់រំបរិយាបន្នសម្រាប់មត្តេយ្យសិក្សា ២០វីដេអូ សម្រាប់ជំនួយដល់លោកគ្រូ អ្នកគ្រូ និងអ្នកអាណាព្យាបាលកុមារពិបាកក្នុងការបង្រៀននិងរៀន និងគាំទ្រពួកគេនៅតាមសាលារៀន និងនៅផ្ទះ
- ផលិតឃ្លីបសំឡេងបង្រៀនថ្នាក់មត្តេយ្យសិក្សាអប់រំពហុភាសា ២៩៣ឃ្លីប (ភាសាព្នង ៨៣ឃ្លីប គ្រឹង ១០៥ឃ្លីប និងទំពួន ១០៥ឃ្លីប) ក្នុងអំឡុងពេលទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩
- ចាក់ផ្សាយ និងផ្សាយឡើងវិញសំឡេងការបង្រៀនថ្នាក់មត្តេយ្យសិក្សាអប់រំពហុភាសាជាភាសាទំពួន គ្រឹង និងភាសាព្នង តាមស្ថានីយវិទ្យុផ្សាយសំឡេង ៤ និងចែកសន្លឹកកិច្ចការដល់សិស្សមត្តេយ្យសិក្សាក្នុងអំឡុងពេលទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ នៅខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ
- ផ្តល់វិទ្យុដល់កុមារមត្តេយ្យសិក្សាអប់រំពហុភាសា ៥៦៧គ្រឿង នៅខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ សហការជាមួយដៃគូអភិវឌ្ឍ
- ផ្តល់កញ្ចប់សម្ភារៈដល់ថ្នាក់មត្តេយ្យសិក្សាអប់រំពហុភាសា ២៦កន្លែង និងសិស្សមត្តេយ្យសិក្សាអប់រំពហុភាសាមានដូចជា សៀវភៅរូបភាព ៥៩៨ក្បាល សៀវភៅរឿងនិទាន និងសៀវភៅផាត់ពណ៌ ១ ៣០០ក្បាល គូល័រឈើ ៣១២ប្រអប់ សម្ភារៈល្បែងសិក្សា និងរូបសត្វ ១៨២ឈុត និងកញ្ចប់សម្ភារសិក្សា (សៀវភៅសរសេរ គូល័រឈើ ខ្មៅដៃ ជ័រលុប ប្រដាប់ខួង ម៉ាស សាប៊ូ) ២០៧ឃីត នៅខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ សហការជាមួយដៃគូអភិវឌ្ឍ
- ផ្តល់កញ្ចប់សម្ភារសិក្សា និងសម្ភារអនាម័យដល់សាលាមត្តេយ្យសិក្សាសាធារណៈ ៤ ៤០៩សាលា និងមត្តេយ្យសិក្សាសហគមន៍ ៣ ០៦៤កន្លែង សហការជាមួយដៃគូអភិវឌ្ឍ
- ថតវីដេអូស្តីពី ការអប់រំពហុភាសានៅតំបន់ជនជាតិដើមភាគតិច ៣ក្លីប សម្រាប់ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម។

## ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

ក្រសួងបាន៖

- ប្រឡងបញ្ចប់ការបណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សាជំនាន់ទី៣២ ចំនួន ២០០នាក់ ស្រី ៩៥,៥ភាគរយ
- បណ្តុះបណ្តាលគរុសិស្សមត្តេយ្យសិក្សាជំនាន់ទី៣៣ ឆ្នាំទី២ ចំនួន ២០០នាក់ ស្រី ៩៦,៥ភាគរយ
- បំប៉នសមត្ថភាពនាយក នាយិកា គ្រូមត្តេយ្យសិក្សា ៣១នាក់ ស្រី ២១នាក់ ស្តីពីការរៀបចំផែនការកែលម្អសាលារៀន នៅខេត្តក្រចេះ កំពង់ស្ពឺ សៀមរាប ព្រៃវែង និងកណ្តាល
- បំប៉នសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ ៥០នាក់ ស្រី ២៧នាក់ ស្តីពីការរៀនសូត្រចិត្តសង្គមនៅកម្រិតមត្តេយ្យសិក្សា នៅខេត្តកំពង់ធំ
- បំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សា ២១៤នាក់ ស្រី ១៩៧នាក់ ស្តីពីការរៀនសូត្រចិត្តសង្គមនៅកម្រិតមត្តេយ្យសិក្សានៅតាមក្រុង ស្រុកគោលដៅ មានស្រុកបាភ្នំ កញ្ជ្រៀច ព្រះស្តេច និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង
- បំប៉នសមត្ថភាពដល់គ្រូមត្តេយ្យសិក្សា ៥៧នាក់ ស្រី ៤០នាក់ ស្តីពីវិធីសាស្ត្របង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា នៅខេត្តរតនគិរី
- បំប៉នគ្រូបឋមបង្រៀនថ្នាក់មត្តេយ្យសិក្សា ១៥នាក់ ស្រី ៩នាក់ ស្តីពីការងារបច្ចេកទេសបង្រៀន និងការងារគ្រប់គ្រងថ្នាក់តាមស្តង់ដា នៅខេត្តស្ទឹងត្រែង សហការជាមួយដៃគូអភិវឌ្ឍ

- បំប៉នគ្រូមត្តេយ្យសិក្សាថ្នាក់កម្រិតខ្ពស់ ២៣៧នាក់ ស្រី ២២៥នាក់ ស្តីពីសម្ភារៈជំនួយបន្ថែមលើមុខវិជ្ជាភាសាខ្មែរ នៅខេត្តកំពត សហការជាមួយដៃគូអភិវឌ្ឍ
- ចូលរួមកម្មវិធីប្រជុំតាមអនឡាញ (Webinar) ស្តីពីការឆ្លើយតបនៃការអប់រំចំពោះការរីករាលដាលសកលនៃជំងឺកូវីដ-១៩ និងការធានាគុណភាពនៃសេវាអប់រំកុមារតូចក្នុងបរិបទកូវីដ-១៩ រៀបចំដោយអង្គការយូណេស្កូប៉ារីស
- ចូលរួមកិច្ចសន្ទនាកម្រិតបច្ចេកទេសក្នុងកម្មវិធី «ជំរុញរបៀបវារៈកុមារតូច៖ កិច្ចសន្ទនាស្តីពីនវានុវត្តន៍បរិយាបន្ន ឆ្ពោះទៅរកយុទ្ធសាស្រ្តភាពជាដៃគូសកល» រៀបចំដោយអង្គការយូណេស្កូប៉ារីស
- ចូលរួមកម្មវិធីប្រជុំតាមអនឡាញ ក្រោមប្រធានបទស្តីពីវិធានការផ្សេងៗគ្នានៃគោលនយោបាយ និងកម្មវិធីសម្រាប់ការអប់រំកុមារតូចក្នុងបរិបទកូវីដ-១៩ រៀបចំដោយបណ្តាញការអភិវឌ្ឍកុមារតូច តំបន់អាស៊ីប៉ាស៊ីហ្វិក
- ចូលរួមកម្មវិធីប្រជុំលើកទី៣ របស់ក្រុមប្រឹក្សាភិបាល តាមរយៈអនឡាញ (Webinar) រៀបចំដោយមជ្ឈមណ្ឌលគាំពារ អប់រំកុមារតូច និងមាតាបិតា (SEAMEO CECCEP)
- បញ្ជូនបុគ្គលិកអប់រំ ២នាក់ ស្រី ១នាក់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍកុមារតូច នៅជប៉ុន
- បញ្ជូនបុគ្គលិកអប់រំជាស្រ្តី ២នាក់ ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់តាមអនឡាញស្តីពី ការអប់រំតាមគន្លងថ្មីសម្រាប់ការអប់រំកុមារតូច និងអប់រំមាតាបិតា រៀបចំដោយមជ្ឈមណ្ឌលគាំពារ អប់រំកុមារតូច និងមាតាបិតា
- បញ្ជូនមន្ត្រីអប់រំ ២នាក់ ចូលរួមកិច្ចប្រជុំស្តីពីការអភិវឌ្ឍឯកសារអប់រំកុមារតូចលើផ្នែកការរៀនសូត្រចិត្តសង្គមកម្រិតអ្នកជំនាញការតំបន់ តាមប្រព័ន្ធអេឡិចត្រូនិក នៅថៃ។

## ការកសាងលិខិតបទដ្ឋានគតិយុត្ត

ក្រសួងបានរៀបចំ៖

- សេចក្តីសម្រេចលេខ ៥៧ អយក.សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងការកសាងមូលដ្ឋានគ្រឹះនៃការអនុវត្តទ្រឹស្តី រៀនតាមតាមរយៈការលេងនិងបរិស្ថាន ផ្អែកលើកម្មវិធីមត្តេយ្យសិក្សាសាធារណៈ
- សេចក្តីណែនាំលេខ ៣៧ អយក.សណន ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ស្តីពីការបើកដំណើរការឡើងវិញគ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូច ក្នុងដំណាក់កាលទី២
- ប្រកាសលេខ ២២៨២ អយក.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា
- ប្រកាសលេខ ២៥៩៨ អយក.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការដាក់សាលាមត្តេយ្យសិក្សាវាលស្លែង ជាឧបសម្ព័ន្ធសាលាបឋមសិក្សាអណ្តូងដៃ ខេត្តកំពង់ចាម
- សេចក្តីណែនាំលេខ ៦៥ អយក.សណន ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបើកដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូចឆ្នាំសិក្សា២០២០-២០២១
- ប្រកាសលេខ ៣២០១ អយក.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់មន្ត្រីកិច្ចសន្យា (គ្រូមត្តេយ្យសិក្សាដែលមានលក្ខណៈស្តង់ដាឆ្នាំ២០២០)។

## ការងារគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច

ក្រសួងបាន៖

- កែសម្រួលសមាសភាពគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច
- តែងតាំងសមាសភាពមន្ត្រីគ្រប់គ្រង ៤រូប ស្រី ១រូប សម្រាប់ក្របខណ្ឌអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច

- រៀបចំក្របខណ្ឌការងារទូទៅសម្រាប់បង្កើត និងគ្រប់គ្រងទារកដ្ឋាននៅក្នុងសហគ្រាសគ្រឹះស្ថាននៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំសេចក្តីព្រាងចុងក្រោយផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៩-២០២៣
- ដាក់ឱ្យអនុវត្តគម្រោងការបង្កើតទារកដ្ឋានប្រចាំសហគមន៍សម្រាប់កូនកម្មករ កម្មការិនីរោងចក្រ ២២កន្លែង (CBCC) នៅខេត្តកំពង់ស្ពឺ កណ្តាល និងកំពង់ចាម និងគម្រោងមត្តេយ្យសិក្សាសហគមន៍ ១០០កន្លែង នៅខេត្តកំពង់ស្ពឺ កំពត ពោធិ៍សាត់ និងព្រះសីហនុ។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

*ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| ល-រ | ការអប់រំកុមារតូច | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន | | | | | | |
| ១. | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៦២,៩ | ៦១,៩ | ៦១,១ | ↓ |
| | ប្រុស | % | ៦២,០ | ៦១,៣ | ៥៨,៦ | ↓ |
| | ស្រី | % | ៦៣,៦ | ៦២,៧ | ៦២,៣ | ↓ |
| ២. | អត្រាចូលរៀនកុមារអាយុ៤ឆ្នាំ(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៣៦,១ | ៤០,៦ | ៣២,៦ | ↓ |
| | ប្រុស | % | ៣៤,៥ | ៣៩,៥ | ៣០,០ | ↓ |
| | ស្រី | % | ៣៧,៨ | ៤១,៥ | ៣៤,១ | ↓ |
| ៣. | អត្រាចូលរៀនកុមារអាយុ៣ឆ្នាំ(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ១៤,១ | ២១,២ | ១២,១ | ↓ |
| | ប្រុស | % | ១៣,៤ | ២០,៣ | ១០,៣ | ↓ |
| | ស្រី | % | ១៤,៩ | ២២,២ | ១២,៩ | ↓ |
| ៤. | អត្រារួមនៃការសិក្សា(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៣៨,៤ | ៤១,៩ | ៣៤,៨ | ↓ |
| | ប្រុស | % | ៣៧,៣ | ៤១,៣ | ៣៣,១ | ↓ |
| | ស្រី | % | ៣៩,៤ | ៤៣,៨ | ៣៥,៩ | ↓ |
| ៥. | ភាគរយសាលាមត្តេយ្យសិក្សាមានអគ្គីសនី(មត្តេយ្យសិក្សារដ្ឋ) | % | ៤៥,១ | ៣៧,៣ | ៧៧,៩ | ↑ |
| ៦. | ភាគរយសាលាមត្តេយ្យសិក្សាមានកន្លែងលាងសម្អាតដៃស្តង់ដាអប្បបរមា(ម.សិក្សារដ្ឋដាច់ដោយឡែក) | | | | | |
| | កម្រិត១ | % | ២៣,៩ | ៤៤,២ | ៣៣,៧ | → |
| | កម្រិត២ | % | ២៧,២ | ២៧,២ | ៣៧,០ | ↑ |
| | កម្រិត៣ | % | ០,៥ | ១,៣ | ៣,៨ | ↑ |
| ៧. | ភាគរយសាលាមត្តេយ្យសិក្សាមាន(ម.សិក្សារដ្ឋដាច់ដោយឡែក) | | | | | |
| | បង្គន់អនាម័យ | % | ៩៦,៧ | ៥៦,៨ | ១០០ | ↑ |
| | ទឹកស្អាតសម្រាប់ទទួលទាន | % | ៩០,១ | ៤៤,១ | ៨៥,៣ | ↑ |
| | កន្លែងលាងដៃ | % | ៦៧,៦ | ៤៧,៥ | ៨៤,៤ | ↑ |
| | ប្រអប់សង្គ្រោះបឋម | % | ១២,២ | ១៧,៥ | ៤៤,១ | ↑ |
| វត្ថុបំណងអនុវិស័យទី២ ៖ លើកកម្ពស់គុណភាពសេវាសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដា | | | | | | |

| ល-រ | ការអប់រំកុមារតូច | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| ៨. | ភាគរយសាលាមត្តេយ្យសិក្សារដ្ឋសម្រេចបានតាមស្តង់ដាអប្បបរមា (ម.សិក្សារដ្ឋដាច់ដោយឡែក) | % | ១៣,៨៧ | ១៨,០ | ១៩,៩ | ↑ |
| ៩. | សាលាមត្តេយ្យសិក្សាសហគមន៍សម្រេចបានតាមស្តង់ដាអប្បបរមា | ចំនួន | ១ ០៥០ | ១ ១៤០ | ១ ២៥០ | ↑ |
| ១០. | ភាគរយសាលាមត្តេយ្យសិក្សារដ្ឋ និងសហគមន៍បានធ្វើតេស្ត សមត្ថភាពកុមារអាយុ៥ឆ្នាំ | % | ៥០,៥៧ | ៤៥,១ | ៦៧,១ | ↑ |
| ១១. | ភាគរយកុមារសាលាមត្តេយ្យសិក្សាទទួលបានអាហារូបត្ថម្ភ (ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៣៧,៦២ | ៣៦,០ | ៤១,៤ | ↑ |
| ១២. | ភាគរយគ្រូមត្តេយ្យសិក្សាមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ (រូបមន្ត១២+២) | % | ៦៦,០ | ៧០,០ | ៦៨,៩ | → |
| ១៣. | គ្រូបង្រៀនពហុភាសា | ចំនួន | ១១៦ | ១១៩ | ១២៣ | ↑ |
| ១៤. | ផលធៀបសិស្ស-គ្រូមត្តេយ្យសិក្សារដ្ឋ | ផលធៀប | ៤៣,១ | ៣១,០ | ៤២,០ | ↓ |
| គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| វត្ថុបំណងអនុវិស័យទី៣ ៖ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច | | | | | | |
| ១៥. | នាយកសាលាមត្តេយ្យសិក្សារដ្ឋទទួលបានការបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៣១ | ៥០ | ៤៣ | → |
| ១៦. | សាលាមត្តេយ្យសិក្សារដ្ឋបានអនុវត្តការគ្រប់គ្រងសាលារៀន | ចំនួន | ៤៣ | ៥៥ | ៤៣ | → |

*សម្គាល់:* ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា៖

- ការកំណត់គោលនយោបាយ គោលការណ៍ និងទិសដៅក្នុងការគ្រប់គ្រងតាមសាលារៀនសម្រាប់មត្តេយ្យសិក្សានៅមិនទាន់ច្បាស់លាស់
- យន្តការគាំទ្រសម្រាប់ការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ជាឧបសម្ព័ន្ធគ្រឹះស្ថានសិក្សាសាធារណៈនៅមានភាពខ្វះចន្លោះ
- ការវិនិយោគលើសេវាអប់រំកុមារតូចនៅមិនទាន់មានសមធម៌ និងបរិយាបន្ន ឆ្លើយតបទៅនឹងគោលដៅរួមនៃវិស័យអប់រំ
- កិច្ចសហការ និងសម្របសម្រួលក្នុងរចនាសម្ព័ន្ធគ្រប់គ្រងអន្តរវិស័យស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅមិនទាន់ប្រទាក់ក្រឡា។

## ២.២.២ អនុវិស័យ ការអប់រំបឋមសិក្សា

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០២០-២០២១ សាលាបឋមសិក្សាសាធារណៈមាន ៧ ៣០៤ កើន ២២ ធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០។ សាលារៀនមិនគ្រប់កម្រិតមាន ៣៨២ ថយ ៥៧។ សាលាបឋមសិក្សាឯកជនមាន ៥៣៩ នៅគ្រប់ខេត្តនិងរាជធានី។ ប្រកាសបើកគ្រឹះស្ថានសិក្សាសាធារណៈ ១ ៧៤៧ ក្នុងនោះសាលាបើកថ្មី ៣ និងទទួលស្គាល់គ្រឹះស្ថានសិក្សាឯកជន ៩៣។

សាលាសាធារណៈមានថ្នាក់រៀន ៦២ ៩៣៦ កើន ៥៣៤ និងបន្ទប់រៀន ៤៥ ៨០២ កើន ៥៤៨។

សិស្សបឋមសិក្សាសាធារណៈមាន ២ ០១០ ២៨៦នាក់ ស្រី ៩៦៤ ១៥២នាក់ ស្មើ ៤៨,០ភាគរយ ថយ ១៣ ១៨៧នាក់ ស្រីថយ ៥ ៩០១នាក់។ សិស្សបឋមសិក្សាឯកជនមាន ១១៨ ៤៣៦នាក់ ស្រី ៥៨ ៤៧៨នាក់ ស្មើ ៤៩,៤ភាគរយ ថយ ១៩ ២០១នាក់ ស្រីថយ ៩ ៥១៦នាក់។ អត្រាពិតចូលរៀនថ្មីសរុប ៨៧,៤ភាគរយ[1] ស្រី ៨៨,០ភាគរយ ថយ ៩,០ភាគរយ ស្រីថយ ៨,៣ភាគរយ ក្នុងនោះសាលាសាធារណៈ ៨២,៧ភាគរយ ស្រី ៨៣,៣ភាគរយ ថយ ៨,០ភាគរយ ស្រីថយ ៧,២ភាគរយ និងឯកជន ៤,៧ភាគរយ ស្រី ៤,៧ភាគរយ ថយ ១,០ភាគរយ ស្រីថយ ១,១ ភាគរយ។ អត្រាពិតនៃការសិក្សាសរុប ៩១,៩ភាគរយ ស្រី ៩២,៣ភាគរយ ថយ ៥,៤ភាគរយ ស្រីថយ ៥,៦ភាគរយ ក្នុងនោះសាលាសាធារណៈ ៨៦,៧ភាគរយ ស្រី ៨៧,០ភាគរយ ថយ ៤,៣ភាគរយ ស្រីថយ ៤,៤ភាគរយ និងឯកជន ៥,២ ភាគរយ ស្រី ៥,៣ភាគរយ ថយ ១,១ភាគរយ ស្រីថយ ១,២ភាគរយ។

*សិស្សថ្នាក់ទី១ចូលរៀនត្រូវតាមអាយុគួរឱ្យកត់សម្គាល់។ ប្រការនេះបញ្ជាក់ឱ្យឃើញថា ការវិនិយោគរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំទទួលបានផ្លែផ្កា ដោយផ្តល់ឱកាសដល់កូនចៅប្រជាជនមានកព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។*

បុគ្គលិកបឋមសិក្សាសាធារណៈ ៥៧ ៣០០នាក់ ស្រី ២៩ ៩៦០នាក់ ស្មើ ៥២,៣ភាគរយ ក្នុងនោះបុគ្គលិកបង្រៀន ៤៤ ៨៧៥នាក់ ស្រី ២៦ ១៨៩នាក់ ស្មើ ៥៨,៤ភាគរយ ថយ ៣៩នាក់ ស្រីកើន ២៦៧នាក់ គ្រូបង្រៀនពីរថ្នាក់ពីរពេល ១០ ២០០នាក់ ស្រី ៤ ៧៧២នាក់ គ្រូបង្រៀនថ្នាក់គួបពីរកម្រិត ២ ៦៦១នាក់ ស្រី ៩២០នាក់ និងគ្រូបង្រៀនថ្នាក់គួបបីកម្រិត ៩៤នាក់ ស្រី ១៣នាក់ និងគ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ ១១ ២៩១នាក់ ស្រី ៦ ៩៣៦នាក់។

*តម្រូវការគ្រូបង្រៀនប្រកបដោយគុណវុឌ្ឍិ នៅតែជាបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំបន្តបន្ទាប់។*

### ការអនុវត្តកម្មវិធី និងសកម្មភាពនានា

***ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ***

ក្រសួងបាន៖

- ផ្តល់ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ
    - ថវិកាជាតិ ៧៨ ៤០១ ៣៧២ ៩០០ រៀល អនុវត្តបាន ៧៨ ២១៤ ៥៨៧ ៤០០ រៀល ស្មើ ៩៩,៨ភាគរយ
    - ថវិកាដៃគូអភិវឌ្ឍ ១៤ ០០៦ ៧៣៤ ៨០០ រៀល អនុវត្តបាន ១០០ភាគរយ
- បណ្តុះបណ្តាលនីតិវិធីហិរញ្ញវត្ថុ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ ១ ០៥៥សាលា

---

*[1]-ចំនួនប្រជាជនសរុបអាយុ ៦ឆ្នាំ តាមជំរឿនប្រជាជនឆ្នាំ១៩៩៨-២០០៨ ។*

- ផ្តល់ថវិកាកម្មវិធីអាហារតាមសាលារៀនដោយប្រើកសិផលក្នុងសហគមន៍ ២០៥សាលា មានឥណទានថវិការដ្ឋ ៧ ០៧២ ៨៣២ ៤០០រៀល អនុវត្តបាន ៣ ៣២២ ៦៦៦ ៩៧០រៀល ស្មើ ៤៧ភាគរយ និង ១៨១ ០២៩ ៨៨០ រៀល ជាឥណទានរបស់ដៃគូអភិវឌ្ឍ សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- ផ្តល់ថវិកាកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក ២៩ ៥៧៥ ១០០ ០០០រៀល អនុវត្តបាន ២៩ ៣៣៤ ៧២០ ០០០រៀល ស្មើ ៩៩,២ភាគរយ
- លើកទឹកចិត្តឱ្យគ្រប់សាលារៀនទាំងអស់អនុវត្តការផ្ទេរសាច់ប្រាក់តាមប្រព័ន្ធធនាគារ
- ណែនាំឱ្យសាលារៀននីមួយៗរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងគ្រោងថវិកាប្រចាំឆ្នាំដែលរៀបចំផ្ទាល់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ រាល់ចំណូលដែលបានពីប្រភពនានា និងការចំណាយត្រូវចុះកិច្ចបញ្ជិកាគណនេយ្យតាមប្រព័ន្ធកុំព្យូទ័រប្រកបដោយគណនេយ្យភាព។ សាលារៀនមានតារាងតម្លាភាពបិទផ្សាយយ៉ាងទូលំទូលាយ។

*ប្រការនេះបានជំរុញឱ្យសាលារៀនកែលម្អប្រព័ន្ធគ្រប់គ្រងថវិកា ជាពិសេសស្វ័យភាពហិរញ្ញវត្ថុដោយផ្តោតលើផលសម្រេចនៃគោលនយោបាយសាលារៀន និងគុណភាពនៃការសិក្សារបស់សិស្សប្រកបដោយគណនេយ្យភាព។*

## *ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងផ្គត់ផ្គង់*

ក្រសួងបាន៖

- សង់អគារសិក្សាថ្មី ៣ខ្នង ២១បន្ទប់ បង្គន់អនាម័យ ៣ខ្នង ១៥បន្ទប់ អាងស្តុកទឹកឬអណ្តូងស្នប់ ៣ នៅខេត្តតាកែវ បន្ទាយមានជ័យ និងរាជធានី
- សង់អគារទីចាត់ការ ១ខ្នង ៣បន្ទប់ នៅសាលាបឋមសិក្សាពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ
- ជួសជុលអគារកែលម្អអគារសិក្សា ៣ខ្នង ២៥បន្ទប់ នៅខេត្តកណ្តាល និងរាជធានី
- ជួសជុលអគារកែលម្អអគារសិក្សា ២សាលា ២៨បន្ទប់ ឱ្យទៅជាសាលារៀនជំនាន់ថ្មី គឺសាលាបឋមសិក្សាអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម និងសាលាបឋមសិក្សា**សម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនីនាថសីហនុ** ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ
- ជួសជុលកែលម្អអគារសិក្សា ១០អគារ ក្នុងនោះ ៥អគារ នៅខេត្តព្រៃវែង ៥អគារ នៅខេត្តក្រចេះ និងបណ្ណាល័យ ៨ អគារ ក្នុងនោះ ៣អគារ នៅខេត្តព្រៃវែង ៥អគារ នៅខេត្តក្រចេះ សហការជាមួយអង្គការឆាលហ្វានកម្ពុជា
- សាងសង់អគារសិក្សាថ្មី ៥ខ្នង មានគ្រឿងសង្ហារិម ក្នុងនោះ ២ខ្នង នៅខេត្តបាត់ដំបង ២ខ្នង នៅខេត្តក្រចេះ ១ខ្នង នៅខេត្តព្រៃវែង សហការជាមួយអង្គការឆាលហ្វានកម្ពុជា
- សាងសង់អគារបណ្ណាល័យថ្មី និងបំពាក់សៀវភៅអាន ល្បែងសិក្សា មានគ្រឿងសង្ហារិម ៨អគារ ក្នុងនោះ ១អគារ នៅខេត្តបាតដំបង និង ៧អគារ នៅខេត្តក្រចេះ សហការជាមួយអង្គការឆាលហ្វានកម្ពុជា
- សង់ផ្ទះបាយស្តង់ដា ៣ខ្នង និងកន្លែងសិស្សទទួលទានអាហារស្តង់ដា ៣ខ្នង នៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ និងកម្មវិធីស្បៀងអាហារពិភពលោក
- ផ្គត់ផ្គង់សម្ភារបរិក្ខាររដ្ឋបាលសាលារៀនដល់គ្រឹះស្ថានសិក្សា ១០៨ រួមមានកុំព្យូទ័រ ៥១គ្រឿង ព្រីនធ័រ ៩៨ គ្រឿង ម៉ាស៊ីនថតចម្លង ២៥គ្រឿង និងទូដាក់ឯកសារ ១៣៨គ្រឿង
- ផ្តល់កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង ៥៨០ ៦៥៧ ដល់ ២ ៣០០សាលា នៅខេត្តសៀមរាប បាត់ដំបង កំពង់ធំ កំពត ព្រះវិហារ ឧត្តរមានជ័យ ស្ទឹងត្រែង និងក្រចេះ
- បំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុកការងារទ្រព្យសម្បត្តិរដ្ឋស្តីពី ការងារទ្រព្យសម្បត្តិរដ្ឋ មានអ្នកចូលរួម ២៣៧នាក់ ស្រី ៤៣នាក់ នៅថ្នាក់កណ្តាល ខេត្ត និងរាជធានី
- ពិនិត្យទ្រព្យសម្បត្តិរដ្ឋ ២២៥សាលា នៅខេត្តព្រះវិហារ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី និងកំពង់ធំ

- ផលិតសៀវភៅណែនាំគ្រូបង្រៀន ៦ ២៧៩ក្បាល និងចែកចាយកញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ទី១ និងទី២ ដល់នាយកសាលា គ្រូបង្រៀន និងសិស្ស ក្នុងនោះសម្ភារបង្រៀននិងរៀន ២ ៥៥០ឈុត សៀវភៅលំហាត់ ៣៤ ១៥៥ក្បាល សៀវភៅកិច្ចការសិស្ស ១២៣ ៣៧២ក្បាល នៅខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ ក្រចេះ និងស្ទឹងត្រែង សហការជាមួយគម្រោងពង្រឹងកម្មវិធីការអប់រំគ្រូបង្រៀននៅកម្ពុជា និងអង្គការយូណេស្កូ
- ផលិតសៀវភៅណែនាំប្រតិបត្តិស្តីពីការប្រឹក្សាគរុកោសល្យថ្នាក់ដំបូង ២ ២០០ក្បាល និងចែកចាយដល់ទីប្រឹក្សាគរុកោសល្យជំនាញ ទីប្រឹក្សាគរុកោសល្យតាមសាលារៀន សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- ផលិតនិងចែកចាយសៀវភៅភាសាខ្មែរថ្នាក់ទី២ ដល់នាយកសាលា គ្រូ និងសិស្ស ក្នុងនោះ សៀវភៅណែនាំគ្រូ ២ ៣១០ក្បាល សៀវភៅជំនួយសិស្ស ៣ ៤០០ឈុត សៀវភៅអាន ៧៧ ០០០ក្បាល នៅខេត្តព្រះវិហារ ក្រចេះ ឧត្តរមានជ័យ និងស្ទឹងត្រែង សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- ផលិតកញ្ចប់សៀវភៅលំហាត់កូនស្វាឆ្លាតមុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១ (សៀវភៅក្រុម គ មាន៤ក្បាល) និងទី២ (សៀវភៅក្រុម ន មាន៤ក្បាល) សហការជាមួយគម្រោងអភិវឌ្ឍន៍សមត្ថភាពអប់រំរបស់អង្គការយូណេស្កូ និងវិទ្យាស្ថានបើកទូលាយ។

*ប្រការនេះ សបញ្ជាក់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍក្នុងការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធសាលារៀនដើម្បីបង្កើនការចូលរៀនរបស់សិស្ស។*

### *កម្មវិធីសាលាកុមារមេត្រី*

ក្រសួងបាន៖

- ទទួលស្គាល់សាលាកុមារមេត្រីកម្រិតមធ្យមនិងកម្រិតអភិវឌ្ឍស្របតាមលក្ខណៈវិនិច្ឆ័យប្រព័ន្ធឌីជីថល ៥ ៤២៤ សាលា
- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រី មកពីគ្រប់ខេត្តនិងរាជធានី មានអ្នកចូលរួម ១៥៣នាក់ ស្រី ៣២នាក់ នៅខេត្តព្រៃវែង
- អនុវត្តកម្មវិធីសាលាកុមារមេត្រី នៅក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ប្រើប្រាស់កម្មវិធី App វាយតម្លៃសាលាកុមារមេត្រីនិងផែនការយុទ្ធសាស្ត្រ
- បំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់វិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ នាយកសាលា និងគ្រូ ក្នុងនោះ ៦ស្រុក ២៨៨សាលា នាយកសាលា ៣៩២នាក់ និងគ្រូបង្រៀន ២ ១៥៤នាក់ នៅខេត្តបាត់ដំបង កំពត និងព្រៃវែង សហការជាមួយអង្គការយូនីសេហ្វ
- បោះពុម្ពសៀវភៅវិន័យបែបវិជ្ជមានសម្រាប់គ្រូនិងនាយកសាលា ៧ ៩៩០ក្បាល
- រៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី ការប្រើប្រាស់ស្វ័យវាយតម្លៃសាលារៀនកម្មវិធីសាលាកុមារមេត្រី ដើម្បីធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនតាមប្រព័ន្ធអ៊ីនធឺណិត (លើគេហទំព័រ) មានអ្នកចូលរួម ៣៩២នាក់ ស្រី ៦៨នាក់ នៅខេត្តស្ទឹងត្រែង ក្រចេះ កំពង់ធំ កំពង់ចាម បាត់ដំបង ពោធិ៍សាត់ កោះកុង ព្រះសីហនុ ព្រៃវែង បន្ទាយមានជ័យ សៀមរាប ស្វាយរៀង កំពង់ឆ្នាំង កំពត និងតាកែវ សហការជាមួយអង្គការយូនីសេហ្វ
- រៀបចំសេចក្តីណែនាំស្តីពីកិច្ចការពារកុមារនៅតាមសាលារៀន(កំពុងអនុវត្តសាកល្បងនៅតាមសាលាគោលដៅ) សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា ឆាលហ្វានកម្ពុជា វើលវីហ្សិន ភ្លែនអន្តរជាតិកម្ពុជា និងយូនីសេហ្វ។

*ប្រការនេះ បង្ហាញថា ក្រសួងបានផ្តោតការយកចិត្តទុកដាក់លើសិទ្ធិកុមារ ជាពិសេសសុខសុវត្ថិភាពនិងកិច្ចការពារកុមារនៅសាលារៀនប្រកបដោយសមធម៌។*

## *សាលារៀនជំនាន់ថ្មី*

ក្រសួងបាន៖

- សហការជាមួយដៃគូអភិវឌ្ឍ ដើម្បីអនុវត្តនៅសាលាបឋមសិក្សាអនុវត្ត **ហ៊ុន សែន** ក្រុងកំពង់ចាម ខេត្តកំពង់ចាម សាលាបឋមសិក្សាស្វាយព្រហូត ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាលាបឋមសិក្សាអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម និងសាលាបឋមសិក្សា **សម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនីនាថសីហនុ** ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- បំប៉នសមត្ថភាពស្តីពី ស្តង់ដាអំណាន ការសិក្សាតាមបែបស្ថាបនានិយម ការសិក្សាបែបសហការ ការប្រើប្រាស់កម្រិតសំណួរ ការបង្រៀននិងរៀន កម្មវិធីថេបប្លេតការបង្រៀនភាសាខ្មែរ និងគណិតវិទ្យា ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ គ្រូបង្វឹកអំណាន និងគន្លងអាជីពដល់នាយកសាលា និងគ្រូបង្រៀន ១០៥នាក់ ស្រី ៥៨នាក់ នៅខេត្តកំពង់ស្ពឺ កំពង់ចាម និងស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀននិងការប្រើប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូង ដល់នាយកសាលា និងគ្រូបង្រៀន ១០៥នាក់ ស្រី ៥៨នាក់ នៅខេត្តកំពង់ស្ពឺ កំពង់ចាម និងស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀន ភ្លឺបមុខវិជ្ជា និងបំណិនជីវិត ដើម្បីបញ្ជ្រាបក្នុងការសិក្សាដល់គ្រូ ១០៥នាក់ ស្រី ៥៨នាក់ នៅខេត្តកំពង់ស្ពឺ កំពង់ចាម និងស្វាយរៀង
- ជួសជុលអគារសិក្សា ៣២បន្ទប់ រៀបចំបណ្ណាល័យ ២បន្ទប់ ផ្តល់ថេបប្លេត ៦០គ្រឿង ផ្តល់សម្ភារឧបទេស ៥៨ឈុត ផ្តល់អិលស៊ីឌី ១០គ្រឿង ផ្តល់ទូរទស្សន៍ ៣គ្រឿង នៅបណ្ណាល័យ បំពាក់កាមេរ៉ាសុវត្ថិភាពតាមអគារសិក្សា បណ្ណាល័យ និងទីចាត់ការ ដល់សាលាបឋមសិក្សាអង្គរបាននិងសាលាបឋមសិក្សា **សម្តេចព្រះរាជអគ្គមហេសីនរោត្តមមុនីនាថសីហនុ** នៅខេត្តកំពង់ចាម និងកំពង់ស្ពឺ។

សាលាបឋមសិក្សាទាំង ៤ ខាងលើ មានសិស្ស ២ ១៨៤នាក់ ស្រី ១ ០៧៤នាក់។

*ការអនុវត្តសាលារៀនជំនាន់ថ្មីកន្លងមក បានឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំស្របតាមបរិបទថ្មី។*

## *ការរៀន និងបង្រៀនពេញមួយថ្ងៃនៅបឋមសិក្សា*

ក្រសួងបាន៖

- ប្រកាសស្តីពី ការទទួលស្គាល់គ្រូបង្រៀនពេញមួយថ្ងៃ នៅសាលាបឋមសិក្សាគោកគ្រើល ត្រពាំងស្វាយ និងដូនឪ នៅស្រុកអង្គរធំ ខេត្តសៀមរាប និងសាលាបឋមសិក្សាអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម
- អនុវត្តសាកល្បងការបង្រៀននិងរៀនពេញមួយថ្ងៃ នៅសាលាបឋមសិក្សាដូនឪ ត្រពាំងស្វាយ និងគោកគ្រើល ខេត្តសៀមរាប និងសាលាបឋមសិក្សាអង្គរបាន ខេត្តកំពង់ចាម តាមរយៈការផ្តល់អាហារថ្ងៃត្រង់សម្រាប់សិស្ស
- អនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃ ដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌របស់មាតាបិតាសិស្ស ឬអ្នកអាណាព្យាបាលសិស្ស នៅសាលាបឋមសិក្សាគំរូក្រុង និងសាលាបឋមសិក្សាគិរីសុវណ្ណវង្ស ខេត្តកំពង់ឆ្នាំង និងសាលាបឋមសិក្សាអនុវត្តក្រុងព្រះវិហារ និងសាលាបឋមសិក្សារុងរឿង ខេត្តព្រះវិហារ
- ពិនិត្យតាមដានដំណើរការបង្រៀន និងរៀនឡើងវិញដំណាក់កាលទី២ របស់សាលារៀនពេញមួយថ្ងៃ និងធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី១ ទី៣ និងទី៦ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា នៅខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រះវិហារ និងសៀមរាប
- ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមលើបៀវត្សរ៍ ៦០ភាគរយ ក្នុងមួយខែ ដល់សាលារៀនអនុវត្តសាកល្បងការបង្រៀន និងរៀនពេញមួយថ្ងៃ និងផ្តល់កញ្ចប់ថវិកាគាំទ្រដំណើរការ ២០ លានរៀល ក្នុងមួយសាលាក្នុងមួយឆ្នាំ នៅខេត្តសៀមរាប និងកំពង់ចាម។

សាលាបឋមសិក្សាទាំង៨ ខាងលើ មានសិស្ស ៥ ២៣៦នាក់ ស្រី ២ ៥០១នាក់។

*ប្រការនេះ បានបង្កើនម៉ោងសិក្សា និងជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សប្រកបដោយគុណភាពដោយមានការចូលរួម និងគាំទ្រពីសហគមន៍។*

## ***ការគ្រប់គ្រងតាមសាលារៀន***

ក្រសួងបាន៖

- បំប៉នសមត្ថភាពស្តីពី ការគ្រប់គ្រងតាមសាលារៀន ដល់គ្រូបង្គោលថ្នាក់ជាតិ ដើម្បីចុះជួយដល់សាលាគោលដៅ ១៦០សាលា ថែមទៀត ក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ការធ្វើតេស្តវាយតម្លៃការសិក្សាសិស្ស និងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន មានអ្នកចូលរួម ១៣០នាក់ ស្រី ២៤នាក់ នៅខេត្តសៀមរាប
- បំប៉នសមត្ថភាពស្តីពី កម្រងសំណួរពាក់ព័ន្ធនឹងការសិក្សារបស់សិស្ស មានអ្នកចូលរួម ៨១នាក់ ស្រី ៧នាក់ នៅខេត្តឧត្តរមានជ័យ
- ហ្វឹកហាត់ការដល់គណៈកម្មការគ្រប់គ្រងសាលារៀន ១៥ស្រុក ២៤សាលា មានអ្នកចូលរួម ៣៤៧នាក់ ស្រី ៩៣នាក់ នៅខេត្តបាត់ដំបង សៀមរាប កំពង់ធំ ព្រះវិហារ និងឧត្តរមានជ័យ
- រៀបចំផែនការសកម្មភាព និងគ្រោងថវិកាជួននិងដៃគូអភិវឌ្ឍន៍ សម្រាប់ពង្រីកគោលដៅអនុវត្តក្នុងឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់ នៅគ្រប់ខេត្ត និងរាជធានី
- រៀបចំក្រុមការងារទីប្រឹក្សាការគ្រប់គ្រងសាលារៀន ដែលមានសមាសភាពបុគ្គលិកអប់រំថ្នាក់ជាតិ និងក្រោមជាតិ មានអ្នកចូលរួម ៥៨៧នាក់ ស្រី ៨៤នាក់ នៅគ្រប់ខេត្ត និងរាជធានី
- ចងក្រងឯកសារណែនាំស្តីពី ការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន ដើម្បីពិនិត្យខ្លឹមសារ និងផ្តល់ធាតុចូលមុនបោះពុម្ពផ្សព្វផ្សាយ
- បំប៉នសមត្ថភាពស្តីពី ការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថានដល់មន្ត្រីថ្នាក់ជាតិ និងគណៈគ្រប់គ្រងសាលារៀន មានអ្នកចូលរួម ៦៤នាក់ ស្រី ១០នាក់
- បំប៉នសមត្ថភាពស្តីពី ការត្រួតពិនិត្យវឌ្ឍនភាព ការវាយតម្លៃគ្រូឧទ្ទេស ដល់គណៈគ្រប់គ្រងសាលារៀន មជ្ឈមណ្ឌលគរុកោសល្យ និងសាលាគរុកោសល្យ មានអ្នកចូលរួម ៣៤នាក់ ស្រី ៨នាក់
- បំប៉នសមត្ថភាពស្តីពី បំណិនបង្វឹកផ្ទាល់ ការវាយតម្លៃគ្រូបង្រៀន ដល់ក្រុមបំប៉ន និងពិនិត្យតាមដានមន្ត្រីមន្ទីរអប់រំ ការិយាល័យអប់រំ និងគណៈគ្រប់គ្រងសាលារៀន មជ្ឈមណ្ឌលគរុកោសល្យ និងសាលាគរុកោសល្យ មានអ្នកចូលរួម ៦១នាក់ ស្រី ១២នាក់
- រៀបចំប្រជុំចែករំលែកបទពិសោធទាក់ទងនឹងការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន ពីសាលាដែលទទួលពានរង្វាន់សាលាមេត្រីបរិស្ថាន ដល់គណៈគ្រប់គ្រងរៀន មជ្ឈមណ្ឌលគរុកោសល្យ និងសាលាគរុកោសល្យ មានអ្នកចូលរួម ២២នាក់ ស្រី ៦នាក់
- បំប៉នសមត្ថភាពស្តីពី ភាពជាអ្នកដឹកនាំដែលឆ្លើយតបនឹងសមភាពយេនឌ័រ ដល់គ្រូឧទ្ទេស គណៈគ្រប់គ្រងសាលារៀន មជ្ឈមណ្ឌលគរុកោសល្យ និងសាលាគរុកោសល្យ មានអ្នកចូលរួម ៤០នាក់ ស្រី ១១នាក់
- ផ្តល់ថវិកាខ្នាតតូចសម្រាប់អនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន ១៣សាលា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ២ និងសាលាគរុកោសល្យនិងក្រឹតការ២
- ប្រារព្ធទិវាបរិស្ថានពិភពលោកតាមប្រព័ន្ធបណ្តាញសង្គម តាមរយៈវីដេអូផ្សព្វផ្សាយស្តីពី ការធ្វើឱ្យសាលាក្លាយជាសាលាមេត្រីបរិស្ថាន និងការចងក្រងខ្លឹមសារសម្រាប់ដាក់បញ្ចូលក្នុងឈុតសម្ភារៈផ្សព្វផ្សាយសាលាមេត្រីបរិស្ថាន មានអ្នកចូលរួម ១៨នាក់ ស្រី ២នាក់

- ប្រជុំឆ្លុះបញ្ចាំងស្តីពី ការវាយតម្លៃគ្រូបង្រៀន គ្រូឧទ្ទេស យេនឌ័រ និងសាលាមេត្រីបរិស្ថាន ដល់គណៈគ្រប់គ្រងមជ្ឈមណ្ឌល និងពិនិត្យទម្រង់វាយតម្លៃគ្រូបង្រៀន គ្រូឧទ្ទេស ដល់ក្រុមធានាគុណភាពផ្ទៃក្នុងរបស់គណៈគ្រប់គ្រងមជ្ឈមណ្ឌល និងសាលាគរុកោសល្យ មានអ្នកចូលរួម ១៨នាក់ ស្រី ៧នាក់
- ពង្រឹងគុណភាពអប់រំនិងបរិស្ថាន និងស្វ័យវាយតម្លៃសាលារៀន ៥០សាលា ដល់នាយកសាលា គ្រូបង្រៀន និងសហគមន៍ ១ ៩១២នាក់ ស្រី ១ ១៧៨នាក់ និងរៀបចំគណៈកម្មការគ្រប់គ្រងសាលារៀន ៦៧គណៈកម្មការ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- កែសម្រួលសូចនាករនៃកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ដើម្បីអនុវត្តផែនការគណនេយ្យភាពសង្គមដំណាក់កាលទី២ (២០១៩-២០២៣)
- ដាក់ឱ្យអនុវត្តគម្រោងគាំទ្រផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ និងយុទ្ធនាការផ្សព្វផ្សាយការងារគណនេយ្យភាពសង្គម
- បង្កើនល្បឿនកែទម្រង់អភិបាលកិច្ច តាមរយៈការធ្វើវិមជ្ឈការអំណាចទៅមូលដ្ឋាន ដើម្បីឱ្យសេវាសាធារណៈបម្រើទាន់ពេលវេលានូវប្រយោជន៍ប្រសើរបំផុត សម្រាប់ប្រជាជន និងការកសាងជាតិ
- អនុវត្តការធ្វើវិមជ្ឈការអំណាចទៅសាលារៀន ដើម្បីធានាថាកុមារ និងយុវជនបានចូលរៀនទាំងអស់ សិស្សរៀនមានសមត្ថភាពល្អ និងល្អប្រសើរ បន្តរៀនរហូតចប់ភូមិសិក្សា និងមានសមត្ថភាពរកចំណូល
- ពង្រឹងកម្មវិធីការគ្រប់គ្រងតាមសាលារៀន គឺជាការផ្ទេរអំណាចពីថ្នាក់កណ្តាលទៅសាលារៀននិងសហគមន៍ ព្រោះគាត់ជាអ្នកដឹងបញ្ហាពិតប្រាកដ ក្នុងនោះការអនុវត្តការគ្រប់គ្រងតាមសាលារៀន នឹងនាំឱ្យសាលារៀន និងសហគមន៍ជាអ្នករៀបរៀងគោលនយោបាយ ការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហា ការសិក្សារបស់សិស្សឱ្យបានទាន់ពេលវេលា និងអភិវឌ្ឍសាលារៀនដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននៅតាមមូលដ្ឋាន ការរកចំណូលការសម្រេចចិត្តចំណាយសម្រាប់លទ្ធផលសិក្សារបស់សិស្ស ការអភិវឌ្ឍសាលារៀន ការប្រើចំណូលក្នុងការថែរក្សា ការកសាងសមត្ថភាពគ្រូបង្រៀន និងនាយកសាលាមានសមត្ថភាពធ្វើការដូចនៅប្រទេសជឿនលឿន
- បំប៉នសមត្ថភាពស្តីពី ការស្វ័យវាយតម្លៃសាលារៀនតាមបែបការចូលរួម ដោយប្រើប្រាស់ឧបករណ៍ក្របខណ្ឌសិក្សាប្រកបដោយគុណភាព ដល់នាយកសាលា គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាកុមារ និងសហគមន៍ មានអ្នកចូលរួម ២១២៥ នាក់ ស្រី ១០៤១នាក់ នៅខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង ពោធិសាត់ និងកោះកុង សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- រៀបចំគណៈកម្មការអភិវឌ្ឍន៍សាលារៀន ៧០សាលា លើ ៧០សាលាគោលដៅរបស់គម្រោង សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- រៀបចំ ២៣៦គណៈកម្មការថ្នាក់រៀន ដើម្បីជួយសាលារៀន និងបំពាក់កង្ហារ ទិញខ្សែភ្លើង រៀបចំកម្រាលថ្នាក់រៀន ៦៥ថ្នាក់ ម៉ាស់ ៥ប្រអប់ ទឹកអាល់កុល ២១៦លីត្រ ម៉ាស់ក្រណាត់ ៧០ និងឧបករណ៍វាស់កំដៅ ៣ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- រៀបចំបញ្ជីកុមារខ្ចីសៀវភៅ និងកត់ត្រាចំនួនកុមារចូលអានជាដើម និងបណ្ណាល័យ២០ត្រូវបានកែលម្អ ដោយមានបន្ថែម សៀវភៅរឿងថ្មីជាច្រើន សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា។

*ប្រការនេះ បានជួយពង្រឹងស្វ័យភាពសាលារៀន ការចូលរួមរបស់សហគមន៍ និងគណនេយ្យភាព និងលទ្ធផលសិក្សារបស់សិស្ស។*

## *ការពង្រឹងវិធីសាស្ត្របង្រៀននិងរៀន*

ក្រសួងបានបំប៉នសមត្ថភាពស្តីពី៖

- វិធីសាស្ត្របង្រៀននិងការប្រើប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ទី១ ឆមាសទី២ ដល់នាយកសាលា គ្រូគាំទ្របច្ចេកទេស និងគ្រូបង្រៀនថ្នាក់ទី១ ចំនួន ២៦២នាក់ ស្រី ១៣២នាក់ ក្នុងដំណាក់កាលសាកល្បងខេត្តសៀមរាប សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា និងអង្គការយូណេស្កូ
- វិធីសាស្ត្របង្រៀននិងការប្រើប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ទី២ ឆមាសទី១ ដល់គ្រូគាំទ្របច្ចេកទេស និងគ្រូបង្រៀនថ្នាក់ទី២ ចំនួន ១៦៧នាក់ ស្រី ១០៦នាក់ ក្នុងដំណាក់កាលសាកល្បង ខេត្តសៀមរាប សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា និងអង្គការយូណេស្កូ
- វិធីសាស្ត្របង្រៀននិងការប្រើប្រាស់កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ទី១ ឆមាសទី១ ដល់នាយកសាលា គ្រូគាំទ្របច្ចេកទេស និងគ្រូបង្រៀនថ្នាក់ទី១ ចំនួន ៩៨១នាក់ ស្រី ៨៦៣នាក់ ខេត្តសៀមរាប សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា និងអង្គការយូណេស្កូ
- វិធីសាស្ត្របង្រៀនគណិតវិទ្យាថ្នាក់ទី១ ដល់ទី៦ ដល់ក្រុមគ្រូបង្គោលថ្នាក់ជាតិគណិតវិទ្យា ៩នាក់ ស្រី ១នាក់ និងចងក្រងវិធីសាស្ត្រលើផ្នែករង្វាស់រង្វាល់ ធរណីមាត្រ តាមរយៈកម្មវិធីលើកកម្ពស់លទ្ធផលសិក្សាគណិតវិទ្យា និងការបង្រៀន(ស្មាត) សហការជាមួយអង្គការវីអូប៊ី
- ការសាកល្បងសេចក្តីព្រាងវិធីសាស្ត្របង្រៀនគណិតវិទ្យាផ្នែកចំនួន ១១សាលា ដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ៩៨នាក់ ស្រី ៧៧នាក់ នៅខេត្តបាត់ដំបង សហការជាមួយអង្គការវីអូប៊ី
- ការកែលម្អកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង មានអ្នកចូលរួម ១១៣នាក់ ស្រី ៩១នាក់ នៅរាជធានី សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា
- ការប្រើប្រាស់កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងសម្រាប់ថ្នាក់ទី១ និងទី២ ដល់គ្រូបង្រៀន គ្រូឧទ្ទេសថ្នាក់ជាតិ នាយកសាលា និងអ្នកពាក់ព័ន្ធ និងនៅតាមបណ្តាស្រុកនៃខេត្តមួយចំនួនទៀត ក្រោមកម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិនិងការសិក្សាកម្រិតថ្នាក់ដំបូង មានអ្នកចូលរួម ៦ ៧០៧នាក់ ស្រី ៣ ៨៦៥នាក់ នៅគ្រប់សាលាបឋមសិក្សាទាំងអស់ក្នុងខេត្តកំពត ក្រចេះ កំពង់ធំ ស្ទឹងត្រែង សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ សហការជាមួយទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិសហរដ្ឋអាមេរិក គម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា អង្គការយូណេស្កូ អប់រំពិភពលោក សង្គ្រោះកុមារកម្ពុជា រូមធូរីដ និងទស្សនពិភពលោក
- ការបង្វឹកអំណានចុះជួយគ្រូលើការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង ៦៨ស្រុក ២ ៣០០សាលា មានអ្នកចូលរួម ២៦៧នាក់ ស្រី ៩៣នាក់ នៅសៀមរាប បាត់ដំបង កំពង់ធំ កំពត ព្រះវិហារ ឧត្តរមានជ័យ ក្រចេះ និងស្ទឹងត្រែង
- ការពិគ្រោះយោបល់សេចក្តីព្រាងស្តីពី ការប្រឹក្សាគរុកោសល្យថ្នាក់ដំបូង មានអ្នកចូលរួម ៧៣នាក់ ស្រី ៤៥នាក់ នៅខេត្តកំពង់ចាម ព្រះវិហារ ក្រចេះ ស្ទឹងត្រែង និងសៀមរាប សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា
- ការប្រឹក្សាគរុកោសល្យថ្នាក់ដំបូង ដល់គ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីបំប៉នបន្តដល់ទីប្រឹក្សាគរុកោសល្យជំនាញ និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀន មានអ្នកចូលរួម ២ ២០៥នាក់ ស្រី ១ ១៥៥នាក់ នៅខេត្តកំពង់ចាម ក្រចេះ ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង កំពង់ធំ និងសៀមរាប សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា អង្គការយូណេស្កូ និងយូនីសេហ្វ
- ការអនុវត្តកម្មវិធីកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងនិងគណិតវិទ្យាថ្នាក់ដំបូង ៣៩សាលា ៤ស្រុក នៅខេត្តបាត់ដំបង និងព្រៃវែង សហការជាមួយអង្គការឆាលហ្វានកម្ពុជា
- ការគាំទ្របច្ចេកទេសវិធីសាស្ត្របង្រៀនគណិតវិទ្យា វិធីផលិតនិងប្រើប្រាស់សម្ភារឧបទេស ១៦សាលា គ្រូបង្រៀន ១១៨នាក់ ស្រី ៨១នាក់ សិស្ស ២ ៦៩៥នាក់ ស្រី ១ ៣១៧នាក់ នៅខេត្តកោះកុង សហការជាមួយអង្គការវីអូប៊ី

- បំណិនគាំទ្រផ្នែកបច្ចេកទេស តាមរយៈកម្មវិធីលើកកម្ពស់លទ្ធផលសិក្សាគណិតវិទ្យា និងការបង្រៀន(ស្មាត) និងប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន ដោយផ្តោតលើការញែកភាពខុសគ្នា ការបែងចែកក្រុមមានភាពបត់បែន និងវិន័យបែបវិជ្ជមាន ដល់គណៈគ្រប់គ្រងសាលារៀន ១៩នាក់ ស្រី ៧នាក់ និងគ្រូបង្រៀន ១៧០នាក់ ស្រី ៩៣នាក់ ចងក្រងឯកសារប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀនដោយផ្តោតលើប្រធានបទ៥ៈ ការញែកភាពខុសគ្នា ការបែងចែកក្រុមមានភាពបត់បែន វិន័យបែបវិជ្ជមាន ការគ្រប់គ្រងពេលវេលា និងការគ្រប់គ្រងទីតាំងបង្រៀននិងរៀន នៅខេត្តកំពង់ចាម និងកណ្តាល សហការជាមួយអង្គការវីអ៊ែប៊ី
- ប្រព័ន្ធតាមដានការសិក្សារបស់សិស្ស ដល់នាយកសាលា និងគ្រូបង្រៀន ២៦៤នាក់ ស្រី ១១៥នាក់ នៅខេត្តសៀមរាប សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- ចេញសេចក្តីណែនាំស្តីពី ការធ្វើតេស្តស្តង់ដាប្រចាំខែ ១០០ច្បាប់ ដល់នាយកដ្ឋាន និងមន្ទីរអប់រំ យុវជន និងកីឡា នៅគ្រប់ខេត្តនិងរាជធានី សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- បង្កើតក្លិបសិក្សា ២០កន្លែង ផ្តល់បដិភាគជាថវិកាពីសហគមន៍ ១ ៥០០ដុល្លារ ដល់សិស្ស ២ ៦៧១នាក់ ស្រី ១ ៥០៦នាក់ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា។

*ប្រការនេះ បានបង្ហាញថាមូលដ្ឋានគ្រឹះបឋមសិក្សាត្រូវបានពង្រឹងតាមរយៈការសិក្សាភាសាខ្មែរ (អាន-សរសេរ) និងគណិតវិទ្យាថ្នាក់ដំបូង សំដៅជួយលើកកម្ពស់គុណភាពអប់រំនិងលទ្ធផលសិក្សារបស់សិស្ស។*

## ***កម្មវិធីអប់រំបរិយាបន្ន***

### ការអប់រំពហុភាសា

ក្រសួងបានៈ

- អនុវត្តកម្មវិធីអប់រំពហុភាសា ៨៧សាលា ១៥ស្រុក គ្រូបង្រៀន ២៣១នាក់ ស្រី ៨៤នាក់ សិស្ស ៤ ៧៦៥នាក់ ស្រី ២ ៣៦០នាក់ នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង
- រៀបចំសុំផ្លាស់ប្តូរ និងបន្ថែមអក្ខរក្រមមួយចំនួន ដើម្បីបំពេញតម្រូវការនៃការប្រើប្រាស់ក្នុងភាសាទំពួន គ្រឹង ព្រៅ ព្នង និងការ៉ែត និងផ្តល់សៀវភៅមគ្គុទេសក៍គ្រូថ្នាក់ទី១ ដល់ទី៣ មាន ២០៤ក្បាល ដល់គ្រូបង្រៀនថ្នាក់អប់រំពហុភាសា នៅខេត្តរតនគិរី និងក្រចេះ សហការជាមួយអង្គការអោយស៊ីស៊ី
- បំប៉នវិធីសាស្ត្របង្រៀនថ្នាក់អប់រំពហុភាសា ដល់អ្នកពាក់ព័ន្ធ និងគ្រូបង្រៀន ១២៦នាក់ ស្រី ២៩នាក់ និងបំប៉នវិធីសាស្ត្របង្រៀនអំណាន សំណេរ កិច្ចតែងការបង្រៀន និងការគ្រប់គ្រង់ថ្នាក់រៀនដល់គ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ១៤៥នាក់ ស្រី ៤៨នាក់ នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង សហការជាមួយអង្គការយូនីសេហ្វ
- បោះពុម្ពសៀវភៅសិក្សាគោលអប់រំពហុភាសាថ្នាក់ទី១ដល់ទី៣ ជាភាសាព្នង និងភាសាគ្រឹង ៣៦ ៨៩៦ក្បាល
- ផលិតឃ្លីបសំឡេងការបង្រៀនកម្មវិធីអប់រំពហុភាសាពីថ្នាក់ទី១ ដល់ទី៣ មាន ៤៦៨ឃ្លីប ក្នុងនោះជាភាសាព្នង ១៨០ឃ្លីប គ្រឹង ១៤៤ឃ្លីប និងទំពួន ១៤៤ឃ្លីប នៅខេត្តរតនគិរី និងមណ្ឌលគិរី សហការជាមួយអង្គការយូនីសេហ្វ
- ចាក់ផ្សាយ និងផ្សាយឡើងវិញឃ្លីបសំឡេងការបង្រៀនកម្មវិធីអប់រំពហុភាសា ជាភាសាទំពួន គ្រឹង និងព្នង នៅ៤ស្ថានីយវិទ្យុផ្សាយសំឡេង និងចែកសន្លឹកកិច្ចការដល់សិស្សអប់រំពហុភាសាថ្នាក់ទី១ ដល់ទី៣ នៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែងនិងក្រចេះ សហការជាមួយអង្គការយូនីសេហ្វ ឃែរកម្ពុជា អេដអេអាក់ស្យុង និងផ្លែនអន្តរជាតិកម្ពុជា
- ផ្តល់សម្ភារសិក្សាពីចម្ងាយដល់សិស្សអប់រំពហុភាសាថ្នាក់ទី១ ដល់ទី៣ រួមមានវិទ្យុ ៤ ១០៦គ្រឿង សៀវភៅផាត់ពណ៌រូបភាព គូល័រឈើ ខ្មៅដៃ ជ័រលុប ប្រដាប់ខួង ម៉ាស សាប៊ូ ៤ ១០៦ឃីត សម្ភារៈដាក់ឯកសារ ១៤៥ឈុត ទូរទស្សន៍ស្មាតធីវីទំហំ ៤២អ៊ីង ៧គ្រឿង បណ្ណាល័យឌីជីថល ៧គ្រឿង ធុងលាងដៃ ៤០ធុង ឧបករណ៍

ថ្នេសម្រាប់លាងដៃ ៤០០ទុយោ នៅខេត្តរតនគិរី មណ្ឌលគិរី និងក្រចេះ សហការជាមួយអង្គការអេដអេអាក់ស្យុង អាយលីដអប់រំ និងសាលាអាយលីដអន្តរជាតិ

- ពិនិត្យតាមដានការបង្រៀននិងរៀនថ្នាក់អប់រំពហុភាសា ២២សាលា ១១ស្រុក នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង សហការជាមួយអង្គការយូនីសេហ្វ។

## ការពន្លឿនការសិក្សា

ក្រសួងបាន៖

- បំប៉នសមត្ថភាពស្តីពី កម្មវិធីពន្លឿនការសិក្សា ដល់នាយកសាលា គ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ៣០៣នាក់ ស្រី ៥៦នាក់ នៅខេត្តកំពត ក្រចេះ ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ បន្ទាយមានជ័យ កោះកុង និងកំពង់ស្ពឺ សហការជាមួយអង្គការយូនីសេហ្វនិងអេដអេអាក់ស្យុង
- អនុវត្តកម្មវិធីពន្លឿនការសិក្សា ៥៨សាលា ២១ស្រុក មានគ្រូបង្រៀន ៩៧នាក់ ស្រី ៣៣នាក់ សិស្ស ២ ៨៤៩នាក់ ស្រី ១ ០៩៤នាក់ នៅខេត្តកំពត ក្រចេះ ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ បន្ទាយមានជ័យ និងកោះកុង សហការជាមួយអង្គការយូនីសេហ្វ
- ពិនិត្យតាមដានការអនុវត្តកម្មវិធីពន្លឿនការសិក្សា ៥៨សាលា នៅខេត្តកំពត ក្រចេះ ស្ទឹងត្រែង កំពង់ធំ ព្រះវិហារ បន្ទាយមានជ័យ និងកោះកុង សហកាជាមួយអង្គការយូនីសេហ្វ។

## ការអប់រំកុមារមានពិការភាព

ក្រសួងបាន៖

- ពិគ្រោះយោបល់ចុងក្រោយស្តីពី ឯកសារកំណត់អត្តសញ្ញាណសម្រាប់កុមារមានពិការភាព មានអ្នកចូលរួម ៤៤ នាក់ ស្រី ១០នាក់ នៅខេត្តកំពង់ចាម និងបាត់ដំបង សហការជាមួយអង្គការយូនីសេហ្វ
- បំប៉នសមត្ថភាពស្តីពី ការអប់រំបរិយាបន្ន ដល់អ្នកពាក់ព័ន្ធ និងគ្រូបង្រៀន ៤៨៥នាក់ ស្រី ១៤១នាក់ នៅខេត្តសៀមរាប បាត់ដំបង ព្រៃវែង រតនគិរី និងកំពង់ធំ សហការជាមួយអង្គការយូនីសេហ្វ
- បំប៉នសមត្ថភាពស្តីពី ឯកសារជំនួយការអប់រំកុមារពិការសតិបញ្ញា ដល់អ្នកពាក់ព័ន្ធ និងគ្រូបង្រៀន ៨៦នាក់ ស្រី ៣១នាក់ នៅខេត្តកំពង់ស្ពឺ និងកំពង់ចាម
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀនភាសាសញ្ញា និងអក្សរប្រៃយ៍ ដល់អ្នកពាក់ព័ន្ធ និងគ្រូបង្រៀន នៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម ២១៥នាក់ ស្រី ៥៤នាក់ នៅខេត្តសៀមរាប
- បំប៉នសមត្ថភាពស្តីពី ការវាយតម្លៃកុមារមានពិការភាព វិធីសាស្ត្របង្រៀនកុមារមានពិការភាព និង ការបង្រៀន និងផលិតសម្ភារៈ សម្រាប់ការបង្រៀនកុមារមានពិការភាពដល់ មន្ត្រីមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា គ្រូ ១៩០នាក់ ស្រី ១០០នាក់ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- បញ្ជូនកុមារមានពិការភាព ១៣នាក់ ស្រី ៥នាក់ ទៅរកសេវានានាក្នុងនោះ ពិនិត្យភ្នែក កាត់វ៉ែនតា ទទួលថ្នាំបំប៉នសុខភាព និងបានបង្កើតថ្នាក់អប់រំបរិយាបន្ន ៣០ថ្នាក់ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- ជ្រើសរើសនិងបណ្តុះបណ្តាលគ្រូអប់រំពិសេស ២២នាក់ ស្រី ៩នាក់ ក្នុងនោះជំនាញ គ-ថ្លង់ ១១នាក់ ស្រី ៦នាក់ និងជំនាញពិការភ្នែក ១១នាក់ ស្រី ៣នាក់ នៅរាជធានី
- បើកថ្នាក់សមាហរណកម្ម គ-ថ្លង់ ៨សាលា ១២ថ្នាក់ សិស្ស ៤០នាក់ ស្រី ៣០នាក់ នៅខេត្តស្វាយរៀង ព្រៃវែង ព្រះសីហនុ និងកំពង់ឆ្នាំង
- បើកថ្នាក់សមាហរណកម្មសតិបញ្ញា ៣០សាលា ៥១ថ្នាក់ សិស្ស ៨៧១នាក់ ស្រី ៣០០នាក់ នៅខេត្តកណ្តាល កំពង់ស្ពឺ សៀមរាប ក្រចេះ និងរាជធានី

- អនុញ្ញាតឱ្យសាលាឯកជន យើងឃើង អនុវត្តការអប់រំពិសេសសម្រាប់សិស្សពិការសតិបញ្ញា ២០៥នាក់ ស្រី ២៤នាក់ នៅខណ្ឌសែនសុខ រាជធានី
- អនុវត្តកម្មវិធីអប់រំពិសេសនៅវិទ្យាល័យអប់រំពិសេស ៥សាលា សិស្ស ៧៤៨នាក់ ស្រី ៣១០នាក់ ក្នុងនោះ សិស្សពិការភ្នែក ១៨១នាក់ ស្រី ៧២នាក់ និងសិស្សគថ្លង់ ៥៦៧នាក់ ស្រី ២៣៨នាក់។ សិស្សកម្រិតបឋមសិក្សា ៥០៥នាក់ ស្រី ២១៤នាក់ ក្នុងនោះសិស្សគថ្លង់ ៤១៣នាក់ ស្រី ១៧៦នាក់ និងសិស្សពិការភ្នែក ៩២នាក់ ស្រី ៣៨នាក់
- អភិវឌ្ឍសៀវភៅភាសាសញ្ញា អក្សរប្រៃយ៍ និងសៀវភៅអំណានភាសាសញ្ញាថ្នាក់ទី១ ជាភាសាខ្មែរ សម្រាប់អនុវត្តនៅវិទ្យាល័យអប់រំពិសេសទាំង៥
- សាងសង់អគារអន្តេវាសិកដ្ឋាន ១ខ្នង ៣ជាន់ ស្មើនឹង ១២បន្ទប់ បង្គន់អនាម័យ ៣៦បន្ទប់ នៅវិទ្យាល័យអប់រំពិសេសកំពង់ចាម សហការជាមួយសប្បុរសជន
- ផ្តល់ប្រាក់ឧបត្ថម្ភរយៈពេល១០ខែ ក្នុង១ឆ្នាំ សម្រាប់ការហូបចុក ស្នាក់នៅ សោហ៊ុយធ្វើដំណើរដល់សិស្សពិការភ្នែក និងគ-ថ្លង់ ៧៣៣នាក់ ស្រី ២៩៥នាក់ ចំនួន ១ ៤៦៦ ០០០ ០០០រៀល ក្នុងនោះសិស្សម្នាក់ៗទទួលបានថវិកា ២០០ ០០០រៀល ក្នុង១ខែៗ នៅវិទ្យាល័យអប់រំពិសេសទាំង៥
- ទទួលថវិកាឧបត្ថម្ភពីសប្បុរសជន ៤៧ ០៣៦ ៥៥០រៀល អនុវត្តបាន ១០០ភាគរយ ក្នុងនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ៦ ០០០ ០០០រៀល សម្រាប់វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី និងវិទ្យាល័យអប់រំពិសេសច្បារអំពៅ។ **ឯកឧត្តម ផាន អួន** អគ្គនាយកនៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ ៣៤ ០៣៦ ៥៥០រៀល សេវាទឹក ភ្លើង សម្រាប់វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី។ សាលាខេត្តសៀមរាប ៧ ០០០ ០០០រៀល សម្រាប់វិទ្យាល័យអប់រំពិសេសសៀមរាប។ **ឯកឧត្តម ខៀវ កាញារីទ្ធ** ៣ ០០០ ដុល្លារ សម្រាប់វិទ្យាល័យអប់រំពិសេសកំពង់ចាម
- ទទួលឧបត្ថម្ភអង្ករពីសប្បុរសជន ៣៩,២តោន ក្នុងនោះ **សម្តេចតេជោ** ១០តោន និងកុមារីខត្តីយ៉ា ១,២តោន សម្រាប់វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី។ **សម្តេចតេជោ** ១០តោន សម្រាប់វិទ្យាល័យអប់រំពិសេសច្បារអំពៅ។ **សម្តេចពិជ័យសេនា ទៀ បាញ់** ៥តោន សម្រាប់វិទ្យាល័យអប់រំពិសេសសៀមរាប។ **សម្តេចក្រឡាហោម ស ខេង** ១២តោន សម្រាប់វិទ្យាល័យអប់រំពិសេសបាត់ដំបង។ **ឯកឧត្តម ខៀវ កាញារីទ្ធ** ១តោន សម្រាប់វិទ្យាល័យអប់រំពិសេសកំពង់ចាម
- ទទួលការឧបត្ថម្ភ ១ ២០០ម៉ាស់ កាតាបសិស្ស ២០៨សម្រាប់ កាតាបគ្រូ ៨៧សម្រាប់ តុក្កតា ២០កេះ សាច់ក្រក ត្រីផាត់ សាច់ងៀត ៥កេះ **ឯកឧត្តម ហ៊ុន ម៉ាណែត** សម្រាប់វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី
- ទទួលការឧបត្ថម្ភ កុំព្យូទ័រលើតុ ១៥គ្រឿង អិលស៊ីឌី ១គ្រឿង ម៉ាស៊ីនហ្វូតូ ១គ្រឿង ព្រីនធ័រគូល័រ ១គ្រឿង កុំព្យូទ័រយួរដៃ ៣០គ្រឿង ម៉ាស៊ីនថតសំឡេង ១៨គ្រឿង **ឯកឧត្តម ហោ ណាំហុង** សម្រាប់វិទ្យាល័យអប់រំពិសេសកំពង់ចាម
- ទទួលការឧបត្ថម្ភអង្ករ ៣តោន ត្រីខ ១០កេះ ទឹកត្រី ទឹកស៊ីអ៊ីវ ២០យួរ មីម៉ាម៉ា ១០កេះ ទឹកក្រូច ២០កេះ ទឹកសុទ្ធ ១០កេះ បាល់ទាត់ ៤បាល់ សំណាញ់បាល់ទាត់២ និងអាហារផ្សេងៗ **ឯកឧត្តម ស សុខា** សម្រាប់វិទ្យាល័យអប់រំពិសេសសៀមរាប
- សាងសង់អគារសិក្សាថ្មី ១ខ្នង ២ជាន់ ស្មើនឹង ៨បន្ទប់ បង្គន់អនាម័យ ៣បន្ទប់ នៅខេត្តកណ្តាលសម្រាប់ថ្នាក់សមាហរណកម្មសតិបញ្ញា នៅអនុវិទ្យាល័យអនុវត្តក្រុងតាខ្មៅ ខេត្តកណ្តាល ជំនួយរាជរដ្ឋាភិបាល
- ជួសជុលអគារសិក្សាចាស់ ១ខ្នង ១ជាន់ ៥បន្ទប់ បង្គន់អនាម័យ ៣បន្ទប់ នៅសាលាបឋមសិក្សាទួលគោក សហការជាមួយអង្គការសាលារៀនទន្សាយ

- ពិនិត្យភ្នែកសិស្សខ្សោយគំហើញ ៧៧នាក់ ស្រី ២១នាក់ និងផ្តល់ឧបករណ៍ជំនួយ ឧបករណ៍អុបទិក ៧៨ ក្នុងនោះ ៦០វ៉ែនតា ១៨កែវពង្រីក វ៉ែនតាឡង់ទីអាចរ៉ាកិល ១០០វ៉ែនតា និងមិនមែនអុបទិក ៦១ នៅវិទ្យាល័យអប់រំពិសេស៤ សហការជាមួយអង្គការគ្រួសារថ្មី និងសប្បុរសជននៅហុងកុង
- ពិនិត្យត្រចៀក និងផ្តល់ឧបករណ៍ជំនួយស្តាប់ ៧០៤ម៉ាស៊ីន ដល់សិស្សថ្លង់ ៤៧០នាក់ ស្រី ១១៩នាក់ នៅវិទ្យាល័យអប់រំពិសេសទាំង៥ និងសាកលវិទ្យាល័យ សហការជាមួយអង្គការគ្រួសារថ្មី និងអ្នកជំនាញត្រចៀកមកពីប្រទេសបារាំង
- ថតវីដេអូភាសាសញ្ញាបញ្ចូលក្នុងវីដេអូឃ្លីបការបង្រៀនពីចម្ងាយ ១០០ឃ្លីប សម្រាប់ថ្នាក់ទី៤ ដល់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា នៅរាជធានី
- ផ្តល់សម្ភារៈសម្រាប់រៀបចំកន្លែងថតវីដេអូ កាមេរ៉ា កុំព្យូទ័រយួរដៃ ទូរទស្សន៍ស្មាតធីវីទំហំ ៥៥អ៊ីង ភ្លើងហ្វា និងជើងទម្រ នៅនាយកដ្ឋានអប់រំពិសេស សហការជាមួយអង្គការស៊ីអាអេស
- ផ្តល់កញ្ចប់សម្ភារៈល្បែងអប់រំបរិយាបន្ន ២០០ឈុត នៅខេត្តកំពង់ធំ សៀមរាប ព្រៃវែង បាត់ដំបង និងរតនគិរី សហការជាមួយអង្គការស៊ីប៉ា
- ផ្តល់ទូរទស្សន៍ស្មាតធីវីទំហំ ៤២អ៊ីង ៥ឈុត កុំព្យូទ័រយួរដៃ ២៥គ្រឿង កូនកណ្តុរ ២៥គ្រឿង បណ្ណាល័យឌីជីថល ៥គ្រឿង សៀវភៅរឿងនិទាន ២៧០ក្បាល និងសៀវភៅរឿងអាស៊ាន ៥០ក្បាល សហការជាមួយអង្គការអេដអេអាក់ស្យុង
- ផ្តល់សៀវភៅអានអប់រំអ្នកពិការភ្នែក និងគ-ថ្លង់ ២៩ក្បាល ជាភាសាអង់គ្លេសដាក់ក្នុងបណ្ណាល័យសម្រាប់គរុសិស្សស្រាវជ្រាវនៅវិទ្យាស្ថានជាតិអប់រំពិសេស
- ផលិត និងបោះពុម្ពសៀវភៅជំនួយការរៀនសម្រាប់កុមារខ្សោយគំហើញ និងជួបការលំបាកក្នុងការសិក្សា ១ ៨៩៦ឈុត សហការជាមួយអង្គការអេរជីអាយ
- ផលិតរឿងខ្លី និងអត្ថបទខ្លីៗជាអក្សរប្រៃយ៍សម្រាប់ថ្នាក់ទី១ និងទី២ មាន ២៥រឿង និង ១០៦អត្ថបទ សហការជាមួយអង្គការ អរ ធី អាយ
- ផ្តល់ក្របខណ្ឌថ្មី ៥១កន្លែង ក្នុងនោះវិទ្យាស្ថានជាតិអប់រំពិសេស ១៥កន្លែង និងវិទ្យាល័យអប់រំពិសេសទាំង៥ និងវិទ្យាល័យអប់រំពិសេសក្រុងតាខ្មៅ ២៦កន្លែង និងសាលារៀនទន្សាយ ១០កន្លែង
- ផ្តល់អនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ៨០០ ០០០រៀល ក្នុង១នាក់ ក្នុង១ខែ សម្រាប់ឧបត្ថម្ភបន្ថែមពិសេសលើប្រាក់បៀវត្សបុគ្គលិក និងគ្រូបង្រៀន នៅវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសទាំង៥
- អនុម័តប្រកាសលេខ ១២០ អយក.ប្រក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ស្តីពីការតែងតាំងក្រុមប្រឹក្សាបច្ចេកទេសវិទ្យាស្ថានជាតិអប់រំពិសេស
- អនុម័តប្រកាសលេខ ៣០៦ អយក.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការលើកកម្ពស់អ្នកសិក្សាពូកែដែលមានទេពកោសល្យ ឬបញ្ញាខ្ពស់
- ពិនិត្យតាមដានការរៀននិងបង្រៀនការអប់រំបរិយាបន្នសិស្សគថ្លង់ និងពិការភ្នែក ១០សាលា ការរៀន និងបង្រៀននៅវិទ្យាល័យអប់រំពិសេសទាំង៥ មាន ២០ថ្នាក់ នៅខេត្តកំពង់ចាម សៀមរាប បាត់ដំបង និងរាជធានី។

*ប្រការនេះ បានបញ្ជាក់ថាការអប់រំបរិយាបន្នមានការយល់ដឹង និងការគាំទ្រកាន់តែទូលំទូលាយ។ ការអប់រំបរិយាបន្នបានផ្តល់ឱកាសដល់កុមារជនជាតិដើមភាគតិច កុមារមានពិការភាព និងកុមារលើសអាយុទទួលបានឱកាសពេញលេញក្នុងការរៀនសូត្រ។*

***កម្មវិធីផ្តល់អាហារូបករណ៍និងផ្តល់អាហារនៅតាមសាលារៀន***

ក្រសួងបាន៖

- ផ្តល់ថវិកាអាហារូបករណ៍ដល់សិស្សក្រីក្រ ១២២ ២២៨នាក់ ស្រី ៥៤,២ភាគរយ ក្នុងនោះសិស្សថ្នាក់ទី១ ដល់ទី៣ មាន ១០ ៦៦៨នាក់ ស្រី ៥២,៧ភាគរយ មាន ៥ ៥៧២សាលា ១៩៣ក្រុង ស្រុក ខណ្ឌ គ្រប់រាជធានី ខេត្ត
- ផ្តល់អាហារតាមសាលារៀន ១ ១១៣សាលា មានសិស្ស ៣០៣ ១៥០នាក់ ស្រី ៤៩ភាគរយ ក្នុងនោះការផ្តល់អាហារពេលព្រឹក និងពេលថ្ងៃត្រង់ ដោយប្រើកសិផលក្នុងសហគមន៍ ៣៨៨សាលា មានសិស្ស ៧៩ ១៩៦នាក់ ស្រី ៤៩ភាគរយ នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ កំពង់ធំ ព្រះវិហារ ស្ទឹងត្រែង និងកំពង់ចាម សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- បំប៉នសមត្ថភាព ស្តីពីឯកសារណែនាំប្រតិបត្តិការអនុវត្តកម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងប្រព័ន្ធព័ត៌មានគ្រប់គ្រងសិស្សអាហារូបករណ៍ ទៅដល់គណៈកម្មការគ្រប់គ្រងអាហារូបករណ៍ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ ៥៧៤នាក់ ស្រី ៧៩នាក់ គ្រប់ខេត្ត រាជធានី និង ១៩៣ក្រុង ស្រុក ខណ្ឌ
- បំប៉នសមត្ថភាព ស្តីពីឯកសារណែនាំប្រតិបត្តិការអនុវត្តកម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងប្រព័ន្ធព័ត៌មានគ្រប់គ្រងសិស្សអាហារូបករណ៍ ដល់គណៈកម្មការគ្រប់គ្រងអាហារូបករណ៍មូលដ្ឋាន ២ ៨៧២នាក់ ស្រី ៦៥២នាក់ នៅខេត្តកំពង់ចាម ត្បូងឃ្មុំ មណ្ឌលគិរី កែប និងរាជធានី
- បំប៉នសមត្ថភាពបន្ថែមដល់គណៈកម្មការគ្រប់គ្រងស្បៀងអាហារតាមសាលារៀន ថ្នាក់ខេត្ត ស្រុក និងសាលារៀន ស្តីពី នីតិវិធីជ្រើសរើសអ្នកផ្គត់ផ្គង់ និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀងតាមសាលារៀន មានគណៈកម្មការគ្រប់គ្រងស្បៀងថ្នាក់ខេត្ត ២៤នាក់ ស្រី ៤នាក់ ថ្នាក់ស្រុក ៣២នាក់ ស្រី ៤នាក់ និងថ្នាក់មូលដ្ឋានសាលារៀន ៦០៥នាក់ ស្រី ៥២នាក់
- ផលិតឃ្លីបស្តីពី នីតិវិធីនៃវិធីសាស្រ្តសាកសួរថ្លៃតាមបែបសាមញ្ញ កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើកសិផលក្នុងសហគមន៍
- អមដំណើរប្រតិភូសាធារណរដ្ឋកូរ៉េ ពិនិត្យការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន នៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- ពិនិត្យគំរូចង្ក្រាន និងផ្ទះបាយ និងសិស្ស ដើម្បីរៀបចំគំនូសប្លង់រួមមួយ សម្រាប់អនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន នៅខេត្តកំពង់ធំ សៀមរាប ពោធិ៍សាត់ និងកំពង់ឆ្នាំង សហការជាមួយនាយកដ្ឋានសំណង់ និងកម្មវិធីស្បៀងអាហារពិភពលោក
- ពិនិត្យតាមដានកម្មវិធីផ្តល់អាហារតាមសាលារៀន ៣៨ស្រុក ១១២សាលា នៅខេត្តកំពង់ឆ្នាំង បន្ទាយមានជ័យ ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រះវិហារ ឧត្តរមានជ័យ កំពង់ធំ កំពង់ចាម និងស្ទឹងត្រែង សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- ចែកស្បៀង(អង្ករ)៤លើក ២០៥សាលា ដំណាក់កាលកូវីដ-១៩ មានអ្នកទទួលផល ៥១ ២២២នាក់ ស្រី ៥២ភាគរយ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ព្រះវិហារ កំពង់ចាម និងស្ទឹងត្រែង គាំទ្រដោយថវិការាជរដ្ឋាភិបាល និង៣លើក ៩០៨សាលា មានអ្នកទទួលផល ២០៣ ១៦១នាក់ ស្រី ៥២,៥ភាគរយ នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ ឧត្តរមានជ័យ កំពង់ធំ និងភាគខ្លះនៃខេត្តសៀមរាប សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក។

*ប្រការនេះ បានជួយលើកកម្ពស់កម្មវិធីផ្តល់អាហារូបត្ថម្ភសម្រាប់ទ្រទ្រង់សុខភាពនិងសុវត្ថិភាពចំណីអាហារដោយប្រើកសិផលក្នុងសហគមន៍ តាមសាលារៀនសម្រាប់កុមារ។ កម្មវិធីផ្តល់អាហារូបករណ៍ បានជួយសិស្សក្រីក្រនៅបឋមសិក្សា ឱ្យរៀនបានចប់ភូមិសិក្សា និងមានលទ្ធភាពឆ្លងភូមិសិក្សា។*

### *ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា*

ក្រសួងបាន ៖

- ពិនិត្យសុខភាពនិងកាយសម្បទាគរុសិស្ស ៣៥៥នាក់ ស្រី ២២៥នាក់ នៅខេត្តកំពង់ស្ពឺ ព្រៃវែង ព្រះវិហារ និង សៀមរាប
- ពិនិត្យភ្នែកនិងវាស់គំហើញដល់គ្រូបង្រៀននិងសិស្ស ៦ ៦៨៧នាក់ ស្រី ៣ ០៨៧នាក់ នៅរាជធានី សហការជាមួយវិទ្យាស្ថានស្តារគំហើញប្រាយអ៊ិនហូលដិន
- ពិនិត្យសុខភាពមាត់ធ្មេញនិងការព្យាបាលមាត់ធ្មេញដល់សិស្ស ២៣៣នាក់ ស្រី ១២២នាក់ នៅសាលាបឋមសិក្សាចតុមុខរាជធានី សហការជាមួយក្រុមទន្តពេទ្យនៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ និងសាកលវិទ្យាល័យទន្តសាស្ត្រទីក្រុងញ៉ូយ៉កសហរដ្ឋអាមេរិក
- រៀបចំបន្ទប់សុខភាពនិងបំពាក់សម្ភារៈសង្គ្រោះបឋម និងថតវីដេអូសកម្មភាពអនុវត្តការងារសុខភាពសិក្សាគ្រប់ជ្រុងជ្រោយ ព្រមទាំងបានប្រកាសសាលាបឋមសិក្សាចតុមុខ ជាសាលាគំរូដែលអនុវត្តសកម្មភាពសុខភាពសិក្សាគ្រប់ជ្រុងជ្រោយ ក្រោមអធិបតីភាពរបស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** សហការជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជន
- ផ្សព្វផ្សាយកម្មវិធីសុវត្ថិភាព និងសុខុមាលភាពចំណីអាហារតាមសាលារៀនដល់គ្រូនិងសិស្ស មានអ្នកចូលរួម ២ ១០០នាក់ ស្រី ៧៩៨នាក់ នៅខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រះសីហនុ កណ្តាល និងរាជធានី
- អភិវឌ្ឍសៀវភៅណែនាំ ស្តីពីដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ សហការជាមួយអង្គការយូនីសេហ្វ និងសុខភាពពិភពលោក
- ផលិតនិងចែកជូនសម្ភារៈអប់រំសុខភាពមាន វីដេអូ រូបភាពផ្ទាំងធំស្តីពី ការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ នៅតាមគ្រឹះស្ថានសិក្សា សហការជាមួយអង្គការយូនីសេហ្វនិងសុខភាពពិភពលោក
- បំប៉នសមត្ថភាពស្តីពី ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ ដល់គ្រូបង្រៀន ២៦៤នាក់ ស្រី ៨៥នាក់ នៅរាជធានី
- អភិវឌ្ឍសមត្ថភាពស្តីពី គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាទឹកស្អាត និងអនាម័យតាមសាលារៀន មានអ្នកចូលរួម ៣៣៨នាក់ ស្រី ៣២នាក់ នៅខេត្តកំពង់ចាម និងព្រៃវែង
- បំប៉នសមត្ថភាពស្តីពី គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពី ទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភតាមសាលារៀន មានអ្នកចូលរួម ៣៣៩នាក់ ស្រី ៦៣នាក់ នៅខេត្តកំពង់ចាម ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី និងត្បូងឃ្មុំ
- បំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់សាកល្បងសៀវភៅសិក្សាគោលមុខវិជ្ជាផ្នែកអប់រំសុខភាពថ្នាក់ទី១ និងទី៤ មានអ្នកចូលរួម ១១៦នាក់ ស្រី ៦៨នាក់ នៅខេត្តកំពង់ចាម កំពង់ឆ្នាំង និងរាជធានី សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា និងអេហ្វអាយឌីអរ
- ប្រារព្ធទិវាពិភពលោកលាងសម្អាតដៃនិងទិវាអនាម័យតាមគ្រឹះស្ថានសិក្សា នៅវិទ្យាល័យ **សម្តេច ហ៊ុន សែន** ពាមជីកង ស្រុកកងមាស មានអ្នកចូលរួម ១០០នាក់ ស្រី ៤៨នាក់ នៅខេត្តកំពង់ចាម
- រៀបចំសិក្ខាសាលាបញ្ចប់គម្រោងស្តីពី ការបង្កើតប្រព័ន្ធសុខភាពតាមសាលារៀន ដើម្បីលើកកម្ពស់ការអប់រំសុខភាព មានអ្នកចូលរួម ៥៣នាក់ ស្រី ២២នាក់ នៅខេត្តកណ្តាល និងរាជធានី សហការជាមួយសាកលវិទ្យាល័យជាតិ កាហ្គាវ៉ា ជប៉ុន
- បោះពុម្ពសៀវភៅស្តីពីការបង្ការ ការទប់ស្កាត់គ្រោះថ្នាក់បង្កដោយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ១៥ ០០០ក្បាល សម្រាប់ចែកផ្សាយនៅតាមគ្រឹះស្ថានសិក្សា សហការជាមួយអង្គការក្មេងអន្តរជាតិកម្ពុជា

- បំប៉នសមត្ថភាពស្តីពី ការចុះសាកល្បងឧបករណ៍វាយតម្លៃដែលអនុវត្តកម្មវិធីស្បៀងអាហារ មានអ្នកចូលរួម ៥០នាក់ ស្រី ២៩នាក់ នៅរាជធានី
- សង់កន្លែងលាងសម្អាតដៃ ៣០៨កន្លែង ផ្តល់ឧបករណ៍លាងសម្អាតដៃចល័ត ១ ២២៥ សង់អាងស្តុកទឹក ១៩កន្លែង សង់ចង្ក្រានសន្សំអុស ៥៤កន្លែង និងជួសជុលផ្ទះបាយ ១៨កន្លែង សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក
- សង់បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងបណ្តាញទឹកស្អាត ២១១សាលា នៅខេត្ត និងរាជធានី សហការជាមួយអង្គការយូនីសេហ្វ ទស្សនពិភពលោក និងភ្លែនអន្តរជាតិកម្ពុជា
- ផ្សព្វផ្សាយនិងចែកជូនសៀវភៅស្តីពី ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ ៥០ ០១១ក្បាល នៅតាមគ្រឹះស្ថានសិក្សា សហការជាមួយអង្គការយូនីសេហ្វ
- ផ្តល់ឧបករណ៍វាស់កម្តៅ ៥៧៦គ្រឿង ឧបករណ៍លាងសម្អាតដៃ ៤ ៤៨៦គ្រឿង និងសាប៊ូដុំ ៧៥មីលីក្រាម ៥២ ២៣២ដុំ នៅខេត្តគោលដៅ៤ និងរាជធានី សហការជាមួយអង្គការយូអេសអេអាយឌី
- ផ្តល់ឧបករណ៍លាងសម្អាតដៃ ១១ ៤១២គ្រឿង ធុងទឹកសម្រាប់លាងដៃចំណុះ ២០លីត្រ ៣៣ ១១៩ធុង ចំណុះ ១៤លីត្រ ១៤ ៤២៥ធុង សាប៊ូដុំ ៧៥មីលីក្រាម ៤៤០ ០៥៥ដុំ កញ្ចប់សម្ភារៈអនាម័យនិងរម្ងាប់មេរោគ ១១មុខ និងខិតបណ្ណស្តីពី ពិធីសាររម្ងាប់មេរោគ ៧ ២៨២សន្លឹក នៅតាមគ្រឹះស្ថានសិក្សា សហការជាមួយអង្គការយូនីសេហ្វ
- ចែកផ្សាយខិតបណ្ណនិងផ្ទាំងរូបភាពស្តីពី ការចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលនិងស្អូច ២ ២៥៦ ៦០៥សន្លឹក ដល់សិស្ស សហការជាមួយអង្គការសុខភាពពិភពលោក
- ផ្តល់ថ្នាំទម្លាក់ដង្កូវព្រូន ២ដងក្នុងមួយឆ្នាំដល់សិស្ស ៣ ០៨៣ ២០៥នាក់ ស្រី ១ ៥១២ ៤៥៧នាក់ នៅតាមគ្រឹះស្ថានសិក្សា សហការជាមួយក្រសួងសុខាភិបាល
- ផ្តល់ប្រអប់សង្គ្រោះបឋម ៥ ៨៥៩សាលា ស្មើ ៨០,៤៦ភាគរយ កើន ២៦,៩៦ភាគរយ មានបន្ទប់សុខភាព ១៤៥សាលា ស្មើ ១,៩៩ ភាគរយ កើន ០,៧៦ ភាគរយ។

*ប្រការនេះ បានជួយលើកកម្ពស់សុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំ ដោយបានបណ្តុះភាពធន់ក្នុងទម្លាប់រស់នៅធម្មតាតាមគន្លងថ្មីក្នុងបរិបទកូវីដ-១៩។*

## ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន

ក្រសួងបាន៖

- រៀបចំការប្រឡងបញ្ចប់ការបណ្តុះបណ្តាលគ្រូបឋមសិក្សា១២+២ ជំនាន់ទី៣៧ មាន ១ ៣៥៧នាក់ ស្រី ៩៣៩នាក់
- បន្តបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិត ១ ៨៩០នាក់ ស្រី ១ ២៨៥នាក់ ក្នុងនោះ ១២+២ ជំនាន់ទី៣៨ ឆ្នាំទី១ ចំនួន ១ ២៩៦នាក់ ស្រី ៨៧១នាក់, ១២+៤ ជំនាន់ទី១ ឆ្នាំទី២ ចំនួន ២៩៧នាក់ ស្រី ២០១នាក់ និង១២+៤ ជំនាន់ទី២ ឆ្នាំទី១ ចំនួន ២៩៧នាក់ ស្រី ២១៣នាក់
- រៀបចំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិគណិតវិទ្យា ដើម្បីកសាងឯកសារវិធីសាស្ត្របង្រៀន និងតាមប្រព័ន្ធអេឡិចត្រូនិក មានអ្នកចូលរួម ៣៥នាក់ ស្រី ៧នាក់ នៅរាជធានី សហការជាមួយអង្គការវីអ៊ែបូ
- រៀបចំកម្មវិធីស្តីពី ការគាំទ្រគ្រូឧទ្ទេស គ្រូបង្រៀនលើប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន ក្រោមប្រធានបទបំណិនគាំទ្រផ្នែកបច្ចេកទេស មានអ្នកចូលរួម ៨១នាក់ ស្រី ២៩នាក់ ដោយប្រើប្រាស់កម្មវិធី ZOOM
- រៀបចំកិច្ចប្រជុំស្តីពី វិធីសាស្ត្របង្រៀនធរណីមាត្រ ការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន និងក្រុមការងារថ្នាក់ជាតិគណិតវិទ្យា មានអ្នកចូលរួម ៦៦នាក់ ស្រី ១៤នាក់ ដោយប្រើប្រាស់កម្មវិធីហ្សូម

- រៀបចំកម្មវិធីស្តីពី ការកែលម្អលំនាំសកម្មភាពនិងវិធីសាស្ត្របង្រៀនគណិតវិទ្យាផ្នែកចំនួន ការវាស់ស្ទង់វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ដោយប្រើប្រាស់កម្មវិធីហ្សូម មានអ្នកចូលរួម ៣៧នាក់ ស្រី ១៥នាក់ នៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តក្រចេះ និងមជ្ឈមណ្ឌលដាយកូនៀ នៅរាជធានី
- រៀបចំក្របខណ្ឌកម្មវិធីសិក្សាជាតិថ្នាក់អនុបណ្ឌិតអប់រំសម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យ សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- រៀបចំកម្មវិធីស្តីពី ការប្រើប្រាស់កម្មវិធី App វិធីសាស្ត្របង្រៀនគណិតវិទ្យាថ្នាក់ទី១ មានអ្នកចូលរួម ៩៣នាក់ ស្រី ៣៥ នាក់ នៅសាលាគរុកោសល្យនិងវិក្រឹតការកំពង់ចាម
- រៀបចំកម្មវិធីការសង្កេតការបង្រៀនគ្រូឧទ្ទេស និងគ្រូបង្រៀនស្តីពី ការប្រមូលទិន្នន័យដំបូងលើការបង្រៀនគណិតវិទ្យា និងប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀនក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យនិងវិក្រឹតការ និងសាលាបឋមសិក្សា មានអ្នកចូលរួម ២០៩នាក់ ស្រី ១៦៥នាក់ នៅខេត្តកំពង់ចាម
- រៀបចំកម្មវិធីស្តីពី ការផ្តល់បទពិសោធក្នុងការបង្រៀនមុខវិជ្ជាគណិតវិទ្យា តាមរយៈការប្រមូលព័ត៌មានសម្រាប់កសាងឯកសារវិធីសាស្ត្របង្រៀន មានអ្នកចូលរួម ៣០នាក់ ស្រី ១៨នាក់ នៅខេត្តបាត់ដំបង
- បំប៉នសមត្ថភាពស្តីពី បំណិនគ្រប់គ្រងបណ្ណាល័យ មានអ្នកចូលរួម ៥៨នាក់ ស្រី ៣០នាក់ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បំប៉នសមត្ថភាពស្តីពី ស្តង់ដានាយកសាលា មានអ្នកចូលរួម ៤៧នាក់ ស្រី ៥នាក់ នៅខេត្តកំពង់ធំ
- បំប៉នសមត្ថភាពស្តីពី ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន មានអ្នកចូលរួម ៣៤នាក់ ស្រី ៥នាក់ នៅរាជធានី
- បំប៉នសមត្ថភាពស្តីពី ការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន មានអ្នកចូលរួម ៣៤នាក់ ស្រី ១២នាក់ នៅខេត្តស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី ការបង្រៀននិងរៀនតាមប្រព័ន្ធអេឡិចត្រូនិក មានអ្នកចូលរួម ៥៩នាក់ ស្រី ២៣នាក់ នៅខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី ការកសាងឯកសារគណិតវិទ្យាផ្នែកចំនួន មានអ្នកចូលរួម ១២នាក់ ស្រី ១នាក់ នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ចាម
- បំប៉នសមត្ថភាពស្តីពី ប្រសិទ្ធភាពនៃការគ្រប់គ្រងថ្នាក់រៀន ក្រោមប្រធានបទ ការបែងចែកក្រុមមានភាពបត់បែនការញែកភាពខុសគ្នា ជូនគណៈគ្រប់គ្រង និងគ្រូឧទ្ទេស ដោយប្រើប្រាស់កម្មវិធីហ្សូម មានអ្នកចូលរួម ៣៦៧នាក់ ស្រី ១៥០នាក់ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការ ខេត្តកំពង់ចាមនិងកណ្តាល
- បំប៉នសមត្ថភាពស្តីពី ការវាយតម្លៃការបំពេញការងាររបស់គ្រូនិងវិធីសាស្ត្របង្រៀនផ្នែកចំនួន មានអ្នកចូលរួម ៥២នាក់ ស្រី ២៩នាក់ នៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី ទីប្រឹក្សាគរុកោសល្យ និងអ្នកគ្រប់គ្រងការស្រាវជ្រាវអនុវត្ត មានអ្នកចូលរួម ៣១នាក់ ស្រី ១៤នាក់ សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- បំប៉នសមត្ថភាពគ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្តស្តីពី ការប្រើប្រាស់សៀវភៅអប់រំ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀនថ្នាក់ទី៤ ដល់ទី៦ មានអ្នកចូលរួម ១១នាក់ ស្រី ៨នាក់
- ពិគ្រោះយោបល់ស្តីពី ការគ្រប់គ្រងថ្នាក់រៀន មានអ្នកចូលរួម ៦៩នាក់ ស្រី ១៥នាក់ នៅសាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ចាម

- កសាងកម្មវិធីសិក្សាលម្អិតផ្នែកកម្មវិធីភាសាខ្មែរកម្រិតបឋមសិក្សា សម្រាប់ការបណ្តុះបណ្តាលគ្រូកម្រិត១២+៤ នៅវិទ្យាស្ថានគរុកោសល្យភ្នំពេញ និងបាត់ដំបង សហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក
- ផលិតសៀវភៅអប់រំស្តីពី ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀនថ្នាក់ទី៤ដល់ទី៦
- អភិវឌ្ឍគុណវុឌ្ឍិរបស់គ្រូឧទ្ទេសសាលាគរុកោសល្យ ៦៨នាក់ ស្រី ៣៣នាក់ មកពីវិទ្យាស្ថានគរុកោសល្យ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ឱ្យដល់កម្រិតបរិញ្ញាបត្រអប់រំ និងការរៀនឆ្នាំទី១ បញ្ចប់ដោយជោគជ័យ សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- អភិវឌ្ឍគុណវុឌ្ឍិទៅកម្រិតបរិញ្ញាបត្រអប់រំគ្រូឧទ្ទេស ៦៨នាក់ ស្រី ៣៣នាក់ បន្តធ្វើការស្រាវជ្រាវដើម្បីអនុវត្ត ដោយទទួលបានការគាំទ្របច្ចេកទេសពីវិទ្យាស្ថានគរុកោសល្យ និងវិទ្យាស្ថានឧត្តមសិក្សា សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជានិងអង្គការយូណេស្កូ
- បំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់សៀវភៅមគ្គុទេសន៍ ជំនួយដល់ការប្រើប្រាស់កុំព្យូទ័របន្ទះ សម្រាប់ការបង្រៀនមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម ដល់គ្រូបង្គោលថ្នាក់ទី១ដល់ទី៦ មានអ្នកចូលរួម ១៣៦នាក់ ស្រី ៧៥នាក់ នៅសាសាបឋមសិក្សាចារ សាលាបឋមសិក្សា **ហ៊ុន សែន** ស្វាយផ្អែម សាលាបឋមសិក្សា **ហ៊ុន សែន** មុខដា
- ពិគ្រោះយោបល់ស្តីពី ការអភិវឌ្ឍសៀវភៅមគ្គុទេសក៍ជំនួយដល់ការប្រើប្រាស់កុំព្យូទ័រថេបប្លេត និងមជ្ឈមណ្ឌលផ្ទុកធនធានឯកសារអប់រំចល័ត ថ្នាក់ទី១ ទី៣ ទី៤ និងទី៦ មានអ្នកចូលរួម ៣០នាក់ ស្រី១២នាក់ នៅសាលាបឋមសិក្សាស្វាយព្រហូត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀនភាសាខ្មែរ និងគណិតវិទ្យា អំណានថ្នាក់ដំបូងសម្រាប់ថ្នាក់ទី២ និងទី៣ និងការរៀបចំតេស្តដល់មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា និងគ្រូបង្រៀន ៤១៩នាក់ ស្រី ២០៦នាក់ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- បំប៉នសមត្ថភាពស្តីពី ការការពារកុមារ និងការប្រើប្រាស់ឧបករណ៍តាមដាន អំពីអំពើហិង្សាលើកុមារ មានអ្នកចូលរួម ២៦០នាក់ ស្រី ១២២នាក់ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា។

*ប្រការនេះ បានជួយលើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យឆ្លើយតបនឹងបរិបទអប់រំឌីជីថល។*

## *ការងារអភិវឌ្ឍកម្មវិធីសិក្សា*

ក្រសួងបាន៖

- ធ្វើបច្ចុប្បន្នកម្មស្ថិតិបណ្ណាល័យនៅគ្រប់ខេត្ត និងរាជធានី
- ព្រាងឯកសារស្តីពី ការអប់រំសិល្បៈ សម្រាប់សិស្សនិងគ្រូថ្នាក់ទី៤ ដល់ទី៦
- ព្រាងឯកសារស្តីពី ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ក្នុងកម្មវិធីសិក្សាថ្នាក់ទី៤ដល់ទី៦
- ផ្គត់ផ្គង់សៀវភៅសិក្សាគោល ៣ ៣៨០ ៥៤៤ច្បាប់ នៅគ្រប់ខេត្ត និងរាជធានី
- អភិវឌ្ឍឯកសារជំនួយលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ដល់ទី៦ វិធីសាស្ត្របង្រៀនសរសេរតាមអានពីថ្នាក់ទី១ ដល់ទី៦ វិធីសាស្ត្របង្រៀនបំណិនជីវិតតាមមូលដ្ឋាន និងវិធីសាស្ត្របង្រៀនគណិតវិទ្យាកម្រិតបឋមសិក្សាផ្សារភ្ជាប់សកម្មភាពស្វែម
- អភិវឌ្ឍឯកសារណែនាំអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅអប់រំសិល្បៈ សម្រាប់សិស្សនិងគ្រូថ្នាក់ទី១ ដល់ទី៣ ឯកសារជំនួយការរៀននិងបង្រៀនមុខវិជ្ជាសិក្សាសង្គមថ្នាក់ទី៣ ដល់ទី៦ និងឯកសារណែនាំការវាយតម្លៃកម្មវិធីសិក្សាកម្រិតសាលារៀន

- បំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់និងយល់ដឹងពីការធ្វើតម្រូវការសៀវភៅសិក្សាគោល មានអ្នកចូលរួម ៦២នាក់ ស្រី ១២នាក់ នៅខេត្តសៀមរាប
- បំប៉នសមត្ថភាពស្តីពី ការតម្រង់ទិសគ្រូបង្គោលលើកម្មវិធីសិក្សា សៀវភៅសិក្សាគោល ឯកសារជំនួយការបង្រៀន វិធីសាស្រ្តបង្រៀនមុខវិជ្ជាភាសាអង់គ្លេសថ្នាក់ទី៤ ដល់ទី៦ ផ្សព្វផ្សាយនិងពង្រឹងការអនុវត្តកម្មវិធីសិក្សាសង្គម មានអ្នកចូលរួម ១១៨នាក់ ស្រី ៤១នាក់ នៅខេត្តសៀមរាប
- បំប៉នសមត្ថភាពស្តីពី ការបញ្ជ្រាបវិស័យធនាគារលើមុខវិជ្ជាសិក្សាសង្គម គណិតវិទ្យា សេដ្ឋកិច្ច និងបំណិនជីវិត មានអ្នកចូលរួម ៤នាក់ ស្រី ០នាក់ នៅខេត្តសៀមរាម
- បំប៉នសមត្ថភាពស្តីពី ការចែករំលែកបទពិសោធនិងស្វែងយល់បន្ថែមលើខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា មានអ្នកចូលរួម ១៤នាក់ ស្រី ៣នាក់ នៅខេត្តកំពង់ចាម
- ផ្សព្វផ្សាយឯកសារជំនួយស្តីពី ការបង្រៀននិងរៀនវិទ្យាសាស្រ្តតាមវិធីស្វែមថ្នាក់ទី៤ ដល់ទី៦ មានអ្នកចូលរួម ៥៦នាក់ ស្រី ២៣នាក់ នៅខេត្តកំពង់ស្ពឺ
- ផ្សព្វផ្សាយការអប់រំមីន គ្រោះថ្នាក់ផ្សេងៗ និងកូវីដ-១៩ មានអ្នកចូលរួម ៦ ៦៣៦នាក់ ស្រី ៣ ៣៤៩នាក់ នៅខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ និងកំពង់ធំ
- ផ្សព្វផ្សាយស្តង់ដាបណ្ណាល័យ មានអ្នកចូលរួម ២២៤នាក់ ស្រី ៥៣នាក់ នៅគ្រប់រាជធានី ខេត្ត។

*ប្រការនេះ បានជួយជំរុញនិងលើកកម្ពស់ការអនុវត្តកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងវិធីសាស្រ្តបង្រៀនស្របតាមបរិបទថ្មី។*

### *ការងារបណ្ណាល័យ*

សាលារៀនមានបណ្ណាល័យ ៤ ៤៨៨ ក្នុងនោះជាអគារ ៦៧៣ខ្នង ជាបន្ទប់ ៨០៧ នៅជាមួយទីចាត់ការ ៨០៧ ជាជ្រុងថ្នាក់ ១៧៥ និងបណ្ណាល័យចល័ត ៨០។

ក្រសួងបាន៖

- រៀបចំប្រារព្ធទិវាជាតិអំណានលើកទី៥ ថ្ងៃទី១១ មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានអ្នកចូលរួម ២ ៥០០នាក់ ស្រី ១ ៣៤៨នាក់ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ប្រកាសលទ្ធផលបេក្ខជនជ័យលាភីវិញ្ញាសា ការអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ និងកថា ១២នាក់ ស្រី ៧នាក់ នៅរាជធានី
- ចេញលិខិតបទដ្ឋានគតិយុត្តក្នុងនោះ លិខិតអញ្ជើញស្ថាប័នពាក់ព័ន្ធ សេចក្តីសម្រេចសម្រាប់គណៈកម្មការរៀបចំទិវាអំណាន ការប្រកួតប្រជែង បញ្ជីឈ្មោះបេក្ខជនចូលរួម
- ព្រាងគោលការណ៍ណែនាំប្រតិបត្តិស្តីពីការងារបណ្ណាល័យ នៅតាមសាលាបឋមសិក្សា សហការជាមួយអង្គការរូមធូរីដ
- ផ្តល់សៀវភៅអាន ១៨ ៩៤០ក្បាល ធ្នើរ ៩ និងចែកសម្ភារសិក្សាដល់សិស្ស ៤ ៤០០នាក់ សហការជាមួយសមាគមសប្បុរសជនជប៉ុន
- ចែកសៀវភៅសិក្សាភាសាអង់គ្លេស ៣៨ ៨៨០ក្បាល នៅខេត្តព្រះវិហារ កំពង់ធំ ក្រចេះ និងព្រះសីហនុ សហការជាមួយអង្គការរូមធូរីដ

- ទទួលអ្នកចូលអាន ២ ៣៦៦នាក់ ស្រី ១ ៣៩៣នាក់ ចុះបញ្ជីសៀវភៅ ៧៥ច្បាប់ សារព័ត៌មាន ១២៤ច្បាប់ ទស្សនាវដ្តី ២៨ច្បាប់ នៅបណ្ណាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ** បឹងត្របែក
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពង្រឹងការអនុវត្តកម្មវិធីសិក្សាសិក្សាសង្គមនៅបឋមសិក្សា មានអ្នកចូលរួម ៤១នាក់ ស្រី ២១នាក់
- រៀបចំសិក្ខាសាលាតម្រង់ទិសគ្រូបង្គោលសាលាបឋមសិក្សា លើកម្មវិធីសិក្សា សៀវភៅសិក្សាគោល ឯកសារជំនួយការបង្រៀន និងវិធីសាស្ត្របង្រៀនមុខវិជ្ជាភាសាអង់គ្លេសថ្នាក់ទី៤ ដល់ទី៦ មានអ្នកចូលរួម ៧៧នាក់ ស្រី ២០នាក់
- រៀបចំសិក្ខាសាលាស្តីពី ការអភិវឌ្ឍឯកសារជំនួយការរៀននិងបង្រៀនគោលវិធីស្វែមថ្នាក់ទី៤ ដល់ទី៦ មានអ្នកចូលរួម ៥៦នាក់ ស្រី ២៣នាក់
- រៀបចំប្រជុំពិគោះយោបល់លើឯកសារជំនួយការរៀននិងបង្រៀន សិក្សាសង្គមថ្នាក់ទី៣ ដល់ទី៦ មានអ្នកចូលរួម ៤០នាក់ ស្រី ១៤នាក់
- រៀបចំសិក្ខាសាលា ផ្សព្វផ្សាយស្តង់ដាបណ្ណាល័យបឋមសិក្សា មានអ្នកចូលរួម ២២៤ នាក់ ស្រី ៥៣នាក់
- បំប៉នសមត្ថភាពស្តីពី ការងារបណ្ណាល័យ មានអ្នកចូលរួម ១៤២នាក់ ស្រី ៦៧នាក់ នៅខេត្តកំពង់ធំ
- ពិគ្រោះយោបល់ឯកសារស្តីពី គេហកិច្ច មានអ្នកចូលរួម ៥២នាក់ ស្រី ៤០នាក់ នៅខេត្តសៀមរាប
- ពិនិត្យតាមដានឯកសារណែនាំការវាយតម្លៃកម្រិតសាលារៀន មានអ្នកចូលរួម ៦៤នាក់ ស្រី ២៥នាក់ នៅខេត្តព្រៃវែង និងកំពង់ធំ
- ចងក្រងស្ថិតិ ១៧បណ្ណាល័យ នៅខេត្ត និងរាជធានី។

*ប្រការនេះ បានជួយបណ្តុះទម្លាប់អាន ការតែងនិពន្ធ និងជំរុញការរៀន និងបង្រៀនប្រកបដោយគុណភាព។*

### *ការបង្រៀននិងរៀនពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក*

ក្រសួងបាន៖

- ផ្សព្វផ្សាយ៖
    - សេចក្តីណែនាំលេខ ២៣ អយក.សណន. ស្តីពីការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសិស្សានុសិស្សកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ចុះថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០
    - សេចក្តីណែនាំប្រតិបត្តិលេខ ២៩ អយក.សណន. ស្តីពីគាំទ្រការអនុវត្តការសិក្សាពីចម្ងាយ ចុះថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០
    - សេចក្តីណែនាំលេខ ៣៦ អយក.សណន. ស្តីពីការប្រើប្រាស់ថវិកាគម្រោងកែលម្អការអប់រំឧត្តមសិក្សាដើម្បីគាំទ្រមូលនិធិដំណើរការសាលារៀននៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាសាធារណៈ ចុះថ្ងៃអង្គារ ៧រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០
    - សេចក្តីណែនាំលេខ ៣៨ អយក.សណន.ស្តីពីការបើកដំណើរការឡើងវិញគ្រឹះស្ថានបឋមសិក្សាក្នុងដំណាក់ទី២ ចុះថ្ងៃអង្គារ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០
    - សេចក្តីណែនាំលេខ ៥៥ អយក.សណន. ស្តីពីការបើកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈក្នុងដំណាក់កាលទី៣ ចុះថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

- សេចក្តីណែនាំលេខ ៥៩ អយក.សណន. ស្តីពី ការបើកដំណើរការគ្រឹះស្ថានបឋមសិក្សាសាធារណៈឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃពុធ ១១រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០

- ផលិតវីដេអូការបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ថ្នាក់ទី១ ដល់ទី៣
  - ផលិតវីដេអូ ៦៥ឃ្លីប ក្នុងនោះភាសាខ្មែរ ៣៣ឃ្លីប និងគណិតវិទ្យា ៣២ឃ្លីប នៅខេត្តកំពង់ធំ សហការជាមួយគម្រោងពង្រឹងកម្មវិធីអប់រំគ្រូនៅកម្ពុជា និងគម្រោងភាពជាដៃគូសកលសម្រាប់ការអប់រំទី៣
  - ផលិតវីដេអូ ១៨០ឃ្លីប ក្នុងនោះភាសាខ្មែរ៩០ឃ្លីប និងគណិតវិទ្យា៩០ឃ្លីប នៅរាជធានី សហការជាមួយគម្រោងអភិវឌ្ឍសមត្ថភាពអប់រំនិងអង្គការយូណេស្កូ
  - ផលិតវីដេអូ ១ ៥៦៧ឃ្លីប ក្នុងនោះភាសាខ្មែរ ១ ០១៦ឃ្លីប និងគណិតវិទ្យា ៥៥១ឃ្លីប នៅរាជធានី សហការជាមួយធនាគារពិភពលោក
- ផលិតកិច្ចការផ្ទះមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១ ដល់ទី៣ មាន ៥៤៣កិច្ចការ ក្នុងនោះកិច្ចការផ្ទះសម្រាប់វាយតម្លៃ ១៧៣កិច្ចការ និងកិច្ចការផ្ទះសម្រាប់ស្វ័យសិក្សាមុខរៀនមេរៀនថ្មី ៣៧០កិច្ចការ សហការជាមួយធនាគារពិភពលោក
- ផលិតវីដេអូការបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី៤ដល់ទី៦ មាន ៥៩៥ឃ្លីប ក្នុងនោះភាសាខ្មែរ ៣០៥ឃ្លីប និងគណិតវិទ្យា ២៩០ឃ្លីប
- ផលិតសន្លឹកកិច្ចការសិស្សមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ទី៤ដល់ទី៦ មាន ៥៤០កិច្ចការ ក្នុងនោះភាសាខ្មែរ ២៧៧កិច្ចការ និងគណិតវិទ្យា ២៦៣កិច្ចការ
- ពិនិត្យតាមដាន និងគាំទ្រការបើកដំណើរការឡើងវិញ តាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកក្នុងបរិបទកូវីដ-១៩ មាន ៥០៧សាលា ៩៦ក្រុង ស្រុក ខណ្ឌ មានអ្នកចូលរួម ២ ០៣០នាក់ ស្រី ៨៧៣នាក់ នៅគ្រប់ខេត្ត និងរាជធានី
- អនុវត្តសាកល្បងគម្រោងការសិក្សាពីចម្ងាយ និងអេឡិកត្រូនិកក្នុងបរិបទកូវីដ-១៩ ដើម្បីគាំទ្រដល់ការសិក្សារបស់កុមារដោយផ្តល់ទូរទស្សន៍វៃឆ្លាតទំហំ ៥១អ៊ីង ៤៥គ្រឿង កុំព្យូទ័របន្ទះរ៉ាឆែល ១៥គ្រឿង ផ្តល់ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់រ៉ាឆែល មានអ្នកចូលរួម ៣០នាក់ ស្រី ១៣នាក់ ១៥សាលា នៅខេត្តស្វាយរៀង សហការជាមួយអង្គការឆាលហ្វានកម្ពុជា
- ផ្សាយផ្ទាល់វីដេអូមេរៀនលើទំព័រហ្វេសប៊ុកគ្រូ របស់ក្រសួងអប់រំ យុវជន និងកីឡា ៣៦៨វីដេអូ
- រៀបចំបញ្ចូលមាតិកាអប់រំលើគេហទំព័រហ្វេសប៊ុកផ្លូវការក្រសួងអប់រំ យុវជន និងកីឡា ៥០៥វីដេអូ
- រៀបចំបញ្ចូលមាតិកាអប់រំលើបណ្តាញសង្គមផ្លូវការក្រសួងអប់រំ យុវជន និងកីឡាយូធូប youtube.com/moeys ៦៥០វីដេអូ
- ធ្វើបច្ចុប្បន្នភាពលើអនុគេហទំព័រ elearning.moeys.gov.kh និងអនុគេហទំព័រ https://beep.moeys.gov.kh/
- ធ្វើឱ្យប្រសើរឡើងនូវវគ្គសិក្សាមកដាក់កម្រិតថ្នាក់សិក្សាដូចជា បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលថ្នាក់សិក្សានីមួយៗ មាននៅគ្រប់មុខវិជ្ជាស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា
- ផលិតវីដេអូមេរៀននៅលើគេហទំព័រ elearning.moeys.gov.kh ៦វគ្គសិក្សាថ្នាក់ទី១ដល់ទី៦ ថ្នាក់ភាសាសញ្ញា និងថ្នាក់អក្ខរកម្ម មានវីដេអូមេរៀន ២៥៨វីដេអូ មានអ្នកចូលរួមប្រើប្រាស់គណនីផ្ទាល់ខ្លួន ៤ ៦០១នាក់
- ចុះអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងព័ត៌មាន នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ ក្នុងគោលការណ៍ផ្សព្វផ្សាយកម្មវិធីការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកលើប្រព័ន្ធទូរទស្សន៍ជាតិកម្ពុជា និង App ក្រសួងព័ត៌មាន

- ផ្សព្វផ្សាយវីដេអូបង្រៀន ២៨០វីដេអូ និងលំហាត់ ៣ ០០០វីដេអូ ក្នុងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក សហការជាមួយអង្គការសិក្សាល្អ (Good Learning General Incorporated Association) ក្នុងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនៅលើគេហទំព័រ https://km.khanacademy.org/ គោលបំណងដើម្បីលើកកម្ពស់សិក្សាដល់សិស្សពីថ្នាក់ទី១ដល់ទី៦ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា ក្នុងអំឡុងពេលនៃការការពារនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- ផ្តល់ម៉ាស់ ៣៨០ប្រអប់ ម៉ាស់ក្រណាត់ ១៨ ៦០៤ម៉ាស់ ដែលលាងដៃ ៣ ៤១៥ដប អាល់កុល ១៩១ដប ទឹកអាល់កុល ១៥២លីត្រ និងសាប៊ូលាងដៃ ៧០០ដុំ ដល់ ៧០សាលា សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- ធ្វើយុទ្ធនាការផ្សព្វផ្សាយ វិធានការទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ តាមរយៈសារសំឡេង រូបភាព និងវីដេអូ សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- បំប៉នសមត្ថភាពស្តីពី បច្ចេកទេសការប្រើប្រាស់អាយស៊ីធី និងបណ្តាញសង្គម ក្នុងនោះ Telegram, Microsoft Teams, Zoom និង Messenger ដើម្បីបម្រើឱ្យការបំពេញការងារពីចម្ងាយ ការបង្រៀនពីចម្ងាយ ការបណ្តុះបណ្តាល ដល់មន្ត្រីអប់រំថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រូបង្រៀន នៅខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង ពោធិ៍សាត់ និងកោះកុង សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា។

*ប្រការនេះ បានបញ្ជាក់ពីការយកចិត្តទុកដាក់លើកកម្ពស់ការសិក្សារបស់សិស្ស ដោយមានភាពទន់ភ្លន់បត់បែនប្រើវិធីចម្រុះ ក្នុងបរិបទកូវីដ-១៩ ដោយអនុវត្តតាមគន្លងជីវិតថ្មីក្នុងវិស័យអប់រំ។*

### ការពិនិត្យតាមដាននិងវាយតម្លៃ

ក្រសួងបាន៖

- បំប៉នសមត្ថភាពស្តីពី ទម្រង់និងការសរសេររបាយការណ៍តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៣ មានអ្នកចូលរួម ៤៩នាក់ ស្រី ៩នាក់ នៅខេត្តកំពង់ស្ពឺ
- បំប៉នសមត្ថភាពស្តីពីការអនុវត្តតេស្តវង្វាយតម្លៃអំណានថ្នាក់ទី១ មានអ្នកចូលរួម ៤៩នាក់ ស្រី ៩នាក់ នៅរាជធានី
- បំប៉នសមត្ថភាពស្តីពី ការប្រើប្រាស់កម្មវិធីត្រួតពិនិត្យតាមដាន និងវាយតម្លៃសាលាកុមារមេត្រីតាមឧបករណ៍ចល័ត និងប្រព័ន្ធផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនតាមអ៊ីនធឺណិត (គេហទំព័រ) នៅរាជធានី សហការជាមួយវិទ្យាស្ថានបើកទូលាយ
- បំប៉នសមត្ថភាពស្តីពី ការប្រមូលធាតុចូល ការកែលម្អឯកសារពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងប្រព័ន្ធអធិការកិច្ចជានាគុណភាពអប់រំ មានអ្នកចូលរួម ១១៧នាក់ ស្រី ២០នាក់ នៅខេត្តកំពង់ចាម ព្រៃវែង កំពង់ឆ្នាំង តាកែវ បាត់ដំបង សៀមរាប និងរាជធានី
- បំប៉នសមត្ថភាពស្តីពី ការវាយតម្លៃសាលារៀនតាមប្រព័ន្ធអេឡិចត្រូនិក បច្ចេកទេសប្រមូលព័ត៌មាន និងការគ្រប់គ្រងទិន្នន័យតាមគោលការណ៍ណែនាំអំពីការប្រើប្រាស់ថេប្លេតកុមារមេត្រី ៩ខេត្ត ៥៧ក្រុង ស្រុក មានអ្នកចូលរួម ១ ៤១៩នាក់ ស្រី ២០៦នាក់
- ពិគ្រោះយោបល់ស្តីពី សំណួរតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៦ មានអ្នកចូលរួម ៤១នាក់ ស្រី ៤នាក់ នៅខេត្តតាកែវ
- ពិគ្រោះយោបល់ស្តីពី របាយការណ៍តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង មានអ្នកចូលរួម ២៥នាក់ ស្រី ៣នាក់ នៅខេត្តកំពង់ចាម សហការអង្គការជាមួយយូណេស្កូ និងខេប
- ពិគ្រោះយោបល់ស្តីពី របាយការណ៍ការតេស្តសាកល្បងគម្រោងការធ្វើឱ្យវង្វាយតម្លៃប្រសើរឡើងសម្រាប់ទាំងអស់គ្នា មានអ្នកចូលរួម ៨០នាក់ ស្រី ៣៨នាក់ នៅខេត្តកំពត

- ពិគ្រោះយោបល់ស្តីពី ការកសាងឧបករណ៍ប្រមូលព័ត៌មានការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក មានការចូលរួមអគ្គាធិការដ្ឋាន នាយកដ្ឋានបឋមសិក្សា និងនាយដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- ពិគ្រោះយោបល់ស្តីពី ការកែលម្អសៀវភៅជំនួយស្មារតីអធិការកិច្ចសាលារៀន ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច ៥៨១សាលា មានអ្នកចូលរួម ៥៣នាក់ ស្រី ៤នាក់ នៅខេត្តព្រះវិហារ ត្បូងឃ្មុំ បន្ទាយមានជ័យ ប៉ៃលិន និងរាជធានី
- ពិគ្រោះយោបល់ស្តីពី របាយការណ៍តេស្តវង្វាយតម្លៃជំនាញសតវត្សរ៍ទី២១ មានអ្នកចូលរួម ៣១នាក់ ស្រី ៦នាក់ នៅខេត្តព្រៃវែង
- ពិគ្រោះយោបល់ស្តីពី លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា មានអ្នកចូលរួម ៧៨ នាក់ ស្រី ១៥ នាក់ នៅខេត្តកំពង់ឆ្នាំង
- ធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា ២៣០សាលា នៅខេត្ត និងរាជធានី
- ធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់តំបន់អាស៊ីអាគ្នេយ៍ និងវិភាគទិន្នន័យ ព្រមទាំងសរសេររបាយការណ៍តេស្ត ១៧៩សាលា នៅគ្រប់រាជធានី ខេត្ត សហការជាមួយអង្គការយូនីសេហ្វ
- ប្រមូលទិន្នន័យតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងសម្រាប់ថ្នាក់ទី១ មាន ២០០សាលា គម្រោងពង្រឹងកម្មវិធីការអប់រំគ្រូបង្រៀននៅកម្ពុជា
- ផ្សព្វផ្សាយស្តីពី លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់ទី៣ និងពង្រឹងការអនុវត្តវង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់ក្រោមជាតិនិងសាលារៀន ឱ្យឆ្លើយតបនឹងវង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិ ១៥ក្រុង ស្រុក មានអ្នកចូលរួម ១ ០៤៣នាក់ ស្រី ២៥៤នាក់ នៅខេត្តបាត់ដំបង សៀមរាប និងតាកែវ សហការជាមួយអង្គការយូនីសេហ្វ
- ផ្សព្វផ្សាយស្តីពី ក្របខណ្ឌវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការតាក់តែងសំណួរតេស្តស្តង់ដាកម្រិតសាលារៀន មានអ្នកចូលរួម ៤៨នាក់ ស្រី ៧នាក់ នៅខេត្តកំពង់ឆ្នាំង សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា
- រៀបចំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំ ជាលទ្ធផលរកឃើញដំណោះស្រាយឆ្លើយតបនឹងលទ្ធផល អេសអ៊ីអេ-ភីអិលអឹម ១០ចំណុច និងផ្សព្វផ្សាយថ្នាក់តំបន់ពីចម្ងាយជាផ្លូវការស្តីពី លទ្ធផលតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** មានអ្នកចូលរួម ៣៤នាក់ ស្រី ៣នាក់ នៅរាជធានី
- ពិនិត្យឡើងវិញកម្មវិធីសិក្សាមាតិកា និងខ្លឹមសារមេរៀន សម្រាប់ការបណ្តុះបណ្តាលអធិការអប់រំ មានអ្នកចូលរួម ១៤នាក់ ស្រី ៤នាក់ នៅរាជធានី
- ពិនិត្យតាមដានស្តីពី វឌ្ឍនភាពនៃការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំ នៅខេត្តតាកែវ ស្ទឹងត្រែង សៀមរាប បាត់ដំបង និងត្បូងឃ្មុំ
- ពិនិត្យតាមដានស្តីពី ការសិក្សាពីចម្ងាយនិងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ផ្តោតលើសាលារៀនទទួលបានពានរង្វាន់ សាលារៀនល្អ និងនាយកល្អ ភាគសំណាកដែលត្រូវបានជ្រើសរើសឱ្យចូលរួមបំពេញកម្រងសំណួរស្ទាបស្ទង់ មាននាយកសាលា ១៧នាក់ និងគ្រូបង្រៀន ៦៧៣នាក់ នៅខេត្ត និងរាជធានី
- ពង្រឹងសមត្ថភាពអធិការអប់រំ និងប្រធានក្រុមបច្ចេកទេស ក្នុងការធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សា និងវាយតម្លៃលទ្ធផលការងារឆ្លើយតបនឹងកំណែទម្រង់វិស័យអប់រំលើចំណុចអាទិភាព មានអ្នកចូលរួម ១០២នាក់ ស្រី ២៧នាក់ នៅខេត្តកំពង់ចាម

- ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចស្តីពី ការធ្វើសុខដុមនីយកម្មឧបករណ៍អធិការកិច្ចសាលារៀនតាមកាលកំណត់ ជាមួយនឹងឧបករណ៍ការគ្រប់គ្រងតាមសាលារៀន កម្មវិធីសាលាកុមារមេត្រី និងស្តង់ដាសាលារៀនមានគុណភាព មានអ្នកចូលរួម ២២នាក់ ស្រី ៤នាក់ នៅរាជធានី
- សិក្ខាសាលាបូកសរុបលទ្ធផលការងារអធិការកិច្ចតាមកាលកំណត់ និងលទ្ធផលរបាយការណ៍អធិការកិច្ចតាមប្រធានបទ មានអ្នកចូលរួម ១២៥នាក់ ស្រី ១២នាក់ នៅខេត្តកំពង់ចាម
- ពិនិត្យ សិក្សាលទ្ធភាព និងបំពាក់បន្ទប់កុំព្យូទ័រ នៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ តាពេន ស្ថិតនៅភូមិស្រះខ្វាយ ឃុំតែ្បង ស្រុកបន្ទាយស្រី នៅខេត្តសៀមរាប
- ពិនិត្យការរៀននិងបង្រៀនពីចម្ងាយនៅតាមសាលារៀន ដើម្បីធានាឱ្យការអប់រំអាចប្រព្រឹត្តទៅបានទោះបីសាលាកំពុងត្រូវបានបិទទ្វារជាបណ្តោះអាសន្នក្នុងស្ថានភាពអន្តរកាលដែលបង្កដោយជំងឺកូវីដ-១៩ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** នៅខេត្តកណ្តាល និងកំពង់ឆ្នាំង
- ផ្តល់កុំព្យូទ័រ ដើម្បីគាំទ្រការរៀននិងបង្រៀន ដល់សាលាបឋមសិក្សាវត្តបូព៌ ៣០គ្រឿង និងបន្ទាយស្រី ២៥គ្រឿង សហការជាមួយក្រុមហ៊ុនកូមពី នៅខេត្តសៀមរាប
- វាយតម្លៃលទ្ធផលសិក្សាសិស្សថ្នាក់ទី៤ មាន ២៦សាលា និងបង្ហាញថាមានកុមារដល់ទៅ ៧៣ភាគរយ ស្រី ៨១ភាគរយ បានជាប់លទ្ធផលតេស្តភាសាខ្មែរនៅឆ្នាំ២០២០ ចំណែកលទ្ធផលសម្រាប់ឆ្នាំ២០១៩ មានតែ ៦៣ភាគរយ ស្រី ៧២ភាគរយ នៅខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង ពោធិ៍សាត់ និងកោះកុង សហការជាមួយអង្គការសង្គ្រោះកុមារកម្ពុជា។

*ប្រការនេះ បានជួយជំរុញនិងកែលម្អបញ្ហាដែលកើតមានតាមគ្រឹះស្ថានសិក្សាទាន់ពេលវេលា។*

## *អត្រាលំហូរសិស្ស*

អត្រាឡើងថ្នាក់ថយមកត្រឹម ៨៥,៧ភាគរយ ស្រី ៨៧,៩ភាគរយ និងប្រុស ៨៣,៦ភាគរយ។ អត្រាត្រួតថ្នាក់បានកើនដល់ ៧,០ភាគរយ ស្រីថយ ៥,៣ភាគរយ និងប្រុសកើនដល់ ៨,៧ភាគរយ។ អត្រាបោះបង់ការសិក្សាបានកើនដល់ ៧,៣ភាគរយ ស្រី ៦,៨ភាគរយ និងប្រុសនៅដដែល ៧,៧ភាគរយ។

**តារាងទី៥ ៖ អត្រាលំហូរសិស្ស**

| បរិយាយ | | អត្រាលំហូរ (សរុប) | | | អត្រាលំហូរ (ស្រី) | | | អត្រាលំហូរ (ប្រុស) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ | ឡើងថ្នាក់ | ត្រួតថ្នាក់ | បោះបង់ |
| ២០១៩-២០ | ថ្នាក់ជាតិ | ៨៥,៧ | ៧,០ | ៧,៣ | ៨៧,៩ | ៥,៣ | ៦,៨ | ៨៣,៦ | ៨,៧ | ៧,៧ |
| | ប្រជុំជន | ៨៧,៣ | ៥,៨ | ៧,០ | ៨៩,៤ | ៤,៣ | ៦,៣ | ៨៥,៣ | ៧,១ | ៧,៥ |
| | ជនបទ | ៨៥,៤ | ៧,៣ | ៧,៣ | ៨៧,៦ | ៥,៥ | ៦,៩ | ៨៣,៣ | ៩,០ | ៧,៧ |
| ២០១៨-១៩ | ថ្នាក់ជាតិ | ៨៦,៩ | ៦,៣ | ៦,៨ | ៨៩,៥ | ៤,៧ | ៥,៩ | ៨៤,៥ | ៧,៨ | ៧,៧ |
| | ប្រជុំជន | ៨៩,៥ | ៤,៨ | ៥,៧ | ៩១,៩ | ៣,៤ | ៤,៧ | ៨៧,២ | ៦,១ | ៦,៧ |
| | ជនបទ | ៨៦,៤ | ៦,៦ | ៧,០ | ៨៩,០ | ៤,៩ | ៦,១ | ៨៣,៩ | ៨,២ | ៧,៩ |

*កំណត់សម្គាល់៖ អត្រាលំហូរសិស្សនេះមិនបានគិតបញ្ចូលសាលាឯកជនទេ។*

## *អត្រាបញ្ចប់ការសិក្សា*

អត្រាបញ្ចប់ការសិក្សាមាន ៨៧,៤ភាគរយ ស្រី ៩១,៦ភាគរយ ប្រុស ៨៣,៤ភាគរយ។

### តារាងទី៦ ៖ អត្រាបញ្ចប់ការសិក្សា

| បរិយាយ | អត្រាបញ្ចប់ការសិក្សា ២០១៩-២០២០ | | | អត្រាបញ្ចប់ការសិក្សា ២០២០-២០២១ | | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| ថ្នាក់ជាតិ | ៨៨,២ | ៩២,៧ | ៨៤,១ | ៨៧,៤ | ៩១,៦ | ៨៣,៤ |
| ប្រជុំជន | ៩៤,០ | ៩៨,៧ | ៨៩,៧ | ៩៣,៩ | ៩៨,៣ | ៨៩,៨ |
| ជនបទ | ៨៦,៧ | ៩១,០ | ៨២,៧ | ៨៥,៧ | ៩០,០ | ៨១,៧ |

*កំណត់សម្គាល់៖ អត្រាបញ្ចប់ការសិក្សានេះរួមបញ្ចូលសាលាឯកជន។*

## ក.២ ធានាស័ក្តិសិទ្ធិភាពនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### *បុគ្គលិកអប់រំ*

ក្រសួងបាន៖

- ពង្រាយគ្រូបង្រៀនបឋមសិក្សាពីសាលាលើសទៅសាលាខ្វះគ្រូ ១៨នាក់ ស្រី ១៣នាក់
- ពង្រាយគ្រូបង្រៀនបឋមសិក្សាចេញថ្មី ១ ៦១៨ នាក់ ស្រី ១ ០៥៣ នាក់ ទៅសាលារៀនដែលមានតម្រូវការគ្រូបង្រៀន។

### *ការលើកទឹកចិត្តបុគ្គលិកអប់រំ*

ក្រសួងបាន៖

- ប្រកាសតែងតាំងគ្រូបង្រៀនកម្រិតបឋមសិក្សា ១ ៨១៨នាក់ ស្រី ១ ២៤៧នាក់ ក្នុងនោះគ្រូបឋមសិក្សា ១ ៦១៨ នាក់ ស្រី ១ ០៥៣នាក់ ស្មើ ៦៥,១ភាគរយ និងគ្រូមត្តេយ្យសិក្សា ២០០នាក់ ស្រី ១៩៤នាក់ ស្មើ ៩៧ភាគរយ
- តែងតាំងស៊ប់ក្នុងក្របខណ្ឌជូនគ្រូបង្រៀនកម្រិតបឋម ២ ០០១នាក់ ស្រី ១ ៣៣៦នាក់
- ប្រកាសដំឡើងថ្នាក់គ្រូបង្រៀនកម្រិតបឋម ២៤ ៧២៨នាក់ ស្រី ១១ ២៤៧នាក់ ស្មើ ៤៥,៥ភាគរយ
- អនុវត្តការបើកបៀវត្សតាមប្រព័ន្ធធនាគារពីរដងក្នុងមួយខែ
- ឧបត្ថម្ភប្រាក់លើកទឹកចិត្តដល់មន្ត្រីលំហែមាតុភាព ជាពិសេសមន្ត្រីជាប់កិច្ចសន្យា
- ផ្តល់គ្រឿងឥស្សរិយយសដល់បុគ្គលិកអប់រំគ្រប់កម្រិតជារៀងរាល់ឆ្នាំ
- វាយតម្លៃនាយកសាលាល្អ គ្រូបង្រៀនល្អ សាលារៀនស្អាត គ្រូបង្រៀនល្អថ្នាក់ទី១ ដល់ទី៣ និងសាលាមេត្រីបរិស្ថាន។

*ប្រការនេះ បានលើកទឹកចិត្តនិងជួយជំរុញបុគ្គលិកអប់រំ ឱ្យបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

### *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| សូចនាករ | | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ៖ លើកកម្ពស់ការចូលរៀនហូតដល់ចប់ថ្នាក់ទី៦ នៃបឋមសិក្សាសម្រាប់កុមារទាំងអស់ ជាពិសេសក្រុមកុមារជួបការលំបាក | | | | | | |
| ១. | អត្រាពិតចូលរៀនថ្មី | % | ៩៦,៤ * | ៩៧,២ | ៨៧,៤ * | ↓ |
| | *ប្រុស* | % | ៩៦,៥ * | ៩៧,២ | ៨៦,៨ * | ↓ |
| | *ស្រី* | % | ៩៦,៣ * | ៩៧,១ | ៨៨,០ * | ↓ |
| ២. | អត្រាពិតនៃការសិក្សា | % | ៩៧,៣ * | ៩៨,២ | ៩១,៩ * | ↓ |
| | *ប្រុស* | % | ៩៦,៨ * | ៩៨,១ | ៩១,០ * | ↓ |
| | *ស្រី* | % | ៩៧,៩ * | ៩៨,៦ | ៩២,៣ * | ↓ |

| | សូចនាករ | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| ៣. | អត្រាបោះបង់ការសិក្សា | % | ៦,៨ ** | ៣,១ | ៧,៣ *** | ↓ |
| | *ប្រុស* | % | ៧,៧ ** | ៣,៤ | ៧,៧ *** | ↓ |
| | *ស្រី* | % | ៥,៩ ** | ២,៦ | ៦,៨ *** | ↓ |
| ៤. | អត្រាត្រួតថ្នាក់ | % | ៦,៣ ** | ៥,៣ | ៧,០ *** | ↓ |
| | *ប្រុស* | % | ៧,៨ ** | ៦,២ | ៨,៧ *** | ↓ |
| | *ស្រី* | % | ៤,៧ ** | ៣,៨ | ៥,៣ *** | ↓ |
| ៥. | ស្រុកដែលសម្រេចបានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាងឬស្មើ ១០ភាគរយ | ចំនួន | ១៨៣** | ១៧៩ | ១៧០ | ↓ |
| ៦. | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨៨,២* | ៨៤,៨ | ៨៧,៤* | ↑ |
| | *ប្រុស* | % | ៨៤,១* | ៨២,៦ | ៨៣,៤* | ↑ |
| | *ស្រី* | % | ៩២,៧* | ៨៩,២ | ៩១,៦* | ↑ |
| ៧. | អត្រាគង់វង្សនៅបឋមសិក្សា | % | ៧៨,១ ** | ៨៣,៦ | ៨០,២ *** | → |
| | *ប្រុស* | % | ៧៣,៤ ** | ៨១,៣ | ៧៥,៧ *** | → |
| | *ស្រី* | % | ៨៣,១ ** | ៨៦,២ | ៨៥,២ *** | → |
| ៨. | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | % | ៨៥,០** | ៨៧,៨ | ៨៤,៣*** | ↓ |
| | *ប្រុស* | % | ៨១,៥** | ៨៥,៥ | ៨០,១*** | ↓ |
| | *ស្រី* | % | ៨៨,៦** | ៩០,០ | ៨៨,៥ *** | → |
| ៩. | ភាគរយសិស្សថ្មីថ្នាក់ទី១ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | % | ៧១,៣ | ៧០,៧ | ៧៤,៥ | ↑ |
| ១០. | ភាគរយសាលាកុមារមេត្រីកម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ | % | ៧៤,៣**** | ៨២,៩ | ៧៩,៣ **** | → |
| ១១. | ភាគរយសាលាបឋមសិក្សាមានអគ្គិសនីប្រើប្រាស់ | % | ៨៨,១ | ៥៨,៨ | ៨៤,៩ | ↑ |
| ១២. | ភាគរយសាលាបឋមសិក្សាអនុវត្តស្តង់ដា ទឹកស្អាត និងអនាម័យ៖ | | | | | |
| | *កម្រិត១* | % | ៤០,៦ | ៥០,៦ | ៣៦,០ | ↓ |
| | *កម្រិត២* | % | ៣១,០ | ២៣,៤ | ៣៨,៦ | ↑ |
| | *កម្រិត៣* | % | ២,៤ | ១,៦ | ៣៣,០ | ↑ |
| ១៣. | ភាគរយសាលាបឋមសិក្សាមាន៖ | | | | | |
| | *បង្គន់អនាម័យ* | % | ៩៩,៣ | ៩៣,២ | ១០០,០ | ↑ |
| | *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៩០,៤ | ៦២,១ | ៨៩,៦ | ↑ |
| | *កន្លែងលាងដៃ* | % | ៧៤,៧ | ៦១,៧ | ៨១,២ | ↑ |
| | *ប្រអប់សង្គ្រោះបឋម* | % | ៥៣,៥ | ៥៧,៦ | ៥៧,៨ | ↑ |
| ១៤. | សិស្សបឋមសិក្សាបានទទួលអាហារនៅតាមសាលារៀន | ចំនួន | ៥២ ១៣០ | ៤០ ០០០ | ៥៣ ៧៣៧ | ↑ |
| ១៥. | សិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | ចំនួន | ១១០ ១៥៦ (២០១៨-១៩) | ៩៧ ០០០ | ១២២ ២២៨ (២០១៩-២០) | ↑ |
| ១៦. | គ្រូបង្រៀនពហុភាសា | ចំនួន | ២១៩ | ២៣១ | ២៣១ | ↑ |
| ១៧. | គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិតឌីប្លូម៉ាស្តីពីការអប់រំពិសេសនៅវិទ្យាស្ថានអប់រំពិសេស | ចំនួន | ២០ | ២២ | ២២ | ↑ |
| វត្ថុបំណងអនុវិស័យទី២៖ កែលម្អការផ្តល់ជាតុចូលប្រកបដោយគុណភាពនៅបឋមសិក្សា | | | | | | |
| ១៨. | ផលធៀបសិស្ស-គ្រូ | ផលធៀប | ៤៥,១ | ៤៨ | ៤៤,៨ | ↓ |
| ១៩. | ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រតាមស្តង់ដា(សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ+២) | % | ៧៩,០ | ៧៦,០ | ៧៥,០ | ↓ |
| ២០. | ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែម | | | | | |
| | *កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង* | ចំនួន | ២ ០២៥** | ៣ ៥០០ | ៤ ១០០*** | ↑ |
| | *កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូង* | ចំនួន | ៨៥៦** | ៣ ៥០០ | ២ ៨៦០*** | → |

| សូចនាករ | | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| | *ការបំប៉នសមត្ថភាពផ្សេងទៀត* | ចំនួន | ២ ៥០០** | ៣ ០០០ | ៣ ៥០០*** | ↑ |
| ២១. | ភាគរយគ្រូបង្រៀនបឋមសិក្សាដែលបានបញ្ចប់បរិញ្ញាបត្រនៅវិទ្យាស្ថានគរុកោសល្យ | % | កំពុងបណ្តុះបណ្តាល ២៩៧ | ៣,០ | កំពុងបណ្តុះបណ្តាល៥៩៤ | ↑ |
| ២២. | ភាគរយសិស្សបឋមសិក្សាទទួលបានសៀវភៅសិក្សាគោល ១ សម្រាប់ក្នុងម្នាក់ | % | ៩៨,០ | ៩៦,០ | ៩៨,២ | ↑ |
| ២៣. | សាលាបឋមសិក្សាមានបន្ទប់កុំព្យូទ័រសម្រាប់សិស្ស | ចំនួន | ៣១ | ២២០ | ៧៦ | → |
| ២៤. | សាលាបឋមសិក្សា មានបណ្ណាល័យតាមស្តង់ដា | ចំនួន | ១ ៨៨៣ | ២ ៨០០ | ១ ៤២៧ | ↓ |
| គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹកការអនុវត្តស្តង់ដាបឋមសិក្សាតាមរយៈការគ្រប់គ្រងសាលារៀន | | | | | | |
| ២៥. | នាយកបឋមសិក្សាបានទទួលការបំប៉នស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៥៣០ | ៥០០ | ០០ | ↓ |
| ២៦. | សាលាបឋមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ | ចំនួន | ១៦០** | ២៦០ | ១៦០*** | → |

សម្គាល់៖ ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

* រួមបញ្ចូលទាំងសាលាឯកជន ** ឆ្នាំសិក្សា២០១៨-២០១៩ *** ឆ្នាំសិក្សា២០១៩-២០២០

**** មិនគិតសាលាបឋមសិក្សាមិនគ្រប់កម្រិត

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការអនុវត្ត ស្តីពីការគ្រប់គ្រងតាមសាលារៀន នៅមានទំហំតូចធៀបទៅនឹងសាលាបឋមសិក្សាទូទាំងប្រទេស
- កង្វះគ្រូនៅតាមសាលារៀនដាច់ស្រយាលនិងជួបការលំបាក
- បញ្ហាគ្រូលើសនិងគ្រូខ្វះនៅតាមសាលារៀន
- កង្វះគ្រូថ្នាក់ទី១និងទី២ កង្វះបណ្ណារក្សនិងជំនាញបណ្ណាល័យ
- សមត្ថភាពគ្រូបង្រៀននៅមានកម្រិតលើចំណេះដឹង វិធីសាស្ត្របង្រៀន បទពិសោធ ការគ្រប់គ្រងថ្នាក់រៀន
- ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ចម្អិនបានតិចតួច ធ្វើឱ្យការអនុវត្តថវិកា សម្រេចបាន ៤៧ភាគរយនៃថវិកាសរុប
- ការគ្រប់គ្រងស្ថិតិ ទិន្នន័យសិស្សអាហារូបករណ៍មានភាពយឺតយ៉ាវ
- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធនិងឧបករណ៍អេឡិចត្រូនិក
- កង្វះខាតទឹកស្អាត បង្គន់អនាម័យ ការប្រើប្រាស់និងថែទាំបង្គន់អនាម័យ សម្ភារៈអនាម័យ ជាពិសេសសម្ភារៈដែលបម្រើឱ្យការលាងសម្អាតដៃ សម្ភារៈម្ងាប់មេរោគ និងឯកសារអប់រំសុខភាពនៅតាមសាលារៀន
- ការខាតបង់ពេលវេលារៀនសូត្ររបស់សិស្ស គរុសិស្ស គរុនិស្សិត។

## ២.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០២០-២០២១ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ១ ៨០០ កើន ០៩ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៦ ថយ ១ និងវិទ្យាល័យ ៥៥៤ កើន ១០ (វិទ្យាល័យធនធាន ៥០ និងវិទ្យាល័យអប់រំពិសេស ៥) វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ៥២០ កើន ១០ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន ៣៤ ថេរ។

គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ២៤៩ ថយ ៩ ក្នុងនោះអនុវិទ្យាល័យ ៦២ ថយ ២៥ និងវិទ្យាល័យ ១៨៧ កើន ១៦។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ទី១២ មាន ១៨២ កើន ១៥ និងកម្រិតថ្នាក់ទី១០ ដល់ទី១២ មាន ៥ កើន ១។

ឃុំ សង្កាត់ ១១៤ លើ ១ ៦៤៦ ស្មើ ៦,៩២ភាគរយ មិនទាន់មានអនុវិទ្យាល័យ (ថយ ១ ឃុំ សង្កាត់) ក្នុងនោះរាជធានី ៤៦សង្កាត់ មិនតម្រូវឱ្យបង្កើតអនុវិទ្យាល័យ និងខេត្តរតនគិរី ២៦ឃុំ មិនទាន់ទាមទារឱ្យបង្កើតអនុវិទ្យាល័យ។ ដោយឡែកស្រុក ២ លើ ២០៣ ស្មើ ០,៩៨ភាគរយ មិនទាន់មានវិទ្យាល័យ គឺ បុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងក្រុងកោះរ៉ុង ខេត្តព្រះសីហនុ ដោយសារស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ។

ក្រសួងបាន៖

- សាងសង់អគារសិក្សាសម្រាប់វិទ្យាល័យដែលមានសិស្សច្រើន ២ខ្នង កម្ពស់ ២ជាន់ ស្មើ ២០បន្ទប់ បន្ទប់ទឹក ២ខ្នង ស្មើ ១០បន្ទប់ និងអណ្តូងទឹក ២
- កំពុងសាងសង់ផ្ទះគ្រូ ៤៤ខ្នង ស្មើ ១៣២បន្ទប់
- សាងសង់អគារធនធាន ១៤ខ្នង កម្ពស់ ២ជាន់ នៅ ១៤ខេត្ត និងអគារសិក្សាសម្រាប់អនុវិទ្យាល័យពង្រីកជាវិទ្យាល័យ ៥ខ្នង ស្មើ ២៥បន្ទប់ បន្ទប់ទឹក ៥ខ្នង ស្មើ ១៥បន្ទប់ និងអណ្តូងទឹក៥ នៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ
- ជួសជុលអគារសិក្សា ៧២បន្ទប់ ផ្ទះគ្រូ ៥បន្ទប់ បង្គន់អនាម័យ២៩ សាងសង់ថ្មី ៥បន្ទប់ ជួសជុល ២៤បន្ទប់ ១១កន្លែង ៦ខេត្តដាច់ស្រយាល នៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ
- ជួសជុលបន្ទប់សិក្សាទៅជាបន្ទប់ពហុបំណងនៅវិទ្យាល័យធនធាន ២៥ នៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២
- កំពុងសាងសង់អគារធនធាន ១៧ខ្នង កម្ពស់ ២ជាន់ និងអគារសិក្សា ២៣ខ្នង ស្មើ ២៩៩បន្ទប់ សម្រាប់វិទ្យាល័យមានសិស្សច្រើន ផ្ទះគ្រូ ៥ខ្នង ស្មើ ១៥បន្ទប់ បន្ទប់ទឹក ៣២ខ្នង ស្មើ ១៦០បន្ទប់ នៅខេត្តកណ្តាល កំពង់ចាម និងរាជធានី នៃគម្រោងជំនួយសាធារណរដ្ឋប្រជាមានិតចិន
- ជួសជុលអគារសិក្សា ១ខ្នង ៦បន្ទប់ នៅអនុវិទ្យាល័យមួយកន្លែង និងរៀបចំប្រព័ន្ធរំដោះទឹកក្នុងអនុវិទ្យាល័យមួយកន្លែងទៀត កែលម្អហេដ្ឋារចនាសម្ព័ន្ធអគារសិក្សានៅវិទ្យាល័យ ២កន្លែង
- សាងសង់អគារសិក្សា ១ខ្នង ៦បន្ទប់ បង្គន់អនាម័យ ១ខ្នង ៥បន្ទប់នៅវិទ្យាល័យ ១កន្លែង នៃគម្រោងកែលម្អការអប់រំចំណេះទូទៅ
- កម្មវិធីកំណែទម្រង់វិស័យអប់រំគាំទ្រដោយសហភាពអឺរ៉ុប (EU-ESRP) នឹងចុះសិក្សារៀបចំផែនការសាងសង់អនុវិទ្យាល័យ និងវិទ្យាល័យ ១៨កន្លែង។

អនុវិទ្យាល័យ និងវិទ្យាល័យមានបង្គន់អនាម័យ១០០ភាគរយ។ អនុវិទ្យាល័យ ១០,៤០ភាគរយ និងវិទ្យាល័យ ៨,៨ភាគរយ មិនទាន់មានទឹកស្អាត។ អនុវិទ្យាល័យ ១៩,៨ភាគរយ និងវិទ្យាល័យ ១៤,៦០ភាគរយ មិនទាន់មានកន្លែងសម្អាតដៃ។ អនុវិទ្យាល័យ ៥៤,៧០ភាគរយ និងវិទ្យាល័យ ៣១,៩០ភាគរយ មិនទាន់មានប្រអប់សង្គ្រោះបឋម។

ក្រសួងបាន៖

- បង្រៀនសាកល្បងការប្រើប្រាស់សៀវភៅសិក្សាគោល មុខវិជ្ជាអប់រំសុខភាព ថ្នាក់ទី៨ និងថ្នាក់ទី១១ នៅខេត្តកំពង់ស្ពឺ មានអ្នកចូលរួម ៦៦នាក់ ស្រី៣៨នាក់
- សហការធ្វើយុទ្ធនាការផ្សព្វផ្សាយទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០២០
- អភិវឌ្ឍនិងបោះពុម្ពសៀវភៅស្តីពី ឯកសារបង្រៀន ការបង្ការ ការទប់ស្កាត់គ្រោះថ្នាក់បង្កដោយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ៦ ០០០ក្បាល សម្រាប់ចែកផ្សាយតាមសាលាមធ្យមសិក្សាគោលដៅ សហការជាមួយអង្គការភ្លែនអន្តរជាតិកម្ពុជា
- ផ្សព្វផ្សាយគ្រោះថ្នាក់ និងការបង្ការនៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ដល់វិទ្យាល័យ ២ក្នុងខេត្តព្រះវិហារ និងវិទ្យាល័យ ២ក្នុងខេត្តស្ទឹងត្រែង មានអ្នកចូលរួម ៤១០នាក់ ស្រី ២១៩នាក់
- សម្របសម្រួលរៀបចំបង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងបណ្ដាញទឹកស្អាត ១១៥សាលានៅគ្រប់រាជធានីខេត្ត គាំទ្រដោយថវិកាជាតិ
- ចែកផ្សាយសៀវភៅដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ ចំនួន ១២ ១៧៩ក្បាល ដល់គ្រប់សាលាមធ្យមសិក្សាទូទាំងប្រទេស សហការជាមួយអង្គការយូនីសេហ្វ
- ផ្តល់ឧបករណ៍វាស់កម្ដៅ ២២៥គ្រឿង ឧបករណ៍លាងសម្អាតដៃ ១៧០៩គ្រឿង និងសាប៊ូដុំ ៧៥មីលីក្រាម ២០ ០៤៣ដុំ ដល់សាលាមធ្យមសិក្សានៅរាជធានី និងខេត្តគោលដៅ ៤ គាំទ្រដោយ USAID
- ផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនដល់សិស្សានុសិស្សសាលាមធ្យមសិក្សាសាធារណៈលើកទី១ ចំនួន ៨១១ ១៣៧នាក់ ស្មើ ៨៥,០៥ ភាគរយ ស្រី ៤១០ ៣២០នាក់ ស្មើ ៨០,៦១ភាគរយ និងលើកទី២ ចំនួន ៣៧៧ ៩០៤នាក់ ស្មើ ៣៩,៦៣ភាគរយ ស្រី ២០២ ៥៦៩នាក់ ស្មើ ៣៩,៨០ភាគរយ សហការជាមួយក្រសួងសុខាភិបាល
- រៀបចំប្រអប់សង្គ្រោះបឋមសម្រាប់សាលាមធ្យមសិក្សាសាធារណៈ ១ ១១៦សាលា ស្មើ ៦២,៣១ភាគរយ កើន ១៦,៩៧ភាគរយ មានបន្ទប់សុខភាព ៩៩សាលា ស្មើ ៥,៥៣ភាគរយ កើន ៤,៥៨ភាគរយ បើប្រៀបធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩។

បុគ្គលិកអប់រំនៅមធ្យមសិក្សាឆ្នាំសិក្សា២០២០-២០២១ មាន ៥១ ១៥៣នាក់ កើន ១ ០៩១នាក់ ស្រី ២០៤៣០នាក់ កើន ៥៥៩នាក់ ក្នុងនោះមធ្យមសិក្សាបឋមភូមិមាន ៣៣ ២៧៤នាក់ កើន ៦៥៤នាក់ ស្រី ១៤ ១៧១នាក់ កើន ៤៧៧នាក់ និងមធ្យមសិក្សាទុតិយភូមិមាន ១៧ ៨៧៩នាក់ កើន ៤៣៧នាក់ ស្រី ៦ ២៥៩នាក់ កើន ៨២នាក់។

បុគ្គលិកបង្រៀនមាន ៤៣ ៦៣១នាក់ កើន ៧៣៤នាក់ ស្រី ១៨ ៤៣១នាក់ កើន ៤៥៦នាក់ ក្នុងនោះមធ្យមសិក្សាបឋមភូមិមាន ២៨ ១៧៤នាក់ កើន ៤៣៦នាក់ ស្រី ១២ ៨៥១នាក់ កើន ៤០៦នាក់ និងមធ្យមសិក្សាទុតិយភូមិមាន ១៥ ៤៥៧ នាក់ កើន ២៩៨នាក់ ស្រី ៥ ៥៧៤នាក់ កើន ៥០នាក់។

ក្រសួងបានបែងចែកគ្រូបង្រៀនចេញថ្មី ៣ ៤៤៣នាក់ ស្រី ២ ០២១នាក់ ក្នុងនោះគ្រូកម្រិតមូលដ្ឋានឯកទេសអប់រំកាយនិងកីឡា ១០១នាក់ ស្រី ៥នាក់ គ្រូកម្រិតមូលដ្ឋានឯកទេសផ្សេងៗ ៦៧៨នាក់ ស្រី ៣៧៦នាក់ និងគ្រូមធ្យមសិក្សាទុតិយភូមិ ៨៤៦នាក់ ស្រី ៣៩៣នាក់។ គ្រូបង្រៀនចេញថ្មីដែលត្រូវធ្វើកម្មសិក្សាការងារ ៣ ១៧៨នាក់ ស្រី ១ ៩២៧នាក់។

*បុគ្គលិកអប់រំកើននៅមធ្យមសិក្សាបឋមភូមិ និងថយនៅមធ្យមសិក្សាទុតិយភូមិ ដែលបានឆ្លងកាត់ការបណ្ដុះបណ្ដាលពេញលេញ សមស្របតាមកំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្រ្តបង្រៀនថ្មី។*

អត្រាររួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦០,៧០ភាគរយ កើន ០,៨០ភាគរយ ស្រី ៦៦,៦០ភាគរយ កើន ១,៥០ភាគរយ ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៥៧,៤០ភាគរយ ស្រី ៦៣,២០ភាគរយ និងឯកជន ៣,៣០ភាគរយ ស្រី ៣,៤០ភាគរយ។

អត្រាឆ្លងភូមិសិក្សានៅមធ្យមសិក្សាបឋមភូមិ ៨១,៣០ភាគរយ កើន ៦,៤០ភាគរយ ស្រី ៨២,៤០ភាគរយ កើន ៣,៨០ភាគរយ។

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ៣២,២០ភាគរយ កើន ១,៣០ភាគរយ ស្រី ៣៦,៤០ ភាគរយ កើន១,៣០ភាគរយ ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៣០,១០ភាគរយ ស្រី ៣៤,២០ភាគរយ និងឯកជន ២,១០ ភាគរយ ស្រី ២,២០ភាគរយ។

**តារាងទី៧ ៖ ស្ថិតិមធ្យមសិក្សាប្រៀបធៀបរវាងឆ្នាំសិក្សា ២០១៨-២០១៩ និង២០១៩-២០២០**

| បរិយាយ | ២០១៩-២០២០ | ២០២០-២០២១ | កើន/ថយ (+/-) |
|---|---|---|---|
| **អនុវិទ្យាល័យ** | | | |
| សាលារៀន * | ១ ៣៣៤ | ១ ៣០៨ | -២៦ |
| បន្ទប់រៀន * | ៧ ១០៣ | ៧ ៣២៧ | +២២៤ |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យសរុប | ១៧ ២៦០ | ១៧ ២៩៥ | +៣៥ |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យស្រី | ៧ ១៥៣ | ៧ ១៦៨ | +១៥ |
| ថ្នាក់រៀនមធ្យមសិក្សាបឋមភូមិ * | ១៥ ១៣១ | ១៥ ៧៧៣ | +៦៤២ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិសរុប | ៣២ ៦២០ | ៣៣ ២៧៤ | +៦៥៤ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិស្រី | ១៣ ៦៩៤ | ១៤ ១៧១ | +៤៧៧ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិសរុប | ២៧ ៧៣៨ | ២៨ ១៧៤ | +៤៣៦ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិស្រី | ១២ ៤៥១ | ១២ ៨៥៧ | +៤០៦ |
| សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋសរុប | ៦១៨ ៩៦៨ | ៦៣២ ៣០៣ | +១៣ ៣៣៥ |
| សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋស្រី | ៣២៥ ៥០៤ | ៣៣ ៩៩៧២ | +១០ ៤៦៨ |
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនសរុប | ៣៦ ០៨៧ | ៣៦ ៣៣៤ | +២៤៧ |
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនស្រី | ១៨ ៥៤៦ | ១៨ ៣៤១ | -២០៥ |
| **វិទ្យាល័យ** | | | |
| សាលារៀន * | ៧១៥ | ៧៤១ | +២៦ |
| បន្ទប់រៀន * | ១៤ ១៥៦ | ១៥ ៥៩០ | +១ ៤៣៤ |
| បុគ្គលិកអប់រំនៅវិទ្យាល័យសរុប | ៣២ ៨០២ | ៣៣ ៨៥៨ | +១ ០៥៦ |
| បុគ្គលិកអប់រំនៅវិទ្យាល័យស្រី | ១២ ៧១៨ | ២៦ ១៤៥ | +១៣ ៤២៧ |
| ថ្នាក់រៀនមធ្យមសិក្សាទុតិយភូមិ * | ៨ ៤០០ | ៩ ០៦៤ | +៦៦៤ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិសរុប | ១៧ ៤៤២ | ១៧ ៨៧៩ | +៤៣៧ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិស្រី | ៦ ១៧៧ | ៦២ ៥៩ | +៨២ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិសរុប | ១៥ ១៥៩ | ១៥ ៤៥៧ | +២៩៨ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិស្រី | ៥ ៥២៤ | ៥ ៥៧៤ | +៥០ |
| សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋសរុប | ៣៣៤ ៧១២ | ៣៥១ ៧៩៤ | +១៧ ០៨២ |
| សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋស្រី | ១៨៣ ៣៩៤ | ១៩១ ៩៧៣ | +៨ ៥៧៩ |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនសរុប | ២៣ ៨៤១ | ២៤ ៨៩៨ | +១ ០៥៧ |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនស្រី | ១២ ២០៩ | ១២ ៥៧៦ | +៣៦៧ |

*** រួមបញ្ចូលទាំងសាលាឯកជន**

គ្រឹះស្ថានសិក្សាដែលផ្តល់សេវាអប់រំបច្ចេកទេសតាមកម្មវិធី ៩+៣ មាន ១៧ ក្នុងនោះមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសសាធារណៈ ១២ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជន ០៣ វិទ្យាស្ថាន ២ វិទ្យាស្ថានអភិវឌ្ឍន៍

សហគមន៍នៃសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ និងវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៃសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ មានសិស្សអប់រំបច្ចេកទេសសរុប ៣ ៣២៤នាក់ ស្រី ១ ២៦៩នាក់ ធៀបនឹងឆ្នាំសិក្សាកន្លងទៅកើន ៦២៤នាក់ ស្មើ ២៣,១១ភាគរយ ស្រី ២៣៣នាក់ និងគ្រូបច្ចេកទេស ២១០នាក់ កើន ៥២នាក់ ស្មើ ៣២,៩១ភាគរយ ស្រី ៥២នាក់ កើន ៨នាក់។

មជ្ឈមណ្ឌលអប់រំបច្ចេកទេសមិត្តភាពកម្ពុជា-ជប៉ុនខេត្តសៀមរាប បានបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ដល់យុវជន ៨៧នាក់ ស្រី ៤០នាក់ លើជំនាញដំណាំបន្លែ បណ្តុះផ្សិត ការិយាល័យជួរមុខ កុំព្យូទ័ររដ្ឋបាល សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ ភាសាជប៉ុន ការធ្វើនំ និងផលិតភេសជ្ជៈ។

ក្រសួងបានបំពាក់សម្ភារបច្ចេកទេសសម្រាប់សិស្សប្រតិបត្តិ និងបណ្តុះបណ្តាលការប្រើប្រាស់សម្ភារបរិក្ខារបច្ចេកទេសជំនាញក្បេត្រសាស្ត្រនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ជា ស៊ីម** ត្បែងមានជ័យ និងជំនាញកែច្នៃអាហារនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។

តារាងទី៨ ៖ ស្ថិតិសិស្សវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស

| បរិយាយ | ២០១៩-២០២០ | | ២០២០-២០២១ | | កើន/ថយ(+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសអនុវត្តកំពង់ឈើទាលនៃវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ៥៥៤ | ២៧៦ | ៥៩៣ | ២៩៥ | +៣៩ | +១៩ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**-ROTA ខ្សាច់កណ្តាល | ៣១៧ | ៤៣ | ៣៧៦ | ៤១ | +៥៩ | -២ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** | ៤២១ | ១៧២ | ៤៧២ | ២១៦ | +៥១ | +៤៤ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ | ១១៦ | ៥២ | ១៤៤ | ៧១ | +២៨ | +១៩ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពួក | ១១៥ | ២ | ១៩៤ | ៦ | +៧៩ | +៤ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ហ៊ុន សែន** ជម្ពូវ័ន | ២៣០ | ៣០ | ២៧៤ | ៤១ | +៤៤ | +១១ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបារិត | ១២៤ | ៤៤ | ១៦៣ | ៦៤ | +៣៩ | +២០ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស**ព្រះរាជសម្ភារ** | ៥០ | ៨ | ៩២ | ២២ | +៤២ | +១៤ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស**ព្រះនរោត្តមសីហមុនី** | ១៥៨ | ៩៦ | ១១២ | ៧២ | -៤៦ | -២៤ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស**ជាស៊ីម**ត្បែងមានជ័យ | ៩១ | ៤៤ | ១៤១ | ៦៤ | +៥០ | +២០ |
| សាលាចំណេះទូទៅនិងបច្ចេកទេសឯកជនអេស៊ីធី (ACT) | ៣២ | ១៩ | ៥៨ | ៣៧ | +២៦ | +១៨ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជនដុនបូស្កូប៉ោយប៉ែត | ៧៣ | ៣២ | ១០០ | ៤៣ | +២៧ | +១១ |
| វិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍នៃសាកលវិ.**ជាស៊ីម**កំចាយមារ | ១៩១ | ១០៣ | ២៦០ | ១៣៥ | +៦៩ | +៣២ |
| វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៃសាកលវិទ្យាល័យ **ហេងសំរិន** ត្បូងឃ្មុំ | ១៤១ | ៧៩ | ១៣៥ | ៨១ | -៦ | +២ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបន្ទាយឆ្មារ | ១៥ | ០ | ២៤ | ០ | +៩ | ០ |
| វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង | ៧២ | ៣៦ | ១៣៨ | ៧១ | +៦៦ | +៣៥ |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **តេជោសែន** កោះកុង | | | ៤៨ | ១០ | +៤៨ | +១០ |
| សរុប | ២ ៧០០ | ១ ០៣៦ | ៣៣២៤ | ១២៦៩ | ៦២៤ | ២៣៣ |

## តារាងទី៩៖ តារាងប្រៀបធៀបស្ថិតិសិស្សផ្នែកអប់រំបច្ចេកទេសតាមមុខជំនាញឆ្នាំទី១ ពីឆ្នាំ២០១៦ ដល់ ២០២១

| ល.រ | ជំនាញ | ឆ្នាំសិក្សា | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | |
| | | | | | | សរុប | ស្រី |
| ១ | អគ្គិសនី | ១៩២ | ២៤៩ | ៣២១ | ៤៩០ | ៤៤៣ | ៦២ |
| ២ | អេឡិចត្រូនិក | ៩៤ | ១២៣ | ១៧៥ | ១៥៥ | ២២៤ | ៣៧ |
| ៣ | បសុវប្បកម្ម | ៨៦ | ៨៨ | ១៥៩ | ១១៧ | ៩៤ | ៥៧ |
| ៤ | ក្សេត្រសាស្ត្រ | ៩៥ | ១៨៦ | ២៩៤ | ២៦៦ | ២៦៣ | ១៥២ |
| ៥ | មេកានិក | | ១៧ | ១៥ | ៤៩ | ៥៤ | ៩ |
| ៦ | ទេសចរណ៍ | | | ៣៤ | ២៨ | ៣២ | ២៦ |
| ៧ | កុំព្យូទ័រ | | | ៥៤ | ៥៧ | ៦៥ | ៤៤ |
| ៨ | គណនេយ្យ | | | ៥៦ | ២៨ | ៥០ | ៤៤ |
| ៩ | កែច្នៃអាហារ | | | | ៥៧ | ៥៦ | ៤៩ |
| ១០ | ឌីជីថលមេឌៀឌីហ្សាញ | | | | ១៣ | ១៤ | ៣ |
| សរុប | | ៥៤៣ | ៦៦៣ | ៦៦៣ | ១ ២៦០ | ១ ២៩៥ | ៤៨៣ |

## តារាងទី១០៖ តារាងប្រៀបធៀបស្ថិតិសិស្សផ្នែកអប់រំបច្ចេកទេសតាមមុខជំនាញនីមួយៗពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០២១

| ល.រ | ជំនាញ | ឆ្នាំសិក្សា | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៦-១៧ | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២០២១ | |
| | | | | | | សរុប | ស្រី |
| ១ | អគ្គិសនី | ៣៩៨ | ៤៩៣ | ៦២៥ | ៨៨០ | ១ ១៥១ | ១៥១ |
| ២ | អេឡិចត្រូនិក | ២២០ | ៣៣៤ | ៣៦៧ | ៣៩១ | ៥០៨ | ៩៦ |
| ៣ | បសុវប្បកម្ម | ២៦២ | ២៣៩ | ៣០៤ | ៣០១ | ៣១៧ | ២០៧ |
| ៤ | ក្សេត្រសាស្ត្រ | ២៦៧ | ៣៨៦ | ៥៧៥ | ៧០៩ | ៧២៦ | ៤៣៧ |
| ៥ | មេកានិក | | ១៩ | ៣៣ | ៨០ | ១២១ | ១០ |
| ៦ | ទេសចរណ៍ | | | ៤៥ | ៦៨ | ៨៦ | ៦៣ |
| ៧ | កុំព្យូទ័រ | | | ៨០ | ១២៧ | ១៥៩ | ១០៥ |
| ៨ | គណនេយ្យ | | | ៧៤ | ៧៤ | ១០៨ | ៨៦ |
| ៩ | កែច្នៃអាហារ | | | | ៥៧ | ១២២ | ១០៥ |
| ១០ | ឌីជីថលមេឌៀឌីហ្សាញ | | | | ១៣ | ២៦ | ៩ |
| សរុប | | ១ ១៤៧ | ១ ៤៧១ | ២ ១០៣ | ២ ៧០០ | ៣ ៣២៤ | ១ ២៦៩ |

## តារាងទី១១ ៖ ស្ថិតិគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ឆ្នាំសិក្សា២០២០-២០២១

| ល.រ | គ្រឹះស្ថានសិក្សា | ចំនួន | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសអនុវត្តកំពង់ឈើទាលនៃវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ២៧ | ១១ |
| ២ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុនសែន**-ROTA ខ្សាច់កណ្តាល | ២៤ | ៣ |
| ៣ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស**ព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី** | ៣៤ | ១៣ |
| ៤ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជនសន្តប្រ៉ូង់ស្វ័រ | ៩ | ៤ |

| | | | |
|---|---|---|---|
| ៥ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពួក | ៩ | ០ |
| ៦ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ហ៊ុន សែន** ជម្លូវ៉ែន | ២៩ | ៥ |
| ៧ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបាវិត | ១៨ | ៣ |
| ៨ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស**ព្រះរាជសម្ភារ** | ៦ | ០ |
| ៩ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ព្រះនរោត្តមសីហមុនី** | ៧ | ២ |
| ១០ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ជា ស៊ីម** ត្បែងមានជ័យ | ៨ | ១ |
| ១១ | សាលាចំណេះទូទៅនិងបច្ចេកទេសឯកជនអេស៊ីធី (ACT) | ៧ | ២ |
| ១២ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជនដុនបូស្កូប៉ោយប៉ែត | ៩ | ១ |
| ១៣ | វិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍នៃសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ | ៧ | ១ |
| ១៤ | វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៃសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ | ៦ | ០ |
| ១៥ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបន្ទាយឆ្មារ | ១ | ០ |
| ១៦ | វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង | ៧ | ៣ |
| ១៧ | វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **តេជោសែន** កោះកុង | ២ | ០ |
| សរុប | | ២១០ | ៤៩ |

*ប្រការនេះបានបង្ហាញថាសិស្ស អ្នកអាណាព្យាបាល បានយល់ដឹងពីសារៈប្រយោជន៍ផ្នែកអប់រំបច្ចេកទេស។ ក្រុមហ៊ុន រោងចក្រ និងសហគ្រាស បានចូលរួមក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។*

## ការអនុវត្តកម្មវិធី និងសកម្មភាពនានា

### *សាលារៀនជំនាន់ថ្មី (NGS)*

ក្រសួងបាន៖

- បន្តអនុវត្តគោលនយោបាយ ស្តីពីសាលារៀនជំនាន់ថ្មី
- ដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មី ៧ រួមមាន៖
  - វិទ្យាល័យ **ហ៊ុន សែន** កំពង់ចាម ខេត្តកំពង់ចាម
  - វិទ្យាល័យ **ព្រះស៊ីសុវត្ថិ** រាជធានីភ្នំពេញ
  - វិទ្យាល័យ **ហ៊ុន សែន** ព្រែកលៀប រាជធានីភ្នំពេញ
  - វិទ្យាល័យ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ព្រែកអញ្ចាញ ខេត្តកណ្តាល
  - អនុវិទ្យាល័យ **គោកព្រីង** ខេត្តស្វាយរៀង
  - វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង ខេត្តកំពង់ចាម
  - វិទ្យាល័យ **ព្រះយុគន្ធរ** រាជធានីភ្នំពេញ E2 STEM
- បង្កើតការគ្រប់គ្រងតាមបែបចម្រុះដោយមានការចូលរួមពីដៃគូពាក់ព័ន្ធ គណៈគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាភិបាលសាលារៀន
- អនុវត្តកម្មវិធីសិក្សាតាមបែបទន់ភ្លន់ ដើម្បីបង្រៀនសិស្សឱ្យមានចំណេះដឹង ជំនាញបច្ចេកទេស បំណិនជីវិត ជំនាញទន់ និងមានអាកប្បកិរិយាល្អ
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូដោយបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀនតាមបែបរិះរក និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀនសិស្សដោយអ្នកជំនាញក្នុងកម្មវិធី NGS
- អនុវត្តវិធីសាស្ត្របង្រៀនបែបចម្រុះ

- រៀបចំការប្រជុំបច្ចេកទេសគ្រូនៅតាមសាលារៀនជំនាន់ថ្មី ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបន្ថែម ជារៀងរាល់សប្តាហ៍ ខែ ប្រចាំឆ្នាំ
- រៀបចំឱ្យមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រតាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សរ៍ទី២១។ សាលារៀនជំនាន់ថ្មីបានអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា
- ពង្រឹងការបង្រៀននិងរៀន ការអប់រំបំណិនជីវិត ការអប់រំស្វែម ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន បន្ទប់សង្គ្រោះបឋម និងក្លឹបសិក្សាលើមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា សារព័ត៌មាន បច្ចេកវិទ្យាព័ត៌មាន និងប្រវត្តិវិទ្យា។

**តារាងទី១២៖ ស្ថិតិសិស្សនៅសាលារៀនជំនាន់ថ្មី**

| បរិយាយ | ២០១៩-២០២០ | | ២០២០-២០២១ | | កើន/ថយ(+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១-វិទ្យាល័យ **ហ៊ុន សែន** កំពង់ចាម ខេត្តកំពង់ចាម | ៤១៦ | ២១០ | ៤៦៨ | ២៣៥ | +៥២ | +២៥ |
| ២-វិទ្យាល័យ **ព្រះស៊ីសុវត្ថិ** រាជធានីភ្នំពេញ | ១ ០០៤ | ៤៩២ | ១០០២ | ៤៨៨ | -២ | -៤ |
| ៣-វិទ្យាល័យ **ហ៊ុន សែន** ព្រែកលៀប រាជធានីភ្នំពេញ | ៧៤១ | ៣៨៧ | ១០៤០ | ៥៥០ | +២៩៩ | +១៦៣ |
| ៤-វិទ្យាល័យ **ជា ស៊ីម** ព្រែកអញ្ចាញ ខេត្តកណ្តាល | ៨០៣ | ៤៤៤ | ១០៩២ | ៦០១ | +២៨៩ | +១៥៧ |
| ៥-អនុវិទ្យាល័យ **គោកព្រីង** ខេត្តស្វាយរៀង | ៣៦៩ | ១៨៦ | ៤១២ | ២០៩ | +៤៣ | +២៣ |
| ៦-វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង ខេត្តកំពង់ចាម | ៥៤០ | ៣០៩ | ៧៩០ | ៤៨៥ | +២៥០ | +១៧៦ |
| ៧-វិទ្យាល័យ **ព្រះយុគន្ធរ** រាជធានីភ្នំពេញ | ១៥១ | ៧៥ | ២៣៧ | ១២៣ | +៨៦ | +៤៨ |
| សរុប | ៣ ០២០ | ២ ១០៣ | ៥ ០៤១ | ២៦៩១ | ២ ០២១ | ៥៨៨ |

**តារាងទី១៣៖ ផលទូផលសិក្សា ឆ្នាំសិក្សា ២០១៩-២០**

| ឈ្មោះសាលារៀន | ចំនួនសិស្ស | | ចំនួនសិស្សជាប់ | | ចំនួនសិស្សធ្លាក់ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | ប្រុស | ស្រី |
| ១-វិទ្យាល័យ **ហ៊ុន សែន** កំពង់ចាម ខេត្តកំពង់ចាម | ៤១៦ | ២១០ | ៣៥៧ | ១៩៣ | ៥៩ | ១៧ |
| ២-វិទ្យាល័យ **ព្រះស៊ីសុវត្ថិ** រាជធានីភ្នំពេញ | ១ ០០៤ | ៤៩២ | ៩៩៤ | ៤៨៨ | ១០ | ៤ |
| ៣-វិទ្យាល័យ **ហ៊ុន សែន** ព្រែកលៀប រាជធានីភ្នំពេញ | ៧៤១ | ៣៨៧ | ៦៧៨ | ៣៥៤ | ៦៣ | ៣៣ |
| ៤-វិទ្យាល័យ **ជា ស៊ីម** ព្រែកអញ្ចាញ ខេត្តកណ្តាល | ៨០៣ | ៤៤៤ | ៨០៣ | ៤៤៤ | ០ | ០ |
| ៥-អនុវិទ្យាល័យ **គោកព្រីង** ខេត្តស្វាយរៀង | ៣៦៩ | ១៨៦ | ៣៤៨ | ១៧៦ | ២១ | ១០ |
| ៦-វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង ខេត្តកំពង់ចាម | ៥៤០ | ៣០៩ | ៥០៩ | ២៧៥ | ៣១ | ៣៤ |
| ៧-វិទ្យាល័យ **ព្រះយុគន្ធរ** រាជធានីភ្នំពេញ | ១៥១ | ៧៥ | ១៤០ | ៧២ | ១១ | ៣ |
| **សរុប** | ៤ ០២៤ | ២ ១០៣ | ៣ ៩២៦ | ២ ០៥៣ | ៩៨ | ៥០ |

*សាលារៀនជំនាន់ថ្មីត្រូវបានក្លាយជាសាលារៀនគំរូសម្រាប់ការបណ្តុះបណ្តាលគ្រូ ការកែលម្អវិធីសាស្ត្របង្រៀន ការពង្រឹងស្វ័យភាព និងគណនេយ្យភាព ការគ្រប់គ្រងសាលារៀន និងការចូលរួមរបស់សហគមន៍។*

***ការគ្រប់គ្រងតាមសាលារៀន (SBM)***

ក្រសួងបាន៖

- ធ្វើតេស្តសិស្សថ្នាក់ទី៦ ឡើងថ្នាក់ទី៧ ថ្មី ១០០សាលា លើសាលារៀនគោលដៅ ១០០ ធៀបនឹងចំណុចដៅ ៩០ សម្រាប់ធ្វើបំណែងចែកកម្មវិធីសិក្សា ដើម្បីបំពេញគម្លាតសមត្ថភាព និងកែលម្អវិធីសាស្ត្របង្រៀនរបស់គ្រូ

- ធ្វើផែនការកែលម្អសាលារៀន និងធ្វើការកែសម្រួលសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀនទាំង១០០ ធៀបនឹងចំណុចដៅ ១០០
- វាយតម្លៃលទ្ធផលសាលារៀនជាប់ស្តង់ដាសាលារៀនមានប្រសិទ្ធភាព ៣៦ ធៀបនឹងចំណុចដៅ ២០
- ធ្វើឱ្យមានការប្រែប្រួលឥរិយាបថ និងពង្រីកការគ្រប់គ្រងតាមសាលារៀន ទៅសាលារៀនផ្សេងទៀតក្នុងមូលដ្ឋាន
- លើកទឹកចិត្តឱ្យសិស្សខិតខំរៀនសូត្រ និងស្តាប់ការណែនាំរបស់គ្រូបង្រៀនជាងមុន ព្រមទាំងមករៀនទៀងទាត់ និងកាត់បន្ថយចំនួនអវត្តមានស្ទើរតែទាំងស្រុង
- ជំរុញឱ្យគ្រូបង្រៀនយកចិត្តទុកដាក់បង្រៀន និងប្រឹងប្រែងរៀនសូត្រពីវិធីសាស្ត្របង្រៀនសិស្សដោយផ្តោតជាពិសេសលើការជួយសិស្សរៀនយឺត និងរៀនលឿន
- ធ្វើឱ្យគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនមានមោទនភាពដោយសារលទ្ធផលសិក្សាមានការរីកចម្រើនជាប្រចាំ និងការប្រឹងប្រែងរៀនរបស់សិស្ស និងការប្រឹងប្រែងបង្រៀនរបស់គ្រូ។ ជាមួយគ្នានោះដែរ ការទទួលខុសត្រូវរបស់មាតាបិតា សហគមន៍ និងអាជ្ញាធរដែនដីលើការធ្វើផែនការ ការអនុវត្តផែនការ និងវាយតម្លៃផលសម្រេចរបស់សាលារៀន
- លើកកម្ពស់ការវាយតម្លៃ ស្វ័យភាព គណនេយ្យភាពនៃអ្នកអនុវត្ត និងការចូលរួមចំណែករបស់សហគមន៍ នៅក្នុងការកាត់បន្ថយការលំបាករបស់គ្រូបង្រៀនលើការអភិវឌ្ឍសាលារៀន តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀនដែលជាស្ពានចម្លងរវាងសហគមន៍ និងសាលារៀន
- ជំរុញគណៈគ្រប់គ្រងមន្ទីរ និងការិយាល័យអប់រំ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យពង្រីកវិសាលភាពក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅតាមគ្រឹះស្ថានសិក្សាដែលមិនមែនគោលដៅគម្រោង និងផ្សារភ្ជាប់ការអនុវត្តជាមួយសាលារៀនបឋមសិក្សាចំណុះ
- ផលិតវីដេអូ ៦មុខវិជ្ជា ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ សម្រាប់គាំទ្រដល់ការរៀន និងបង្រៀនពីចម្ងាយតាមរយៈទូរទស្សន៍ Facebook, Telegram, Zoom Google Meet...
- ផលិតសន្លឹកកិច្ចការសម្រាប់សិស្សស្វ័យសិក្សាមានកម្រងសំណួរ លំហាត់ ចំណោទគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់
- បង្កើតកម្មវិធីបំណិនរកចំណូលនៅតាមសាលារៀនគោលដៅ។

*កម្មវិធីនេះ បានជួយពង្រីកការលើកកម្ពស់ការគ្រប់គ្រងល្អតាមសាលារៀន ការពង្រឹងសមត្ថភាពគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន ការចូលរួមរបស់គណៈកម្មការគ្រប់គ្រងសាលារៀន លើការកសាង និងអនុវត្តផែនការកែលម្អសាលារៀន ការអនុវត្តតេស្តស្តង់ដាហ្មត់ចត់ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស។*

### *កម្មវិធីបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM )*

ក្រសួងបាន៖

- អនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ពង្រឹងការអនុវត្តគណៈកម្មការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាគ្រប់វិទ្យាល័យ ជាពិសេសវិទ្យាល័យធនធាន
- ផ្សព្វផ្សាយវិធីរៀននិងបង្រៀន វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាដល់គ្រូអនុវិទ្យាល័យនិងវិទ្យាល័យ
- រៀបចំពិព័រណ៍ស្នែមតាមអនឡាញមានមន្ត្រីអប់រំ និងសិស្សានុសិស្សនៅតាមវិទ្យាល័យធនធាន ៥០បានចូលរួម
- រៀបចំថ្នាក់និទស្សន៍សម្រាប់មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា គ្រូបង្រៀន ៦៨១នាក់ ស្រី ៣០៩នាក់ និងសិស្ស ២ ៣៦០នាក់ ស្រី ១ ២៤៨នាក់។

*កម្មវិធីនេះបានចូលរួមលើកកម្ពស់គុណភាពអប់រំ ព្រមទាំងបានជួយជំរុញសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាឱ្យអនុវត្តលើវិធីសាស្ត្របង្រៀនតាមបែបស្នែម។*

*ការលើកកម្ពស់ការអប់រំបច្ចេកទេស ការងារតម្រង់ទិសវិជ្ជាជីវៈ មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា*

ក្រសួងបាន៖

- ចេញប្រកាស ស្តីពីការប្រែក្លាយវិទ្យាល័យកោះកុង ទៅជាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **តេជោសែន** កោះកុង
- ចេញប្រកាស ស្តីពីការកំណត់វិញ្ញាបនបត្របច្ចេកទេសនិងវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ
- ដាក់ឱ្យប្រើប្រាស់ឯកសារណែនាំ ស្តីពីការចុះកម្មសិក្សារបស់សិស្សវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ដាក់ឱ្យប្រើប្រាស់ឯកសារណែនាំស្តីពីការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គមឬជំនាញបច្ចេកទេសវិជ្ជាជីវៈ
- ដាក់ឱ្យអនុវត្តកម្មវិធីសិក្សាលម្អិតជំនាញកែច្នៃអាហារកម្រិតមធ្យមសិក្សាទុតិយភូមិផ្នែកអប់រំបច្ចេកទេស
- ដាក់ឱ្យប្រើប្រាស់ឯកសារជំនាញទន់ និងមូលដ្ឋានគ្រឹះផលិតកម្ម សម្រាប់ប្រើប្រាស់ការបង្រៀននិងរៀននៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- បោះពុម្ពសន្លឹកសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ចំនួន ២ ០០០សន្លឹក
- ពង្រីកបន្ថែមជំនាញ៖
    - បសុវប្បកម្ម និងអគ្គិសនី នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ជា ស៊ីម** ត្បែងមានជ័យ
    - មេកានិក នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះរាជសម្ភារ
    - កែច្នៃអាហារ នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបារិត
    - បសុវប្បកម្ម នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ព្រះនរោត្តមសីហមុនី** ខេត្តកំពត
- បញ្ជូនសិស្ស៖
    - បច្ចេកទេសជំនាញក្សេត្រសាស្ត្រ ២០នាក់ ស្រី ១៨នាក់ ចុះកម្មសិក្សានៅក្រុមហ៊ុន Farm Cambodia
    - បច្ចេកទេសជំនាញអេឡិចត្រូនិក ២នាក់ ស្រី ១នាក់ និងគណនេយ្យ ១នាក់ ស្រី ១នាក់ ចុះកម្មសិក្សានៅក្រុមហ៊ុន Winsun (Cambodia) Co.,Ltd តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
    - វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ហ៊ុន សែន** ជម្ពូវ័ន ១០៦នាក់ ស្រី ១៤នាក់ ទៅសិក្សាប្រតិបត្តិនៅវិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា
- វាយតម្លៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ២ ក្នុងខេត្តកំពង់ធំ និងកណ្តាល
- រៀបចំបន្ទប់ពិសោធន៍ និងបណ្តាញអគ្គិសនី នៅវិទ្យាល័យ **ហ៊ុន សែន** ពាមជីកង
- បណ្តុះបណ្តាលគ្រូប្រឹក្សាតាមសាលារៀន ១៦៤នាក់ ស្រី ៧១នាក់ និងអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីព និងផ្តល់ប្រឹក្សានៅគ្រឹះស្ថានមធ្យមសិក្សា ៦៥ មាន ១១ ខេត្ត រាជធានី
- រៀបចំវេទិកាតម្រង់ទិសវិជ្ជាជីវៈដល់សិស្សថ្នាក់ទី៩ និងទី១២ ចំនួន ២ ២៧៥នាក់ ស្រី ១ ៣៤៩នាក់ នៅខេត្តមណ្ឌលគិរី ព្រះវិហារ និងឧត្តរមានជ័យ
- រៀបចំវេទិកាផ្សព្វផ្សាយកម្មវិធីផ្តល់ប្រឹក្សាអេឡិចត្រូនិក "ត្រីវិស័យ" ដល់សិស្ស ៨ ០៥៣នាក់ ស្រី ៤ ៧៤៤ នាក់ ១១ខេត្ត និងអ្នកចូលបង្កើតគណនេយ្យប្រើប្រាស់កម្មវិធីនេះ សរុប ១១ ២៩០នាក់
- រៀបចំវេទិកាផ្សព្វផ្សាយឯកសារណែនាំស្តីពី ការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ ដល់សិស្ស ៤ ២៩០នាក់ ស្រី ២ ៤០០នាក់ ៩ខេត្ត
- រៀបចំកម្មវិធីទស្សនាចរណ៍សិក្សាក្លាហាន៩ នៅខេត្តសៀមរាប បាត់ដំបង កំពត កំពង់ធំ និងពោធិ៍សាត់ មានសិស្សចូលរួម ៥ ៨០៥នាក់ ស្រី ៣ ៧៦២នាក់ និងអ្នកចូលទស្សនាតាមបណ្តាញសង្គមហ្វេសប៊ុក ១៥ ១៤៤ នាក់ សហការជាមួយអង្គការ BBC Media Action

- រៀបចំកម្មវិធី "ពិព័រណ៍ជំនាញសិក្សា ការងារ និងព័ត៌មានអាហារូបករណ៍សហរដ្ឋអាមេរិក ២០១៩-២០២០" មានសិស្ស ៣៩៦នាក់ស្រី ២២៣នាក់ នៅខេត្តសៀមរាប និងកំពង់ចាម និងតាមបណ្តាញសង្គមហ្វេសប៊ុក មានអ្នកចូលទស្សនា ២៦១ ២០៤ នាក់ សហការជាមួយសមាគមន៍និស្សិតអាហារូបករណ៍សហរដ្ឋអាមេរិក។

*កម្មវិធីនេះ បានជួយតម្រង់ទិសសិស្សឱ្យមានមូលដ្ឋានក្នុងការសម្រេចចិត្តជ្រើសរើសផ្លូវសិក្សា និងមុខរបរថ្ងៃអនាគតស្របតាមសមត្ថភាព ចំណង់ចំណូលចិត្ត ឧបនិស្ស័យ និងតម្រូវការទីផ្សារការងារ។*

## កម្មវិធីសាលាកុមារមេត្រី និងកម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា

ក្រសួងបាន៖

- ដាក់ឱ្យអនុវត្តឯកសារណែនាំប្រតិបត្តិ ប្រព័ន្ធរំលឹកជាមុនដើម្បីទប់ស្កាត់សិស្សបោះបង់ការសិក្សានៅមធ្យមសិក្សា
- អនុវត្តកម្មវិធីសាលាកុមារមេត្រីនៅតាមសាលារៀន ៤២២ ស្មើ ២៤,០១ភាគរយ នៃសាលារៀនដែលមានកម្រិតមធ្យមសិក្សាបឋមភូមិ ១ ៧៥៧សាលា សាលារៀនបានចុះធ្វើអធិការកិច្ច ១៣០ ក្នុងនោះកម្រិតមូលដ្ឋាន ៦២ ស្មើ ៤៧,៦៩ភាគរយ កម្រិតមធ្យម ៥៦ ស្មើ ៤៣,០៨ភាគរយ និងកម្រិតអភិវឌ្ឍ ១២ ស្មើ ៩,២៣ភាគរយ សម្រាប់ខេត្តគោលដៅរួមមាន តាកែវ សៀមរាប កំពត រតនគិរី ព្រះសីហនុ និងស្ទឹងត្រែង សហការជាមួយអង្គការយូនីសេហ្វ។

  *កម្មវិធីនេះ បានរួមចំណែកកាត់បន្ថយអត្រាបោះបង់ការសិក្សា នៅមធ្យមសិក្សា។*

## កម្មវិធីសាលាមធ្យមសិក្សាធនធាន

ក្រសួងបាន៖

- ផ្តល់កញ្ចប់ថវិកា ៤០លានរៀល សម្រាប់ដំណើរការអគារធនធាន ក្នុងមួយឆ្នាំសិក្សាសម្រាប់កិច្ចការប្រតិបត្តិ ក្នុងនោះសិស្សចូលប្រើប្រាស់បណ្ណាល័យ ២៣៩ ៥២៨នាក់ ស្រី ១៣៤ ០០០នាក់ បន្ទប់កុំព្យូទ័រ ១៨៥ ៦៦០នាក់ ស្រី ៨៩ ៧៦៥នាក់ បន្ទប់ពិសោធន៍ ១២១ ៥០៧នាក់ ស្រី ៦៦ ១៨៦នាក់ ម៉ោងចូលពិសោធន៍មុខវិជ្ជារូបវិទ្យា ៣ដងក្នុង១ថ្នាក់១ឆ្នាំ គីមីវិទ្យា ១០ដង ក្នុង១ថ្នាក់១ឆ្នាំ ជីវវិទ្យា ១៥ដងក្នុង១ថ្នាក់១ឆ្នាំ ផែនដីវិទ្យា ១ដងក្នុង១ថ្នាក់១ឆ្នាំ
- ផ្តល់ថវិកាបន្ថែម ៥០០ដុល្លារ ក្នុងមួយឆ្នាំសម្រាប់វិទ្យាល័យធនធានទាំង៥០ និងបណ្តាញ ២៤៧សាលា ដើម្បីចូលរួមពិសោធន៍ ១ដង ទៅ ២ដង ក្នុងមួយឆ្នាំលើបួនមុខវិជ្ជាគ្រប់កម្រិតថ្នាក់នៅវិទ្យាល័យធនធាន
- បង្កើតក្រុមការងារកែលម្អសាលារៀន ៥តំបន់ (ខេត្តកំពង់ចាម បាត់ដំបង កណ្តាល តាកែវ និងសៀមរាប) ដើម្បីជួយលើកកម្ពស់ការងារគ្រប់គ្រងរដ្ឋបាល ដំណើរការប្រតិបត្តិអគារធនធាន និងការចូលរួមពីសាលាបណ្តាញ
- ពិនិត្យតាមដាននិងវាយតម្លៃវិទ្យាល័យធនធាន ៣៦ ក្នុងនោះវិទ្យាល័យ ២២កម្រិតល្អណាស់ ១១កម្រិតល្អ និង ៣កម្រិតល្អបង្គួរ
- ពិនិត្យតាមដាននិងវាយតម្លៃស្ថានភាពអគារសិក្សា បន្ទប់រៀន ដើម្បីកែលម្អថ្នាក់រៀននៅវិទ្យាល័យធនធាន២៥ ទៅជាបន្ទប់ពហុបំណង
- កែលម្អហេដ្ឋារចនាសម្ព័ន្ធអគារធនធាន បន្ទប់ពិសោធន៍ បណ្ណាល័យ និងបន្ទប់កុំព្យូទ័រនៅវិទ្យាល័យធនធាន ៣៦
- កែលម្អថ្នាក់រៀន២ ក្នុងមួយសាលាជាបន្ទប់ពិសោធន៍នៅវិទ្យាល័យធនធាន ៥០
- កែលម្អថ្នាក់រៀន១ ក្នុងមួយសាលាជាបន្ទប់ពិសោធន៍ និងថ្នាក់រៀន១ ជាបណ្ណាល័យ នៅសាលាបណ្តាញ ៨៧
- ចុះវាយតម្លៃទីតាំងដើម្បីដំឡើងបន្ទះសូឡា នៅវិទ្យាល័យធនធាន ២០ និងវិទ្យាល័យបណ្តាញ ៣០
- ផ្គត់ផ្គង់កុំព្យូទ័របន្ទះ ១ ១៥២គ្រឿង ដល់វិទ្យាល័យធនធាន ២៤

*កម្មវិធីនេះ បានរួមចំណែកលើកកម្ពស់គុណភាព ប្រសិទ្ធភាពនៃការគ្រប់គ្រង ការរៀននិងបង្រៀន និងផ្តល់សមធម៌ដល់អ្នកសិក្សា។*

### *កម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រ*

ក្រសួងបាន៖

- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ ៧៩ ៥៦៧នាក់ ស្រី ៤៧ ៣៧៦នាក់ មាន ១ ៣៩២ សាលា និងមធ្យមសិក្សាទុតិយភូមិ ១១ ០៧០នាក់ ស្រី ៦ ៦៤៧នាក់ មាន ២០០សាលា
- ផ្តល់អាហារូបករណ៍ដល់សិស្សអន្តេវាសិកដ្ឋាន ៥៤៨នាក់ ស្រី ២៩៨នាក់ នៅខេត្តរតនគិរី និងមណ្ឌលគិរី គាំទ្រដោយថវិកាកម្មវិធី
- ផ្តល់អាហារូបករណ៍ដល់សិស្សថ្នាក់ទី១១ និងទី១២ ជាជនជាតិដើមភាគតិច ៤៥៩នាក់ ស្រី ២៤៣នាក់ នៅ ៥ ខេត្ត សហការជាមួយអង្គការយូនីសេហ្វ
- ផ្តល់អាហារូបករណ៍សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ២ ៨៧៤នាក់ ស្រី ១ ៧១៤នាក់ នៅតំបន់ជួបការលំបាក ៧ខេត្ត និងតំបន់ធម្មតាមាន ១៨ ខេត្ត រាជធានី
- ផ្តល់សម្ភារៈសិក្សាដល់សិស្សស្រីជួបការលំបាកបឋមភូមិ ៤ ២៩១នាក់ និងទុតិយភូមិ ៣ ៥១៧នាក់ នៅខេត្តកំពង់ធំ សៀមរាប កំពង់ចាម និងព្រៃវែង សហការជាមួយអង្គការរូមធូរីដ
- ផ្តល់អាហារូបករណ៍ដល់សិស្សបឋមភូមិ ៥៥នាក់ ស្រី ៣៣នាក់ និងទុតិយភូមិ ១២៦នាក់ ស្រី៨៤នាក់ ក្នុងខេត្តបាត់ដំបង ប៉ៃលិន សៀមរាប និងកំពង់ធំ សហការជាមួយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍។

*កម្មវិធីនេះ បានជួយកាត់បន្ថយអត្រាបោះបង់ការសិក្សា។*

### *ការអប់រំបំណិនជីវិត*

ក្រសួងបាន៖

- ចុះណែនាំ និងបង្ហឹកកម្មវិធីអប់រំបំណិនជីវិតផ្នែកសហគ្រិនភាពដល់នាយក ៦២នាក់ នាយករង ៨នាក់ គ្រូបង្រៀន ២៩០នាក់ ដល់សាលារៀន ៧០ នៅ ១៥ខេត្ត រាជធានី
- រៀបចំ និងពិគ្រោះយោបល់ឯកសារណែនាំស្តីពី ភាពជាដៃគូសាលាជួយសាលា ខេត្តជួយខេត្ត ក្នុងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន។

*ការអប់រំបំណិនជីវិតផ្នែកសហគ្រិនភាពបានជួយបណ្តុះស្មារតីយុវជនក្លាយជាពលរដ្ឋល្អដែលមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាក្នុងការបង្កើតការងារដោយខ្លួនឯង និងបង្កើតការងារសម្រាប់អ្នកដទៃ។*

### *អត្រាលំហូរសិស្ស*

- អត្រាឡើងថ្នាក់មធ្យមសិក្សាបឋមភូមិកើន ២,៨០ភាគរយ ស្រីកើន ១,៩០ភាគរយ និងមធ្យមសិក្សាទុតិយភូមិកើន ៩,៩០ភាគរយ ស្រីកើន ៧,៦០ភាគរយ
- អត្រាត្រួតថ្នាក់មធ្យមសិក្សាបឋមភូមិថយ ២,៤០ភាគរយ ស្រីថយ ១,៣០ភាគរយ និងមធ្យមសិក្សាទុតិយភូមិថយ ១,៤០ភាគរយ ស្រីថយ ០,៩០ភាគរយ
- អត្រាបោះបង់ការសិក្សាមធ្យមសិក្សាបឋមភូមិថយ ០,៤០ភាគរយ ស្រីថយ ០,៥០ភាគរយ និងមធ្យមសិក្សាទុតិយភូមិថយ ៨,៥០ភាគរយ ស្រីថយ ៦,៧០ភាគរយ។

### តារាងទី១៤ ៖ អត្រាលំហូរសិស្សនៅមធ្យមសិក្សា រវាងឆ្នាំសិក្សា ២០១៨-២០១៩ និង ២០១៩-២០២០

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|
| | ២០១៨-២០១៩ | ២០១៩-២០២០ | កើន-ថយ | ២០១៨-២០១៩ | ២០១៩-២០២០ | កើន-ថយ |
| អត្រាឡើងថ្នាក់ | ៧៨,៦ | ៨១,៤ | +២,៨ | ៨១,៥ | ៩១,៤០ | +៩,៩ |
| អត្រាត្រួតថ្នាក់ | ២,៨ | ០,៤ | -២,៤ | ១,៦ | ០,២០ | -១,៤ |
| អត្រាបោះបង់ការសិក្សា | ១៨,៦ | ១៨,២ | -០,៤ | ១៦,៩ | ៨,៤០ | -៨,៥ |
| អត្រាឆ្លងភូមិសិក្សា | ៨៥,០ | ៨៤,៣ | -០,៧ | ៧៤,៩ | ៨១,៣ | -៦,៤ |

- ផលធៀបសិស្ស-គ្រូមធ្យមសិក្សាបឋមភូមិកើនពី ២២,៣ ដល់ ២២,៤ និងមធ្យមសិក្សាទុតិយភូមិកើនពី ២២,១ ដល់ ២២,៨
- ផលធៀបសិស្ស-ថ្នាក់មធ្យមសិក្សាបឋមភូមិថយពី៤៥,២ មកត្រឹម ៤៤,២ និងមធ្យមសិក្សាទុតិយភូមិថយពី ៤៥,២ មកត្រឹម ៤៣,៨
- ផលធៀបសិស្ស-បន្ទប់មធ្យមសិក្សាបឋមភូមិថយពី ៥០,០ មកត្រឹម ៤៨,១ និងមធ្យមសិក្សាទុតិយភូមិថយពី ៤៩,៦ មកត្រឹម ៤៨,១។

### តារាងទី១៥ ៖ ផលធៀបសំខាន់ៗនៅមធ្យមសិក្សា រវាងឆ្នាំសិក្សា ២០១៩-២០២០ និង ២០២០-២០២១

| បរិយាយ | មធ្យមសិក្សាបឋមភូមិ | | | មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|
| | ២០១៩-២០ | ២០២០-២១ | កើន-ថយ | ២០១៩-២០ | ២០២០-២១ | កើន-ថយ |
| ផលធៀបសិស្ស-គ្រូ | ២២,៣ | ២២,៤ | +០,១ | ២២,១ | ២២,៨ | +០,៧ |
| ផលធៀបសិស្ស-ថ្នាក់រៀន | ៤៥,២ | ៤៤,២ | -១,០ | ៤៥,២ | ៤៣,៨ | -១,៤ |
| ផលធៀបសិស្ស-បន្ទប់រៀន | ៥០,០ | ៤៨,១ | -១,៩ | ៤៩,៦ | ៤៨,១ | -១,៥ |

*ប្រការនេះបញ្ជាក់ឱ្យឃើញថា កំណែទម្រង់វិស័យអប់រំ ជាពិសេសការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន វិធីសាស្ត្របង្រៀន ការបង្កើតក្លឹបសិក្សា បានជំរុញឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។*

### *ការងារប្រឡងសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅ បំពេញវិជ្ជា បច្ចេកទេស និងជ្រើសរើសសិស្សពូកែ*

បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១០០ភាគរយ ដោយមិនកំណត់និទ្ទេស។

បេក្ខជនមានពិការភ្នែក និងគ-ថ្លង់ បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៥៤នាក់ ស្រី ២៧នាក់ ស្មើ ១០០ភាគរយ។

### តារាងទី១៦៖ ស្ថិតិបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅនិងបំពេញវិជ្ជា ឆ្នាំសិក្សា២០១៨-២០១៩ និងឆ្នាំសិក្សា២០១៩-២០២០

| ជាប់ | ឆ្នាំសិក្សា២០១៨-២០១៩ | | ឆ្នាំសិក្សា២០១៩-២០២០ | | ស្ថានភាព |
|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | |
| សរុប | ៧៩ ០៥២ | ៤៣ ៧២៨ | ១២១ ០៧៤ | ៦៣ ៨៩០ | ↑ |

សម្គាល់៖ ↑ កើនឡើង ↓ ថយចុះ

## រូបភាពទី២០៖ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិឆ្នាំសិក្សា ២០១៩-២០២០




### *ការប្រឡងបញ្ចប់ផ្នែកអប់រំបច្ចេកទេស*

បេក្ខជនដាក់ពាក្យប្រឡងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ចំនួន ៥៦៨នាក់ ស្រី ២០៩នាក់។ បេក្ខជនមកប្រឡង ៥៥៩នាក់ ស្រី ២០៥នាក់។ បេក្ខជនប្រឡងជាប់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ចំនួន ៥៣៧នាក់ ស្មើ ៩៦,០៦ភាគរយ ស្រី ២០០នាក់ ស្មើ ៩៧,៥៦ភាគរយ ក្នុងនោះជំនាញអគ្គិសនី ១៦១នាក់ ស្រី ១៧នាក់ ជំនាញអេឡិចត្រូនិក ៨៤នាក់ ស្រី ២៦នាក់ ជំនាញក្សេត្រសាស្ត្រ ១៧៤នាក់ ស្រី ៨៧នាក់ ជំនាញបសុវប្បកម្ម ៥៦នាក់ ស្រី ៤២នាក់ ជំនាញមេកានិក ១៧នាក់ ស្រី ០នាក់ ជំនាញកុំព្យូទ័រ ២២នាក់ ស្រី១៤នាក់ ជំនាញគណនេយ្យ ១៣ នាក់ ស្រី៧នាក់ និងជំនាញទេសចរណ៍ ១០នាក់ ស្រី ៧នាក់។

## រូបភាពទី២១៖ លទ្ធផលការប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ឆ្នាំសិក្សា២០១៩-២០២០



**រូបភាពទី២២៖ លំហូរសិស្សបញ្ចប់ឆ្នាំសិក្សាសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត៣ ឆ្នាំសិក្សា២០១៩-២០២០**




*ប្រការនេះបង្ហាញឱ្យឃើញថា សក្តានុពលធនធានមនុស្សរបស់កម្ពុជាកាន់តែមានឧត្តមភាពប្រកួតប្រជែងនៅលើឆាកអន្តរជាតិ។*

## *ការអភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា*

ក្រសួងបាន៖

- បញ្ចប់ការសរសេរសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព សម្រាប់ថ្នាក់ទី៨ និងទី១១ សម្រាប់គ្រូ និងសិស្ស
- កែលម្អកម្មវិធីសិក្សាលម្អិត ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រតាមវិធីសាស្ត្របង្រៀនបែបស្ថាបនានិយម
- អភិវឌ្ឍឯកសារជំនួយការរៀន និងបង្រៀនមុខវិជ្ជាគណិតវិទ្យាតាមគោលវិធីស្វែង នៅមធ្យមសិក្សាបឋមភូមិ
- អភិវឌ្ឍឯកសារណែនាំការបង្រៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន
- ព្រាងសេចក្តីណែនាំ អនុវត្តកម្មវិធីសិក្សាគណិតវិទ្យា ភាសាខ្មែរ វិទ្យាសាស្ត្រ សិក្សាសង្គម ភាសាអង់គ្លេស និងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានសម្រាប់ឆមាសទី២
- ព្រាងឯកសារសិក្សាអក្សរសិល្ប៍បរទេស ៣រឿង៖ រឿងរ៉ូម៉េអូហ្ស៊ូលីយ៉េត រឿងហាំលែត និងរឿងទុគ៌តជន
- ព្រាងឯកសារជំនួយការរៀន និងបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ តាមគោលវិធីស្វែងសម្រាប់មធ្យមសិក្សាទុតិយភូមិ
- ព្រាងសៀវភៅណែនាំការអនុវត្តប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី ខេត្ត
- ធ្វើសុខដុមនីកម្ម សៀវភៅជំនួយស្មារតីឧបករណ៍អធិការកិច្ចសាលារៀនសម្រាប់រាជធានី ខេត្ត។

*ប្រការនេះ បានបង្ហាញឱ្យឃើញថា ក្រសួងបានធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា និងឯកសារបង្រៀនឱ្យឆ្លើយតបទៅនឹងបរិបទថ្មីតាមបែបស្ថាបនានិយម។*

## *ការផ្គត់ផ្គង់សៀវភៅសិក្សាគោល និងសម្ភារបច្ចេកវិទ្យា*

ក្រសួងបាន៖

- ដឹកជញ្ជូនសៀវភៅសិក្សាគោលដល់សាលាបង្គោលសម្រាប់បឋមសិក្សា និងដល់សាលានីមួយៗសម្រាប់មធ្យមសិក្សា
- ផ្គត់ផ្គង់សៀវភៅសិក្សាគោល ២ ២១៥ ០០០ក្បាល ដល់សាលារៀនសាធារណៈ តាមផលធៀប ១:១ (សិស្សម្នាក់ទទួលបានសៀវភៅសិក្សាគោលមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់មធ្យមសិក្សាបឋមភូមិ) និង២:១ (សិស្ស២នាក់ទទួលបានសៀវភៅសិក្សាគោលមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់មធ្យមសិក្សាទុតិយភូមិ) លើកលែងតែខេត្ត ៧ គឺខេត្តកោះកុង ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ទទួលបានសៀវភៅសិក្សាគោលតាមផលធៀប ១:១ ដូចមធ្យមសិក្សាបឋមភូមិដែរ

- បញ្ចប់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានសៀវភៅសិក្សាគោលដោយប្រើបច្ចេកវិទ្យាព័ត៌មាន សហការជាមួយអង្គការអប់រំពិភពលោក និងគាំទ្រថវិកាក្នុងការបង់ថ្លៃសេវាប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ។

*ប្រការនេះ បានបង្ហាញឱ្យឃើញថា ការផ្គត់ផ្គង់សម្ភារសិក្សា និងសៀវភៅសិក្សាគោលដល់សិស្សនិងគ្រូ រួមទាំងសម្ភារឧបទេសកាន់តែមានប្រសិទ្ធភាពតាមប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោលជូនសាលារៀន (TnT) ។*

### *ការងារបណ្ណាល័យ*

បណ្ណាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន និងលោកជំទាវ**បាន៖

- ទទួលអ្នកអាន ២ ៣៦៦នាក់ ស្រី ១ ៣៩៣នាក់
- ទទួលសារព័ត៌មាន ១ ៧៩៦ច្បាប់
- ទទួលទស្សនាវដ្ដី/ព្រឹត្តបត្រ ១៤៣ច្បាប់
- ទទួលសៀវភៅ ២៨៦ចំណងជើង ស្មើ ៧០១ក្បាល
- ទទួលព្រះរាជក្រឹត្យ (រាជកិច្ច) ៣៩ច្បាប់
- រៀបចំបណ្ណាល័យថ្មី ៨កន្លែង
- ប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០២០ ក្រោមប្រធានបទ ការអានបណ្ដុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍ មានអ្នកចូលរួម ៥០ ០០០នាក់
- រៀបចំការប្រឡងប្រណាំងជ័យលាភីផ្នែកអានអត្ថបទ សូត្រកំណាព្យ និងតែងនិពន្ធ មានអ្នកចូលរួម ៧៥នាក់ ស្រី ៣៥នាក់ មកពី ២៥ ខេត្ត រាជធានី
- រៀបចំការប្រឡងប្រណាំងស្នាដៃសរសេរសិក្សាកថា ដោយជ្រើសរើសបានជ័យលាភី ៩នាក់។

**មជ្ឈមណ្ឌលឯកសារ ក្រសួងអប់រំ យុវជន និងកីឡាបាន៖**

- ប្រមូលព័ត៌មានស្ថិតិបណ្ណាល័យ និងចងក្រង ១៩ ខេត្ត រាជធានី
- ចុះបញ្ជីសារពើភណ្ឌសៀវភៅតាមកុំព្យូទ័រ ១២៧ ចំណងជើង ស្មើ ៤៤០ ក្បាល។

**តារាងទី១៧ ៖ស្ថិតិបណ្ណាល័យសាលាមធ្យមសិក្សាឆ្នាំ២០១៩-២០២០**

| ល.រ | រាជធានី/ខេត្ត | អនុវិទ្យាល័យ | | | | | វិទ្យាល័យ | | | | | សរុបរួម | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនសាលា | ចំនួនបណ្ណាល័យ | ដំណើរការ | ចំនួនបណ្ណារក្ស | ឆ្លងបំប៉ន | ចំនួនសាលា | ចំនួនបណ្ណាល័យ | ដំណើរការ | ចំនួនបណ្ណារក្ស | ឆ្លងបំប៉ន | ចំនួនសាលា | ចំនួនបណ្ណាល័យ | ដំណើរការ | ចំនួនបណ្ណារក្ស | ឆ្លងបំប៉ន |
| ១ | បន្ទាយមានជ័យ | 54 | 43 | 23 | 19 | 0 | 30 | 29 | 25 | 33 | 3 | 84 | 72 | 48 | 52 | 3 |
| ២ | បាត់ដំបង | 96 | 38 | 35 | 49 | 27 | 28 | 25 | 21 | 40 | 17 | 124 | 63 | 56 | 89 | 44 |
| ៣ | កំពង់ចាម | 81 | 18 | 18 | 24 | 0 | 43 | 33 | 33 | 77 | 2 | 124 | 51 | 51 | 101 | 2 |
| ៤ | កំពង់ឆ្នាំង | 61 | 23 | 17 | 13 | 1 | 16 | 16 | 15 | 27 | 6 | 77 | 39 | 32 | 40 | 7 |
| ៥ | កំពង់ស្ពឺ | 72 | 26 | 21 | 21 | 2 | 24 | 22 | 20 | 38 | 8 | 96 | 48 | 41 | 59 | 10 |
| ៦ | កំពង់ធំ | 67 | 34 | 33 | 11 | 0 | 25 | 18 | 18 | 35 | 12 | 92 | 52 | 51 | 46 | 12 |
| ៧ | កំពត | 76 | 70 | 70 | 76 | 8 | 24 | 24 | 23 | 44 | 8 | 100 | 94 | 93 | 120 | 16 |
| ៨ | កណ្ដាល | 102 | 93 | 93 | 61 | 11 | 39 | 39 | 39 | 90 | 32 | 141 | 132 | 132 | 151 | 43 |
| ៩ | កែប | 4 | 4 | 4 | 7 | 1 | 2 | 2 | 2 | 4 | 2 | 6 | 6 | 6 | 11 | 3 |
| ១០ | កោះកុង | 19 | 0 | 0 | 0 | 0 | 12 | 5 | 5 | 12 | 2 | 31 | 5 | 5 | 12 | 2 |
| ១១ | ក្រចេះ | 43 | 20 | 10 | 0 | 0 | 12 | 11 | 11 | 14 | 3 | 55 | 31 | 21 | 14 | 3 |
| ១២ | មណ្ឌលគិរី | 8 | 8 | 0 | 0 | 0 | 5 | 5 | 1 | 1 | 0 | 13 | 13 | 1 | 1 | 0 |
| ១៣ | ឧត្ដរមានជ័យ | 29 | 6 | 0 | 0 | 0 | 9 | 7 | 6 | 9 | 0 | 38 | 13 | 6 | 9 | 0 |
| ១៤ | ប៉ៃលិន | 7 | 4 | 3 | 3 | 0 | 2 | 2 | 2 | 4 | 1 | 9 | 6 | 5 | 7 | 1 |
| ១៥ | រាជធានីភ្នំពេញ | 27 | 24 | 20 | 21 | 1 | 40 | 39 | 39 | 76 | 12 | 67 | 63 | 59 | 97 | 13 |
| ១៦ | ព្រះសីហនុ | 18 | 14 | 5 | 5 | 2 | 9 | 9 | 9 | 11 | 4 | 27 | 23 | 14 | 16 | 6 |
| ១៧ | ព្រះវិហារ | 47 | 40 | 18 | 6 | 1 | 17 | 11 | 8 | 7 | 3 | 64 | 51 | 26 | 13 | 4 |
| ១៨ | ព្រៃវែង | 92 | 43 | 43 | 44 | 44 | 32 | 32 | 32 | 64 | 64 | 124 | 75 | 75 | 108 | 108 |
| ១៩ | ពោធិ៍សាត់ | 44 | 38 | 21 | 23 | 8 | 16 | 14 | 12 | 30 | 11 | 60 | 52 | 33 | 53 | 19 |
| ២០ | រតនគិរី | 16 | 9 | 8 | 8 | 1 | 11 | 11 | 10 | 11 | 4 | 27 | 20 | 18 | 19 | 5 |
| ២១ | សៀមរាប | 82 | 58 | 45 | 25 | 1 | 41 | 35 | 34 | 46 | 10 | 123 | 93 | 79 | 71 | 11 |
| ២២ | ស្ទឹងត្រែង | 30 | 30 | 4 | 5 | 0 | 8 | 5 | 3 | 7 | 1 | 38 | 35 | 7 | 12 | 1 |
| ២៣ | ស្វាយរៀង | 54 | 45 | 25 | 30 | 8 | 20 | 19 | 19 | 34 | 6 | 74 | 64 | 44 | 64 | 14 |
| ២៤ | តាកែវ | 67 | 62 | 54 | 48 | 7 | 52 | 52 | 51 | 89 | 22 | 119 | 114 | 105 | 137 | 29 |
| ២៥ | ត្បូងឃ្មុំ | 52 | 18 | 18 | 4 | 0 | 27 | 19 | 19 | 27 | 0 | 79 | 37 | 37 | 31 | 0 |
| | សរុប | 1248 | 768 | 588 | 503 | 123 | 544 | 484 | 457 | 830 | 233 | 1792 | 1252 | 1045 | 1333 | 356 |

## រូបភាពទី២៣៖ ស្ថិតិបណ្ណាល័យសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈឆ្នាំសិក្សា២០១៩-២០២០




*ប្រការនេះ បានជួយបណ្តុះទម្លាប់ការសិក្សាស្រាវជ្រាវរបស់គ្រូ សិស្ស និងសាធារណជនពេញមួយជីវិត។*

### *ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន*

ក្រសួងបាន៖

- បញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ (១២+២) ឆ្នាំទី២ ជំនាន់ទី២៩ ចំនួន ៤៧៩ នាក់ ស្រី ២៥៦ នាក់
- បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅមធ្យមសិក្សាបឋមភូមិ៖
    - (១២+២) ជំនាន់ទី៣០ ឆ្នាំទី១ ចំនួន ៤០៥នាក់ ស្រី ២៣៣នាក់
    - (១២+៤) ជំនាន់ទី១ ឆ្នាំទី២ ចំនួន ១៨៧នាក់ ស្រី ១១០នាក់
    - (១២+៤) ជំនាន់ទី២ ឆ្នាំទី១ ចំនួន ១៩៧នាក់ ស្រី ១៣០នាក់
- ប្រឡងបញ្ចប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ (បរិញ្ញា+១) ១ ០១៥នាក់ ស្រី ៤៨០នាក់ (ក្នុងនោះក្របខណ្ឌចាស់ ២៨៧ នាក់ ស្រី ១១៨ នាក់)
- រៀបចំសិក្ខាសាលាស្តីពី ការបង្កើតបណ្តាញចំណេះដឹងមេរៀន និងតេស្តស្វ័យវាយតម្លៃ ១០៨នាក់ ស្រី ២៤នាក់
- រៀបចំសិក្ខាសាលាស្តីពី តួនាទីរបស់អ្នកស្ម័គ្រចិត្តសហរដ្ឋអាមេរិក និងគណៈគ្រប់គ្រងសាលារៀន ៦០នាក់ ស្រី ១៥ នាក់
- រៀបចំសិក្ខាសាលាស្តីពី ការកសាងខ្លឹមសារលម្អិតតាមមុខវិជ្ជាសម្រាប់បណ្តុះបណ្តាលគ្រូបឋមសិក្សា ១២+២ តាមប្រព័ន្ធក្រេឌីត ៩៨នាក់ ស្រី ២៥នាក់
- រៀបចំសន្និសីទ CamTESOL លើកទី១៦ ស្តីពីការបង្រៀនភាសាអង់គ្លេស មានអ្នកចូលរួម ១ ៨៦៩នាក់ ស្រី ៥៤១នាក់
- រៀបចំសិក្ខាសាលាស្តីពីកំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន មានអ្នកចូលរួម ២១នាក់ ស្រី ២នាក់
- រៀបចំសិក្ខាសាលាស្តីពីការបង្ហាញលទ្ធផលនៃវគ្គបណ្តុះបណ្តាល ការអភិវឌ្ឍវិជ្ជាជីវៈនៅប្រទេសសិង្ហបុរី ៦៦នាក់ ស្រី ២៧នាក់
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ប្រព័ន្ធនៃការផ្តល់ក្រេឌីតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ៣៨នាក់ ស្រី ៥នាក់

- បញ្ជូនគ្រូឧទ្ទេសពីវិទ្យាស្ថានគរុកោសល្យរាជធានី ៤នាក់ ទៅបង្រៀនមុខវិជ្ជារូបវិទ្យាដល់គរុនិស្សិត១២+៤ នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង
- បញ្ជូនអនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ទៅចូលរួមទស្សនកិច្ចសិក្សាលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ នៅវៀតណាម។

*ប្រការនេះ បានផ្តល់ឱកាសដល់បុគ្គលិកអប់រំបានផ្លាស់ប្តូរបទពិសោធ និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ។*

## *កម្មវិធីអប់រំបរិយាបន្ន*

ក្រសួងបាន ៖

- អនុវត្តកម្មវិធីអប់រំបរិយាបន្ននៅសាលាមធ្យមសិក្សាចំណោះទូទៅសាធារណៈ ដែលសិស្សមានពិការភាព ៣ ៥៨២ នាក់ ស្រី ១ ៩១៦នាក់ ក្នុងនោះសិស្សមានពិការភាពនៅមធ្យមសិក្សាបឋមភូមិ ២ ០២៦នាក់ ស្រី ១ ០៥៨ នាក់ និងសិស្សមានពិការភាពនៅមធ្យមសិក្សាទុតិយភូមិ ១ ៥៥៦នាក់ ស្រី ៨៥៨នាក់
- អនុវត្តកម្មវិធីអប់រំពិសេស នៅវិទ្យាល័យអប់រំពិសេសទាំង៥ ដែលសិស្សមធ្យមសិក្សាបឋមភូមិ ១៥៣នាក់ ស្រី ៥១ នាក់ ក្នុងនោះមានសិស្សពិការភ្នែក ៥១នាក់ ស្រី ១៤នាក់ សិស្សគ-ថ្លង់ ១០២នាក់ ស្រី ៣៧នាក់ សិស្សមានពិការភាពនៅមធ្យមសិក្សាទុតិយភូមិ ៧៤នាក់ ស្រី ៣៦នាក់ ក្នុងនោះមានសិស្សពិការភ្នែក ៣៤នាក់ ស្រី ១៧នាក់ សិស្សគ-ថ្លង់ ៤០នាក់ ស្រី ១៩នាក់
- ផ្តល់ឱកាសសិស្សមានទេព្យកោសល្យ ឬបញ្ញាខ្ពស់គឺ កុមារ **ហ៊ី ទៀងគីមហុង** មកពីខេត្តតាកែវ អាយុ ១០ឆ្នាំ រៀនថ្នាក់ទី១០ នៅសាលាប៊ែលធីអន្តរជាតិសាខាទី៩ ស្ទឹងមានជ័យ បានទទួលអាហារូបករណ៍ពី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សិស្សវិទ្យាល័យអប់រំពិសេសបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ២០នាក់ ស្រី ៤នាក់ ក្នុងនោះសិស្សពិការភ្នែក ៥នាក់ ស្រី ២នាក់ និងសិស្សគ-ថ្លង់ ១៥នាក់ ស្រី ២ នាក់។ ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១២នាក់ ស្រី ៥នាក់ ក្នុងនោះសិស្សពិការភ្នែក ៥នាក់ ស្រី ៣នាក់ និងសិស្ស គ-ថ្លង់ ៧នាក់ ស្រី ២នាក់
- ថតវីដេអូជាភាសាសញ្ញាបញ្ចូលក្នុងវីដេអូសកម្មភាពថ្នាក់ទី៩ មុខវិទ្យាភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ១៦៧វីដេអូ សហការជាមួយអង្គការយូនីសេហ្វ
- ថតវីដេអូជាភាសាសញ្ញាបញ្ចូលក្នុងវីដេអូសកម្មភាពមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ថ្នាក់ទី១២ ចំនួន ១៦៦វីដេអូ សហការជាមួយអង្គការយូនីសេហ្វ
- បកប្រែវីដេអូជាអក្សរប្រៃយ៍មុខវិទ្យាគណិតវិទ្យា ៥៧វីដេអូសកម្មភាព ក្នុងនោះមានថ្នាក់ទី៩ ចំនួន ៣១វីដេអូ និងថ្នាក់ទី១២ ចំនួន ២៦វីដេអូ សហការជាមួយអង្គការយូនីសេហ្វ
- អភិវឌ្ឍឯកសារស្តីពី ការអប់រំបរិយាបន្នមធ្យមសិក្សាទុតិយភូមិ សម្រាប់បណ្តុះបណ្តាលគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ (គរុនិស្សិត និងគ្រូឧទ្ទេស)
- ពិគ្រោះយោបល់ស្តីពី ការរៀបចំខ្លឹមសារមេរៀនសម្រាប់ឧទ្ទេស ឯកសារបណ្តុះបណ្តាល ស្តីពីការអប់រំបរិយាបន្នសម្រាប់មធ្យមសិក្សាទុតិយភូមិ មានអ្នកចូលរួម ៥៦នាក់ ស្រី ១០នាក់ នៅរាជធានី សហការជាមួយអង្គការយូនីសេហ្វ។

*ប្រការនេះ បានជួយឱ្យការគ្រប់គ្រង និងផ្តល់ឱកាសសិស្សមានពិការភាព និងសិស្សមានទេពកោសល្យឬបញ្ញាខ្ពស់ទទួលបានការសិក្សាប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។*

*ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្អែកលើលទ្ធផល*

ក្រសួងបាន៖

- ពិនិត្យតាមដានអាហារូបករណ៍សិស្សជនជាតិដើមភាគតិច ២៨សាលា ៥ខេត្ត សហការអនុវត្តជាមួយអង្គការយូនីសេហ្វ
- ពិនិត្យតាមដាន និងប្រមូលព័ត៌មានព្រមទាំងឯកសារទូទាត់ថវិកាលើកទី១ និងទី២ កម្មវិធីអាហារូបករណ៍សិស្សក្រីក្ររៀនពូកែ និងសិស្សពូកែលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ៧៦សាលា ២៥ ខេត្ត រាជធានី សហការជាមួយគម្រោងអភិវឌ្ឍវិស័យអប់រំនៅមធ្យមសិក្សាទុតិយភូមិ
- ពិនិត្យតាមដានការអនុវត្តកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅមធ្យមសិក្សា ៥៥សាលា ១១ខេត្ត
- ពិនិត្យតាមដានការអនុវត្តកម្មវិធីថ្នាក់ពីរភាសា បារាំង-ខ្មែរ តាមគ្រឹះស្ថានមធ្យមសិក្សា ១៥សាលា បឋមសិក្សា៧ វិទ្យាល័យ៨ ក្នុង ៧ខេត្ត រាជធានី
- រៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាថ្នាក់ពីរភាសា បារាំង-ខ្មែរ ៧ខេត្ត រាជធានី មានបេក្ខជនប្រឡងជាប់មធ្យមសិក្សាបឋមភូមិ ៣៩៨នាក់ ស្រី ២១០នាក់ ស្មើ ១០០ភាគរយ មធ្យមសិក្សាទុតិយភូមិ ២៤៥នាក់ ស្រី ១៣៤នាក់ ស្មើ ១០០ភាគរយ
- ពិនិត្យតាមដានពីដំណើរការរៀននិងបង្រៀនពីចម្ងាយ ក្នុងកម្មវិធីថ្នាក់ពីរភាសា បារាំង-ខ្មែរ ១៦សាលា ៧ខេត្ត រាជធានី
- ពិនិត្យតាមដានពីស្ថានភាពជាក់ស្តែង និងប្រមូលព័ត៌មានស្តីពីការសុំបើក ពង្រីក ប្តូរឈ្មោះ និងទទួលស្គាល់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ ៤៣សាលា ១៤ខេត្ត
- ពិនិត្យតាមដានពីស្ថានភាពជាក់ស្តែង និងប្រមូលព័ត៌មានស្តីពីការសុំបើក ពង្រីក ប្តូរឈ្មោះ និងទទួលស្គាល់គ្រឹះស្ថានសិក្សាឯកជនពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ៧២សាលា ក្នុង ១៤ខេត្ត រាជធានី
- ពិនិត្យតាមដានលើការងារដំណើរការប្រតិបត្តិអគារធនធាន ៣៦សាលា ២៥ខេត្ត រាជធានី
- ចាត់តាំងគ្រូបង្គោលថ្នាក់ជាតិចុះជួយសាលារៀនគោលដៅ នៃការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (SEIP) ១០០សាលា ក្នុង ២៥ខេត្ត រាជធានី
- ដឹកនាំប្រជុំប្រចាំសប្តាហ៍ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃការដឹកនាំ និងគ្រប់គ្រងការសិក្សាពីចម្ងាយតាមតំណ ZOOM ដល់ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យមធ្យមសិក្សាចំណេះទូទៅ និងគណៈគ្រប់គ្រងសាលាគោលដៅ១០០ ក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- ពិនិត្យតាមដានការអប់រំបរិយាបន្ននៅសាលារៀនមធ្យមសិក្សាគោលដៅ ១២ ក្នុងខេត្តព្រៃវែង និងកំពង់ឆ្នាំង
- ពិនិត្យតាមដានការអនុវត្តការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកនៅវិទ្យាល័យអប់រំពិសេស ក្នុងខេត្តកំពង់ចាម សៀមរាប និងបាត់ដំបង
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាសិក្សាសង្គមនៅខេត្តតាកែវ
- ពិនិត្យតានដានការងារបណ្ណាល័យ ៣១សាលា
- ពិនិត្យតាមដានការអនុវត្តការបង្រៀនអក្សរសិល្ប៍បរទេសនៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ២៤សាលា ខេត្តព្រៃវែង និងស្វាយរៀង
- ចុះប្រមូលស្ថិតិបណ្ណាល័យសាលាមធ្យមសិក្សា និងពិនិត្យតាមដានការអនុវត្តស្តង់ដាបណ្ណាល័យ ២៨សាលា នៅខេត្តកំពត ព្រះសីហនុ និងតាកែវ
- ពិនិត្យតាមដានការផ្គត់ផ្គង់ គ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលនៅតាមសាលារៀន២១ នៅខេត្តកំពង់ធំ
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ៣៥សាលា នៅខេត្តបាត់ដំបង និងតាកែវ

- ពិនិត្យតាមដានការតាក់តែងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមបឋមភូមិមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់៧-៩ នៅខេត្តតាកែវ
- ពិនិត្យតាមដានការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក នៅតាមសាលារៀនល្អ និងនាយកល្អ នៃ ៩គ្រឹះស្ថានមធ្យមសិក្សា (អនុវិទ្យាល័យ១ និងវិទ្យាល័យ ៨)
- ធ្វើអធិការកិច្ចតាមប្រធានបទ ១៦សាលាមធ្យមសិក្សាធនធាន ៩ខេត្ត រាជធានី
- ចុះស្រាវជ្រាវ និងប្រមូលព័ត៌មានដើម្បីកំណត់មុខជំនាញទៅតាមទីផ្សារការងារ ១៥សាលារៀន ៥ខេត្ត និង១៦ ក្រុមហ៊ុនឯកជន
- ចុះស្រាវជ្រាវនិងប្រមូលព័ត៌មានពីតម្រូវការជំនាញស្នែម ៧សាលារៀន ៧ខេត្តគោលដៅ
- ចុះពិគ្រោះយោបល់លើការរៀបចំកម្មវិធីសិក្សាលម្អិតលើជំនាញអគ្គិសនី នៅខេត្តកំពត និងជំនាញអេឡិចត្រូនិក នៅខេត្តកំពង់ធំ
- ចុះណែនាំពង្រឹងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាដល់គ្រូប្រឹក្សាតាមសាលារៀន ៣៧នាក់ ស្រី ១៣នាក់ ២ខេត្ត
- ចុះពង្រឹងគុណភាពការបង្រៀន និងរៀននៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ៨សាលា ៨ខេត្ត
- ចុះដឹកនាំប្រជុំពិភាក្សានិងណែនាំបច្ចេកទេសបន្ថែមលើការបង្រៀនពីចម្ងាយ ដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ផ្នែកអប់រំបច្ចេកទេស ១៣៥នាក់ ស្រី ៣២នាក់ ៨ខេត្ត
- ពិនិត្យណែនាំមុនដំណើរការរៀននិងបង្រៀនផ្នែកប្រតិបត្តិតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅ ៥ខេត្ត
- ចុះដឹកនាំប្រជុំស្តីពី ការពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃការដឹកនាំ និងគ្រប់គ្រងការអប់រំបច្ចេកទេស និងការចែករំលែកបទពិសោធ និងមេរៀនពិសោធន៍ ដល់គណៈគ្រប់គ្រងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស១៦សាលាទូទាំងប្រទេស នៅវិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍នៃសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ ខេត្តព្រៃវែង
- ដឹកនាំប្រជុំប្រចាំសប្តាហ៍ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃការដឹកនាំ និងគ្រប់គ្រងការសិក្សាពីចម្ងាយតាមZOOM ដល់គណៈគ្រប់គ្រងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ១៦សាលា ក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- ពិនិត្យតាមដានបន្ទប់កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យាសម្រាប់បំពាក់បន្ទប់កុំព្យូទ័រនៅមធ្យមសិក្សាទុតិយភូមិនៃគម្រោង CBR&D នៅវិទ្យាល័យ **ហ៊ុន សែន** វត្តស្វាយ
- ពិនិត្យសិក្សាបច្ចេកទេស និងបរិក្ខារព័ត៌មានវិទ្យា នៅទីតាំងផលិតផលកុំព្យូទ័រខ្មែរ KOOMPI
- ពិនិត្យវាយតម្លៃ និងប្រគល់-ទទួលកុំព្យូទ័រដែលត្រូវបំពាក់នៅតាមអគារធនធានដល់វិទ្យាល័យធនធាន ៨ ក្នុង ៨ ខេត្ត គាំទ្រដោយគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ
- ពិនិត្យនិងដំឡើងដំណើរការ Computer V Cloud សម្រាប់បំពាក់តាមអគារធនធានថ្មី ១៤ ក្នុង ១៤ខេត្ត គាំទ្រដោយគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ
- ពិនិត្យការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ៣០០ទីតាំង សហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- រៀបចំតារាងទិន្នន័យដែលជាព័ត៌មានបឋម ដែលមានអសយដ្ឋាន ទីតាំងវិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សា ៥០០ទីតាំង សហប្រតិបត្តិការជាមួយក្រុមហ៊ុនមិត្តហ្វូន
- ប្រគល់និងដំឡើងសម្ភារបច្ចេកទេស ជូនគ្រឹះស្ថានសិក្សាសាធារណៈទូទាំងប្រទេស កុំព្យូទ័របន្ទះ ៤៥៦គ្រឿង កុំព្យូទ័រយួរដៃ ៨៦គ្រឿង និងម៉ូនីទ័រ ១០៨គ្រឿង និងធុងសាកថ្ម ៣គ្រឿង សហការជាមួយក្រុមហ៊ុននានា
- ពិនិត្យមណ្ឌលប្រឡងសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២១០មណ្ឌល គ្រប់រាជធានី ខេត្ត។

*ប្រការនេះ បានជួយកែលម្អ និងលើកកម្ពស់ការងារដឹកនាំ គ្រប់គ្រង ការបង្រៀននិងរៀន ពិសេសការបង្រៀន និងរៀនពីចម្ងាយ តាមបែបបម្រុះ ដោយពង្រឹងស្វ័យភាព និងគណនេយ្យភាពរបស់សាលារៀន។*

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

*ការអភិវឌ្ឍសមត្ថភាព*

ក្រសួងបាន៖

- ផ្សព្វផ្សាយស្តីពីមុខជំនាញសិក្សានៅតាមគ្រឹះស្ថានមធ្យមសិក្សាដែលប្រើប្រាស់ភាសាបារាំង ដល់សិស្សមធ្យមសិក្សាទុតិយភូមិថ្នាក់ពីរភាសា បារាំង-ខ្មែរ ១៣សាលា ៦ខេត្ត
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀនគណិតវិទ្យា និងពិសោធន៍វិទ្យាសាស្ត្រ ៤មុខវិជ្ជា និងផ្សព្វផ្សាយឯកសារណែនាំមូលដ្ឋានការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដល់គ្រូបង្រៀនវិទ្យាល័យធនធាន ៨១នាក់ ស្រី ១៨នាក់ នៅខេត្តកំពង់ចាម
- បំប៉នសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ គណៈគ្រប់គ្រងសាលា និងប្រធានក្រុមបច្ចេកទេសស្តីពី ឯកសារក្រុមបច្ចេកទេស ដល់វិទ្យាល័យធនធាន និងបណ្តាញ ៨៨នាក់ ស្រី ២៦នាក់ នៅខេត្តកំពង់ចាម
- បំប៉នសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ មន្ត្រីបង្គោលប្រចាំតំបន់ទាំង៥ និងគណៈគ្រប់គ្រងវិទ្យាល័យធនធានស្តីពីស្វ័យឆ្លុះបញ្ចាំងសាលារៀន ៥៩នាក់ ស្រី ១២នាក់ នៅខេត្តកំពង់ធំ
- រៀបចំសិក្ខាសាលាលើកទី៣ និងទី៤ ស្តីពីការគ្រប់គ្រងតាមសាលារៀន ដល់មន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ៩៧៧នាក់ ស្រី ១០៣នាក់ នៅខេត្តសៀមរាប សហការជាមួយគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា
- រៀបចំសិក្ខាសាលាស្តីពី ការពង្រឹងការងារគ្រប់គ្រងអនុវិស័យមធ្យមសិក្សា ៨២នាក់ ស្រី១៥នាក់ ខេត្តកំពង់ចាម
- រៀបចំសិក្ខាសាលាស្តីពី ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងតាមសាលារៀនសម្រាប់អនុវិស័យការអប់រំមធ្យមសិក្សា និងបច្ចេកទេស មានអ្នកចូលរួម ៦៦នាក់ ស្រី ១០នាក់ នៅខេត្តកំពង់ចាម
- បំប៉នសមត្ថភាពស្តីពី ការអប់រំបរិយាបន្នសម្រាប់សិស្សមានពិការភាពនៅមធ្យមសិក្សាបឋមភូមិ ៦៥នាក់ ស្រី ១២នាក់ នៅខេត្តកំពង់ចាម
- បំប៉នសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ចស្តីពី ការវាយតម្លៃសាលារៀនតាមប្រព័ន្ធអេឡិចត្រូនិក ដល់មន្ត្រីការិយាល័យអធិការកិច្ច និងការិយាល័យជំនាញនៃមន្ទីរអប់រំ យុវជន និងកីឡា ៤៩នាក់ ស្រី ៥នាក់ មកពី ៥ខេត្ត នៅខេត្តកំពង់ចាម
- បំប៉នសមត្ថភាពស្តីពី ការវាយតម្លៃសាលារៀនតាមប្រព័ន្ធអេឡិចត្រូនិក ដល់ថ្នាក់ដឹកនាំការិយាល័យ មន្ត្រីការិយាល័យ ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក គណៈគ្រប់គ្រង និងក្រុមបច្ចេកទេស ១ ៤១៩នាក់ ស្រី ២១៨នាក់ មកពី ៦០ ក្រុង ស្រុក នៃ ៩ខេត្ត
- បំប៉នសមត្ថភាព នាយក នាយិកា និងគ្រូបង្រៀនវិទ្យាល័យធនធាន ៣៦ ស្តីពីការអនុវត្តកម្មវិធីអប់រំសហគ្រិនភាព នៅខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ មានអ្នកចូលរួម ៦៤នាក់ ស្រី ១៥នាក់
- បំប៉នសមត្ថភាពស្តីពី ការតម្រង់ទិសកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាកម្រិតមធ្យមសិក្សា ដល់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ៨៣៥នាក់ ស្រី ២៤៧នាក់
- បំប៉នសមត្ថភាពស្តីពី ការផលិតវីដេអូកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ២២វីដេអូសកម្មភាព សហការជាមួយអង្គការជំនួយព្រះវិហារហ្វាំងឡង់
- បណ្តុះបណ្តាលស្តីពី កម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាសម្រាប់មធ្យមសិក្សា មានអ្នកចូលរួម ៦៦នាក់ ស្រី ៣៣នាក់ សហការជាមួយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអ៊ែត

- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្រនៃការបង្រៀនដល់គ្រូបច្ចេកទេស ១២នាក់ ស្រី ៧នាក់ នៅខេត្តកំពង់ឆ្នាំង
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្រផលិតអាហារបែបសម្ងួតនិងឆ្អើរ ដល់គ្រូបច្ចេកទេស ១២នាក់ ស្រី ៧នាក់ នៅខេត្តកំពង់ឆ្នាំង
- បំប៉នសមត្ថភាពស្តីពី ការផលិតស្រាពីបន្លែផ្លែឈើ ដល់គ្រូបច្ចេកទេស ៩នាក់ ស្រី ៧នាក់ នៅខេត្តកំពង់ឆ្នាំង
- បំប៉នសមត្ថភាពដល់គ្រូបច្ចេកទេសជំនាញកែច្នៃអាហារជាស្ត្រី ៥នាក់ ស្តីពីការធ្វើនំប៉ុង ប្រហិត សាច់ក្រក និងនំខួបកំណើត នៅមជ្ឈមណ្ឌលកែច្នៃអាហារ KSK រាជធានី
- បណ្តុះបណ្តាលស្តីពី ការប្រើប្រាស់បន្ទប់រៀនអនឡាញ (Google Classroom) ដល់គណៈគ្រប់គ្រង និងគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ២៥៣នាក់ ស្រី ៦៨នាក់ នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ៩ខេត្ត
- បំប៉នសមត្ថភាពស្តីពី ការធ្វើបច្ចុប្បន្នភាពកម្មវិធីចុះឈ្មោះបេក្ខជន គណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ ដោយ ប្រើប្រាស់កុំព្យូទ័រសម្រាប់ប្រឡងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ ៦១០នាក់ ស្រី ៤៦នាក់ នៅ ៦ខេត្ត រួមមានខេត្តតាកែវ កំពត កំពង់ចាម បាត់ដំបង សៀមរាប និងព្រៃវែង
- បំប៉នសមត្ថភាពស្តីពី ភារកិច្ចរបស់គណៈកម្មការក្រុមមុខវិជ្ជា ដើម្បីរៀបចំអក្សរសម្ងាត់សម្រាប់ដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២៧៣នាក់ ស្រី ៤៧នាក់ នៅរាជធានី
- បំប៉នសមត្ថភាពស្តីពី តួនាទី និងភារកិច្ចគណៈកម្មការអប្បមាទ និងជំនួយការអប្បមាទទូទាំងប្រទេស សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ៣ ២៧៥នាក់ នៅ ១៨ខេត្ត រាជធានី
- បំប៉នសមត្ថភាពស្តីពី ការណែនាំកម្មវិធីភាសាអង់គ្លេសថ្នាក់ទី៧ ទី៨ ទី៩ ដល់ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេស ២៧៦នាក់ ស្រី ៦២នាក់
- បំប៉នសមត្ថភាពស្តីពី ការគ្រប់គ្រងតាមសាលារៀន ដល់នាយកសាលាមធ្យមសិក្សា ១០០នាក់ ស្រី ៥នាក់
- បំប៉នសមត្ថភាពស្តីពី កម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន ដល់គ្រូឧទ្ទេសដែលបង្រៀនមុខវិជ្ជាបំណិនជីវិត ៦២នាក់ ស្រី ១០នាក់
- បំប៉នសមត្ថភាពស្តីពី ការអប់រំបរិស្ថាន ដល់គ្រូឧទ្ទេសមុខវិជ្ជាវិទ្យាសាស្ត្រ ១៤នាក់ ស្រី ១១នាក់
- បំប៉នសមត្ថភាពស្តីពី ការរៀន និងបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក ២៩៩នាក់ ស្រី ១១០នាក់
- បំប៉នសមត្ថភាពស្តីពី ជំនាញក្នុងការរៀន និងបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក ១៧៧នាក់ ស្រី ៥៣នាក់
- បំប៉នសមត្ថភាពស្តីពី បំណិនគ្រប់គ្រងបណ្ណាល័យ ១៦នាក់ ស្រី ៥នាក់
- បំប៉នសមត្ថភាពស្តីពី ភាពធាប់ចាប់អារម្មណ៍លើយេនឌ័រក្នុងការអប់រំ ៣៨នាក់ ស្រី១៤នាក់
- បណ្តុះបណ្តាលស្តីពី ការសិក្សាពីចម្ងាយ និងប្រើប្រាស់កុំព្យូទ័របន្ទះ (Tablet) សម្រាប់គាំទ្រការរៀន និងបង្រៀនមានអ្នកចូលរួមម ២០នាក់ ស្រី ៥នាក់ នៅខេត្តបន្ទាយមានជ័យ
- បណ្តុះបណ្តាលស្តីពី ការបង្រៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក ដល់គ្រូបង្រៀនវិទ្យាល័យធនធាន១៦ និងសាលាបណ្តាញ ២៣ មានអ្នកចូលរួម ៤០០នាក់ ស្រី ៨៥នាក់ ៩ខេត្ត
- បំប៉នសមត្ថភាពស្តីពី បច្ចេកទេសអនុវត្តការប្រជុំតាមវីដេអូ ដល់អគ្គនាយកដ្ឋានទាំង៦ ចំណុះក្រសួងអប់រំ យុវជន និងកីឡា មានអ្នកចូលរួម ៦នាក់ ស្រី ១នាក់ នៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- បណ្តុះបណ្តាលតាមវីដេអូអនឡាញស្តីពី ការប្រើប្រាស់បណ្តាញសង្គម វិធីសាស្ត្រក្នុងការផលិតនិងគ្រប់គ្រងមាតិកាអប់រំបែបឌីជីថលសម្រាប់ការរៀននិងបង្រៀន និងការប្រើប្រាស់ផតខាស់សម្រាប់ការបង្រៀននិងរៀនភាសាអង់គ្លេស មានអ្នកចូលរួម ៣២១នាក់ ស្រី ៤២នាក់ នៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- បណ្តុះបណ្តាលសាកល្បងស្តីពី ប្រព័ន្ធគ្រប់គ្រងទិន្នន័យសិស្សតាមអនឡាញ ដល់សាលារៀនគោលដៅ ៣០ មានអ្នកចូលរួម ១១៦នាក់ ស្រី ៩០នាក់ នៅខេត្តសៀមរាប

- បណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការអាន និងការប្រើប្រាស់ផែនទី ដល់គ្រូបង្រៀន វិទ្យាល័យគោលដៅ ១៥នាក់ ស្រី ២នាក់ នៅខេត្តសៀមរាប
- បណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងថ្នាក់រៀន បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងជួសជុលកុំព្យូទ័រ មានអ្នកចូលរួម ៩នាក់ ស្រី ៧នាក់ នៅខេត្តសៀមរាប
- បណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងជួសជុល និងថែទាំកុំព្យូទ័រ ដល់គ្រូបង្រៀន ២៨នាក់ ស្រី ១៥នាក់ នៃ១៤ វិទ្យាល័យ នៅខេត្តកំពង់ស្ពឺ
- បណ្តុះបណ្តាលពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកស្តីពី ការប្រើប្រាស់កម្មវិធី (LMS) NAVER BAND បម្រើដល់ការបង្រៀន និងរៀន តាមរយៈអនឡាញ ៤០នាក់ ស្រី ៥នាក់ នៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន សហការជាមួយមន្ទីរអប់រំទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ
- បណ្តុះបណ្តាលស្តីពី ប្រព័ន្ធពង្រឹងសមត្ថភាពសិស្សថ្នាក់ទី១២ ដែលមានតំណភ្ជាប់ https://exam.moeys.gov.kh និងកម្មវិធីបច្ចេកទេសផ្សេងៗសម្រាប់ជំនួយដល់ការត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដល់ ៣ខេត្ត រាជធានី មានអ្នកចូលរួម ១ ០៤៦នាក់ ស្រី ៥៤១នាក់
- បំប៉នសមត្ថភាពគ្រូឧទ្ទេសថ្នាក់ជាតិស្តីពី វិធីសាស្ត្របង្រៀននិងការប្រើប្រាស់សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាពសម្រាប់ថ្នាក់ទី៧ និងថ្នាក់ទី១០ ចំនួន ២៨នាក់ ស្រី ១៤នាក់ នៅនាយកដ្ឋានសុខភាពសិក្សា
- បំប៉នសមត្ថភាពគ្រូបង្រៀនថ្នាក់ទី៧ និងថ្នាក់ទី១០ ចំនួន ៩៨នាក់ ស្រី ៤៩នាក់មកពីអនុវិទ្យាល័យនិងវិទ្យាល័យ ១២ ក្នុងស្រុកកងមាស និងវិទ្យាល័យ២ ក្នុងស្រុកស្រីសន្ធរ ស្តីពីវិធីសាស្ត្របង្រៀន និងការប្រើប្រាស់សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព នៅខេត្តកំពង់ចាម
- បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្រវាស់គំហើញ ដល់គ្រូបង្រៀន ៩នាក់ ស្រី ២នាក់ មកពីសាលារៀនគោលដៅ ៣ ក្នុងរាជធានី នៅនាយកដ្ឋានសុខភាពសិក្សា សហការជាមួយវិទ្យាស្ថានស្តារគំហើញប្រាអ៊ិនហូលដិន
- បំប៉នសមត្ថភាពស្តីពី ដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ-១៩ ដល់គណៈគ្រប់គ្រង និងគ្រូបង្រៀនមកពីសាលាមធ្យមសិក្សាក្នុងរាជធានី ៣៦៥នាក់ ស្រី ១២៣នាក់
- បញ្ជូនគ្រូផ្នែកអប់រំបច្ចេកទេស ៣៤នាក់ ស្រី ១១នាក់ ចូលរួមសិក្ខាសាលាស្តីពី ការកសាងសមត្ថភាពសម្រាប់គ្រូនៅកម្ពុជាផ្នែកបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងការអភិវឌ្ឍសម្ភារសិក្សាបែបឌីជីថល សហការជាមួយមជ្ឈមណ្ឌល SEAMEO TED
- បញ្ជូនគ្រូផ្នែកអប់រំបច្ចេកទេស ៣៥នាក់ ចូលរួមសិក្ខាសាលាស្វែងយល់ពីតម្រូវការការងារក្នុងយុគសម័យបដិវត្តឧស្សាហកម្ម៤.០ រវាងតំណាងវិស័យឯកជននិងគ្រូផ្នែកអប់រំបច្ចេកទេស និងទស្សនកិច្ចសិក្សានៅក្នុងរោងចក្រ ៣ នៅតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង សហការជាមួយមជ្ឈមណ្ឌល SEAMEO TED
- រៀបចំបណ្ណាល័យឌីជីថលសម្រាប់ ការបង្ការ ការទប់ស្កាត់គ្រោះថ្នាក់បង្កដោយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ១កន្លែង នៅបរិវេណវិទ្យាល័យបឹងត្របែកក្នុងរាជធានី សហការជាមួយស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា។

*ប្រការនេះ បានជួយពង្រឹងសមត្ថភាពមន្ត្រីអប់រំក្នុងការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាពក្នុងបរិបទថ្មី។*

## ខ. ទន្នន័យនៃសូចនាករផលសម្រេច

១៥ខេត្ត និងរាជធានី ដែលមានអត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ភាគរយ ។

## *ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច*

| | សូចនាករ | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ៖ កែលម្អការចូលរៀននិងរក្សាសិស្សឱ្យបានគង់វង្ស ប្រកបដោយសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា | | | | | | |
| ១. | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៥៩,៩ * | ៦៣,៧ | ៦០,៧ * | → |
| | *ប្រុស* | % | ៥៥,១ * | ៦១,១ | ៥៥,៣ * | → |
| | *ស្រី* | % | ៦៥,១ * | ៦៨,៦ | ៦៦,៦ * | → |
| ២. | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | % | ៣០,៩ * | ៣៤,២ | ៣២,២ * | → |
| | *ប្រុស* | % | ២៧,១ * | ៣២,២ | ២៨,៥ * | → |
| | *ស្រី* | % | ៣៥,១ * | ៣៦,៤ | ៣២,៣ * | ↓ |
| ៣. | អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ | % | ៧៤,៩ | ៨២,៣ | ៨១,៣ | → |
| | *ប្រុស* | % | ៧០,៨ | ៨០,៧ | ៨០,១ | → |
| | *ស្រី* | % | ៧៨,៦ | ៨៣,៩ | ៨២,៤ | → |
| ៤. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៤៧,៣ * | ៥០,២ | ៤៨,១ * | → |
| | *ប្រុស* | % | ៤២,៤ * | ៤៦,៩ | ៤៣,១ * | → |
| | *ស្រី* | % | ៥២,៥ * | ៥៤,២ | ៥៣,៤ * | → |
| ៥. | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ១៨,៦ | ១១,៦ | ១៨,២ | → |
| | *ប្រុស* | % | ២០,០ | ១២,៣ | ១៩,៦ | → |
| | *ស្រី* | % | ១៧,៤ | ១០,៥ | ១៦,៩ | → |
| ៦. | អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ | % | ៤២,២ | ៥៥,៨ | ៤៣,១ | → |
| | *ប្រុស* | % | ៣៨,១ | ៥១,២ | ៤០,០ | → |
| | *ស្រី* | % | ៤៨,៩ | ៦០,៨ | ៤៦,៤ | ↓ |
| ៧. | អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិ | % | ២៤,៥ | ៣៨,៧ | ២៤,៧ | → |
| | *ប្រុស* | % | ២០,៥ | ៣៦,៥ | ២២,៦ | → |
| | *ស្រី* | % | ២៨,៩ | ៤២,០ | ២៧,០ | ↓ |
| ៨. | ចំនួនក្រុង-ស្រុកដែលមានអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិច្រើនជាង ១៨,៩ភាគរយ | ចំនួន | ៩៦ | ៣៦ | ៩៦ | → |
| ៩. | ចំនួនសិស្សអាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ | ចំនួន | ៧២ ៤១៨ (២០១៨-១៩) | ៧៥ ៤១៨ | ៧៩ ៥៦៧ (២០១៩-២០) | ↑ |
| ១០. | ភាគរយសាលាមធ្យមសិក្សាអនុវត្តសាលាកុមារមេត្រី | % | ២៤,០១ | ២៤,៤ | ២៤.០ | → |
| ១១. | ភាគរយសាលាមធ្យមសិក្សាឆ្លើយតបនឹងស្តង់ដាអប្បរមាអនាម័យ ទឹកស្អាត | | | | | |
| | អនុវិទ្យាល័យ៖ | | | | | |
| | *កម្រិត ១* | % | ៥០,៤ | ៥៨,៩ | ៤៧,៧ | ↓ |
| | *កម្រិត ២* | % | ១៧,២ | ១៣,៤ | ២៦,៧ | ↑ |
| | *កម្រិត ៣* | % | ១,០ | ១,៨ | ១,៦ | → |
| | វិទ្យាល័យ៖ | | | | | |
| | *កម្រិត ១* | % | ៤៦,៧ | ៤៩,៣ | ៤២,៦ | ↓ |
| | *កម្រិត ២* | % | ២៨,១ | ២៦,៧ | ៣៦,៥ | ↑ |
| | *កម្រិត ៣* | % | ២,៨ | ១,៩ | ៣,១ | ↑ |
| ១២. | ភាគរយអនុវិទ្យាល័យមាន៖ | | | | | |
| | *បង្គន់អនាម័យ* | % | ៩៩,២ | ៩៣,១ | ១០០ | ↑ |
| | *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៨៦,៥ | ៤៧,០ | ៨៩,៦ | ↑ |

| | សូចនាករ | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| | *កន្លែងលាងដៃ* | % | ៥៥,៣ | ៤៣,៤ | ៨០,២ | ↑ |
| | *ប្រអប់សង្គ្រោះបឋម* | % | ៣៨,៣ | ៥០,៨ | ៤៥,៣ | → |
| ១៣. | ភាគរយវិទ្យាល័យមាន៖ | | | | | |
| | *បង្គន់អនាម័យ* | % | ៩៨,៩ | ៩៨,៨ | ១០០ | ↑ |
| | *ទឹកស្អាត* | % | ៨៧,៩ | ៥៧,៨ | ៩១,២ | ↑ |
| | *កន្លែងលាងដៃ* | % | ៧០,៦ | ៥៨,០ | ៨៥,៤ | ↑ |
| | *ប្រអប់សង្គ្រោះបឋម* | % | ៦១,៤ | ៥០,៨ | ៦៨,១ | ↑ |
| ១៤. | ភាគរយនៃសាលាមធ្យមសិក្សាដែលមានអគ្គិសនីប្រើប្រាស់៖ | | | | | |
| | *អនុវិទ្យាល័យ* | % | ៩៤,៣ | ៧៣,០ | ៩៣,៣ | ↑ |
| | *វិទ្យាល័យ* | % | ៩៨,៧ | ៩៣,៧ | ៩៨,៩ | ↑ |
| ១៥. | ចំនួនសាលាជំនាន់ថ្មី | ចំនួន | ៧ | ៨ | ៧ | → |
| ១៦. | ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | ចំនួន | ១៦ | ១៥ | ១៧ | ↑ |
| ១៧. | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | ចំនួន | ២ ៧០០ | ២ ៣៨៨ | ៣ ៣២៤ | ↑ |
| | *ចំនួនសិស្សស្រី* | ចំនួន | ១ ០៣៦ | ៥៨៣ | ១ ២៦៩ | ↑ |
| ១៨. | ចំនួនសាលារៀនអនុវត្តកម្មវិធីមគ្គុទ្ទេសក៏អាជីពនិងការផ្តល់ប្រឹក្សា | ចំនួន | ៦៥ | ១៨៥ | ៦៥ | → |
| ១៩. | ចំនួនសាលារៀនអនុវត្តកម្មវិធីជំនាញជីវិតតាមមូលដ្ឋាន | ចំនួន | ៥៩០ | ៧៨៨ | ៦៥០ | → |
| វត្ថុបំណងអនុវិស័យទី២ ៖ កែលម្អគុណភាពបង្រៀននិងរៀនឱ្យស្របតាមជំនាញសតវត្សទី២១ | | | | | | |
| ២០. | ភាគរយគ្រូមធ្យមសិក្សាបឋមភូមិមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិតាមរូបមន្ត ១២+២ | % | ៨៧,០ | ៩២,០ | ៨៨,២ | → |
| ២១. | ចំនួនគ្រូមធ្យមសិក្សាបានទទួលការធ្វើក្រឹតការ | ចំនួន | ២ ៤៩៨ | ១ ៧០០ | ១ ៣៨៧ | ↓ |
| ២២. | ភាគរយសាលាមធ្យមសិក្សាទុតិយភូមិប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍សម្រាប់គាំទ្រការបង្រៀននិងរៀន | % | ១៧,០ | ១៧,០ | ២៤,៦ | ↑ |
| ២៣. | ភាគរយគ្រូមធ្យមសិក្សាបឋមភូមិបញ្ចប់បរិញ្ញាបត្រផ្នែកអប់រំវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ | % | ២៦,២ | ១១,៧ | កំពុងបណ្តុះបណ្តាល ៣៨៤ | → |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅមធ្យមសិក្សា | | | | | | |
| ២៤. | ចំនួនគណៈគ្រប់គ្រងសាលាមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលលើការគ្រប់គ្រងតាមសាលារៀន | ចំនួន | ១៨០ | ២០០ | ១៨០ | → |
| ២៥. | ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ | ចំនួន | ១០០ | ២២៥ | ១០០ | → |

<u>**សម្គាល់៖**</u> ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

* រួមបញ្ចូលទាំងសាលាឯកជន

## បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- គណៈគ្រប់គ្រងសាលារៀនមួយចំនួនមិនទាន់មានសមត្ថភាពពេញលេញលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន
- ការអនុវត្តកម្មវិធីអប់រំស្នេហ៍ម នៅតែជាបញ្ហាសម្រាប់សាលារៀន
- ថវិការដ្ឋ និងដៃគូអភិវឌ្ឍមិនទាន់ឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានសម្រាប់ការពង្រីកវិសាលភាពនិងសមត្ថភាពការអប់រំបរិយាបន្ន

- គ្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសមិនទាន់អាចអនុវត្តបានពេញលេញ
- បរិវច្ឆការីមិនបានទទួលការបំប៉នសមត្ថភាព មានការផ្លាស់ប្តូរញឹកញាប់ និងខុសឯកទេសក្នុងការគ្រប់គ្រង បន្ទប់ពិសោធន៍នីមួយៗ
- សហគ្រាស កសិដ្ឋាន និងផ្នែកឯកជនមួយចំនួនពុំទាន់អាចផ្តល់ការគាំទ្រតាមតម្រូវការជាក់ស្តែងរបស់សាលាក្នុងការរៀបចំកម្មវិធីសិក្សា ការចុះកម្មសិក្សា និងទស្សនកិច្ចសិក្សា
- សាលាមធ្យមសិក្សាមិនទាន់អនុវត្តកម្មវិធីអប់រំបំណិនជីវិតបានល្អដោយសារសមត្ថភាពគណៈគ្រប់គ្រង និងគ្រូបង្រៀន និងកង្វះកិច្ចសហការពីអ្នកពាក់ព័ន្ធ
- គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសមួយចំនួនពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៍ពិសោធន៍ គរុកោសល្យ និងវិធីសាស្ត្របង្រៀនថ្មី
- ខ្វះមន្ត្រីបច្ចេកទេសផ្នែកបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) ដើម្បីធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបុគ្គលិក និងគរុសិស្ស នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- ខ្វះមន្ត្រីជំនាញបច្ចេកទេសផ្នែកប្រព័ន្ធគ្រប់គ្រងការរៀនពីចម្ងាយ
- សមត្ថភាពមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) សម្រាប់ដំណើរការកិច្ចការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពុំទាន់មានគ្រប់គ្រាន់តាមតម្រូវការ
- របនាសម្ព័ន្ធ និងមន្ត្រីទទួលបន្ទុកសុខភាពសិក្សានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទំហំការងារជាក់ស្តែង។

## ២.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន ១២៨ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៤៨ និងឯកជន ៨០ ដែលមានទីតាំងស្ថិតនៅ ២០ខេត្ត និងរាជធានី។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ១៦។

គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា៨០ ក្នុងនោះសាធារណៈ ១៣ និងឯកជន ៦៧ មានបុគ្គលិកអប់រំ ១៦ ៦៧៦នាក់ ស្រី ៣ ៤៧៥នាក់ និងនិស្សិតកំពុងសិក្សាមាន ២០១ ៩០០នាក់ ស្រី ១០២ ៥៩៩នាក់ ស្មើ ៥០,៨ភាគរយ។ គ្រឹះស្ថានឧត្តមសិក្សា ៤៥ ផ្តល់សេវាអប់រំថ្នាក់ក្រោយបរិញ្ញាបត្រក្នុងនោះ គ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បណ្ឌិត ២១ ។

តារាងទី១៨ ៖ ស្ថិតិគ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

| ល.រ | ឈ្មោះក្រសួង ស្ថាប័ន | រដ្ឋ | ឯកជន | សរុប |
|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | ១៣ | ៦៧ | ៨០ |
| ២ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១២ | ១៣ | ២៥ |
| ៣ | ក្រសួងការពារជាតិ | ៥ | ០ | ៥ |
| ៤ | ក្រសួងធម្មការ និងសាសនា | ៣ | ០ | ៣ |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣ | ០ | ៣ |
| ៦ | ក្រសួងសុខាភិបាល | ២ | ០ | ២ |
| ៧ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ | ០ | ១ |
| ៨ | ក្រសួងមហាផ្ទៃ | ១ | ០ | ១ |
| ៩ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១ | ០ | ១ |
| ១០ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ | ០ | ១ |
| ១១ | ធនាគារជាតិនៃកម្ពុជា | ១ | ០ | ១ |
| ១២ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ | ០ | ១ |
| ១៣ | ក្រសួងរ៉ែ និងថាមពល | ១ | ០ | ១ |
| ១៤ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១ | ០ | ១ |
| ១៥ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | ០ | ១ |
| ១៦ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ | ០ | ១ |
| | សរុប | ៤៨ | ៨០ | ១២៨ |

រូបភាពទី២៤ ៖ ការប្រៀបធៀបចំនួនគ្រឹះស្ថានឧត្តមសិក្សាពីឆ្នាំសិក្សា ២០១៥-១៦ ដល់ ២០១៩-២០



បុគ្គលិកអប់រំនៅឧត្តមសិក្សាមាន ១៦ ៦៧៦នាក់ ស្រី ៣ ៤៧៥នាក់ ស្មើ ២០,៨៤ភាគរយ ក្នុងនោះគ្រូមានសញ្ញាបត្របរិញ្ញាបត្រ ៤ ៤២៦នាក់ ស្មើ ២៦,៥៤ភាគរយ ស្រី ១ ៨២៥នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១០ ៨៥៩នាក់ ស្មើ ៦៥,១២ភាគរយ ស្រី ១ ៥០៣នាក់ និងបណ្ឌិត ១ ៣៩១នាក់ ស្មើ ០៨,៣៤ភាគរយ ស្រី ១៤៧នាក់។ បើធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ បរិញ្ញាបត្រជាន់ខ្ពស់កើន ៣០៥នាក់ ស្មើ ២,៨៩ភាគរយ និងបណ្ឌិតកើន ២៣នាក់ ស្មើ ១,៦៨ភាគរយ។

*ជារួម គុណវុឌ្ឍិគ្រូបង្រៀនកម្រិតឧត្តមបម្រើការនៅគ្រឹះស្ថានឧត្តមសិក្សាមានការប្រែប្រួលតិចតួចដែលទាមទារឱ្យមានការវិនិយោគបន្ថែមទៀតដោយមានផែនការគោលដាក់លាក់ ដើម្បីសម្រេចចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០។*

**រូបភាពទី២៥ ៖ ការប្រៀបធៀបបុគ្គលិកអប់រំនៅឧត្តមសិក្សាពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**




និស្សិតកំពុងសិក្សានៅឧត្តមសិក្សាទាំងអស់មាន ២០១ ៩០០នាក់ ស្រី ១០២ ៥៩៩នាក់ ស្មើ ៥០,៨ភាគរយ ក្នុងនោះនិស្សិតបរទេស ១៥៥នាក់ ស្រី ៧១នាក់ ស្មើ ៤៥,៨០ភាគរយ ប្រៀបធៀបនឹងឆ្នាំសិក្សា ២០១៩-២០២០ និស្សិតថយចុះ ២០ ៩៧៩នាក់ ស្មើ ៩,៤០ភាគរយ។

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង ១៩ ៧៨២នាក់ ស្រី ១០ ២៣៩នាក់ ស្មើ ៥១,៧៦ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ ២ ១៩៧នាក់ ស្រី ១ ០៥៩នាក់ ស្មើ ៤៨,២០ភាគរយ និងនិស្សិតសិក្សាបង់ថ្លៃ ១៧ ៥៨៥នាក់ ស្រី ៩ ១៨០នាក់ ស្មើ ៥២,២០ភាគរយ ប្រៀបធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ និស្សិតថ្នាក់បរិញ្ញាបត្ររងកើន ២០៧នាក់ ស្មើ ១,០៦ភាគរយ ស្រីថយ ៥២នាក់ ស្មើ ០,៥០ភាគរយ។

**រូបភាពទី២៦ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**




និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ១៧១ ១៨៣នាក់ ស្រី ៩២ ២៣៧នាក់ ស្មើ ៥៣,៨៨ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ ថយ ៨ ០៧៥នាក់ ស្មើ ៤,៥០ភាគរយ ស្រីកើន ១ ៣០៤នាក់ ស្មើ ១,៤៣ភាគរយ។

និស្សិតអាហារូបករណ៍ ២៧ ៣៩១នាក់ ស្រី ១៥ ០៥៧នាក់ ស្មើ ៥៤,៩៧ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ កើន ៥៣នាក់ ស្មើ ០,២០ភាគរយ ស្រីកើន ៨៩៨នាក់ ស្មើ ៦,៣៤ភាគរយ។ និស្សិតថ្នាក់បរិញ្ញាបត្រកំពុងសិក្សាឆ្នាំទី១ ចំនួន ៥៨ ៧៦៧នាក់ ស្រី ៣២ ២៥៥នាក់ ស្មើ ៥៤,៨៨ភាគរយ បើធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ កើន ៤ ១៧១នាក់ ស្មើ ៧,៦៤ភាគរយ ស្រីកើន ៤ ៣៣៩នាក់ ស្មើ ១៥,៥៤ភាគរយ។

*និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រថយចុះក្នុងឆ្នាំសិក្សា២០១៩-២០២០ ដោយសារផលប៉ះពាល់ជំងឺកូវីដ-១៩។*

**រូបភាពទី២៧ ៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**




និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ ១០ ៩៤៥នាក់ ថយ ៥៤,៤៨ភាគរយ ស្រី ៣ ១២៣នាក់ ស្មើ ២៨,៥៣ ភាគរយ ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៩ ៩៨៤នាក់ ស្រី ៣ ០៣៥នាក់ ស្មើ ៣០,៤០ភាគរយ និងថ្នាក់បណ្ឌិត ៩៦១នាក់ ស្រី ៨៨នាក់ ស្មើ ៩,១៦ភាគរយ ប្រៀបធៀបឆ្នាំសិក្សា២០១៨-២០១៩ និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ថយ ៥៧,០៧ភាគរយ និស្សិតថ្នាក់បណ្ឌិត កើន ២១,៦ភាគរយ។

*ជារួមយើងសង្កេតឃើញថា ចំនួននិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានការថយចុះគួរឱ្យកត់សម្គាល់ ដោយសារគ្រឹះស្ថានបានធ្វើបច្ចុប្បន្នកម្មបញ្ជីនិស្សិតដែលលើសឆ្នាំកំណត់ បោះបង់ការសិក្សា និងជាពិសេសផលប៉ះពាល់ជំងឺកូវីដ-១៩ ប៉ុន្តែនិស្សិតថ្នាក់បណ្ឌិតមានការកើនឡើង។*

**រូបភាពទី២៨៖ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**



រូបភាពទី២៩៖ និស្សិតកំពុងសិក្សាថ្នាក់បណ្ឌិត ពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០




និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង ៨ ១៨៤នាក់ ស្រី៤ ៣៦០នាក់ ស្មើ ៥៣,២៧ភាគរយ ក្នុងនោះ និស្សិតអាហារូបករណ៍ ៩២៤នាក់ ស្រី ៤៧៥នាក់ ស្មើ ៥១,៤០ភាគរយ និងនិស្សិតសិក្សាបង់ថ្លៃ ៧ ២៦០នាក់ ស្រី ៣ ៨៨៥នាក់ ស្មើ ៥៣,៥១ភាគរយ។ បើប្រៀបធៀបនឹងឆ្នាំសិក្សា២០១៨-២០១៩ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងកើន ១៧៤នាក់ ស្មើ ២,១៧ភាគរយ ស្រីកើន ១៧១នាក់ ស្មើ ៤,០៨ភាគរយ ប៉ុន្តែនិស្សិតអាហារូបករណ៍ថយ ២៣នាក់ ស្មើ ២,៤២ភាគរយ ស្រីថយ ១២៨នាក់ ស្មើ ២១,២២ភាគរយ។

រូបភាពទី៣០៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររងពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០




និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ៣២ ៦៤០នាក់ ស្រី ១៦ ៤៨២នាក់ ស្មើ ៥០,៤៩ភាគរយ ក្នុងនោះ និស្សិតអាហារូបករណ៍ ៥ ៥៨៧នាក់ ស្រី ២ ៩៣៨នាក់ ស្មើ ៥២,៥៨ភាគរយ និងនិស្សិតសិក្សាបង់ថ្លៃ ២៧ ០៥៣នាក់ ស្រី ១៣ ៥៤៤នាក់ ស្មើ ៥០,០៦ភាគរយ។ ធៀបទៅនឹងឆ្នាំសិក្សា២០១៨-២០១៩ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រថយ ៦ ០៦៩នាក់ ស្មើ១៥,៦៧ភាគរយ ស្រីថយ ៣ ៨៥៨នាក់ ស្មើ ១៨,៩៦ភាគរយ ក្នុងនោះនិស្សិតអាហារូបករណ៍ថយ ២១២នាក់ ស្មើ ៣,៦៥ភាគរយ ស្រីថយ ២៣នាក់ ស្មើ ០,៧៧ភាគរយ ។

រូបភាពទី៣១៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០



**រូបភាពទី៣២៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**




**រូបភាពទី៣៣៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយសរសេរនិក្ខេបទពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**




**រូបភាពទី៣៤៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ពីឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ២០១៩-២០២០**




និស្សិតកំពុងសិក្សានៅឧត្តមសិក្សាតាមវិស័យក្នុងឆ្នាំសិក្សា២០១៩-២០២០

**រូបភាពទី៣៥៖ ស្ថានភាពនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំសិក្សា២០១៩-២០២០**




និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រតាមវិស័យឆ្នាំសិក្សា២០១៩-២០២០

ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រមាននិស្សិតប្រមាណ ៧០ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ក្នុងនោះ ៤២ភាគរយសិក្សាជំនាញធុរកិច្ច ៧ភាគរយសិក្សាជំនាញច្បាប់ ១០ភាគរយសិក្សាជំនាញភាសាបរទេស ២ភាគរយសិក្សាជំនាញទេសចរណ៍ និង ៩ភាគរយសិក្សាជំនាញវិទ្យាសាស្ត្រសង្គមនិងសិល្បៈផ្សេងៗទៀត។ ចំណែកជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈនិងគណិតវិទ្យា(STEAM) មាន ៣០ភាគរយ ក្នុងនោះ ៥ភាគរយសិក្សាជំនាញវិទ្យាសាស្ត្រមូលដ្ឋាន ៩ភាគរយសិក្សាជំនាញ បច្ចេកវិទ្យាព័ត៌មាន ៨ភាគរយសិក្សាជំនាញសិក្សាវិស្វកម្ម ៣ភាគរយសិក្សាជំនាញកសិកម្ម និង ៥ភាគរយសិក្សាជំនាញសុខាភិបាល។ ជារួមក្នុងរយៈពេល ៥ឆ្នាំ ការសិក្សាជំនាញ STEAM បានកើនពី ២២ភាគរយ នៅឆ្នាំសិក្សា ២០១៥-២០១៦ ដល់ ៣០ភាគរយ នៅឆ្នាំសិក្សា ២០១៩-២០២០។

*ដូច្នេះ កិច្ចខិតខំនឹងត្រូវពង្រឹងបន្ថែមជាបន្តបន្ទាប់ទៀតពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងការវិនិយោគលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈនិងគណិតវិទ្យា(STEAM) ដើម្បីឱ្យឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។*

**រូបភាពទី៣៦៖ ស្ថានភាពនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្នុងឆ្នាំសិក្សា២០១៩-២០២០**




*ក្នុងចំណោមនិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៧៦ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ១១ភាគរយសិក្សាផ្នែកមនុស្សសាស្ត្រ ៨ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រធម្មជាតិ ៣ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រកសិកម្ម និង ២ភាគរយសិក្សាផ្នែកវិស្វកម្មនិងបច្ចេកវិទ្យា។*

**រូបភាពទី៣៧៖ ស្ថានភាពនិស្សិតកំពុងសិក្សាថ្នាក់បណ្ឌិតក្នុងឆ្នាំសិក្សា២០១៩-២០២០**



*និស្សិតថ្នាក់បណ្ឌិត ៨៩ភាគរយសិក្សាផ្នែកវិទ្យាសាស្ត្រសង្គម។ គ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន មិនទាន់ផ្តោតការវិនិយោគលើការបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) នៅឡើយ។ ដូច្នេះ ទាមទារឱ្យមានការជំរុញការវិនិយោគបន្ថែម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។*

**និស្សិតបញ្ចប់ការសិក្សាគ្រប់កម្រិតនៅឧត្តមសិក្សាតាមវិស័យក្នុងឆ្នាំសិក្សា២០១៩-២០២០**

**រូបភាពទី៣៨៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំសិក្សា២០១៩-២០២០**




និស្សិតដែលបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រប្រមាណ ៦៧ភាគរយ សិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ក្នុងនោះ ៣៧ភាគរយ សិក្សាជំនាញធុរកិច្ច ៨ភាគរយ សិក្សាជំនាញច្បាប់ ១០ភាគរយ សិក្សាជំនាញភាសាបរទេស ២ភាគរយ សិក្សាជំនាញទេសចរណ៍ និង ១០ភាគរយ សិក្សាជំនាញវិទ្យាសាស្ត្រសង្គម និងសិល្បៈផ្សេងៗទៀត។ ចំណែកជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈនិងគណិតវិទ្យា(STEAM) មាន ៣៣ភាគរយ ក្នុងនោះមានវិទ្យាសាស្ត្រមូលដ្ឋាន ៦ភាគរយ បច្ចេកវិទ្យាព័ត៌មាន ១០ភាគរយ វិស្វកម្ម ៨ភាគរយ កសិកម្ម ៤ភាគរយ និងសុខាភិបាល ៥ភាគរយ។

*លទ្ធផលខាងលើឆ្លុះបញ្ចាំងថា និស្សិតដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា (STEM) នៅមានចំនួនតិច មិនទាន់ឆ្លើយតបបានពេញលេញទៅនឹងតម្រូវការទីផ្សារការងារ។*

**រូបភាពទី៣៩៖ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្នុងឆ្នាំសិក្សា២០១៩-២០២០**



និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ១ភាគរយប៉ុណ្ណោះ បានបញ្ចប់ការសិក្សាផ្នែកវិស្វកម្មនិងបច្ចេកវិទ្យា ១ភាគរយ ផ្នែកវិទ្យាសាស្ត្រវិជ្ជសាស្ត្រនិងសុខាភិបាល ២ភាគរយ ផ្នែកវិទ្យាសាស្ត្រកសិកម្ម ៥ភាគរយ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ ៩ភាគរយ ផ្នែកមនុស្សសាស្ត្រ ក្រៅពីនោះគឺផ្នែកវិទ្យាសាស្ត្រសង្គម។ ដូច្នេះ កម្ពុជានៅតែមានបញ្ហាប្រឈមខាងគម្លាតជំនាញកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដែលទាមទារឱ្យវិនិយោគបន្ថែមឱ្យបានច្រើនថែមទៀតក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។

*ចំពោះនិស្សិតបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតក្នុងឆ្នាំសិក្សា២០១៩-២០២០ ផ្នែកវិទ្យាសាស្ត្រសង្គម ១០០ភាគរយ។*

## *ការពង្រឹងយន្តការជ្រើសរើសនិស្សិតចូលរៀន ការប្រឡងបញ្ចប់ការសិក្សា និងនិស្សិតអាហារូបករណ៍*

ក្រសួងបាន៖

- បោះពុម្ពសៀវភៅមគ្គុទេសក៍ ២៤ ៤០០ក្បាល សៀវភៅកម្រងព័ត៌មានអាហារូបករណ៍ ១១០ ០០០ក្បាល ពាក្យសុំអាហារូបករណ៍ ១១០ ០០០ច្បាប់ បង្កាន់ដៃពាក្យសុំ ១១០ ០០០ច្បាប់ សលាកបត្រឯកត្តជន ៤៥ ០០០ច្បាប់ ពាក្យសុំអាហារូបករណ៍ក្រីក្រ ៤៥ ០០០ច្បាប់ ពាក្យសុំសម្រាប់សិស្សពិការភាព ២ ៥០០ច្បាប់ និងបង្កាន់ដៃពាក្យសុំសម្រាប់សិស្សពិការភាព ២ ៥០០ច្បាប់
- បំប៉នសមត្ថភាពស្តីពី នីតិវិធី និងយន្តការនៃការបំពេញសំណុំពាក្យស្នើសុំក្នុងអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សម្រាប់មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា ២៥ ខេត្ត រាជធានី និងវិទ្យាល័យ មានអ្នកចូលរួម ៧៣៦នាក់ ស្រី ៥៨នាក់
- ពិនិត្យការប្រឡងនិងជ្រើសរើសនិស្សិតឱ្យចូលរៀនឆ្នាំទី១ ថ្នាក់បរិញ្ញាបត្ររង ៦ ០៥១នាក់ ស្រី ៣ ០៣៣នាក់ ស្មើ ៥០ភាគរយ និងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ២៥ ៣៩៩នាក់ ស្រី ១៤ ៥៤៩នាក់ ស្មើ ៥៧ភាគរយ ព្រមទាំងផ្តល់អាហារូបករណ៍ដល់និស្សិត ៩ ១៣០នាក់
- ពិនិត្យការប្រឡងនិស្សិតបញ្ចប់ការសិក្សា និងការពារសារណាបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្ររង ២ ៩៦៣នាក់ ស្រី១ ៧១៤នាក់ និងថ្នាក់បរិញ្ញាបត្រ ១១ ១៥១នាក់ ស្រី ៥ ៥៩៧នាក់ ព្រមទាំងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៣ ២៩៦នាក់ ស្រី ៩៣២នាក់ ក្នុងនោះនិស្សិតការពារនិក្ខេបបទ ៤៦៥នាក់ ស្រី ១៤៧នាក់ និងថ្នាក់បណ្ឌិត ៣១នាក់ ស្រី ៣នាក់។

## *និស្សិតបរទេសសិក្សានៅកម្ពុជា និង និស្សិតកម្ពុជាសិក្សានៅបរទេស*

ក្រសួងបាន៖

- ទទួលនិស្សិតបរទេសសិក្សានៅកម្ពុជា ១៥៥នាក់ ស្រី ៧១នាក់ ស្មើ ៤៥,៨១ភាគរយ ក្នុងនោះនិស្សិតវៀតណាម ៨៦នាក់ និស្សិតឡាវ ៥៤នាក់ និងនិស្សិតសាធារណរដ្ឋប្រជាមានិតចិន ១៥នាក់។ និស្សិតបានបញ្ចប់ការសិក្សាដោយជោគជ័យ ៤៧នាក់ ស្រី ២៨នាក់ ស្មើ ៥៩,៥៧ភាគរយ
- បញ្ជូននិស្សិតអាហារូបករណ៍កម្ពុជា ៤៣៧នាក់ ស្រី ១៤៣នាក់ ស្មើ ៣២,៧៣ភាគរយ ឱ្យទៅសិក្សានៅបរទេសចាប់ពីកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈដល់ថ្នាក់បណ្ឌិត រួមមានថ្នាក់បណ្ឌិត ១៣នាក់ ស្រី ១នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១១២នាក់ ស្រី ៣៩នាក់ បរិញ្ញាបត្រ ២៨០នាក់ ស្រី ៩៣នាក់ ថ្នាក់បច្ចេកទេស ១២នាក់ ស្រី ២នាក់ វិជ្ជាជីវៈ ៩នាក់ ស្រី ៣នាក់ និងការស្រាវជ្រាវ ១១នាក់ ស្រី ៥នាក់ នៅប្រទេស ៧ រួមមានវៀតណាម ១៤០នាក់ ស្រី ៣២នាក់ ឡាវ ១៥នាក់ ស្រី ១០នាក់ ថៃ ៥៩នាក់ ស្រី ២៤នាក់ និស្សិតសាធារណរដ្ឋប្រជាមានិតចិន ១៥៥នាក់ ស្រី ៥៦នាក់ ជប៉ុន ៥៦នាក់ ស្រី ១៧នាក់ ហុងគ្រី ១៥នាក់ ស្រី ៤នាក់ គុយបា ១នាក់ ដោយមានកិច្ចសហការជាដៃគូ និងភាគីមិត្ត

- ទទួលនិស្សិតកម្ពុជា និងបរទេសឱ្យស្នាក់នៅមជ្ឈមណ្ឌលអន្តេវាសិកដ្ឋាននិស្សិតនារី ៨២៣នាក់ ស្រី ៦០៨នាក់ ស្មើ ៧៣,៨៨ភាគរយ ក្នុងនោះនិស្សិតបរទេស ១៥៥នាក់ ស្រី ៧១នាក់
- ចេញសេចក្តីបញ្ជាក់សញ្ញាបត្រមកពីក្រៅប្រទេស ចាប់ពីកម្រិតមធ្យមសិក្សាទុតិយភូមិ មធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ៣៨០នាក់ ស្រី ៩៤នាក់។

*ប្រការនេះបញ្ជាក់ថា ចំនួននិស្សិតអាហារូបករណ៍បរទេសសិក្សាក្នុងប្រទេសមានចំនួនថេរ។ រីឯការផ្លាស់ប្តូរនិស្សិតក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយភាគីមិត្តមានចំនួនថយចុះដោយបញ្ហាជំងឺកូវីដ-១៩។ ប៉ុន្តែកិច្ចសហប្រតិបត្តិការត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់។*

## *ការរៀបចំក្របខណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយឧត្តមសិក្សា*

ក្រសួងបាន៖

- ទទួលអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យឡានម៉ែកម្ពុជារបស់រាជរដ្ឋាភិបាលកម្ពុជា
- ចេញប្រកាសលេខ ២១០៦ អយក.ប្រក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ អនុញ្ញាតឱ្យសាកលវិទ្យាល័យស្វាយរៀង ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញ កែច្នៃអាហារ និងនវានុវត្តន៍
- ចេញប្រកាសលេខ ២១០៧ អយក.ប្រក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ អនុញ្ញាតឱ្យវិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញវិទ្យាសាស្ត្រទិន្នន័យ ការគ្រប់គ្រងបច្ចេកវិទ្យា និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត
- ចេញប្រកាសលេខ ២១០៨ អយក.ប្រក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ អនុញ្ញាតឱ្យសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញកែច្នៃអាហារ និងនវានុវត្តន៍
- ចេញប្រកាសលេខ ២៤៧៨ អយក.ប្រក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ អនុញ្ញាតឱ្យវិទ្យាស្ថានសិល្បៈភ្នំពេញអន្តរជាតិធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញគំនូរ រចនា និងតូរ្យតន្ត្រី
- ចេញប្រកាសលេខ ២០២៥ អយក.ប្រក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់មុខជំនាញថ្មី និងបន្ថែមកម្រិតបរិញ្ញាបត្ររងលើមុខជំនាញដែលមានស្រាប់ នៃសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ
- ប្រកាសលេខ ១០៦០ អយក.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់មុខជំនាញវិស្វកម្មសំណង់ស៊ីវិល កម្រិតបរិញ្ញាបត្រ នៅសាកលវិទ្យាល័យលីមកុកវីង យូនីវើស៊ីធី អហ្វគ្រេអេតទីវ តិចណូឡូជី
- ចេញប្រកាសលេខ ៥៧៩ អយក.ប្រកចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ស្តីពីការទទួលស្គាល់វិទ្យាស្ថានតាក់ក្លូបល
- ចេញប្រកាសលេខ ២៣៧ អយក.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតមហាវិទ្យាល័យរដ្ឋបាលធុរកិច្ច និងសហគ្រិនភាព កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររងនៃសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ
- ចេញប្រកាសលេខ ៦៤០ អយក.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការបង្កើតមហាវិទ្យាល័យសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង
- ចេញប្រកាសលេខ ៧០៣ អយក.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការបង្កើតមុខជំនាញថ្មី នៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ
- ចេញប្រកាសលេខ ២០២៤ អយក.ប្រក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការបង្កើតដេប៉ាតឺម៉ង់ថ្មី និងជំនាញថ្មី នៅសាកលវិទ្យាល័យស្វាយរៀង
- ចេញប្រកាសលេខ ២៩៥៥ អយក.ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់ការបង្កើតមុខជំនាញគណនេយ្យ របស់វិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា

- ចេញប្រកាសលេខ ២៤១៤ អយក.ប្រក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់ការរៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រ
- ចេញប្រកាសស្តីពីការបង្កើតដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅវិទ្យាស្ថានធុរកិច្ចនិងបច្ចេកវិទ្យា ក្រុងព្រះសីហនុ សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីបូព៌ា និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ
- ចេញសេចក្តីសម្រេចស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មីនៃវិទ្យាស្ថានសិក្សាដើម្បីជោគជ័យនិងវិទ្យាស្ថានស៊ីតិក
- ចេញលិខិតទទួលស្គាល់ ស្តីពីការទទួលស្គាល់កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់នៃវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា បរិញ្ញាបត្ររងនៃវិទ្យាស្ថានបច្ចេកវិទ្យាជប៉ុន បរិញ្ញាបត្ររងនៃវិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ចៈ បរិញ្ញាបត្ររងនិងបរិញ្ញាបត្រនៃសាកលវិទ្យាល័យបៀលប្រាយ បរិញ្ញាបត្ររងនៃសាកល វិទ្យាល័យភ្នំពេញអន្តរជាតិ បរិញ្ញាបត្ររងនៃវិទ្យាស្ថានគ្រប់គ្រងភីស៊ីអិល បរិញ្ញាបត្រនៃសាកលវិទ្យាល័យធនធានមនុស្ស និងបរិញ្ញាបត្ររងនិងបរិញ្ញាបត្រនៃសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ
- ចេញលិខិតយល់ព្រមជាគោលការណ៍លេខ ៣៨៥៩ អយក.ឧស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីករណីស្នើសុំពិនិត្យ និងផ្តល់ការគាំទ្រដល់គម្រោងបើកសាលាបណ្តុះបណ្តាលគិលានុបដ្ឋាកដែលឧបត្ថម្ភគាំទ្រដោយសកម្មភាពមនុស្សធម៌ របស់អង្គការអន្តរជាតិហេប្រុន មជ្ឈមណ្ឌលវេជ្ជសាស្ត្រហេប្រុន
- ចេញលិខិតយល់ព្រមលេខ ៥៦០០ អយក.ឧស ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស្តីពីករណីស្នើសុំប្តូរទីតាំងវិទ្យាស្ថានគ្រប់គ្រង ភីស៊ីអិល ពីរាជធានីភ្នំពេញ ទៅខេត្តសៀមរាប
- រៀបចំសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ សម្រាប់អនុវិស័យឧត្តមសិក្សា មានអ្នកចូលរួម ១៣២នាក់ ស្រី ៣២នាក់
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំឯកសារទស្សនាទានស្តីពីគោលនយោបាយស្រាវជ្រាវ និងអភិវឌ្ឍន៍នៅក្នុងអនុវិស័យឧត្តមសិក្សា មានអ្នកចូលរួម ៤៦នាក់ ស្រី ៩នាក់។

### *ការធានាគុណភាពអប់រំនៅឧត្តមសិក្សា*

ក្រសួងបាន៖

- ដាក់ឱ្យអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការយុទ្ធសាស្ត្រគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាឆ្នាំ២០២០-២០៣០ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០
- ចេញសេចក្តីណែនាំលេខ ០១/២០ គ.ទ.ក សណន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ស្តីពីដំណើរការ និងនីតិវិធីនៃការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាសម្រាប់មន្ត្រីវាយតម្លៃ
- ព្រាងសៀវភៅណែនាំស្តីពីប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- រៀបចំសិក្ខាសាលាស្តីពី ការអនុវត្តលើការតេរ៉ារបស់និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា មានអ្នកចូលរួម ៦៤នាក់ ស្រី ១២នាក់
- ធ្វើបុរេវាយតម្លៃពីគុណភាពនៃរបាយការណ៍ស្វ័យវាយតម្លៃ និងការចុះពិនិត្យនិងផ្ទៀងផ្ទាត់លក្ខណសម្បត្តិរបស់គ្រឹះស្ថានឧត្តមសិក្សា ១៤ រួមមាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យស្វាយរៀង សាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយុទ្ធពលខេមរភូមិន្ទ សាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ សាកលវិទ្យាល័យអន្តរជាតិ សាកលវិទ្យាល័យអង្គរ វិទ្យាស្ថានវ៉ាន់ដា វិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា និងសាកលវិទ្យាល័យឯកទេសនៃកម្ពុជាទីតាំងគោលភ្នំពេញ ព្រមទាំងសាខាចំនួនពីរ

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់បញ្ចប់សៀវភៅណែនាំសម្រាប់មន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សាមានអ្នកចូលរួម ៤៥នាក់ ស្រី ៧នាក់
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីវាយតម្លៃ ស្តីពីការអនុវត្តសៀវភៅណែនាំមន្ត្រីវាយតម្លៃក្នុងការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា មានអ្នកចូលរួម ៤៧នាក់ ស្រី ៨នាក់
- ពិនិត្យស្ថានភាពបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា ៤។

*ការបង្រៀន និងការស្រាវជ្រាវ*

ក្រសួងបានៈ

- រៀបចំសន្និសីទជាតិលើកទី២ ស្តីពី ការស្រាវជ្រាវ និងនវានុវត្តន៍នៅកម្ពុជា ក្រោមប្រធានបទ តួនាទីរបស់សាកលវិទ្យាល័យនៅកម្ពុជាក្នុងការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យា តាមរយៈប្រព័ន្ធអនឡាញ មានអ្នកចូលរួម ៣៤៧នាក់ ស្រី ៥២នាក់
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រក្នុងនោះរួមមានៈ ១.ការអនុវត្តសាកល្បងលើទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ ២.សេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានអ្នកចូលរួម ៤៩នាក់ ស្រី ៦នាក់
- បណ្តុះបណ្តាលស្តីពី ការស្រាវជ្រាវលើវិធីសាស្ត្របង្រៀននិងវង្វាយតម្លៃ ដើម្បីបន្ស៊ីនឹងតេស្ត PISA_D វគ្គបណ្តុះបណ្តាលជាលក្ខណៈមគ្គុទ្ទេសក៍ មានអ្នកចូលរួម ៨៧នាក់ ស្រី ៣៧នាក់
- ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តគម្រោងស្រាវជ្រាវ ៣០ គម្រោងរបស់គ្រឹះស្ថានសិក្សាគោលដៅទាំង ៥ រួមមាន សាកលវិទ្យាល័យជាតិបាត់ដំបង សាកលវិទ្យាល័យស្វាយរៀង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- រៀបចំសិក្ខាសាលាបច្ចេកទេសការគាំទ្រការអនុវត្ត ពិនិត្យតាមដានគម្រោងស្រាវជ្រាវ និងវគ្គតម្រង់ទិសស្តីពីការរៀបចំគម្រោងស្រាវជ្រាវ មានអ្នកចូលរួម ៧៧នាក់ ស្រី ៥នាក់
- បោះពុម្ពផ្សាយ ១៥៣ ប្រធានបទ ក្នុងនោះ បោះពុម្ពផ្សាយក្នុងស្រុក៩៥ប្រធានបទ លើផ្នែកវិទ្យាសាស្ត្រសង្គម, ច្បាប់, អប់រំ, ទេសចរណ៍, ស្ត្រី, សេដ្ឋកិច្ចអភិវឌ្ឍន៍, ភាសាអង់គ្លេស, អភិបាលកិច្ច, ទំនាក់ទំនងអន្តរជាតិ, សេដ្ឋកិច្ច, បច្ចេកវិទ្យា, កសិកម្ម, ទឹកនិងបរិស្ថាន, បច្ចេកវិទ្យាអាហារនិងអាហារូបត្ថម្ភ, វិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្គុំ, មេកាត្រូនិក និងបច្ចេកវិទ្យាពត៌មាន, បច្ចេកវិទ្យាថាមពល និងគ្រប់គ្រង និងបោះពុម្ពផ្សាយអន្តរជាតិ៥៨ ប្រធានបទស្តីពីច្បាប់, អប់រំ, ទំនាក់ទំនងអន្តរជាតិ, សេដ្ឋកិច្ច បច្ចេកវិទ្យា, វិស្វកម្ម, ទេសចរណ៍, ទឹកនិងបរិស្ថាន, បច្ចេកវិទ្យាអាហារ និងអាហារូបត្ថម្ភ, វិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្គុំ, មេកាត្រូនិក និងបច្ចេកវិទ្យាព័ត៌មាន, បច្ចេកវិទ្យាថាមពល និងគ្រប់គ្រង
- កំពុងអនុវត្តគម្រោងស្រាវជ្រាវ ២៩៤ ក្នុងនោះគម្រោងស្រាវជ្រាវជាមួយដៃគូ ១១៥ អត្ថបទ ស្រាវជ្រាវផ្នែកអប់រំ, ច្បាប់, សង្គមសាស្ត្រ មនុស្សសាស្ត្រ សិក្សាអភិវឌ្ឍន៍, ភាសាបរទេស, កសាងសមត្ថភាពគ្រឹះស្ថាន, ទំនាក់ទំនងអន្តរជាតិ, ការអភិវឌ្ឍសង្គម, គ្រប់គ្រងទេសចរណ៍, គ្រប់គ្រងធុរកិច្ច, ធនាគារ, ហិរញ្ញវត្ថុ, សេដ្ឋកិច្ច, បណ្តាញទំនាក់ទំនងបច្ចេកវិទ្យា, កសិកម្ម, ឧស្សាហកម្ម និងបច្ចេកវិទ្យា, ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ទឹកនិងបរិស្ថាន, បច្ចេកវិទ្យាអាហារ និងអាហារូបត្ថម្ភ, វិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្គុំ, មេកាត្រូនិក និងបច្ចេកវិទ្យា, ពត៌មាន, បច្ចេកវិទ្យាថាមពល និងគ្រប់គ្រង
- បណ្តុះបណ្តាលអ្នកស្រាវជ្រាវពេញម៉ោង ១០៧នាក់ ស្រី ២៧នាក់ មិនពេញម៉ោង ៣០នាក់ ស្រី ២នាក់ និងបុគ្គលិកគាំទ្រការស្រាវជ្រាវពេញម៉ោង ៤៩នាក់ ស្រី ១៧នាក់ និងមិនពេញម៉ោង ១០៤នាក់ ស្រី ១៤នាក់

- ពិនិត្យវាយតម្លៃនិងផ្តល់មូលនិធិគម្រោងស្រាវជ្រាវ ៩៣ ដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ៥ ក្នុងនោះ ៤៥ គម្រោងបានផ្សារភ្ជាប់ទៅនឹងឧស្សាហកម្ម ដែលដឹកនាំនិងសហដឹកនាំដោយស្ត្រី ២២គម្រោង
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការព្រាងគោលការណ៍មជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា មានអ្នកចូលរួម ៦១នាក់ ស្រី ១១នាក់
- រៀបចំសិក្ខាសាលាស្តីពី គោលការណ៍ណែនាំលើការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា នៅតាមគ្រឹះស្ថានឧត្តមសិក្សា មានអ្នកចូលរួម ៣៥នាក់ ស្រី ៦នាក់។

### *គន្លងថ្មីក្នុងវិស័យអប់រំក្នុងបរិបទកូវីដ-១៩ នៅតាមគ្រឹះស្ថានឧត្តមសិក្សា*

ក្រសួងបាន៖

- រៀបចំដំណើរការនៃការផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដោយកំណត់យកកម្មវិធី Microsoft Office ៣៦៥ (Microsoft Teams), Google meet, Google Classroom និង Hangout Meet / Zoom, BlueJeans និងកម្មវិធីផ្សេងៗទៀត ដោយមានការអនុញ្ញាតពីក្រសួង
- បង្កើតមធ្យោបាយ ឧបករណ៍ណែនាំនិស្សិតក្នុងការប្រើប្រាស់នូវទម្រង់សិក្សាពីចម្ងាយ
- រៀបចំបណ្តាញ ទំហំ និងល្បឿនអ៊ីនធឺណិតបម្រើឱ្យការរៀននិងបង្រៀន
- រៀបចំសៀវភៅមគ្គុទ្ទេសក៍សម្រាប់ការរៀន ការបង្រៀនពីចម្ងាយ និងរៀបចំវីដេអូណែនាំ អំពីរបៀបបង្រៀន និងរៀនជូនដល់សាស្ត្រាចារ្យ និងនិស្សិត
- បណ្តុះបណ្តាលគ្រូបង្រៀន និងគ្រូជំនួយស្តីពី ការប្រើប្រាស់កម្មវិធីតាមបែបឌីជីថលដោយផលិតជាវីដេអូរៀបចំមេរៀន និងឯកសារសិក្សាផ្សេងៗ
- បង្កើតគណៈកម្មការគ្រប់គ្រង និងក្រុមអ្នកបច្ចេកទេសគាំទ្រក្នុងការផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដោយមានការបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់
- បង្កើតកម្មវិធីអនឡាញ ដើម្បីទំនាក់ទំនងជូនព័ត៌មាននិស្សិត ទាក់ទងការសិក្សា ការចុះឈ្មោះចូលរៀន និងបង់ថ្លៃសិក្សា
- បំពាក់ឧបករណ៍វាស់កម្តៅស្វ័យប្រវត្តិ ម៉ាស៊ីនបាញ់សម្លាប់មេរោគ រៀបចំកន្លែងលាងដៃ ផ្តល់ទឹកអាល់កុលសម្រាប់លាងដៃ ម៉ាស់ រក្សាគម្លាតអង្គុយ ព្រមទាំងបានអនុវត្តយ៉ាងត្រឹមត្រូវ និងខ្ជាប់ខ្ជួន ជាពិសេសស្តង់ដា SOP នៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ពិនិត្យតាមដាន និងវាយតម្លៃលើការបង្រៀន និងការរៀនតាមបែបឌីជីថលនេះ ដើម្បីធានាគុណភាពអប់រំរបស់និស្សិត។

### *ចំណុចប្រឈមនៃគន្លងថ្មីវិស័យអប់រំក្នុងបរិបទកូវីដ-១៩*

ទោះបីជាមានការខិតខំដោះស្រាយគ្រប់មធ្យោបាយយ៉ាងណាក្តី បញ្ហាប្រឈមជាក់ស្តែងនៅតែមានដែលគួរកត់សម្គាល់រួមមាន៖

- ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ដំណើរការបណ្តុះបណ្តាលបែបឌីជីថលកង្វះកម្មវិធី Software ឧបករណ៍សម្ភារៈថតវីដេអូ បម្រើឱ្យការបង្រៀន និងការគ្រប់គ្រង ព្រមទាំងប្រឈមលើការចំណាយ
- នៅគ្រឹះស្ថានសិក្សាមួយចំនួននិស្សិតចូលរៀនមានចំនួនតិច ឬសិក្សាមិនពេញលេញ និងនិស្សិតមានបញ្ហាប្រឈមទាក់ទងនឹងឯកសារ ឧបករណ៍សិក្សា សេវាអ៊ីនធឺណិតមានតម្លៃថ្លៃ ដំណើរការពុំបានល្អ កង្វះថវិកា ព្រមទាំងពិបាកទំនាក់ទំនងរវាងគណៈគ្រប់គ្រង គ្រូបង្រៀនជាមួយនិស្សិតជាដើម

- សមត្ថភាពគ្រូបង្រៀននៅមានកម្រិត កង្វះបទពិសោធន៍ក្នុងការរៀបចំមេរៀន ការរៀបចំវីដេអូរូបភាពបង្រៀនតាមបែបឌីជីថល ហើយសាស្ត្រាចារ្យជាជនជាតិបរទេសពុំអាចធ្វើដំណើរមកបង្រៀនបាន
- យន្តការនៃការគ្រប់គ្រងទិន្នន័យនិស្សិត ការតាមដានវត្តមាន និងការរៀបចំគ្រប់គ្រងពិន្ទុនិស្សិត នៅមានភាពមិនទាន់ច្បាស់លាស់
- មានផលវិបាករៀបចំការសិក្សាបែបអនុវត្តផ្សាភ្ជាប់ទ្រឹស្តីក្នុងកសិដ្ឋាន រោងជាង និងបន្ទប់ពិសោធន៍។

## ក២. ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

*ការចូលរួមសន្និសីទ កិច្ចប្រជុំ និងសិក្ខាសាលានៅក្រៅប្រទេស (មុនបរិបទកូវីដ-១៩)*

ក្រសួងបាន៖

- បញ្ជូនមន្ត្រី ៧នាក់ ស្រី ២នាក់ ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការរៀបចំនិងវាយតម្លៃកម្មវិធីសិក្សានៅរ៉ូម៉ានី អ៊ីតាលី និងម៉ាឡេស៊ី
- បញ្ជូនមន្ត្រីបុរស ៤នាក់ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិបណ្តាញធានាគុណភាពអាស៊ាន និងកិច្ចប្រជុំតុមូលវិសាមញ្ញរបស់បណ្តាញធានាគុណភាពអាស៊ានប្រចាំឆ្នាំ២០២០ នៅឥណ្ឌូនេស៊ី និងប្រជុំបច្ចេកទេសស្តីពីសមាហរកម្មនៃឧត្តមសិក្សានិងការទទួលស្គាល់ នៅវៀតណាម
- បញ្ជូនមន្ត្រីបុរស ២នាក់ ចូលរួមកិច្ចប្រជុំស្តីពីកិច្ចប្រជុំពិនិត្យឡើងវិញប្រចាំឆ្នាំលើកទី១៣ នៃចល័តភាពអន្តរជាតិក្នុងតំបន់អាស៊ាន នៅថៃ
- បញ្ជូនមន្ត្រីបុរស ១នាក់ ចូលរួមសន្និសីទវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍អាស៊ាន-ជប៉ុន ស្តីពីគោលនយោបាយវិទ្យាសាស្ត្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់អាស៊ាន នៅវៀតណាម។

*ការលើកកម្ពស់អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា*

ក្រសួងបាន៖

- រៀបចំសិក្ខាសាលាស្តីពី ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផែនការផ្អែកលើលទ្ធផលសម្រាប់អនុវិស័យឧត្តមសិក្សា មានអ្នកចូលរួម ១០០នាក់ ស្រី ២១នាក់
- រៀបចំសិក្ខាសាលាស្តីពី ការរៀបចំទម្រង់សម្រាប់ប្រមូលព័ត៌មានអំពីយុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងកែលម្អការអប់រំឧត្តមសិក្សា មានអ្នកចូលរួម ៣៦នាក់ ស្រី ១២នាក់
- ពិនិត្យតាមដានប្រមូលព័ត៌មាន និងទិន្នន័យស្តីពី ការអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សា នៅតាមគ្រឹះស្ថានឧត្តមសិក្សា៥ និងរៀបចំរបាយការណ៍វឌ្ឍនភាព
- ចេញសេចក្តីសម្រេចស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាល ២គ្រឹះស្ថាន
- បណ្តុះបណ្តាលមន្ត្រីគ្រឹះស្ថានឧត្តមសិក្សា៣ ស្តីពី ការអនុវត្តសេចក្តីណែនាំសម្រាប់វាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំ
- បណ្តុះបណ្តាលស្តីពី របៀបសរសេររបាយការណ៍ស្វ័យវាយតម្លៃនៅសាកលវិទ្យាល័យអង្គរ និងសាកលវិទ្យាល័យជាតិបាត់ដំបង
- ចុះសិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនៃគុណភាពអប់រំក្រោយពេលវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

*ប្រការនេះបញ្ជាក់ថា អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា និងកិច្ចសហប្រតិបត្តិការអន្តរជាតិត្រូវបានពង្រឹង និងពង្រីកជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។*

*ការអភិវឌ្ឍសមត្ថភាពមន្ត្រីឧត្តមសិក្សា*

ក្រសួងបាន៖

- បំប៉នសមត្ថភាពមន្ត្រីក្នុងការរៀបចំផែនការសកម្មភាព និងថវិកាមានអ្នកចូលរួម ៣៦នាក់ ស្រី ៣នាក់
- បញ្ជូនមន្ត្រីបុរស ២នាក់ ចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រង និងវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធី SPSS
- បញ្ជូនមន្ត្រី ១១នាក់ ស្រី ៣នាក់ ចូលរួមសិក្ខាសាលាស្តីពី បច្ចេកទេសគាំទ្រការអនុវត្ត និងពិនិត្យតាមដានគម្រោងស្រាវជ្រាវ
- បណ្តុះបណ្តាលស្តីពី ការសរសេររបាយការណ៍វឌ្ឍនភាព ៦ខែ សម្រាប់អង្គភាពអនុវត្តគម្រោងកែលម្អការអប់រំឧត្តមសិក្សា មានអ្នកចូលរួម ៥០នាក់ ស្រី ១៣នាក់
- បណ្តុះបណ្តាលមន្ត្រីគ្រឹះស្ថានឧត្តមសិក្សា ១៦ ស្តីពី របៀបសរសេររបាយការណ៍ស្វ័យវាយតម្លៃ មានអ្នកចូលរួម ៤៧នាក់ ស្រី ៩នាក់។

*ប្រការនេះបញ្ជាក់ថា បានជួយលើកកម្ពស់សមត្ថភាពលើការងារដឹកនាំ ការងារគ្រប់គ្រង ការងារបច្ចេកទេស ការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធ។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

### ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច

| | សូចនាករ | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ៖ លើកកម្ពស់ការចូលរៀន និងកែលម្អគុណភាពនៃកម្មវិធីបណ្តុះបណ្តាលនៅឧត្តមសិក្សា ឆ្ពោះទៅការទទួលស្គាល់គុណភាពកម្រិតជាតិ និងអន្តរជាតិ | | | | | | |
| ១. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា | % | ១២.០ | ១៤,២ | ១៣,៣ | → |
| | *ប្រុស* | % | ១២.២ | ១៦,៦ | ១៥,៥ | → |
| | *ស្រី* | % | ១១,៨ | ១២,៣ | ១១,៩ | → |
| ២. | ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលផ្នែកស្ទែម | % | ២៨,៣ * | ៣០,០ | ៣០,៤ ** | ↑ |
| | *ប្រុស* | % | ៤០,១ * | ៣៧,៨ | ៤៥,៤ ** | ↑ |
| | *ស្រី* | % | ១៦,៩ * | ២០,៥ | ១៧,៥ ** | → |
| ៣. | មជ្ឈមណ្ឌលឧត្តមភាព | ចំនួន | ១ | ២ | ២ | ↑ |
| ៤. | ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត | % | ៤,១ * | ៤,៤ | ៤,១ ** | → |
| | *ស្រី* | % | ៣,៦ * | ១៦,១ | ៣,៦ ** | → |
| ៥. | គ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា | ចំនួន | ៥ | ៦ | ៥ | → |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| វត្ថុបំណងអនុវិស័យទី២៖ អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងសម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សាឱ្យទទួលបានស្វ័យភាពពេញលេញ | | | | | | |
| ៦. | គ្រឹះស្ថានឧត្តមសិក្សាដែលអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | ចំនួន | ១០ | ១៥ | ១៦ | ↑ |
| ៧. | គ្រឹះស្ថានឧត្តមសិក្សាដែលបានការទទួលស្គាល់គុណភាពអប់រំ | ចំនួន | ១០ | ១៥ | ១០ | → |
| ៨. | គ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យឧត្តមសិក្សា | ចំនួន | ១៣ | ២៤ | ២៤ | ↑ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

* ទិន្នន័យឆ្នាំសិក្សា២០១៨-២០១៩ ** ទិន្នន័យឆ្នាំសិក្សា២០១៩-២០២០

### គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- គ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយចំនួន ពុំទាន់ទទួលបានការវិនិយោគលើការស្រាវជ្រាវ ធនធានសាស្ត្រាចារ្យតាមការកំណត់
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យបែបឌីជីថលលើស្នាដៃស្រាវជ្រាវ និងការបណ្ដុះបណ្ដាលថ្នាក់ក្រោយបរិញ្ញាបត្រពុំទាន់បានយកទៅដំណើរការនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- កង្វះខាតសមត្ថភាពនិងបទពិសោធក្នុងការសរសេរអត្ថបទស្រាវជ្រាវសម្រាប់បោះពុម្ពក្នុងទស្សនាវដ្ដីស្រាវជ្រាវ
- ដំណើរការផ្ដល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សមិនទាន់បានសម្រេចតាមការកំណត់
- ប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សាពុំទាន់ដំណើរការបានល្អប្រសើរ។

## ២.២. ៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

រាជធានី ខេត្តដែលបានអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ២៥ កម្មវិធីក្រោយអក្ខរកម្មមាន ១៧ កម្មវិធីចូលរៀនឡើងវិញមាន ៣ កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន ២២ កម្មវិធីសមមូលបឋមសិក្សាមាន ២៣ កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិមាន ៥ និងកម្មវិធីបំពេញវិជ្ជាមាន ២០ ។

**តារាងទី១៩ ៖ រាជធានី ខេត្តដែលបានអនុវត្តកម្មវិធី**

| កម្មវិធី | រាជធានី ខេត្ត | |
|---|---|---|
| | ២០១៨-២០១៩ | ២០១៩-២០២០ |
| អក្ខរកម្មវិជ្ជាជីវៈ | ២៥ | ២៥ |
| ក្រោយអក្ខរកម្ម | ១៧ | ១៧ |
| ចូលរៀនឡើងវិញ | ២២ | ៣ |
| បង្កើនប្រាក់ចំណូល | ២៥ | ២២ |
| សមមូលបឋមសិក្សា | ២៤ | ២៣ |
| សមមូលមធ្យមសិក្សាបឋមភូមិ | ៨ | ៥ |
| បំពេញវិជ្ជា | ២១ | ២០ |

*កម្មវិធីអប់រំក្រៅប្រព័ន្ធនៅតាមរាជធានី ខេត្តមួយចំនួនបានថយចុះ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។*

### *កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ*

តាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បង្ហាញថា អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង មាន ៨៧,៨ភាគរយ សម្រាប់ជនពេញវ័យទាំងពីរភេទ ដែលក្នុងនោះអត្រាអក្ខរកម្មសម្រាប់ស្ត្រីមាន ៨៤,៨ភាគរយ និងបុរស ៩០,៩ភាគរយ នៅឆ្នាំ២០១៧ សម្រាប់ជនពេញវ័យទាំងពីរភេទ មាន ៨២,៥ភាគរយ ស្រី ៧៨,១ភាគរយ។ អត្រាអក្ខរជនជាស្ត្រីមានការកើនឡើង ដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលលើការលើកកម្ពស់យេនឌ័រក្នុងវិស័យអប់រំ។ ដោយឡែក ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បង្ហាញថា អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើងសម្រាប់ជនពេញវ័យទាំងពីរភេទ មាន ៨៧,៧ភាគរយ ។

ទិវាអក្ខរកម្មជាតិ ៨ កញ្ញា ជាកម្លាំងចលករជួយជំរុញឱ្យកម្មវិធីនេះ កាន់តែមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយអត្រាអនក្ខរភាពគួរឱ្យកត់សម្គាល់។ ជាក់ស្តែងក្រសួងបានផ្សព្វផ្សាយទិវាអក្ខរកម្មជាតិ ៨ កញ្ញា ឆ្នាំ២០២០ ក្រោមប្រធានបទ «អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត» ។

**រូបភាពទី៤០៖ អត្រាអក្ខរកម្មជនពេញវ័យអាយុ១៥ឆ្នាំឡើង**




*ប្រភព៖ របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ (វិទ្យាស្ថានជាតិស្ថិតិ, ធ្នូ ២០២០)*

ថ្នាក់អក្ខរកម្មមាន ៨៩៤ថ្នាក់ គ្របដណ្តប់ ៨៣០ភូមិ ៥៥១ឃុំ សង្កាត់ ១៨៦ក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស។ ក្រសួងគ្រប់គ្រងថ្នាក់អក្ខរកម្ម ៨៧៨ ថយ ១១ ស្មើ ១,២៥ភាគរយ និងដៃគូអភិវឌ្ឍគ្រប់គ្រងថ្នាក់អក្ខរកម្ម ១៦ ថយ ៣៦ ស្មើ ៦៩,២៣ភាគរយ។ ក្រសួងសហការជាមួយអង្គការយូណេស្កូ អង្គការស៊ីប៉ា អង្គការអាយឡូ និងរោងចក្រ បាន អនុវត្តកម្មវិធីអក្ខរកម្មនៅតាមរោងចក្រមាន ១៣ថ្នាក់ ដោយដំណើរការនៅរាជធានី ខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង ស្វាយរៀង និងកំពង់ស្ពឺ។ សហការជាមួយក្រសួងមហាផ្ទៃ បានអនុវត្តកម្មវិធីអក្ខរកម្មនៅតាមពន្ធនាគារមាន ៣៣ ថ្នាក់ ក្នុង ១៨ខេត្ត រាជធានី រួមមានខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កណ្តាល កោះកុង ក្រចេះ ពោធិ៍សាត់ រតនគិរី សៀមរាប ព្រះសីហនុ ស្វាយរៀង តាកែវ ឧត្តរមានជ័យ ត្បូងឃ្មុំ និងរាជធានី និង នៅមណ្ឌលកែប្រែមាន ៧ថ្នាក់ នៅរាជធានី និងខេត្តត្បូងឃ្មុំ។

គ្រូអក្ខរកម្មមាន ៨៩៤នាក់ ស្រី ៣៩,៧១ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៨៧៨នាក់ ស្រី ៣៩,៥២ ភាគរយ និងគ្រប់គ្រងដោយដៃគូអភិវឌ្ឍ ១៦នាក់ ស្រី ៥០ភាគរយ។ គ្រូអក្ខរកម្មបានបំប៉ន ៨១៩នាក់ ស្រី ៣៨,៤៦ ភាគរយ ក្នុងនោះបំប៉នដោយក្រសួង ៨០៣នាក់ ស្រី ៣៦,៩៩ភាគរយ រួមទាំងគ្រូអក្ខរកម្មសម្រាប់កម្មករ កម្មការិនី តាមរោងចក្របានបំប៉ន ២៤នាក់ ស្រី ៦៦,៦៧ភាគរយ ពន្ធនាគារបានបំប៉ន ៣២នាក់ ស្រី ១៥,៦៣ភាគរយ និង មណ្ឌលកែប្រែបានបំប៉ន ៧នាក់ ស្រី ១៤,២៩ភាគរយ។ គ្រូអក្ខរកម្មបំប៉នដោយដៃគូអភិវឌ្ឍ ១៦នាក់ ស្រី ៥០ភាគរយ។

អ្នកសិក្សាមាន ១៧ ៦៩៧នាក់ ស្រី ៦៤,៩៨ភាគរយ ក្នុងនោះអ្នកសិក្សានៅតាមរោងចក្រមាន ២៧៧នាក់ ស្រី ១០០ភាគរយ នៅពន្ធនាគារ ៦៧៧នាក់ ស្រី ៧,៥៣ភាគរយ នៅមណ្ឌលកែប្រែ ១៦០នាក់ ស្រី ១៣,១២ភាគរយ ។ អ្នក សិក្សាបានបញ្ចប់វគ្គ ១៥ ៣០៩នាក់ ស្រី ៦៦,០៦ភាគរយ ក្នុងនោះបានឆ្លងកាត់តេស្តស្តង់ដាបញ្ចប់ជាប់ ១៤ ២១០ នាក់ ស្មើ ៩២,៨២ភាគរយ ស្រី ៦៦,១៦ភាគរយ ដោយបំណិនផ្នែកអក្សរ ១២ ១៩៤នាក់ ស្មើ ៧៩,៦៥ភាគរយ ស្រី ៦៦,៣៥ភាគរយ និងបំណិនផ្នែកលេខ ១០ ៨៨៩នាក់ ស្មើ ៧១,១៣ភាគរយ ស្រី ៦៦,៣៩ភាគរយ។

អនក្ខរជនអាយុ ១៥ឆ្នាំឡើងមាន ៥៦៨ ៧៧៥នាក់ ស្រី ៥១,៧៨ភាគរយ (ស្ថិតិពីមន្ទីរ អយក រាជធានី ខេត្តឆ្នាំ ២០២០) ក្នុងឆ្នាំនេះ កម្មវិធីអក្ខរកម្មបានរំដោះអនក្ខរជន ១៤ ២១០នាក់ ស្មើ ២,៥ភាគរយ ស្រី ៦៦,១៦ភាគរយ។

*ចំនួននេះទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតពីគ្រប់ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការរំដោះអនក្ខរជន ពីគ្រោះមិនចេះអក្សរ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។*

**តារាងទី២០ ៖ ចំនួនថ្នាក់ គ្រូ និងអ្នកសិក្សាកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ**

| បរិយាយ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់អក្ខរកម្ម | អយក | ៨៨៩ | | ៨៧៨ | | -១១ | |
| | ដៃគូ | ៥២ | | ១៦ | | -៣៦ | |
| | *សរុប* | ៩៤១ | | ៨៩៤ | | -៤៧ | |
| គ្រូអក្ខរកម្ម | អយក | ៨៨៩ | ៣៥២ | ៨៧៨ | ៣៤៧ | -១១ | -៥ |
| | ដៃគូ | ៦៩ | ៣១ | ១៦ | ៨ | -៥៣ | -២៣ |
| | *សរុប* | ៩៥៨ | ៣៨៣ | ៨៩៤ | ៣៥៥ | -៦៤ | -២៨ |
| អ្នកសិក្សា | អយក | ១៧ ៩២២ | ១១ ៧៦៨ | ១៧ ២៨៥ | ១១ ១៩៣ | -៦៣៧ | -៥៧៥ |
| | ដៃគូ | ១ ១៧៩ | ៧២៨ | ៤០៩ | ៣០៥ | -៧៧០ | -៤២៣ |
| | *សរុប* | ១៩ ១០១ | ១២ ៤៩៦ | ១៧ ៦៩៤ | ១១ ៤៩៨ | -១ ៤០៧ | -៩៩៨ |

រូបភាពទី៤១៖ លទ្ធផលអ្នកសិក្សាបញ្ចប់កម្មវិធីអក្ខរកម្ម




រូបភាពទី៤២៖ លទ្ធផលអ្នកសិក្សាកម្មវិធីអក្ខរកម្មឆ្នាំ២០២០




*លទ្ធផលនេះបង្ហាញថា កម្រិតសមត្ថភាពនៃអ្នកបញ្ចប់ការសិក្សាដោយជោគជ័យលើកម្មវិធីអក្ខរកម្មផ្នែកបំណិនអក្សរខ្ពស់ជាងបំណិនលេខ។ ប្រការដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត អំពីវិធីសាស្ត្រ និងសម្ភារៈសម្រាប់ការបង្រៀនបំណិនលេខ។*

រូបភាពទី៤៣៖ លទ្ធផលអ្នកសិក្សាបញ្ចប់កម្មវិធីអក្ខរកម្មឆ្នាំ២០២០ តាមក្រុមអាយុ




*អនក្ខរជនពេញវ័យអាយុ ១៥ឆ្នាំឡើងមានការថយចុះ ប្រការនេះបញ្ជាក់ឱ្យឃើញថា កម្មវិធីអក្ខរកម្មរៀងជីវិតបានពង្រីកវិសាលភាព និងមានការទាក់ទាញ ដោយសារពីមួយឆ្នាំទៅមួយឆ្នាំ អាចរំដោះបានអក្ខរជនថ្មីប្រមាណជា ២,៥ភាគរយ ដោយផ្តល់ឱកាសឱ្យអ្នកទាំងនោះអាចបន្តការសិក្សាតាមកម្មវិធី និងជំនាញផ្សេងៗ។*

*កម្មវិធីក្រោយអក្ខរកម្ម*

កម្មវិធីនេះបានជួយបង្កើនចំណេះដឹង និងទប់ស្កាត់ការភ្លេចអក្សរដល់អក្ខរជនថ្មី និងប្រជាសហគមន៍។ ក្រសួង និងដៃគូអភិវឌ្ឍមានបណ្ណាល័យ ៣៩ ដំណើរការ ៣៤ ស្មើ ៨៧,១៨ភាគរយ។ បណ្ណាល័យគ្រប់គ្រងដោយក្រសួងមាន ២៥ ដំណើរការ ២០ ស្មើ ៨០ភាគរយ និងដៃគូអភិវឌ្ឍមាន ១៤ ដំណើរការ ១០០ភាគរយ។

អ្នកចូលអាន ១៨ ៣០៩នាក់ ថយ ១៣ ៧០៦នាក់ ស្មើ ៤២,៨១ភាគរយ ស្រី ៥៧,៣០ភាគរយ ថយ ៧ ៩៦៦នាក់ ស្មើ ៤៣,១៦ភាគរយ។ អ្នកចូលអាននៅបណ្ណាល័យគាំទ្រដោយក្រសួង ១៣ ១២៩នាក់ ថយ ៦ ៨១៥នាក់ ស្មើ ៣៤,១៧ ភាគរយ ស្រី ៥៦,៦៤ភាគរយ ថយ ៣ ៧៩៦នាក់ ស្មើ ៣៣,៨០ភាគរយ និងអ្នកចូលអាននៅបណ្ណាល័យគាំទ្រដោយ ដៃគូអភិវឌ្ឍ ៥ ១៨០នាក់ ថយ ៦ ៨៩១ នាក់ ស្មើ ៥៧,០៩ភាគរយ ស្រី ៥៨,៩៨ភាគរយ ថយ ៤ ១៧០នាក់ ស្មើ ៥៧,៧២ភាគរយ ធៀបនឹងឆ្នាំ២០១៩។

**តារាងទី២១ ៖ ស្ថិតិបណ្ណាល័យនិងអ្នកចូលអាន**

| បរិយាយ | | | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| បណ្ណាល័យ | អយក | សរុប | ២៥ | | ២៥ | | ០ | |
| | | ដំណើរការ | ២៥ | | ២០ | | -៥ | |
| | ដៃគូ | សរុប | ១៦ | | ១៤ | | -២ | |
| | | ដំណើរការ | ១៤ | | ១៤ | | ០ | |
| | *សរុប* | *សរុប* | *៤១* | | *៣៩* | | -២ | |
| | | *ដំណើរការ* | *៣៩* | | *៣៤* | | -៥ | |
| អ្នកចូលអាន | អយក | | ១៩ ៩៤៤ | ១១ ២៣២ | ១៣ ១២៩ | ៧ ៤៣៦ | -៦ ២៤១ | -៣ ៤១១ |
| | ដៃគូ | | ១២ ០៧១ | ៧ ២២៥ | ៥ ១៨០ | ៣ ០៥៥ | -៦ ៨៩១ | -៤ ១៧០ |
| | *សរុប* | | *៣២ ០១៥* | *១៨ ៤៥៧* | *១៨ ៣០៩* | *១០ ៤៩១* | *-១៣ ១៣២* | *-៧ ៥៨១* |

**រូបភាពទី៤៤៖ លទ្ធផលអ្នកចូលអានក្នុងបណ្ណាល័យ**




*ប្រការនេះបង្ហាញថា អ្នកចូលអាននៅក្នុងបណ្ណាល័យមានការថយចុះ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ជំនួសមកវិញ អ្នកចូលអានផ្ទាល់ក្នុងបណ្ណាល័យ អាចអាន និងសិក្សាស្រាវជ្រាវតាមប្រព័ន្ធអេឡិចត្រូនិកវិញ។*

ទន្ទឹមនឹងនេះកម្មវិធីកែលម្អគុណភាពរស់នៅ ក៏បានចូលរួមចំណែកបង្កើនចំណេះដឹង និងទប់ស្កាត់គ្រោះភ្លេចអក្សរដល់ប្រជាសហគមន៍ ដែលក្នុងនោះមានការផ្សព្វផ្សាយអត្ថបទតាមវិទ្យុជាតិកម្ពុជាបាន ៩ ថយ ៣៨ ស្មើ ៨០,៨៥ ភាគរយ។ ការផ្សព្វផ្សាយវីដេអូបាន ៣ កើន ១ ស្មើ ៥០ភាគរយ ដូចជាវីដេអូស្តីពីអក្ខរកម្មជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត វីដេអូស្តីពីបរិយាបន្ននិងការអប់រំ និងវីដេអូស្តីពីរួមគ្នាលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍យើង

ដែលមានអ្នកទស្សនាសរុប ៥២ ៨២៥នាក់ កើន ២០ ២៦៩នាក់ ស្មើ ៦០,៦៦ភាគរយ អ្នកពេញចិត្ត ៣១១១នាក់ និងអ្នកចែករំលែក ៣៩៦នាក់។

### *កម្មវិធីចូលរៀនឡើងវិញ*

កម្មវិធីនេះ ផ្ដល់ឱកាសឱ្យសិស្សបោះបង់ការសិក្សានៅថ្នាក់ទី៣ ដល់ទី៦ បានបន្តការសិក្សាឡើងវិញនៅតាមសាលាចំណេះទូទៅអប់រំក្នុងប្រព័ន្ធ។ ស្ថិតិ និងសូចនាករអប់រំឆ្នាំសិក្សា ២០១៩-២០២០ បង្ហាញថា អត្រាបោះបង់ការសិក្សាកម្រិតបឋមសិក្សាពីថ្នាក់ទី៣ ដល់ទី៦ មាន ៨,៩៨ភាគរយ ស្រី ៧,៧ភាគរយ នៃសិស្សប្រមាណជា ១១៤ ៨៧៤ នាក់ ស្រី ៤៧ ៩០៩នាក់ និងអត្រាបោះបង់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ១៨,៦ភាគរយ ស្រី ១៧,៤ភាគរយ នៃសិស្សប្រមាណ ១១៥ ១២៨នាក់ ស្រី ៥៦ ៦៣៨នាក់។

ថ្នាក់ចូលរៀនឡើងវិញមាន ៩១ ថយ ៥៣៩ ស្មើ ៨៥,៥៦ភាគរយ ក្នុងនោះគាំទ្រដោយក្រសួងទាំងអស់ ដោយឡែកដៃគូអភិវឌ្ឍមិនបានអនុវត្តទេ។ គ្រូកម្មវិធីចូលរៀនឡើងវិញ ៩១នាក់ ថយ ៥៧០នាក់ ស្មើ ៨៦,២៣ភាគរយ ស្រី ២៧,៤៧ភាគរយ ថយ ៨៤,៤៧ភាគរយ ។

សិស្សចូលរៀនមាន ១ ៧៤២នាក់ ថយ ១០ ០៦៩នាក់ ស្មើ ៨៥,២៥ភាគរយ ស្រី ៤២,៧១ភាគរយ ថយ ៤៥០៩នាក់ ស្មើ ៨៥,៨៤ភាគរយ ។ សិស្សបានបញ្ចប់មាន ១ ៧០៤នាក់ ថយ ៩ ៣១៦នាក់ ស្មើ ៨៤,៥៤ភាគរយ ស្រី ៤៣,០៨ភាគរយ ថយ ៤ ២៦២នាក់ ស្មើ ៨៥,៣១ភាគរយ។ សិស្សបញ្ជូនមាន ១ ៦២៤នាក់ ថយ ៨ ៩៧៣នាក់ ស្មើ ៨៤,៦៧ភាគរយ ស្រី ៤៣,១០ភាគរយ ថយ ៤ ០៦៥នាក់ ស្មើ ៨៥,៣១ភាគរយ។ សិស្សបញ្ជូនចូលរៀនតាមសាលាក្នុងប្រព័ន្ធវិញ ១,៤១ភាគរយនៃសិស្សបោះបង់ការសិក្សាឆ្នាំសិក្សា២០១៩-២០២០។

**តារាងទី២២ ៖ ស្ថិតិថ្នាក់ គ្រូ និងសិស្សកម្មវិធីចូលរៀនឡើងវិញ**

| បរិយាយ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិស្សបោះបង់ | បឋមសិក្សា | ៨៩ ៧៧១ | ៣៦ ២១៧ | ១១៤ ៨៧៤ | ៤៧ ៩០៩ | | |
| | មធ្យមសិក្សា | ៥១ ៧៣២ | ២៤ ៤៣៨ | ១១៥ ១២៨ | ៥៦ ៦៣៨ | | |
| ថ្នាក់ | អយក | ៦៣០ | | ៩១ | | -៥៣៩ | |
| | ដៃគូ | *៣១* | | ០ | | -៣១ | |
| | ***សរុប*** | ***៦៦១*** | | ***៩១*** | | -៥៧០ | |
| គ្រូ | អយក | ៦៣០ | ១៥៣ | ៩១ | ២៥ | -៥៣៩ | -១២៨ |
| | ដៃគូ | ៣១ | ៨ | ០ | ០ | -៣១ | -៨ |
| | ***សរុប*** | ***៦៦១*** | ***១៦១*** | ***៩១*** | ***២៥*** | -៥៧០ | -១៣៦ |
| សិស្ស | អយក | ១១ ៣០០ | ៥ ០១៨ | ១ ៧៤២ | ៧៤៤ | -៩ ៥៥៨ | -៤ ២៧៤ |
| | ដៃគូ | ៥១១ | ២៣៥ | ០ | ០ | -៥១១ | -២៣៥ |
| | ***សរុប*** | ***១១ ៨១១*** | ***៥ ២៥៣*** | ***១ ៧៤២*** | ***៧៤៤*** | -១០ ០៦៩ | -៤ ៥០៩ |

**រូបភាពទី៤៥៖ លទ្ធផលសិស្សបញ្ជូននៃកម្មវិធីចូលរៀនឡើងវិញ**



*ប្រការនេះបង្ហាញថា ចំនួនសិស្សចូលរៀនឡើងវិញមានការថយចុះ ដោយអនុវត្តបានតែ ៣ខេត្តប៉ុណ្ណោះ ដោយសារសាលាត្រូវផ្អាកដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ពីព្រោះកម្មវិធីនេះអនុវត្តនៅក្នុងសាលាបឋមសិក្សា ពេលវិស្សមកាលធំ។*

***កម្មវិធីបង្កើនប្រាក់ចំណូល***

មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានចាត់ទុកជាសាលារៀនផ្នែកអប់រំក្រៅប្រព័ន្ធ។ មជ្ឈមណ្ឌលសិក្សាសហគមន៍មាន ៣៤៩ ថយ ២ ស្មើ ០,៥៧ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៣៣០ ដំណើរការ ៣០៣ ស្មើ ៩១,៨២ភាគរយ និងដៃគូអភិវឌ្ឍ ១៩ ដំណើរការ ១៨ ស្មើ ៩៤,៧៤ភាគរយ។ ឆ្នាំ២០២០នេះ មានតែមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ កោះកុង និងរាជធានីប៉ុណ្ណោះ ដែលបានផ្តល់ថវិកាដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍ស្របតាមប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធី។

ថ្នាក់ជំនាញមុខរបរមាន ៥៨៤ ថយ ២៥ ស្មើ ៤,១១ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៥៧៤ ថយ ៩ ស្មើ ១,៥៤ភាគរយ និងដៃគូអភិវឌ្ឍ ១០ ថយ ១៦ ស្មើ ៦១,៥៤ភាគរយ។

គ្រូជំនាញមុខរបរមាន ៥៨៤នាក់ កើន ២០ ស្មើ ៣,៥៥ភាគរយ ស្រី ៥៣,៧៧ភាគរយ កើន ៤នាក់ ស្មើ ៤,២៩ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៥៧៤នាក់ កើន ៣៦ ស្មើ ៦,៦៩ភាគរយ ស្រី៥៣,៨៣ភាគរយ កើន ១៤ ស្មើ ៤,៧៥ភាគរយ និងដៃគូអភិវឌ្ឍ ១០ ថយ ១៦ ស្មើ ៦១,៥៤ភាគរយ ស្រី ៥០ភាគរយ ថយ ១០ ស្មើ ៦៦,៦៧ ភាគរយ។

អ្នកសិក្សាមាន ៨ ៦២២នាក់ ថយ ៧៥៥នាក់ ស្មើ ៨,០៥ភាគរយ ស្រី ៦៥,៩៦ភាគរយ ថយ ៣៧៧នាក់ ស្មើ ៦,២២ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៨ ២១២នាក់ ថយ ៤២៦នាក់ ស្មើ ៤,៩៣ភាគរយ ស្រី ៦៥,៨៩ភាគរយ ថយ ២៧៤នាក់ ស្មើ ៤,៨២ភាគរយ និងដៃគូអភិវឌ្ឍ ៤១០នាក់ ថយ ៣២៩នាក់ ស្មើ ៤៤,៥២ភាគរយ ស្រី ៦៧,៣២ ភាគរយ ថយ ១០៣នាក់ ស្មើ ២៧,១៨ភាគរយ ។

គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍មាន ១ ២៩៤នាក់ ថយ ៤០០នាក់ ស្មើ ២៣,៦១ភាគរយ ស្រី ២៨,៥២ ភាគរយ ថយ ១៤នាក់ ស្មើ ៤,៧៥ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ១ ១៥០នាក់ ថយ ៤០១នាក់ ស្មើ ២៥,៨៥ភាគរយ ស្រី ២៦,៥២ភាគរយ ថយ ៣២នាក់ ស្មើ ៩,៥០ភាគរយ និងដៃគូអភិវឌ្ឍ ១៤៤នាក់ កើន ១នាក់ ស្មើ ០,៧០ភាគរយ ស្រី ៤៤,៤៤ភាគរយ ថយ ៤នាក់ ស្មើ ៥,៨៨ភាគរយ។

ដោយឡែកនៅឆ្នាំ២០២០ ក្រសួងបានដំណើរការកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន(BEEP)នៅមជ្ឈមណ្ឌលសិក្សាសហគមន៍សង្កាត់វត្តគរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង និងមជ្ឈមណ្ឌលសិក្សាសហគមន៍ជំរិល ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ មានអ្នកសិក្សាសរុប ៣៥នាក់ ស្រី ៤២,៨៦ភាគរយ។

**តារាងទី២៣ ៖ ស្ថិតិមជ្ឈមណ្ឌលសិក្សាសហគមន៍ ថ្នាក់ គ្រូជំនាញ និងអ្នកសិក្សាជំនាញមុខរបរ**

| បរិយាយ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ម.ស.ស | អយក | ៣៣០ | | ៣៣០ | | ០ | |
| | ដៃគូ | ២១ | | ១៩ | | -២ | |
| | *សរុប* | *៣៥១* | | *៣៤៩* | | -២ | |
| ថ្នាក់ជំនាញ មុខរបរ | អយក | ៥៨៣ | | ៥៧៤ | | -៩ | |
| | ដៃគូ | ២៦ | | ១០ | | -១៦ | |
| | *សរុប* | *៦០៩* | | *៥៨៤* | | -២៥ | |
| គណៈ | អយក | ១ ៥៥១ | ៣៣៧ | ១ ១៥០ | ៣០៥ | -៤០១ | -៣២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រប់គ្រងមសស | ដៃគូ | ១៤៣ | ៦៨ | ១៤៤ | ៦៤ | ១ | -៤ |
| | *សរុប* | *១ ៦៩៤* | *៤០៥* | *១ ២៩៤* | *៣៦៩* | -៤០០ | -៣៦ |
| គ្រូជំនាញមុខរបរ | អយក | ៥៣៨ | ២៩៥ | ៥៧៤ | ៣០៩ | ៣៦ | ១៤ |
| | ដៃគូ | ២៦ | ១៥ | ១០ | ៥ | -១៦ | -១០ |
| | *សរុប* | *៥៦៤* | *៣១០* | *៥៨៤* | *៣១៤* | ២០ | ៤ |
| អ្នកសិក្សាជំនាញមុខរបរ | អយក | ៨ ៦៣៨ | ៥ ៦៨៥ | ៨ ២១២ | ៥ ៤១១ | -៤២៦ | -២៧៤ |
| | ដៃគូ | ៧៣៩ | ៣៧៩ | ៤១០ | ២៧៦ | -៣២៩ | -១០៣ |
| | *សរុប* | *៩ ៣៧៧* | *៦ ០៦៤* | *៨ ៦២២* | *៥ ៦៨៧* | -៧៥៥ | -៣៧៧ |

**រូបភាពទី៤៦៖ លទ្ធផលអ្នកសិក្សាជំនាញមុខរបរបានបញ្ចប់កម្មវិធីបង្កើនប្រាក់ចំណូល**




អ្នកសិក្សាជំនាញមុខរបរបានបញ្ចប់ ៧ ០៩០នាក់ ថយ ១ ១៨៨នាក់ ស្មើ ១៤,៣៥ភាគរយ ស្រី ៦៥,៥០ភាគរយ ថយ ៧៤៩នាក់ ស្មើ ១៣,៨៩ភាគរយ និងបានប្រឡងជាប់ ៦ ៤៧៨នាក់ ស្មើ ៩១,៣៧ ភាគរយ ស្រី ៤ ២៣៦នាក់ ធៀបនឹងអ្នកសិក្សាបញ្ចប់។

ឆ្នាំ២០២០ ជំនាញមុខរបរមាន ៤០ ថ្នាក់ជំនាញមុខរបរមាន ៥៨៤ ថ្នាក់ជំនាញកាត់ដេរមាន ១៧១។ ថ្នាក់កាត់ដេរមានអ្នកសិក្សា ២ ៤៧០នាក់ ស្មើ ២៨,៦៥ភាគរយ ស្រី ២ ២៥៩នាក់ ស្មើ ៩១,៤៦ភាគរយ។ អ្នកសិក្សាប្រឡងជាប់ ៦ ៤៧៨នាក់ ស្មើ ៩១,៣៧ភាគរយ ស្រី ៤ ២៣៦នាក់ ស្មើ ៦៥,៣៩ភាគរយ ក្នុងនោះអ្នកសិក្សាជំនាញកាត់ដេរមាន ១៦៧១នាក់ ស្មើ ២៥,៧៩ភាគរយ ស្រី ១ ៥៤៤នាក់ ស្មើ ៦៨,៣៥ភាគរយ។

**តារាងទី២៤ ៖ ស្ថិតិអ្នកសិក្សាជំនាញមុខរបរ ឆ្នាំ២០២០**

| ល.រ | ជំនាញមុខរបរ | ថ្នាក់ | ចូលរៀន | | ប្រឡងជាប់ | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| ១ | កាត់ដេរ | ១៧១ | ២ ៤៧០ | ២ ២៥៩ | ១ ៦៧១ | ១ ៥៤៤ |
| ២ | កុំព្យូទ័រ | ៨៤ | ១ ៣៦០ | ៧៧៤ | ៩៧៧ | ៥៧០ |
| ៣ | កែសម្ផស្ស | ៤១ | ៥៨៥ | ៥៥៥ | ៤០៨ | ៣៨៩ |
| ៤ | សំអាងកាយ | ៤០ | ៥០៨ | ៥០៣ | ៤០៣ | ៤០១ |
| ៥ | ភ្លេងប្រពៃណី | ៣០ | ៣៥២ | ៩០ | ២៤៤ | ៦១ |
| ៦ | ភ្លេងពិណពាទ្យ | ២៩ | ២៩២ | ៧៩ | ២២៨ | ៦៣ |
| ៧ | ភាសាបរទេស | ២៧ | ៥៩៦ | ៣០៥ | ៤៥៨ | ២៣៧ |
| ៨ | កាត់សក់ | ១៩ | ២៤០ | ៣៤ | ១៩២ | ២៧ |
| ៩ | សំអាងការ | ១៨ | ២៣២ | ២៣២ | ២០៦ | ២០៦ |
| ១០ | កសិកម្មចំរុះ | ១៦ | ២២២ | ១២២ | ១៦៥ | ៨៤ |
| ១១ | ជួសជុលម៉ាស៊ីន | ១៦ | ១៧៦ | ៨ | ១៦១ | ៨ |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | ផ្សារដែក | ១៤ | ១៨៧ | ៧ | ១៣៥ | ០ |
| ១៣ | ចិញ្ចឹមមាន់ ទា | ១២ | ១៧៦ | ៧៩ | ១៥៩ | ៧៧ |
| ១៤ | ដាំដំណាំ | ៥ | ៧៨ | ៤០ | ៦១ | ៣០ |
| ១៥ | របាំជូនពរ | ៥ | ៩៤ | ៧៣ | ៩៣ | ៧២ |
| ១៦ | ជួសជុលម៉ាស៊ីនខ្នាតតូច | ៤ | ៦១ | ០ | ៤០ | ០ |
| ១៧ | ជួសជុលម៉ូតូ | ៤ | ៤១ | ១៦ | ៣៧ | ១៦ |
| ១៨ | ដាំបន្លែ | ៤ | ៦០ | ៤១ | ៥៥ | ៣៩ |
| ១៩ | តន្ត្រីសម័យ | ៤ | ៧៤ | ៤១ | ៦០ | ៣៥ |
| ២០ | ធនាគារស្រូវ | ៤ | ២៤០ | ១៦០ | ២៤០ | ១៦០ |
| ២១ | ចិញ្ចឹមជ្រូក | ៣ | ៣៧ | ២៧ | ២៤ | ២១ |
| ២២ | ជួសជុលវិទ្យុ ទូរទស្សន៍ | ៣ | ៤៣ | ០ | ៣៧ | ០ |
| ២៣ | តម្បាញ | ៣ | ៣៥ | ៣២ | ១០ | ១០ |
| ២៤ | បណ្តុះផ្សិត | ៣ | ៣៤ | ២២ | ៣១ | ២២ |
| ២៥ | បោះពុម្ពឥដ្ឋ ចាក់លូ | ៣ | ៤៥ | ០ | ៤០ | ០ |
| ២៦ | សំណង់ | ៣ | ៤២ | ៣ | ៤០ | ៣ |
| ២៧ | ចិញ្ចឹមចង្រិត | ២ | ២២ | ១៣ | ២១ | ១២ |
| ២៨ | ច្នៃម៉ូតផ្កា | ២ | ៣៥ | ៣៥ | ១៦ | ១៦ |
| ២៩ | ធនាគារគោ | ២ | ១០ | ៦ | ១០ | ៦ |
| ៣០ | សិប្បកម្មផ្តៅ | ២ | ៥៣ | ៣៣ | ៤៨ | ៣០ |
| ៣១ | ឥណទានខ្នាតតូច | ២ | ១១០ | ៨០ | ១១០ | ៨០ |
| ៣២ | ចម្លាក់ | ១ | ១៥ | ០ | ១៥ | ០ |
| ៣៣ | ចាក់លូ | ១ | ១១ | ០ | ១១ | ០ |
| ៣៤ | ចិញ្ចឹមគោ | ១ | ១២ | ០ | ១០ | ០ |
| ៣៥ | ច្នៃត្រឡោកដូង | ១ | ១០ | ០ | ១០ | ០ |
| ៣៦ | ជាងឈើ | ១ | ១០ | ០ | ៨ | ០ |
| ៣៧ | ជួសជុលទូរស័ព្ទ | ១ | ១៩ | ៧ | ១៩ | ៧ |
| ៣៨ | សិប្បកម្មធ្វើលបត្រី | ១ | ១០ | ១ | ០ | ០ |
| ៣៩ | ស្នូត | ១ | ១០ | ១០ | ១០ | ១០ |
| ៤០ | អគ្គិសនី | ១ | ១៥ | ០ | ១៥ | ០ |
| សរុប | | ៥៨៤ | ៨ ៦២២ | ៥ ៦៨៧ | ៦ ៤៧៨ | ៤ ២៣៦ |

អ្នកសិក្សាជំនាញមុខរបរបានបង្កើតមុខរបរផ្ទាល់ខ្លួនមាន ២ ១៨១នាក់ ស្មើ ៣០,៧៦ភាគរយ ស្រី ១ ៣២៧នាក់ លើ ៣៧ ប្រភេទជំនាញ ធៀបអ្នកសិក្សាបានបញ្ចប់កម្មវិធី ក្នុងនោះមុខរបរកាត់ដេរមាន ៥៥៣នាក់ ស្រី ៥១៨នាក់។ កម្មវិធីបង្កើនប្រាក់ចំណូល ជាពិសេសជំនាញកាត់ដេរនៅតែមានភាពទាក់ទាញជាងគេ។

### តារាងទី២៥៖ អ្នករៀនជំនាញបានបង្កើតមុខរបរផ្ទាល់ខ្លួន

| ល.រ | ជំនាញមុខរបរ | អ្នកបង្កើតមុខរបរផ្ទាល់ខ្លួន | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | កាត់ដេរ | ៥៥៣ | ៥១៨ |
| ២ | កុំព្យូទ័រ | ៣៤១ | ១៨៦ |
| ៣ | ភ្លេងប្រពៃណី | ១៧៨ | ៦៤ |

| | | | |
|---|---|---|---|
| ៤ | ភ្លេងពិណពាទ្យ | ១៣១ | ៣១ |
| ៥ | ចិញ្ចឹមមាន់ ទា | ១៣០ | ៤៦ |
| ៦ | កែសម្ផស្ស | ១២៦ | ១១៦ |
| ៧ | សម្អាងកាយ | ៩៥ | ៩១ |
| ៨ | កាត់សក់ | ៦២ | ១២ |
| ៩ | ភាសាបរទេស | ៥៨ | ៣៨ |
| ១០ | របាំជូនពរ | ៥២ | ៣៦ |
| ១១ | ដាំដំណាំ | ៥១ | ២២ |
| ១២ | ដាំបន្លែ | ៤២ | ៣៤ |
| ១៣ | កសិកម្មចម្រុះ | ៣៧ | ១៨ |
| ១៤ | តម្បាញ | ២៩ | ២១ |
| ១៥ | ជួសជុលម៉ាស៊ីនខ្នាតតូច | ២៦ | ០ |
| ១៦ | ចម្លាក់ | ២៤ | ០ |
| ១៧ | ចិញ្ចឹមជ្រូក | ២០ | ១៧ |
| ១៨ | ចិញ្ចឹមចង្រិត | ២០ | ១០ |
| ១៩ | ជួសជុលម៉ាស៊ីន | ១៩ | ០ |
| ២០ | ចិញ្ចឹមត្រី បង្កង | ១៨ | ៧ |
| ២១ | ផ្សារដែក | ១៨ | ៤ |
| ២២ | សិប្បកម្មកំប្លោក | ១៦ | ១៦ |
| ២៣ | ជាងឈើ | ១៤ | ០ |
| ២៤ | ជួសជុលម៉ូតូ | ១៤ | ៤ |
| ២៥ | សំណង់ | ១៤ | ០ |
| ២៦ | តន្ត្រីសម័យ | ១៣ | ៧ |
| ២៧ | ចិញ្ចឹមគោ | ១២ | ០ |
| ២៨ | បណ្តុះផ្សិត | ១២ | ១១ |
| ២៩ | សម្អាងការ | ១១ | ១០ |
| ៣០ | ក្រឡឹងឈើ | ១០ | ២ |
| ៣១ | ច្នៃត្រឡោកដូង | ១០ | ០ |
| ៣២ | អគ្គិសនី | ៨ | ០ |
| ៣៣ | បសុពេទ្យ | ៦ | ០ |
| ៣៤ | កែច្នៃម្ហូបអាហារ | ៥ | ៤ |
| ៣៥ | ជួសជុលវិទ្យុ ទូរទស្សន៍ | ៣ | ០ |
| ៣៦ | ស្មូត | ២ | ២ |
| ៣៧ | ចាក់លូ | ១ | ០ |
| សរុប | | ២ ១៨១ | ១ ៣២៧ |

*ប្រការនេះបង្ហាញថា ទោះស្ថិតក្នុងបរិបទនៃការប្រឈមនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ កម្មវិធីនេះនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយប្រជាសហគមន៍ឱ្យទទួលបានចំណេះដឹង បំណិន និងជំនាញមុខរបរងាយៗ ជាពិសេសជនជួបការលំបាក និងជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ជីវភាពរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងជាពលរដ្ឋសកលស្របតាមបរិបទនៃការសិក្សាពេញមួយជីវិត។ កត្តានេះទាមទារឱ្យយកចិត្តទុកដាក់បន្ថែមក្នុងការ*

*អភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍ និងប្រែក្លាយទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ដែលត្រូវធ្វើបច្ចុប្បន្នកម្មនៃកម្មវិធីសិក្សា ការផ្តល់ជំនាញ ការពិនិត្យជំនាញឡើងវិញ និងការអភិវឌ្ឍជំនាញដោយប្រើបច្ចេកវិទ្យា ឱ្យឆ្លើយតបទៅនឹងសង្គម និងសេដ្ឋកិច្ចឌីជីថល។*

### *កម្មវិធីសមមូល-បំពេញវិជ្ជា*

### *កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ*

ថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមាន ៣៧៤ កើន ១៦ ស្មើ ៤,៤៧ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៣៦៣ កើន ១០ ស្មើ ២,៨៣ភាគរយ និងដៃគូអភិវឌ្ឍ ១១ កើន ៦ ស្មើ ១២០ភាគរយ។ កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធថ្នាក់ឆ្នាំទី១ មាន ២១៨ កើន ២៥ ស្មើ ១២,៩៥ភាគរយ និងថ្នាក់ឆ្នាំទី២ មាន ១៥៦ ថយ ៩ ស្មើ ៥,៤៥ភាគរយ។ ក្រសួងសហការជាមួយក្រសួងមហាផ្ទៃ បានដំណើរការថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធនៅមណ្ឌលកែប្រែ ២ថ្នាក់ និងនៅពន្ធនាគារ ១១ថ្នាក់។

គ្រូបង្រៀនមាន ៣៧៤នាក់ កើន ១៦នាក់ ស្មើ ៤,៤៧ភាគរយ ស្រី ៣៤,៤៩ភាគរយ កើន ២២នាក់ ស្មើ ២០,៥៦ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៣៦៣នាក់ កើន ១០នាក់ ស្មើ ២,៨៣ភាគរយ ស្រី ៣៤,១៦ភាគរយ កើន ១៩នាក់ ស្មើ ១៨,១០ភាគរយ និងដៃគូអភិវឌ្ឍ ១១នាក់ កើន ៦នាក់ ស្មើ ១២០ភាគរយ ស្រី ៤៥,៤៥ភាគរយ កើន ៣នាក់ ស្មើ ១៥០ភាគរយ។

អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធនៅឆ្នាំទី១ និងឆ្នាំទី២ មាន ៧ ០៨៣នាក់ កើន ៣២៣នាក់ ស្មើ ៤,៧៨ភាគរយ ស្រី ៤២,១៦ភាគរយ ថយ ១២២នាក់ ស្មើ ៣,៩៣ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៦ ៨៦៩នាក់ កើន ២១៥នាក់ ស្មើ ៣,២៣ភាគរយ ស្រី ៤១,៩០ភាគរយ ថយ ១៧៩នាក់ ស្មើ ៥,៨៦ភាគរយ (អ្នកសិក្សានៅមណ្ឌលកែប្រែ ៣៨នាក់ ស្រី ០០នាក់ និងនៅក្នុងពន្ធនាគារ ២៣១នាក់ ស្រី ១៣នាក់) និងដៃគូអភិវឌ្ឍ ២១៤នាក់ កើន ១០៨នាក់ ស្មើ ១០១,៨៩ភាគរយ ស្រី ៥០,៤៧ភាគរយ កើន ៥៧នាក់ ស្មើ ១១១,៧៦ភាគរយ។

**តារាងទី២៦ ៖ ស្ថិតិថ្នាក់ គ្រូ និងអ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សា**

| បរិយាយ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | អយក | ៣៥៣ | | ៣៦៣ | | ១០ | |
| | ដៃគូ | ៥ | | ១១ | | ៦ | |
| | *សរុប* | *៣៥៨* | | *៣៧៤* | | *១៦* | |
| គ្រូបង្រៀន | អយក | ៣៥៣ | ១០៥ | ៣៦៣ | ១២៤ | ១០ | ១៩ |
| | ដៃគូ | ៥ | ២ | ១១ | ៥ | ៦ | ៣ |
| | *សរុប* | *៣៥៨* | *១០៧* | *៣៧៤* | *១២៩* | *១៦* | *២២* |
| អ្នកសិក្សា | អយក | ៦ ៦៥៤ | ៣ ០៥៧ | ៦ ៨៦៩ | ២ ៨៧៨ | ២១៥ | -១៧៩ |
| | ដៃគូ | ១០៦ | ៥១ | ២១៤ | ១០៨ | ១០៨ | ៥៧ |
| | *សរុប* | *៦ ៧៦០* | *៣ ១០៨* | *៧ ០៨៣* | *២ ៩៨៦* | *៣២៣* | *-១២២* |

កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមានរយៈពេល ២ឆ្នាំ ទើបចប់កម្មវិធី ដូច្នេះអ្នកសិក្សាដែលបានបញ្ចប់កម្មវិធីសមមូលបឋមសិក្សានេះ គឺជាអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់ឆ្នាំទី២។ ក្នុងឆ្នាំ២០២០ អ្នកសិក្សាបានបញ្ចប់កម្មវិធីសមមូលបឋមសិក្សា ២ ៦០៥នាក់ ថយ ១៨៨នាក់ ស្មើ ៦,៧៣ភាគរយ ស្រី ៤៤,៦១ភាគរយ ថយ ១៥៧នាក់ ស្មើ ១១,៩០ភាគរយ ក្នុងនោះប្រឡងជាប់ ២ ៤១៨នាក់ ស្មើ ៩២,៨២ ភាគរយ ស្រី ១ ០៨៦នាក់ ស្មើ ៩៣,៤៣ភាគរយ។

## តារាងទី២៧៖ ចំនួនអ្នករៀនបញ្ចប់តាមកម្រិតឆ្នាំ

| ស្ថាប័ន | ថ្នាក់ឆ្នាំទី១ | | ថ្នាក់ឆ្នាំទី២ | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| អ.យ.ក | ៣ ៥៧៣ | ១ ៤៥១ | ២ ៥១៥ | ១ ១២០ |
| ដៃគូអភិវឌ្ឍ | ១២៣ | ៦៦ | ៩០ | ៤២ |
| សរុប | ៣ ៦៩៦ | ១ ៥១៧ | ២ ៦០៥ | ១ ១៦២ |

អ្នករៀនបានបញ្ចប់ទាំងឆ្នាំទី១ និងឆ្នាំទី២ មាន ៦ ៣០១នាក់ កើន ១៦០នាក់ ស្មើ ២,៦១ភាគរយ ស្រី ៤២,៥២ភាគរយ ថយ ១៧៦នាក់ ស្មើ ៦,១៦ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៦ ០៨៨នាក់ កើន ៥១នាក់ ស្មើ ០,៨៤ភាគរយ ស្រី ៤២,២៣ភាគរយ ថយ ២៣៣នាក់ ស្មើ ៨,៣១ភាគរយ និងដៃគូអភិវឌ្ឍ ២១៣នាក់ កើន ១០៩នាក់ ស្មើ ១០៤,៨១ភាគរយ ស្រី ៥០,៧០ភាគរយ កើន ៥៧នាក់ ស្មើ ១១១,៧៦ភាគរយ ។

**រូបភាពទី៤៧៖ ចំនួនអ្នកសិក្សាបញ្ចប់កម្មវិធីសមមូលបឋមសិក្សា (ថ្នាក់ឆ្នាំទី២)**




*ប្រការនេះបង្ហាញថាកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធមានការកើនឡើង ដោយសារមានការចាប់អារម្មណ៍ពីក្រុមមុខសញ្ញា ការសិក្សាពីចម្ងាយនិងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្សព្វផ្សាយគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ។*

### *កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ*

ថ្នាក់សមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធមាន ៥ ថយ ១៤ ស្មើ ៧៣,៦៨ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៤ ថយ ១៣ ស្មើ ៧៦,៤៧ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍមាន ១ ថយ ១ ស្មើ ៥០ភាគរយ។

គ្រូបង្រៀនមាន ១៤នាក់ ថយ ៤១នាក់ ស្មើ ៧៤,៥៤ភាគរយ ស្រី ៤២,៨៦ភាគរយ ថយ ២នាក់ ស្មើ ២៥ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ១០នាក់ ថយ ៤២នាក់ ស្មើ ៨០,៧៧ភាគរយ ស្រី ៣០ភាគរយ ថយ ៣នាក់ ស្មើ ៥០ភាគរយ និងដៃគូអភិវឌ្ឍ ៤នាក់ កើន ១ ស្មើ ៣៣,៣៣ភាគរយ ស្រី ៧៥ភាគរយ កើន ១ ស្មើ ៥០ភាគរយ ។

អ្នកសិក្សាឆ្នាំទី១ និងឆ្នាំទី២ មាន ១០៤នាក់ ថយ ២៧០នាក់ ស្មើ ៧២,១៩ភាគរយ ស្រី ៣៦,៥៤ភាគរយ ក្នុងនោះគ្រប់គ្រងដោយក្រសួង ៨៥នាក់ ថយ ២៥៣នាក់ ស្មើ ៧៤,៨៥ភាគរយ ស្រី ៣១,៧៦ភាគរយ ថយ ១០៤នាក់ ស្មើ ៧៩,៣៩ភាគរយ និងដៃគូអភិវឌ្ឍ ១៩នាក់ ថយ ១៧នាក់ ស្មើ ៤៧,២២ភាគរយ ស្រី ៥៧,៨៩ភាគរយ ថយ ១៧នាក់ ស្មើ ៦០,៧១ភាគរយ។ អ្នកសិក្សាចូលរៀនថ្នាក់ឆ្នាំទី១ មាន ៤៣នាក់ ស្រី ២៥,៥៨ភាគរយ និងថ្នាក់ឆ្នាំទី២ មាន ៦១នាក់ ស្រី ៤៤,២៦ភាគរយ។

កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធមានរយៈពេល ២ឆ្នាំទើបបញ្ចប់កម្មវិធី ដូច្នេះអ្នកសិក្សាដែលបានបញ្ចប់កម្មវិធីនេះ គឺជាអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់ឆ្នាំទី២។ អ្នកសិក្សាបានបញ្ចប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិមាន ៥៦នាក់ ស្រី ២៦នាក់ មកប្រឡង ៥៥នាក់ ស្រី ២៦នាក់ ប្រឡងជាប់ ៥៥នាក់ ស្រី ២៦នាក់។

### តារាងទី២៨៖ ស្ថិតិថ្នាក់ គ្រូ និងអ្នកសិក្សាកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ

| បរិយាយ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន(+) / ថយ(-) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់ | អយក | ១៧ | | ៤ | | -១៣ | |
| | ដៃគូ | ២ | | ១ | | -១ | |
| | *សរុប* | *១៩* | | *៥* | | *-១៤* | |
| គ្រូបង្រៀន | អយក | ៥២ | ៦ | ១០ | ៣ | -៤២ | -៣ |
| | ដៃគូ | ៣ | ២ | ៤ | ៣ | ១ | ១ |
| | *សរុប* | *៥៥* | *៨* | *១៤* | *៦* | *-៤១* | *-២* |
| សិស្សចូលរៀន | អយក | ៣៣៨ | ១៣១ | ៨៥ | ២៧ | -២៥៣ | -១០៤ |
| | ដៃគូ | ៣៦ | ២៨ | ១៩ | ១១ | -១៧ | -១៧ |
| | *សរុប* | *៣៧៤* | *១៥៩* | *១០៤* | *៣៨* | *-២៧០* | *-១២១* |
| សិស្សមកប្រឡង | អយក | ២១៦ | ៨១ | ២៩ | ១៦ | -១៨៧ | -៦៥ |
| | ដៃគូ | ១៦ | ១៦ | ១៦ | ១០ | ០ | -៦ |
| | *សរុប* | *២៣២* | *៩៧* | *៤៥* | *២៦* | *-១៨៧* | *-៧១* |
| សិស្សប្រឡងជាប់ | អយក | ២១២ | ៨៣ | ២៩ | ១៦ | -១៨៣ | -៦៧ |
| | ដៃគូ | ១៥ | ១៥ | ១៦ | ១០ | ១ | -៥ |
| | *សរុប* | *២២៧* | *៩៨* | *៤៥* | *២៦* | *-១៨២* | *-៧២* |

រូបភាពទី៤៨៖ ចំនួនអ្នកសិក្សាប្រឡងជាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ (ថ្នាក់ឆ្នាំទី២)




*កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ បានជួយកុមារ និងយុវជនក្រៅសាលាឱ្យមានឱកាសបានចូលរៀនបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ ដើម្បីបន្តការសិក្សាទៅកម្រិតខ្ពស់ជាង និងចាប់យកជំនាញបច្ចេកទេសវិជ្ជាជីវៈ។ កត្តាថយចុះនៃអ្នកសិក្សា បានបង្ហាញពីបញ្ហាប្រឈម ដែលអ្នកសិក្សាពុំអាចបត់បែនតាមការសិក្សាស្របតាមគន្លងថ្មី ដែលទាមទារឱ្យធ្វើស្វ័យសិក្សា និងស្រាវជ្រាវដោយខ្លួនឯងតាមប្រព័ន្ធអេឡិចត្រូនិក។ ដូច្នេះអ្នកសិក្សាត្រូវធ្វើការរៀនសូត្របន្ថែមលើជំនាញប្រើប្រព័ន្ធអេឡិចត្រូនិក និងបន្សាំខ្លួនលើការរៀនសូត្រតាមគន្លងថ្មីនៃវិស័យអប់រំក្នុងបរិបទកូវីដ-១៩។*

### *មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា*

អ្នកសិក្សាចូលរៀនកម្មវិធីមធ្យមសិក្សាបឋមភូមិបំពេញវិជ្ជាមាន ៨៣០នាក់ ថយ ១៤៩នាក់ ស្មើ ១៥,២២ ភាគរយ ស្រី ២៦,២៧ភាគរយ ថយ ២៥នាក់ ស្មើ ១០,២៩ភាគរយ។

## តារាងទី២៩៖ ស្ថិតិថ្នាក់ គ្រូ និងអ្នកសិក្សាមធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា

| បរិយាយ | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន ឬ ថយ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូបង្រៀន | ប្រើប្រាស់គ្រូអប់រំក្នុងប្រព័ន្ធ | | | | | |
| សិស្សចូលរៀន | ៩៧៩ | ២៤៣ | ៨៣០ | ២១៨ | -១៤៩ | -២៥ |
| សិស្សមកប្រឡង | ៨១០ | ២១០ | ៧៧០ | ១៩៣ | -៤០ | -១៧ |
| សិស្សប្រឡងជាប់ | ៥៣៨ | ១៦៦ | ៧៧០ | ១៩៣ | ២៣២ | ២៧ |

បេក្ខជនមធ្យមសិក្សាបឋមភូមិបំពេញវិជ្ជានិងស្វែរិនមកប្រឡង ៧៧០នាក់ ថយ ៤០នាក់ ស្មើ ៤,៩៤ភាគរយ ស្រី ២៥,០៦ភាគរយ ថយ ១៧នាក់ ស្មើ ៨,១០ភាគរយ ក្នុងនោះប្រឡងជាប់ ៧៧០នាក់ កើន ២៣២នាក់ ស្មើ ៤៣,១២ ភាគរយ ស្រី ២៥,០៦ភាគរយ កើន ២៧នាក់ ស្មើ ១៦,២៧ភាគរយ។

## រូបភាពទី៤៩៖ លទ្ធផលអ្នកសិក្សាប្រឡងជាប់មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា




### មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា

អ្នកសិក្សាចូលរៀនកម្មវិធីមធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា ៣ ៩៦៩នាក់ ថយ ១ ៦៤៩នាក់ ស្មើ ២៩,៣៥ ភាគរយ ស្រី ៣២,៩៨ភាគរយ ថយ ៥០៦នាក់ ស្មើ ២៧,៨៨ភាគរយ។

## តារាងទី៣០៖ ស្ថិតិថ្នាក់ គ្រូ និងអ្នកសិក្សាមធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា

| បរិយាយ | ២០១៨-២០១៩ | | ២០១៩-២០២០ | | កើន ឬថយ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូបង្រៀន | ប្រើប្រាស់គ្រូអប់រំក្នុងប្រព័ន្ធ | | | | | |
| សិស្សចូលរៀន | ៥ ៦១៨ | ១ ៨១៥ | ៣ ៩៦៩ | ១ ៣០៩ | -១ ៦៤៩ | -៥០៦ |
| សិស្សមកប្រឡង | ៧ ៧៥១ | ២ ៥០២ | ៥ ១៨៤ | ១ ៥១២ | -២ ៥៦៧ | -៩៩០ |
| សិស្សប្រឡងជាប់ | ២ ៩៤១ | ១ ១៩៧ | ៥ ១៨៤ | ១ ៥១២ | ២ ២៤៣ | ៣១៥ |

បេក្ខជនមធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា និងស្វែរិនបំពេញវិជ្ជាមកប្រឡង ៥ ១៨៤នាក់ ថយ ២ ៥៦៧នាក់ ស្មើ ៣៣,១២ភាគរយ ស្រី ២៩,១៧ភាគរយ ថយ ៩៩០នាក់ ស្មើ ៣៩,៥៧ភាគរយ ក្នុងនោះប្រឡងជាប់ ៥ ១៨៤នាក់ កើន ២ ២៤៣នាក់ ស្មើ ៧៦,២៧ភាគរយ ស្រី ២៩,១៧ភាគរយ កើន ៣១៥នាក់ ស្មើ ២៦,៣២ភាគរយ។

## រូបភាពទី៥០៖ លទ្ធផលអ្នកសិក្សាប្រឡងជាប់មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា



*កម្មវិធីមធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា ផ្តល់ឱ្យអ្នកសិក្សាដែលពុំមានឱកាសគ្រប់គ្រាន់បានបន្តការសិក្សា និងប្រឡងបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងចាប់យកជំនាញវិជ្ជាជីវៈ និងបន្តទៅកម្រិតឧត្តមសិក្សា។*

## ក.២. ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ក្រសួងបានរៀបចំការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធ ដោយអនុលោមតាមអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល គឺបង្កើនប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធតាមកម្មវិធីពី ៥០ ទៅ១០០ភាគរយ នៃបៀវត្សសរុបប្រចាំខែរបស់គ្រូបង្រៀនកម្រិតបឋមសិក្សាទើបចេញថ្មី ព្រមទាំងមានប្រាក់លើកទឹកចិត្តសម្រាប់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ១២ខែ។

ដើម្បីជំរុញការអនុវត្តអនុវិស័យអប់រំក្រៅប្រព័ន្ធ ឱ្យមានភាពរលូនប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅទូទាំងប្រទេស ក្រសួងបាន៖

- ចេញប្រកាសទទួលស្គាល់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ២ ៤៧២នាក់ ក្នុងនោះមាន កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ៨៩៩នាក់ កម្មវិធីសមមូលបឋមសិក្សា ៣៥៩នាក់ កម្មវិធីចូលរៀនឡើងវិញ ៦៣៧នាក់ និងកម្មវិធីបង្កើនប្រាក់ចំណូល ៥៧៧នាក់
- បណ្តុះបណ្តាលគ្រូបង្រៀនកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ២២៣នាក់ ស្រី ៧៣នាក់
- ចុះកិច្ចព្រមព្រៀងជាមួយអង្គការ ជីអិនអាយ ប្រទេសកូរ៉េ
- ចុះកិច្ចព្រមព្រៀងជាមួយអង្គការ យូណេស្កូភ្នំពេញ
- ចុះកិច្ចព្រមព្រៀងជាមួយអង្គការ ឡាយអិនក្លឹប ប្រទេសកូរ៉េ
- ចុះកិច្ចព្រមព្រៀងជាមួយអង្គការ ឌីវីវី អន្តរជាតិ សម្រាប់ឆ្នាំ២០២០
- ជ្រើសរើសមន្ត្រីគ្រប់គ្រងជាប្រធាន និងអនុប្រធានការិយាល័យ ១០រូប
- ផលិត និងផ្សព្វផ្សាយវីដេអូ ៨៤ឃ្លីប ស្តីពីការបង្រៀនពីចម្ងាយសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ និងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- ចេញសេចក្តីណែនាំស្តីពីកិច្ចដំណើរការឡើងវិញថ្នាក់រៀនកម្មវិធីអប់រំក្រៅប្រព័ន្ធឆ្នាំ២០២០
- ចេញសេចក្តីណែនាំស្តីពី ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់កម្មវិធីអក្ខរកម្មកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ
- ដាក់បញ្ចូលកម្មវិធីសមមូលមធ្យមសិក្សាអប់រំក្រៅប្រព័ន្ធ ទៅក្នុងសេវាច្រកចេញចូលតែមួយ
- ផ្សព្វផ្សាយទិវាអក្ខរកម្មជាតិ ៨កញ្ញា ២០២០ តាមវិទ្យុជាតិ និងទូរទស្សន៍ជាតិ ក្រោមប្រធានបទ «អក្ខរកម្មជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត»
- ពិនិត្យមើលដំណើរការថ្នាក់អក្ខរកម្ម សមមូល និងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ៨ខេត្ត
- ពិនិត្យការអនុវត្តប្រព័ន្ធ NFE-MIS នៅខេត្តស្ទឹងត្រែង ពោធិ៍សាត់ និងព្រៃវែង
- ចែក Posters និងផ្សព្វផ្សាយពីបញ្ហាជំងឺកូវីដ-១៩ នៅ ១៣ខេត្ត
- កែសម្រួលប្រកាសលេខ ២៤២៩ ស្តីពីការបង្កើត និងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍
- ផលិតស្ប៉ត និងផ្សព្វផ្សាយចំនួន ៣ ដើម្បីអបអរសាទរទិវាអក្ខរកម្មជាតិ ៨ កញ្ញា ២០២០ ស្តីពីបរិយាបន្ន និងការអប់រំមជ្ឈមណ្ឌលសិក្សាសហគមន៍ផ្សារភ្ជាប់នឹងជំនាញមុខរបរ និងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍
- ប្រជុំក្រុមការងារបច្ចេកទេសរៀបចំផែនការសកម្មភាពជាតិ ស្តីពីការសិក្សាពេញមួយជីវិត មានអ្នកចូលរួម ២២នាក់ ស្រី ២នាក់
- ជ្រើសរើស និងផ្តល់រង្វាន់លើកទឹកចិត្តដល់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ឆ្នើម ៥រូប

- បណ្តុះបណ្តាលគ្រូអក្ខរកម្មតាមពេងចក្រ ៤៤នាក់ ស្រី ១៩នាក់
- ផ្សាយអត្ថបទស្តីពីសកម្មភាពការងារអប់រំក្រៅប្រព័ន្ធតាមវិទ្យុជាតិកម្ពុជា ៩ អត្ថបទ
- បានប្រជុំស្តីពីកម្មវិធីសមមូលមធ្យមបឋមភូមិអប់រំក្រៅប្រព័ន្ធ ជាមួយអង្គការយូណេស្កូភ្នំពេញ យូណេស្កូបាងកក និងអង្គការ ជីអិនអាយ ប្រទេសកូរ៉េ តាមប្រព័ន្ធអេឡិចត្រូនិក
- ចូលរួមជាគណៈកម្មការប្រឆាំងគ្រឿងញៀន ប្រឆាំងការជួញដូរផ្លូវភេទ ទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក និងសរសេររឿងនិទាន រូបភាព ដើម្បីផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋនៅតាមសហគមន៍។

*ប្រការនេះបានពង្រឹងសមត្ថភាព កិច្ចសហការ និងលើកកម្ពស់ការងារអប់រំក្រៅប្រព័ន្ធតាមបែបគន្លងថ្មីស្របតាមបរិបទនៃយុគសម័យឌីជីថល។*

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

សូចនាករផលសម្រេចរបស់អនុវិស័យអប់រំក្រៅប្រព័ន្ធ ធៀបនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ សម្រេចបានតាមចំណុចដៅ ១២,៥០ភាគរយ អាចទទួលយកបាន ២៥ភាគរយ និងសម្រេចមិនបាន ៦២,៥០ភាគរយ។

**ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច**

| | សូចនាករ | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១៖ បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់កុមារ និងយុវជនក្រៅសាលា ព្រមទាំងពេញវ័យដែលជាអនក្ខរជន ទទួលបានសេវាអប់រំក្រៅប្រព័ន្ធបានពេញលេញក្នុងក្របខណ្ឌការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា | | | | | | |
| ១. | ប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ចំនួន | ១៦ ៥៣៥* | ១៥ ២០០ | ១៥ ៣០៩** | ↑ |
| ២. | សិស្សចូលរៀនក្នុងកម្មវិធីសមមូល | ចំនួន | ៧ ១៣៤* | ៨ ៣០០ | ៧ ១៨៧** | → |
| ៣. | ម..ស.ស.ដែលប្រែក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | ចំនួន | ៧* | ១៥ | ១៤** | → |
| ៤. | កុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ចំនួន | ១០ ៥៩៧* | ១០ ១៨០ | ១ ៦២៤** | ↓ |
| ៥. | អ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ | ចំនួន | ៨ ២៧៨* | ១១ ១០០ | ៧ ០៩០** | ↓ |
| គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| វត្ថុបំណងអនុវិស័យទី២៖ ជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងអប់រំក្រៅប្រព័ន្ធផ្អែកលើកលទ្ធផលឱ្យមានដំណើរការបានពេញលេញ | | | | | | |
| ៦. | ខេត្តដែលបានអនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃអប់រំក្រៅប្រព័ន្ធផ្អែកលើលទ្ធផល | ចំនួន | ០ | ១០ | ០ | ↓ |
| ៧. | ស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | ចំនួន | ០ | ៦០ | ០ | ↓ |
| វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ | | | | | | |
| ៨. | មន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | ចំនួន | ១៣០* | ២៦០ | ០ | ↓ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

* ទិន្នន័យឆ្នាំសិក្សា២០១៨-២០១៩ **ទិន្នន័យឆ្នាំសិក្សា២០១៩-២០២០

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការអនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មិនទាន់បានទូលំទូលាយ
- ឯកសារបណ្តុះបណ្តាលគ្រូកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធតាមប្រព័ន្ធក្រេឌីត ពុំទាន់បានរៀបចំនៅឡើយ

- មន្ត្រីដឹកនាំមជ្ឈមណ្ឌលសិក្សាសហគមន៍ពុំមែនជាមន្ត្រីទទួលបន្ទុកការងារដឹកនាំមជ្ឈមណ្ឌលសិក្សាសហគមន៍ដាច់ដោយឡែក ដែលមានទំនួលខុសត្រូវពេញលេញ លើដំណើរការដឹកនាំ និងគ្រប់គ្រង
- ដំណើរការប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតមានធនធាននៅមានកម្រិតនៅឡើយ
- ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលពុំទាន់បានអនុវត្តនៅទូទាំងប្រទេស
- មន្ត្រីអប់រំក្រៅប្រព័ន្ធមិនបានទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធពុំទាន់បានអនុវត្តនៅកម្រិតក្រុង ស្រុក ខណ្ឌ
- ចំនួនសរុបនៃអត្រាអនក្ខរជនអាយុពី ១៥ឆ្នាំឡើងនៅមានកម្រិតខ្ពស់ បើធៀបនឹងចំនួនអត្រារំដោះអនក្ខរជនក្នុងមួយឆ្នាំៗ បានប្រមាណតែ ២,៥ភាគរយប៉ុណ្ណោះ។

## ២.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

*កម្មវិធីកូនល្អ សិស្សល្អ មិត្តល្អ*

ក្រសួងបានជំរុញចលនាប្រឡងប្រណាំង ៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" ចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ និងរៀបចំបូកសរុបចលនាប្រឡងប្រណាំង ៣ល្អនៅថ្នាក់រាជធានី ខេត្ត។

*ការងារក្រុមប្រឹក្សាកុមារកម្ពុជា*

ក្រុមប្រឹក្សាកុមារកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិ គិតពីថ្នាក់ទី៤ ដល់ថ្នាក់ទី៩។ ក្រសួងបានធ្វើបច្ចុប្បន្នកម្មស្ថិតិក្រុមប្រឹក្សាកុមារកម្ពុជា មានដូចតារាងខាងក្រោម៖

តារាងទី៣១៖ ស្ថិតិក្រុមប្រឹក្សាកុមារកម្ពុជាឆ្នាំសិក្សា២០១៨-២០១៩ និង២០១៩-២០២០

| បរិយាយ | ២០១៨-២០១៩ | ២០១៩-២០២០ | កើន/ថយ (+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាកុមារកម្ពុជា | ៨ ៩៦៧ | ៨ ៥៨៥ | -៣៨២ |
| ចំនួនសាខា | ៤២ ៧២៨ | ៣៧ ៣៤៧ | -៥ ៣៨១ |
| ចំនួនអនុសាខា | ២៥៦ ៣៦៨ | ២៤០ ៣៣៦ | -១៦ ០៣២ |
| ចំនួនសមាជិក | ១ ៥៥២ ៨៤០ (ស្រី ៧៨៨ ៩០១) | ១ ៣៤៧ ៦៥៤ (ស្រី ៧៣៦ ១១០) | -២០៥ ១៨៦ (ស្រី -៥២ ៧៩១) |

ក្រុមប្រឹក្សាកុមារកម្ពុជា រួមមានសាខា អនុសាខា និងសមាជិកជាកុមារ មានការថយចុះដោយសារក្រសួងអប់រំ យុវជន និងកីឡា បានធ្វើបច្ចុប្បន្នកម្មស្ថិតិ ដោយធ្វើការញែកដាច់ចេញពីគ្នារវាងស្ថិតិសិស្សសាលាបឋមសិក្សាមិនគ្រប់កម្រិត និងសិស្សសាលាបឋមសិក្សាគ្រប់កម្រិត និងញែកស្ថិតិសិស្សមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។

*ការងារក្រុមប្រឹក្សាយុវជនកម្ពុជា*

ក្រុមប្រឹក្សាយុវជនកម្ពុជាបានកំណត់ក្របខណ្ឌអនុវត្តនៅមធ្យមសិក្សាទុតិយភូមិ។ ក្រសួងបានធ្វើបច្ចុប្បន្នកម្មស្ថិតិក្រុមប្រឹក្សាយុវជនកម្ពុជា មានដូចតារាងខាងក្រោម៖

តារាងទី៣២៖ ស្ថិតិក្រុមប្រឹក្សាយុវជនកម្ពុជាឆ្នាំសិក្សា២០១៨-២០១៩ ដល់ឆ្នាំសិក្សា២០១៩-២០២០

| បរិយាយ | ២០១៨-២០១៩ | ២០១៩-២០២០ | កើន/ថយ (+/-) |
|---|---|---|---|
| ចំនួនក្រុមប្រឹក្សាយុវជនកម្ពុជា | ៥២៥ | ៥៤៣ | +១៨ |
| ចំនួនសាខា | ៧ ១៧៩ | ៧ ៤០៣ | +២២៤ |
| ចំនួនអនុសាខា | ៤៣ ០៧៤ | ៤៤ ៤១៨ | +១ ៣៤៤ |
| ចំនួនសមាជិក | ៣២១ ១៤៥ (ស្រី ១៥៩ ២២៥) | ២៩៦ ៥៩៧ (ស្រី ១៨៣ ៣៤៣) | -២៤ ៥៤៨ (ស្រី +២៤ ១១៨) |

ក្រុមប្រឹក្សាយុវជនកម្ពុជា មានសាខា និងអនុសាខា កើនឡើង ដោយមានកម្មវិធីស្ម័គ្រចិត្ត កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន កំណើនគ្រឹះស្ថានសិក្សា និងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ។

ក្រុមប្រឹក្សាយុវជនកម្ពុជា និងក្រុមប្រឹក្សាកុមារកម្ពុជា បានជួយដល់ការងារស្វ័យគ្រប់គ្រងសាលារៀន គាំទ្រសកម្មភាពក្លឹប ការងារស្ម័គ្រចិត្ត និងជួយសិស្សប្រឡងថ្នាក់ទី១២។

### *ការងារកាយរឹទ្ធិកម្ម*

ក្រសួងបានធ្វើបច្ចុប្បន្នកម្មស្ថិតិសមាជិកកាយរឹទ្ធិជាតិកម្ពុជា មានដូចតារាងខាងក្រោម៖

**តារាងទី៣៣៖ ស្ថិតិសមាជិកភាពឆ្នាំសិក្សា២០១៨-២០១៩ ធៀបនឹងឆ្នាំសិក្សា២០១៩-២០២០**

| បរិយាយ | ២០១៨-២០១៩ | ២០១៩-២០២០ | ស្ថានភាព(+/-) |
|---|---|---|---|
| ចំនួនកាយរឹទ្ធិប្អូន(៩-១១ឆ្នាំ) | ១២ ០២៣ | ១២ ៩២៣ | +៩០០ |
| ចំនួនកាយរឹទ្ធិ (១២-១៧ឆ្នាំ) | ១១២ ៥៤២ | ១១៦ ៦៤២ | +៤ ១០០ |
| ចំនួនកាយរឹទ្ធិរៀមច្បង (១៨-២៥ឆ្នាំ) | ២១ ១៤៤ | ២១ ២៤៤ | +១ ០០ |
| ចំនួនមេដឹកនាំកាយរឹទ្ធិ (២៦ឆ្នាំឡើង) | ១២ ៩៣៧ | ១២ ៩៨៩ | +៥២ |
| ចំនួនសមាជិកកិត្តិយស | ២ ៣១៧ | ២ ៣៣៧ | +២០ |
| **សរុប** | **១៦០ ៩៦៣** | **១៦៦ ១៣៥** | **+៥ ១៧២** |

តារាងខាងលើបង្ហាញថា សមាជិកកាយរឹទ្ធិកើនឡើង ដោយសារការពង្រឹងប្រសិទ្ធភាពរចនាសម្ព័ន្ធកងល្បាតនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។ ក្នុងឆ្នាំសិក្សា២០១៩-២០២០ សមាជិកភាពនៃកាយរឹទ្ធិជាតិកម្ពុជាមាន ១៦៦ ១៣៥ នាក់ ស្រី ៤៩ភាគរយ។

ក្រសួងបានរៀបចំ៖

- វគ្គសមាជិកភាពដល់នវកាយរឹទ្ធិ ៣៤៤នាក់ ស្រី ៥២,៣២ភាគរយ នៅខេត្តកែប
- វគ្គសមាជិកភាពដល់នវកាយរឹទ្ធិសហគមន៍នៃកងឯកភាពអង្គការមេជ្ឈមណ្ឌលអប់រំនៅកម្ពុជា ១០៨នាក់ ស្រី ៥៥,៥៥ភាគរយ នៅខេត្តកំពង់ចាម។

### *ការងារលើកកម្ពស់ការស្ម័គ្រចិត្ត និងការចូលរួមរបស់យុវជន*

ក្រសួងបាន៖

- ជ្រើសរើសយុវជនចូលរួមអនុវត្តគម្រោងការស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ២៦៤នាក់ ស្រី ៥៣,៤០ភាគរយ
- ជ្រើសរើសយុវជនស្ម័គ្រចិត្ត ៣០នាក់ និងគ្រូបង្វឹកស្ម័គ្រចិត្ត ១៦នាក់ ដើម្បីសម្របសម្រួល និងដឹកនាំសិស្សវិទ្យាល័យ ១៦ក្រុម មកពី ១៦វិទ្យាល័យ ស្រាវជ្រាវរកអំណះអំណាងលើប្រធានបទសិក្សា ១៥
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអ្នកនាំសារសន្តិភាពដើម្បីសហគមន៍ខ្ញុំ មានកាយរឹទ្ធិចូលរួម ២១១នាក់ ស្រី ៧០,៦ភាគរយ
- ផ្សព្វផ្សាយអ្នកនាំសារសន្តិភាព និងទិវាសន្តិភាពពិភពលោក ក្រោមប្រធានបទ ការកសាងសន្តិភាពជាមួយគ្នា មានមេដឹកនាំកាយរឹទ្ធិចូលរួម ១៣០នាក់ ស្រី១១,៥៤ភាគរយ
- ផ្សព្វផ្សាយពីវិធីការពារជំងឺកូវីដ១៩ យុវជនកាយរឹទ្ធិចូលរួម ២១នាក់ ស្រី៤២,៨៥ភាគរយ
- ជួយប្រមូលផលកសិកម្ម និងផ្តល់អំណោយមូលនិធិកាយរឹទ្ធិជាតិកម្ពុជាដល់ប្រជាពលរដ្ឋក្រីក្រ មានមេដឹកនាំកាយរឹទ្ធិចូលរួម ៥នាក់ នៅខេត្តកំពង់ចាម
- ជួយប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់នៅខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន កំពង់ធំ សៀមរាប កំពង់ស្ពឺ ឧត្តរមានជ័យ និងព្រះសីហនុ យុវជនកាយរឹទ្ធិចូលរួម ១៧៥នាក់ ស្រី ៣៨,៨៥ភាគរយ
- រៀបចំទិវាសហគ្រិនភាពកម្ពុជា ២១កញ្ញា មានអ្នកចូលរួម ១ ៦៦៦នាក់ ស្រី ៥៩,៦០ភាគរយ។

### *ការអប់រំសហគ្រិនភាព និងភាពជាអ្នកដឹកនាំ*

ក្រសួងបាន៖

- បណ្តុះបណ្តាលកម្មវិធីអប់រំសហគ្រិនភាពស្តីពី ការយល់ដឹងពីធុរកិច្ចដល់គ្រូបង្គោល ២៧នាក់ ស្រី ៣៣,៣ភាគរយ

- បណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍសហគ្រាសតាមសហគមន៍ មានអ្នកចូលរួម ៣៤០នាក់ ស្រី ៥៨,២ភាគរយ
- បណ្តុះបណ្តាលស្តីពី ការប្រកួតប្រជែងផែនការអាជីវកម្មមានឈ្មោះថា អាជីវកម្មខ្ញុំ មានអ្នកចូលរួម ៩០នាក់ ស្រី ៤៦,៧ភាគរយ។

### *ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញឌីជីថល និងជំនាញបច្ចេកទេសរយៈពេលខ្លី*

ក្រសួងបាន៖

- រៀបចំដំណើរការកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន មានសិស្សចូលរួម ៣៥០នាក់ ស្រី ៤៧,១ភាគរយ
- រៀបចំសិក្ខាសាលាអក្ខរកម្មឌីជីថល មានអ្នកចូលរួម ៦០០នាក់ ស្រី ៥៨,៨ភាគរយ
- រៀបចំសិក្ខាសាលាស្តីពីជំនាញទន់ មានអ្នកចូលរួម ៩០នាក់ ស្រី ៦១,១ភាគរយ
- រៀបចំសិក្ខាសាលាស្តីពីព័ត៌មានទីផ្សារការងារអាជីព មានអ្នកចូលរួម ១៥០នាក់ ស្រី ៥៨,០ភាគរយ
- រៀបចំវេទិកាបច្ចេកវិទ្យាព័ត៌មានតាមរលកធាតុអាកាសលើកទី៦៣ និងប្រព័ន្ធអ៊ីនធឺណិតលើកទី២៤ មានកាយរឹទ្ធិចូលរួម ៥០នាក់ ស្រី ៤៤,០ភាគរយ
- ទទួលយុវជនចូលអានក្នុងបណ្ណាល័យមជ្ឈមណ្ឌលយុវជន ៥ ៥៧៩នាក់ ស្រី ៥៣,៩ភាគរយ
- ទទួលកុមារចូលអានក្នុងបណ្ណាល័យមជ្ឈមណ្ឌលយុវជន ៣ ៦៩៤នាក់ ស្រី ៦៦,១ភាគរយ
- រៀបចំសេវាកម្មប្រើប្រាស់អ៊ីនធឺណិតដល់យុវជន ១១ ៥១១នាក់ ស្រី ៥០,៥ភាគរយ
- បណ្តុះបណ្តាលជំនាញខ្លីៗនៅមជ្ឈមណ្ឌលជាតិយុវជនលើជំនាញព្យាណូ របាំសិល្បៈបុរាណ និងប្រពៃណី ភ្លេងបុរាណ អក្សរភ្លេង ភ្លេងព្យុហយាត្រា តន្ត្រីសម័យ សម្លាងកាយ ភាសាអង់គ្លេស ភាសាកូរ៉េ ការតម្រង់ទិសអាជីពមគ្គុទ្ទេសទេសចរណ៍ និងចំណេះដឹងជាមូលដ្ឋានងាយៗពីបុរាណវិទ្យា មូលដ្ឋានក្បាច់គុណល្បុក្កតោ របៀបប្រើប្រាស់អ៊ីនធឺណិត និងបណ្តាញទំនាក់ទំនងសង្គម រដ្ឋបាលកុំព្យូទ័រ រចនាវីដេអូឯកសារ សញ្ញាណដំបូងនៃស្ថាបត្យកម្ម ជួសជុលកុំព្យូទ័រ ដល់យុវជន ១ ៥៤៥នាក់ ស្រី ៦៤,៤ភាគរយ។

### *ការលើកកម្ពស់សុខភាព និងសុខុមាលភាពយុវជន*

ក្រសួងបានរៀបចំ៖

- សិក្ខាសាលាផ្សព្វផ្សាយអប់រំស្តីពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការបង្ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដល់យុវជនកាកបាទក្រហម កាយរឹទ្ធិ និងក្រុមប្រឹក្សាយុវជនកម្ពុជា ៥០នាក់ ស្រី ៥៦,០ភាគរយ
- សិក្ខាសាលាស្តីពីការអប់រំផ្លូវចិត្តដល់យុវជន ៣០០នាក់ ស្រី ៦១,៣ភាគរយ
- ផ្សព្វផ្សាយបន្តផ្ទាល់តាមទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង ស្តីពីការអប់រំចិត្តយុវជនក្នុងបរិបទកូវីដ-១៩ មានអ្នកចូលទស្សនា ៥០៨ ០០០នាក់។

### *ការប្រកួតប្រជែងសមត្ថភាពយុវជន*

ក្រសួងបានរៀបចំ៖

- កម្មវិធី "ការប្រកួតប្រជែងជជែកដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ២០២០" មានយុវជនចូលរួមជម្រុះវគ្គ១ ចំនួន ៨០នាក់ ស្រី ៧៥,៥ភាគរយ បែងចែកជា ១៦ក្រុម។ វគ្គទី២ មានយុវជនចូលរួម ៤០នាក់ ចែកជា ៨ក្រុម។ វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ មានយុវជនចូលរួម ២០នាក់ ៦២,៥ភាគរយ ចែកជា ៤ក្រុម និងវគ្គផ្តាច់ព្រ័ត្រ មានយុវជនចូលរួម ១០នាក់ ស្រី ៧៥,០ភាគរយ ចែកជា ២ក្រុម ដើម្បីទទួលបានជ័យលាភីពីក្រសួង

- កម្មវិធីការប្រកួតប្រជែងសរសេរផែនការអាជីវកម្មក្រោមប្រធានបទ អាជីវកម្មខ្ញុំ មានយុវជនចូលរួមជម្រុះវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ ៩០នាក់ ស្រី ៤៦,៧ភាគរយ បែងចែកជា១៥ ក្រុម និងវគ្គផ្ដាច់ព្រ័ត្រ មានយុវជនចូលរួម ៣០នាក់ ស្រី ៤៣,៣ភាគរយ ដើម្បីទទួលបានជ័យលាភីពីក្រសួង។

### *ការបោះជំរំ និងទស្សនកិច្ចសិក្សា*

ក្រសួងបានរៀបចំបោះជំរំមេដឹកនាំកាយរឹទ្ធិលើកទី១ ក្រោមប្រធានបទ ការគ្រប់គ្រងការផ្លាស់ប្ដូរ មានអ្នកចូលរួម ១១៤នាក់ ស្រី ២០,១៧ភាគរយ។

### *ការផ្សព្វផ្សាយសកម្មភាពកិច្ចការយុវជន*

ក្រសួងបាន៖

- ផលិតវីដេអូអប់រំខ្លីស្ដីពីយុវជនសតវត្សរ៍ទី២១ សម្រាប់ការផ្សព្វផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា និងបណ្ដាញព័ត៌មានសង្គម
- ផលិតវីដេអូសកម្មភាព និងផ្សាយបន្តផ្ទាល់ប្រកួតប្រជែងរបស់យុវជនស្ដីពី កម្មវិធីប្រកួតប្រជែងដេញដោលយុវជនថ្នាក់ជាតិ ឆ្នាំ២០២០ មានអ្នកចូលទស្សនា ៤៥០ ០០០នាក់
- ផលិតផ្ទាំងផ្សព្វផ្សាយសកម្មភាពយុវជន តាមរយៈព្រឹត្តិបត្រយុវជន និងគេហទំព័រយុវជនស្ម័គ្រចិត្តកម្ពុជា www.yvc.moeys.gov.kh ដែលជាទម្រង់ព័ត៌មានការងារស្ម័គ្រចិត្ត និងជាយន្តការច្រកចេញចូលតែមួយសម្រាប់ផ្ដល់ព័ត៌មាន ផ្ដល់ឱកាសការងារស្ម័គ្រចិត្ត ការចុះកម្មសិក្សា ការបណ្ដុះបណ្ដាលជំនាញ និងបំណិនដល់យុវជនកម្ពុជា ។

### *ការពង្រឹងសមាគមនិស្សិត*

ក្រសួងបានពង្រឹងរចនាសម្ព័ន្ធ និងសកម្មភាពរបស់សមាគមនិស្សិតនៃសាកលវិទ្យាល័យជាតិមានជ័យ និងសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ។

### *ការសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ*

ក្រសួងបាន៖

- ព្រាងក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃរបស់អនុវិស័យការអភិវឌ្ឍយុវជន សហការជាមួយអង្គការ EWMI និងនាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបង្កើតបណ្ដាញកាយរឹទ្ធិសហគមន៍ឥស្លាម មានអ្នកចូលរួម ២៥នាក់ ស្រី ២៤ ភាគរយ សហការជាមួយសមាគមសាសនិកឥស្លាមកម្ពុជា
- ព្រាងអនុស្សរណៈនៃការយោគយល់ជាមួយសាធារណរដ្ឋកូរ៉េ និងប្រ៊ុយណេ លើកិច្ចសហប្រតិបត្តិការក្នុងវិស័យយុវជន
- អនុញ្ញាតជាគោលការណ៍ឱ្យក្រសួងបរិស្ថានរៀបចំវេទិកាយុវជនជជែកពិភាក្សាអំពីបរិស្ថានឆ្នាំ២០២០ ដល់សិស្សានុសិស្សនៅតាមវិទ្យាល័យក្នុងរាជធានី
- បណ្ដុះបណ្ដាលគ្រូសម្របសម្រួលកម្មវិធីអប់រំសហគ្រិនភាព និងកម្មវិធីទិវាសហគ្រិនភាព ២១កញ្ញា សហការជាមួយអង្គការអន្តរជាតិការងារ
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍ ដូចជា UNESCO, UNFPA, UNV, VSO, DVV & BOOKBRIDGE Foundation។

*ការផ្លាស់ប្តូរទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ*

ក្រសួងបាន៖

- បញ្ជូនថ្នាក់ដឹកនាំ ១០នាក់ ស្រី ២០ភាគរយ និងគណៈប្រតិភូយុវជន ២៧នាក់ ស្រី ៣៧ភាគរយ ដើម្បីចូលរួមវេទិកាកិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ថ្នាក់តំបន់ និងពិភពលោក តាមរយៈកិច្ចប្រជុំអនឡាញ ដូចជា៖ កិច្ចប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិស្តីពីយុវជនលើកទី៧៥ កិច្ចប្រជុំមេដឹកនាំ យុវជនអាស៊ាន កិច្ចប្រជុំពិគ្រោះយោបល់របស់ឧត្តមមន្ត្រីយុវជនអាស៊ាននិងអាស៊ានបូក៣ ស្តីពីសេចក្តីព្រាងផែនការសកម្មភាពអាស៊ានស្តីពីយុវជនឆ្នាំ២០២១-២០២៥ កិច្ចប្រជុំឧត្តមមន្ត្រីយុវជនអាស៊ានលើកទី១០ និងអាស៊ានបូក៣លើកទី៩ វេទិកាយុវជនអាស៊ានឆ្នាំ២០២០ វេទិកាមេដឹកនាំយុវជនអាស៊ីឆ្នាំ២០២០ ការសម្ពោធឯកសារផ្សព្វផ្សាយស្តីពី ការស្ម័គ្រចិត្តខាងត្បូង-ខាងត្បូងជាកម្លាំងជំរុញសម្រាប់ការអភិវឌ្ឍ បទពិសោធពីអាស៊ីប៉ាស៊ីហ្វិក កិច្ចប្រជុំរដ្ឋមន្ត្រីយុវជនអាស៊ានលើកទី១២ និងអាស៊ានបូក៣លើកទី៨ វេទិកាអ្នកវិទ្យាសាស្ត្រវ័យក្មេង និងចូលរួមផ្ទាល់ក្នុងវេទិកាថ្នាក់តំបន់អាស៊ានលើកទី៩
- បញ្ជូនមេដឹកនាំកាយរឹទ្ធិ ១៦នាក់ ស្រី ១៨,៨ភាគរយ ដើម្បីចូលរួមកិច្ចប្រជុំនិមិត្ត ជាមួយអង្គការពិភពលោកនៃចលនាកាយរឹទ្ធិថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក ដូចជា កិច្ចប្រជុំស្តីពីការវាយតម្លៃស្តង់ដាកាយរឹទ្ធិជាតិកម្ពុជា កិច្ចប្រជុំស្តីពីកំណើនសមាជិកភាពកាយរឹទ្ធិតំបន់អាស៊ីប៉ាស៊ីហ្វិក និងវេទិកាលើកទី២ ស្តីពីការអប់រំកាយរឹទ្ធិកម្មថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក។

## ក.២ .ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

*ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌល*

ក្រសួងបានរៀបចំ៖

- សេចក្តីព្រាងលក្ខន្តិកៈ និងឯកសារណែនាំអនុវត្តការងារក្រុមប្រឹក្សាយុវជនកម្ពុជានៅតាមវិទ្យាល័យ
- កិច្ចប្រជុំស្តីពីយន្តការពង្រឹងការអនុវត្តការងារក្រុមប្រឹក្សាយុវជនកម្ពុជា និងក្រុមប្រឹក្សាកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកការងារយុវជននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមរយៈសន្និសីទអនឡាញ (Video Conference)
- គោលការណ៍ និងនីតិវិធីដាក់បញ្ចូលកម្មវិធីការយល់ដឹងពីធុរកិច្ច (KAB) បញ្ចូលទៅក្នុងកម្មវិធីសិក្សា
- គោលការណ៍ និងសេចក្តីណែនាំស្តីពីការប្រារព្ធខួបលើកទី៧១ ទិវាកុមារអន្តរជាតិ ០១មិថុនា ដល់រាជធានី ខេត្ត និងអង្គភាព ស្ថាប័នពាក់ព័ន្ធ
- គោលការណ៍ សេចក្តីណែនាំ និងលិខិតពាក់ព័ន្ធសម្រាប់ប្រារព្ធខួបលើកទី២១ទិវាអន្តរជាតិសម្រាប់យុវជន១២ សីហា ២០២០ ដល់រាជធានី ខេត្ត និងអង្គភាព ស្ថាប័នពាក់ព័ន្ធ
- គោលការណ៍ សេចក្តីណែនាំ និងលិខិតពាក់ព័ន្ធបង្កើតគណៈកម្មការជំនាញទាំង៧ របស់កាយរឹទ្ធិជាតិកម្ពុជា
- បណ្តុះបណ្តាលមេដឹកនាំកាយរឹទ្ធិជាន់ខ្ពស់ជំនាន់ទី៣ មានអ្នកចូលរួម ៧៦នាក់ ស្រី ២៥,០ភាគរយ
- សិក្ខាសាលាពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយកាយរឹទ្ធិជាតិកម្ពុជា មានអ្នកចូលរួម ៥៦នាក់ ស្រី ១៧,៩ភាគរយ
- បញ្ចប់ដំណើរការជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលជាតិយុវជនកម្ពុជាខេត្តសៀមរាប
- ពិនិត្យតាមដាននិងវាយតម្លៃការងារមជ្ឈមណ្ឌលយុវជន ៤ខេត្ត និងពង្រឹងដំណើរការកម្មវិធីអភិវឌ្ឍន៍នៅតាមមជ្ឈមណ្ឌលយុវជន ២៥ ខេត្ត រាជធានី
- ពិនិត្យលើដំណើរការប្រតិបត្តិរបស់មណ្ឌលសិក្សាប៊ុកប្រីដច៍ និងការរៀបចំកងឯកភាពកាយរឹទ្ធិនៅមណ្ឌលសិក្សាប៊ុកប្រីដច៍ ខេត្តតាកែវ កំពង់ធំ និងសៀមរាប។

*ការងារអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន*

ក្រសួងបានរៀបចំ៖

- សិក្ខាសាលាស្ដីពីការសិក្សា និងការងារ ដល់យុវជន ១ ៨០០នាក់ ស្រី ៤៥,០ភាគរយ នៅខេត្តបាត់ដំបង កំពង់ធំ បន្ទាយមានជ័យ សៀមរាប រតនគិរី និងមណ្ឌលគិរី
- សិក្ខាសាលាស្ដីពី ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងការអភិវឌ្ឍយុវជនកម្ពុជា មានអ្នកចូលរួម ២២០នាក់ ស្រី ៣៧,០ភាគរយ
- សិក្ខាសាលាស្ដីពីការអភិវឌ្ឍឧបករណ៍ពិនិត្យតាមដាននិងវាយតម្លៃ មានអ្នកចូលរួម ១១០នាក់ ស្រី ៣០,០ភាគរយ
- សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការសកម្មភាពជាតិស្ដីពី ការអភិវឌ្ឍយុវជនកម្ពុជា២០២១-២០២៣ មានអ្នកចូលរួម ១៦០នាក់ ស្រី ៤៧,០ភាគរយ
- សេចក្ដីព្រាងផែនការសកម្មភាពជាតិស្ដីពី ការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២១-២០២៥
- សេចក្ដីព្រាងក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃសម្រាប់អនុវត្តផែនការសកម្មភាពជាតិស្ដីពី ការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០២១-២០២៥។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

**ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច**

| | សូចនាករ | ឯកតា | ជាក់ស្ដែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្ដែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១៖ អភិវឌ្ឍកម្មវិធីឌីជីថល សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់ផ្សេងៗទៀតសម្រាប់ការអភិវឌ្ឍយុវជន | | | | | | |
| ១. | យុវជនទទួលបានការបណ្ដុះបណ្ដាលរយៈពេលខ្លី ជំនាញវិជ្ជាជីវៈ ឌីជីថល និងបច្ចេកទេស | ចំនួន | ២ ៨០៩ | ១ ៦៤៤ | ២ ៥១៧ | ↑ |
| ២. | យុវជនទទួលបានការបណ្ដុះបណ្ដាលស្ដីពីការងារស្ម័គ្រចិត្ត | ចំនួន | ១ ៨២៨ | ១ ២៤៤ | ២ ៣២៤ | ↑ |
| ៣. | យុវជនទទួលបានការបណ្ដុះបណ្ដាលស្ដីពី សហគ្រិនភាពភាពជាអ្នកដឹកនាំ អក្ខរកម្មហិរញ្ញវត្ថុ ការសិក្សានិងការណែនាំការងារ | ចំនួន | ៩ ៥១០ | ៩ ៥១០ | ២ ២៤៦ | ↑ |
| ៤. | យុវជន និងកុមារទទួលបានបណ្ណសរសើរក្នុងការអនុវត្តចលនាប្រឡងប្រណាំង៣ល្អ " កូនល្អ សិស្សល្អ មិត្តល្អ " | ចំនួន | ៣៩៨ | ៣១៩ | ៣១៩ | ↑ |
| ៥. | ក្រុមប្រឹក្សាកុមារកម្ពុជាដែលកំពុងដំណើរការ | % | ១៤,២ | ១៥,៨ | ១៤,២ | → |
| ៦. | ក្រុមប្រឹក្សាយុវជនកម្ពុជាដែលកំពុងដំណើរការ | % | ២៥,៩ | ២៧,០ | ២៥,៩ | → |
| ៧. | យុវជនកាយរឹទ្ធិនៅបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងសហគមន៍ចូលរួមចលនាកាយរឹទ្ធិ | ចំនួន | ១៦០ ៩៦៣ | ២៧០ ៣៨៥ | ១៦៦ ១៣៥ | → |
| ៨. | យុវជនក្រៅសាលាចូលរួមសិក្សាក្នុងកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋាន " បឹប " | ចំនួន | ៣១៣ | ២៥០ | ៣៥០ | ↑ |
| វត្ថុបំណងអនុវិស័យទី២៖ ពង្រឹងការអភិវឌ្ឍយុវជនតាមរយៈមជ្ឈមណ្ឌលយុវជន ទីកន្លែង និងបរិក្ខារទាន់សម័យ | | | | | | |
| ៩. | មជ្ឈមណ្ឌលយុវជនដែលកំពុងដំណើរការ | ចំនួន | ៦ | ៨ | ៦ | → |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |
| វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រីទទួលបន្ទុកការងារយុវជននៅថ្នាក់ជាតិ និងក្រោមជាតិ | | | | | | |
| ១០. | មន្ត្រីទទួលបន្ទុកការងារយុវជនទទួលបានការបណ្ដុះបណ្ដាល | ចំនួន | ៣៣៨ | ២០០ | ៥៤២ | ↑ |
| ១១. | ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនតាមក្រសួង ស្ថាប័នត្រូវបានបង្កើត | ចំនួន | ត្រូវកំណត់ | ១០ | ត្រូវកំណត់ | → |
| ១២. | ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនតាមរាជធានី ខេត្ត ត្រូវបានបង្កើត | ចំនួន | ត្រូវកំណត់ | ៧ | ត្រូវកំណត់ | → |

<u>សម្គាល់</u>: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

### គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- កម្មវិធីយុវជនមួយចំនួនខកខានមិនបានអនុវត្ត ដោយសារបញ្ហាការរាតត្បាតនៃជំងឺកូវីដ-១៩
- កង្វះលិខិតបទដ្ឋានគតិយុត្តិ និងគោលការណ៍ណែនាំសម្រាប់កម្មវិធីអភិវឌ្ឍយុវជន និងកុមារ
- កង្វះសម្ភារៈគាំទ្រកម្មវិធីបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលយុវជន
- កង្វះគ្រឿងឥស្សរិយយសកាយរឹទ្ធិក្នុងការពង្រីកសមាជិកភាព
- កង្វះធនធានមនុស្សដែលមានសមត្ថភាពជំនាញកិច្ចការយុវជន និងចំណេះដឹងផ្នែកឌីជីថល។

## ២.២.៧ អនុវិស័យការអប់រំកាយ និងកីឡា

### ក. លទ្ធផលសម្រេចបាន

### ក.១ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

*ការប្រកួតកីឡាសហព័ន្ធ*

ក្រសួងបានសហការរៀបចំការប្រកួតកីឡាជ្រើសរើសជើងឯកថ្នាក់ជាតិឆ្នាំ២០២០នៅ ៖

- រាជធានី៖ កីឡាបាល់ទាត់ពានរង្វាន់យុវជនអាយុក្រោម ១៨ឆ្នាំ ៩៧៥នាក់ កីឡាអត្តពលកម្ម ២០៥នាក់ ស្រី ៧៥នាក់ កីឡាវាយសី ១៣៩នាក់ ស្រី ២៥នាក់ កីឡាតេក្វាន់ដូដាប៊ែលយូធី ៩០នាក់ ស្រី ៤១នាក់ កីឡាហែលទឹក ៩៩នាក់ ស្រី ៣៤នាក់ កីឡាកាយសម្ព័ន្ធ ៦១នាក់ ស្រី ២៨នាក់ កីឡាប្រដាល់សកល ៤១នាក់ ស្រី ៥នាក់ កីឡាសូរីនហ្ស៊ិកាំប៉ូ ៣៨នាក់ ស្រី ១៣នាក់ កីឡាតេក្វាន់ដូអាយធីអេហ្វ ១៤៥នាក់ ស្រី ៤១នាក់ កីឡាការ៉ាតេ ១៦៨នាក់ ស្រី ៥៨នាក់ កីឡាប្រដាល់គុនខ្មែរ ៩៣នាក់ កីឡាបាល់ឱប ៨៥នាក់ កីឡាវ៉ូវីណាម ៧៦នាក់ ស្រី ២៨នាក់ កីឡាសូហ្វតិន្នីស ៦២នាក់ ស្រី ២៤នាក់ កីឡាតុងហ្គីលម៉ូដូ ១០៤នាក់ ស្រី ៣១នាក់ កីឡាវាយកូនឃ្លីលើតុ ១៣១នាក់ ស្រី ១៨នាក់ កីឡាអុកចត្រង្គ ៦៥នាក់ កីឡាសីដក់និងឈិនឡុង ៥៣នាក់ ស្រី ១៦នាក់ កីឡាទាញព្រ័ត្រ ១០៥នាក់ ស្រី ៥០នាក់ កីឡារាំ ៣០នាក់ ស្រី ២០នាក់ កីឡាបាល់ទះ ២១៦នាក់ ស្រី ៨៤នាក់ កីឡាចំបាប់ ៦៤នាក់ ស្រី ១៦នាក់ កីឡាប៊ូលនិងប៉េតង់ ៣៥០នាក់ ស្រី ៧០នាក់ កីឡាគុនល្បុក្កតោ ១៤៦នាក់ ស្រី ៤៦នាក់ កីឡាទូកប្រពៃណីនិងកានូកាយ៉ាក់ ៣០០នាក់ ស្រី ៦៤នាក់ កីឡាយូដូ ៥៧នាក់ ស្រី ២៥នាក់ កីឡាគុនដាវ ៣២នាក់ ស្រី ៩នាក់ កីឡាវាយកូនគោល ១៥នាក់ កីឡាវូស៊ូ ៣០នាក់ ស្រី ២០នាក់ កីឡាបាល់ទះជនពិការ ៩៣នាក់ ស្រី ៤៣នាក់ កីឡាបាញ់កាំភ្លើង ៦១នាក់ ស្រី ១៨នាក់ កីឡាវាយកូនបាល់ ៦១នាក់ ស្រី ២៨នាក់ និងកីឡាបាល់បោះ ១២០នាក់ ស្រី ៦០នាក់
- ខេត្តកែប៖ ប្រកួតកីឡាទ្រីយ៉ាត្លុងជើងឯកថ្នាក់ជាតិ កីឡាករ ៥៤នាក់ ស្រី ១៦នាក់
- ខេត្តកំពង់ធំ៖ កីឡាបេស្បូល កីឡាករ ៩១នាក់ ស្រី ៥នាក់
- ខេត្តសៀមរាប៖ កីឡាឡើងភ្នំ កីឡាករ ៧២នាក់ ស្រី ២៧នាក់ និងប្រណាំងកង់ កីឡាករ ៣១៤នាក់ ស្រី ១៩នាក់
- ខេត្តព្រះសីហនុ៖ កីឡាទូកក្តោង កីឡាករ ២៤នាក់ ស្រី ២នាក់
- ខេត្តកំពង់ឆ្នាំង៖ កីឡាបង្ហាត់ជិះសេះ កីឡាករ ១៦នាក់ ស្រី ៨នាក់
- ខេត្តកំពត៖ កីឡាម៉ូតូទឹក កីឡាករ ១២នាក់។

*ការប្រកួតកីឡាលក្ខណៈអន្តរជាតិក្នុងប្រទេស*

ក្រសួងបានបញ្ជូន៖

- គ្រូបង្វឹក កីឡាករបាល់ទះឆ្នេរខ្សាច់ ៦នាក់ ស្រី ៤នាក់ ចូលរួមប្រកួត កីឡាបាល់ទះឆ្នេរខ្សាច់អន្តរជាតិ លំដាប់ផ្កាយ ២ លើកទី៣ នៅខេត្តសៀមរាប
- ប្រតិភូ គ្រូបង្វឹក កីឡាករថ្នាល ១២នាក់ ស្រី ២នាក់ ចូលរួមប្រកួតកីឡាវាយកូនបាល់យុវជនអន្តរជាតិលើកទី១១ នៅរាជធានី
- គ្រូបង្វឹក និងកីឡាករបាល់ទះ ៦នាក់ ចូលរួមប្រកួតកីឡាបាល់ទះឆ្នេរខ្សាច់អន្តរជាតិលំដាប់ផ្កាយ២ នៅរាជធានី។

*ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិក្រៅប្រទេស*

ក្រសួងបានបញ្ជូនប្រតិភូ គ្រូបង្វឹក និងកីឡាកររទោចក្រយានថ្នាល ៧នាក់ ចូលរួមប្រកួតកីឡាកង់ភ្នំជ្រើសរើសជើងឯកទ្វីបអាស៊ីលើកទី២៦ និង ៧នាក់ ស្រី ២នាក់ ចូលរួមប្រកួតកីឡាទ្រីយ៉ាត្លុងពានរង្វាន់អិនធីធីអាស៊ាន នៅថៃ។

## *ការគាំទ្រថវិការបស់ក្រសួងដល់សហព័ន្ធកីឡាជាតិ*

ក្រសួងបានផ្តល់ថវិកាគាំទ្រដល់សហព័ន្ធកីឡាជាតិ ៤២ ដើម្បីពន្លឿនការអភិវឌ្ឍឆ្ពោះទៅឆ្នាំ២០២៣ រួមមាន សហព័ន្ធកីឡាៈ អត្តពលកម្មស្ម័គ្រចិត្ត តេក្វាន់ដូដាប៊ែលយូធី បាល់បោះ បាល់ទះ ការ៉ាតេ ប៊ូលនិងប៉េតង់ ហែលទឹក វាយកូនបាល់ កាយសម្ព័ន្ធ វាយកូនគោល ចំបាប់ ប្រដាល់សកល ទូកកានូនិងរ៉ូអ៊ីង តេក្វាន់ដូអាយធីអេហ្វ បាញ់កាំភ្លើង វាយកូនឃ្លីលើតុ យូដូ គុនដាវ វាយសី សីដក់និងឈិនឡូន វូស៊ូ អុកចត្រង្គ វ៉ូវីណាម ប្រដាល់គុនខ្មែរ គុនល្បុក្កតោ ឡើងភ្នំ សូហ្វតិនីស ទូកក្តោង បាល់ឱប សូរីនហ្សិកកាំប៉ូ ទាញព្រ័ត្រ តុងហ្គីលម៉ូដូ បាល់ទាត់ ទ្រីយ៉ាត្លុង បេស្បល ជិះសេះ ម៉ូតូទឹក ទោចក្រយាន គណៈកម្មាធិការប៉ារ៉ាឡាំពិក សហព័ន្ធកីឡាសិស្ស-និស្សិត កីឡារាំ និងជីជីតស៊ូ។

## *ការលើកកម្ពស់សកម្មភាព រៀន និងបង្រៀន អប់រំកាយក្នុងម៉ោងសិក្សា និង ហ្វឹកហាត់កីឡាក្រៅម៉ោងសិក្សា*

ក្រសួងបានៈ

- ចេញលិខិតលេខ ៤៩ អយក.សណន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយ ការប្រើប្រាស់គ្រូមុខវិជ្ជាអប់រំកាយ និងកីឡានៅគ្រឹះស្ថានមធ្យមសិក្សាឯកជន
- ចេញលិខិតលេខ ៤២ អយក.សណន ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំទិវាអប់រំកាយថ្នាក់ជាតិ រៀងរាល់ឆ្នាំ នៅតាមរាជធានី ខេត្ត និងគ្រឹះស្ថានបឋមសិក្សាទូទាំងប្រទេស
- បោះពុម្ពសៀវភៅទិវាអប់រំកាយ សម្រាប់គ្រឹះស្ថានបឋមសិក្សា ១៤ ០០០ ក្បាល
- ចងក្រងសៀវភៅគ្រូមុខវិជ្ជាអប់រំកាយ សម្រាប់មធ្យមសិក្សាទុតិយភូមិ ស្មើ ៦០ភាគរយ។

## *អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំកាយ និងកីឡា*

ក្រសួងបានៈ

- សិក្ខាសាលាពង្រឹងការអនុវត្តសៀវភៅមុខវិជ្ជាអប់រំកាយ នៅគ្រឹះស្ថានបឋមសិក្សា ដល់លោកនាយក នាយិកា នាយករង នាយិការង ១៦៦នាក់ ស្រី ៦នាក់ នៅខេត្តត្បូងឃ្មុំ ព្រៃវែង និងខេត្តពោធិ៍សាត់
- សិក្ខាសាលាណែនាំការអនុវត្តសៀវភៅមុខវិជ្ជាអប់រំកាយ នៅមធ្យមសិក្សាបឋមភូមិ នៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ មានអ្នកចូលរួម ៣០នាក់
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃ និងឧបករណ៍វាយតម្លៃ អនុវិស័យ អប់រំកាយ និងកីឡា នៅខេត្តស្វាយរៀង មានអ្នកចូលរួម ១៩នាក់ ស្រី ៣នាក់
- រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការចងក្រងសៀវភៅអប់រំកាយនៅមធ្យមសិក្សាទុតិយភូមិ ជាមួយប្រធានអង្គការបេះដូងមាស និងគ្រូឧទ្ទេសថ្នាក់ជាតិ ១១នាក់ តាមកម្មវិធីស៊្ូម
- បញ្ជូនគ្រូឧទ្ទេសថ្នាក់ជាតិមុខវិជ្ជាអប់រំកាយ ៨នាក់ ចុះសហការ និងរៀបចំបង្រៀនអប់រំកាយ នៅសាលាបឋមសិក្សាចតុមុខ
- បញ្ជូនបុគ្គលិកអប់រំបុរស ២នាក់ ចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គអាជ្ញាកណ្តាលបាល់ទាត់លើកទី២ នៅមជ្ឍមណ្ឌល និងសាលាបាល់ទាត់ជាតិបាទី
- បញ្ជូនបុគ្គលិកអប់រំបុរស ១នាក់ ចូលរួមវគ្គអាជ្ញាកណ្តាលបាល់ទាត់ក្នុងសាលថ្នាក់ជាតិ នៅមជ្ឍមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- បញ្ជូនគ្រូបង្វឹកកីឡាផ្ទាល ១នាក់ ចូលរួមសិក្ខាសាលា នៅម៉ាឡេស៊ី
- បញ្ជូនមន្ត្រី ១១នាក់ ស្រី ៣នាក់ បន្តការសិក្សាបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ នៅវៀតណាម
- បញ្ជូនមន្ត្រី ១នាក់ បន្តការសិក្សាផ្នែកគ្រប់គ្រងវិទ្យាសាស្ត្រកីឡា នៅថៃ

- បញ្ជូនមន្ត្រី ១នាក់ ទៅសិក្សាផ្នែកអប់រំកាយ នៅជប៉ុន
- បំប៉នសមត្ថភាពគ្រូអប់រំកាយ និងកីឡា មានអ្នកចូលរួម ៤០នាក់ ស្រី ១១នាក់ ក្នុងនោះមកពីខេត្តសៀមរាប ២០នាក់ ស្រី ៥នាក់ ឧត្តរមានជ័យ ១០នាក់ ស្រី ៣នាក់ ព្រះវិហារ ១០នាក់ ស្រី ៣នាក់ នៅខេត្តសៀមរាប
- បំប៉នសមត្ថភាពគ្រូអប់រំកាយនិងកីឡា មានអ្នកចូលរួម ៤០នាក់ ស្រី ៨នាក់ ក្នុងនោះមកពីខេត្តបាត់ដំបង ២០នាក់ ស្រី ៥នាក់ បន្ទាយមានជ័យ ១០នាក់ ស្រី ៣នាក់ ប៉ៃលិន ១០នាក់ នៅខេត្តបាត់ដំបង
- ប្រគល់សញ្ញាបត្រដល់គ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសអប់រំកាយ និងកីឡាជំនាន់ទី២៧ និងជំនាន់ទី២៨ ចំនួន ២៤៩នាក់ ស្រី ១៦នាក់
- ដឹកនាំគរុសិស្សហ្វឹកហាត់ត្រៀមសម្តែងនៅក្នុងកម្មវិធីបើកព្រឹត្តិការណ៍កីឡាជាតិលើកទី៣
- ដឹកនាំគរុសិស្សសម្តែងក្នុងកម្មវិធីបិទការប្រកួតកីឡាបាល់ទាត់ពានរង្វាន់ មិត្តភាពយុវជនអន្តរក្រសួង-ស្ថាប័ន នៅពហុកីឡដ្ឋានជាតិអូឡាំពិក
- រៀបចំសិក្ខាសាលាស្តីពី ភាពសមស្របនៃរាងកាយ និងអ៊ែរ៉ូប៊ិច មានគ្រូឧទ្ទេស គរុសិស្ស និងគរុនិស្សិត ចូលរួម ៣៩នាក់ ស្រី ៧នាក់ សហការជាមួយសាកលវិទ្យាល័យតូក្យូប្រទេសជប៉ុន។

### *ការកសាងលិខិតបទដ្ឋានស្តីពីការអប់រំកាយ និងកីឡា*

ក្រសួងបាន៖

- បង្កើតនាយកដ្ឋានថ្មី២ ចំណុះអគ្គនាយកដ្ឋានកីឡា តាមរយៈអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០
- កែលម្អប្រកាសអន្តរក្រសួងលេខ ៧១៦ ប្រក.សហវ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីគោលការណ៍សម្រាប់ប្រមូលផ្តុំហ្វឹកហាត់ក្រុមជម្រើសជាតិ និងការប្រកួតលក្ខណៈអន្តរជាតិផ្លូវការប្រចាំឆ្នាំ
- ចេញលិខិតលេខ ៧១១០ អយក.អកសន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីកម្មវិធីប្រកួតកីឡាសិស្ស និស្សិតជ្រើសរើសជើងឯកថ្នាក់ជាតិ
- រៀបចំបទប្បញ្ញត្តិទូទៅ និងបទបញ្ជាបច្ចេកទេស សម្រាប់ការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិ និងការប្រកួតកីឡាសាកលវិទ្យាល័យថ្នាក់ជាតិលើកទី១
- បោះពុម្ពបទប្បញ្ញត្តិទូទៅ និងបទបញ្ជាបច្ចេកទេសការប្រកួតកីឡាសិស្សបឋមសិក្សាថ្នាក់ជាតិឆ្នាំ២០២០
- ចេញលិខិតលេខ ១៦៣៥, ១៦៣៦ អយក.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពសៀវភៅទិវាអប់រំកាយសម្រាប់បឋមសិក្សា
- ចេញលិខិតលេខ ២៩៧៧ អយក.អកសន ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការផ្តល់សៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិ និងសៀវភៅអប់រំកាយសម្រាប់គ្រូពីថ្នាក់ទី៧,៨,៩ ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- រៀបចំសិក្ខាសាលាប្រមូលធាតុចូលដើម្បីរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអនុវិស័យអប់រំកាយ និងកីឡាលើកទី២ មានអ្នកចូលរួម ១១០នាក់ ស្រី ១០នាក់ នៅរាជធានី
- ព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអនុវិស័យអប់រំកាយ និងកីឡា ២លើក នៅខេត្តបន្ទាយមានជ័យ និងកំពត
- ចេញលិខិតលេខ ៤៥៥៣ អយក.អកឡ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ឱ្យរាជធានី ខេត្ត ផ្តល់ទិន្នន័យប្រជាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាព និងកីឡាប្រពៃណី
- ចេញសេចក្តីសម្រេចលេខ ៦៦ អយក.សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ អនុញ្ញាតឱ្យបង្កើតសហព័ន្ធប៊ូលីងកម្ពុជា

- ចេញប្រកាសលេខ ២២៤ អយក.ប្រករ. ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាប៊ូលីងកម្ពុជាបំពេញភារកិច្ចអាណត្តិទី១ ឆ្នាំ២០១៩-២០២៣
- ចេញសេចក្តីសម្រេចលេខ ៦៦ អយក.សសរ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យបង្កើតសហព័ន្ធកីឡាបាល់បោះរទេះជនពិការកម្ពុជា
- ចេញសេចក្តីសម្រេចលេខ ៥៩ អយក.សសរ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យបង្កើតសហព័ន្ធកីឡាប្រដាល់ឃីកបុកស៊ីងកម្ពុជា
- ចេញប្រកាសលេខ ១៩៦៧ អយក.ប្រក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាប្រដាល់ឃីកបុកស៊ីងកម្ពុជាបំពេញភារកិច្ចអាណត្តិទី១ឆ្នាំ២០២០-២០២៤
- រៀបចំកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយសហព័ន្ធកីឡាជាតិ៤២ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការអនុវត្តថវិកាគាំទ្ររបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអភិវឌ្ឍសហព័ន្ធកីឡាជាតិ
- ចេញសេចក្តីសម្រេចលេខ ៦៣ អយក.សសរ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងប្រើប្រាស់អាងហែលទឹក នៃពហុកីឡដ្ឋានជាតិ
- ចេញប្រកាសលេខ ៣០៤ អយក.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាវ៉ូវីណាមកម្ពុជា បំពេញភារកិច្ចអាណត្តិទី៣ ឆ្នាំ២០១៧-២០២១
- ចេញប្រកាសលេខ ៦៣៤ អយក.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាវូស៊ូកម្ពុជា បំពេញភារកិច្ចអាណត្តិទី៥ ឆ្នាំ២០១៧-២០២១
- ចេញប្រកាសលេខ ១០៥៤ អយក.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាលើកទម្ងន់កម្ពុជា បំពេញភារកិច្ចបន្តអាណត្តិទី១ ឆ្នាំ២០១៨-២០២២
- ចេញប្រកាសលេខ ១៩៦៦ អយក.ប្រក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាយុទ្ធក្រមខមកម្ពុជា បំពេញភារកិច្ចអាណត្តិទី២ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០០៧ អយក.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាឡើងភ្នំកម្ពុជា បំពេញភារកិច្ចអាណត្តិទី៣ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០៥៣ អយក.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាទាញព្រ័ត្រកម្ពុជា បំពេញភារកិច្ចអាណត្តិទី៤ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០០៦ អយក.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាតេក្វាន់ដូអាយធីអែហ្វកម្ពុជា បំពេញភារកិច្ចអាណត្តិទី៦ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ២៧១៩ អយក.ប្រក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិខេមរៈសហព័ន្ធតេក្វាន់ដូ បំពេញភារកិច្ចអាណត្តិទី៦ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០៥២ អយក.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាសីដក់ និងឈិនឡូនកម្ពុជា បំពេញភារកិច្ចអាណត្តិទី៧ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១៦៤៥ អយក.ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាវាយសីកម្ពុជា បំពេញភារកិច្ចអាណត្តិទី៧ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០៨០ អយក.ប្រក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាបាល់បោះកម្ពុជា បំពេញភារកិច្ចអាណត្តិទី៨ ឆ្នាំ២០២០-២០២៤

- ចេញប្រកាសអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាកាយវប្បកម្ម និងលំហាត់ប្រាណកម្ពុជាបំពេញភារកិច្ចអាណត្តិទី៣ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០៥៥ អយក.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាការ៉ាតេកម្ពុជា បំពេញភារកិច្ចអាណត្តិទី៩ ឆ្នាំ២០២០-២០២៤
- ចេញប្រកាសលេខ ១០៥៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ជ័យលាភីក្នុងការប្រកួតកីឡាតុងហ្គីលម៉ូដូ ជើងឯកពិភពលោក កីឡាប៉េតង់ជើងឯកអាស៊ី និងកីឡាវ៉ូវីណាមជើងឯកពិភពលោក
- ពិនិត្យឡើងវិញកម្មវិធីសិក្សាលម្អិត សម្រាប់ថ្នាក់បរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រឯកទេសអប់រំកាយឆ្នាំទី១ ចងក្រងកម្មវិធីសិក្សាលម្អិត និងឯកសារមេរៀន ឆ្នាំទី២ និងឆ្នាំទី៣។

*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តកីឡា*

ក្រសួងបាន៖

- ជួសជុល កែលម្អ និងថែទាំទីលានកីឡាបាល់ទាត់សាលាតម្រង់ទិស ២៥ខេត្ត រាជធានី (ក្នុងមួយរាជធានី ខេត្ត សាលាតម្រង់ទិសមួយវិទ្យាល័យ)
- ជួសជុលអគាររដ្ឋបាល ប្រព័ន្ធភ្លើង និងបន្ទប់អនាម័យនៃវិមានពហុកីឡដ្ឋានជាតិ
- ជួសជុលកែលម្អអគាររដ្ឋបាល ទីលានហ្វឹកហាត់ របងផ្នែកខាងត្បូង រៀបចំប្រព័ន្ធលូបង្ហូរទឹក ចាក់ដីបំពេញទីធ្លា បញ្ចប់ការសាងសង់ផ្លូវបេតុង ៤ខ្សែ បន្ទប់អនាម័យ និងថែទាំអាងហែលទឹក នៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុនតាមរយៈអង្គការបេះដូងមាស
- ប្រគល់ឧបករណ៍ហ្វឹកហាត់តេក្វាន់ដូឌីជីថលដល់វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា សហការជាមួយអង្គការ KOICA។

## ក.២. ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

*ការគាំទ្រនិងលើកទឹកចិត្តកីឡាករ*

ក្រសួងបាន៖

- ប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តដល់គ្រូបង្វឹក កីឡាករជ័យលាភី ៣០នាក់ ស្រី ១០នាក់ ក្នុងការប្រកួតកីឡាគុនដាវជើងឯកសកលវិទ្យាល័យអាស៊ីអាគ្នេយ៍ ការប្រកួតកីឡាការ៉ាតេជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី៨ ការប្រកួតកីឡាការ៉ាតេជ្រើសរើសជើងឯកអាស៊ីលើកទី១៨ និងការប្រកួតកីឡាគុនដាវសាកលវិទ្យា ល័យអាស៊ី
- ប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តរបស់រាជរដ្ឋាភិបាលជូនដល់គ្រូបង្វឹក កីឡាករ ២២នាក់ ស្រី ៦នាក់ក្នុងការប្រកួតកីឡាសូហ្វតិន្នីសជ្រើសរើសជើងឯកយុវជនអាស៊ីលើកទី១ នៅហ្វីលីពីន, កីឡាប៉េតង់ជ្រើសរើសជើងឯកពិភពលោក យុវជន និងស្ត្រី លើកទី១៧ នៅរាជធានី, កីឡាតេក្វាន់ដូ ITF ជ្រើសរើសជើងឯកពិភពលោកលើកទី១៤ សម្រាប់យុវជនថ្នាលនិងលើកទី២១ ឈុតធំនៅប៊ុលហ្គារី, កីឡាសូហ្វតិន្នីសជ្រើសរើសជើងឯកវិទ្យាល័យអាស៊ីលើកទី១ នៅហ្វីលីពីន, កីឡាអត្តពលកម្មជនពិការជ្រើសរើសជើងឯកនៅសាធារណរដ្ឋប្រជាមានិតចិន
- ប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តរបស់រាជរដ្ឋាភិបាលជូនដល់គ្រូបង្វឹក កីឡាករ ៤នាក់ ស្រី ១នាក់ ក្នុងការប្រកួតកីឡាតុហ្គីលម៉ូដូសជ្រើសរើសជើងឯកពិភពលោក នៅសាធារណរដ្ឋកូរ៉េ កីឡាប៉េតង់ ១៤នាក់ ស្រី ២នាក់ ការប្រកួតជ្រើសរើសជើងឯកអាស៊ី នៅសាធារណរដ្ឋសង្គមនិយមវៀតណាម កីឡាវ៉ូវីណាម ២៦នាក់ ស្រី ៩នាក់ ការប្រកួតជ្រើសរើសជើងឯកអាស៊ី នៅវៀតណាម។

### *ការលើកកម្ពស់សមត្ថភាពគ្រូបង្វឹក និងកីឡាករ*

ក្រសួងបាន៖

- ប្រមូលផ្តុំ គ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករថ្នាល ៥០៩នាក់ ស្រី ១០៨នាក់ លើ ៣២ ប្រភេទកីឡា មកធ្វើការហ្វឹកហាត់បង្កើនសមត្ថភាពបច្ចេកទេសត្រៀមលក្ខណៈឆ្ពោះទៅស៊ីហ្គេមឆ្នាំ២០២៣
- ប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករជម្រើសជាតិ ៥០៩នាក់ ស្រី ១០៤នាក់ លើ ៣៣ប្រភេទកីឡា និង ១ប្រភេទកីឡាជនពិការ មកធ្វើការប្រមូលផ្តុំរយៈពេល ០៩ខែ ១៦ថ្ងៃ ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣១ ឆ្នាំ២០២១ នៅវៀតណាម និងចូលរួមការប្រកួតជាលក្ខណៈអន្តរជាតិនានា
- បញ្ជូនកីឡាករវាយសីថ្នាល ១នាក់ កីឡាករហែលទឹក ១នាក់ ទៅហ្វឹកហាត់ នៅថៃ
- បញ្ជូនកីឡាករជីជីតស៊ូថ្នាល ២នាក់ ស្រី ១នាក់ ទៅហ្វឹកហាត់ នៅសហរដ្ឋអាមេរិក
- បញ្ជូនគ្រូបង្វឹក គ្រូជំនួយ កីឡាករម៉ូតូទឹក ៩នាក់ ទៅហ្វឹកហាត់នៅថៃ កីឡាករប្រដាល់សកល ១នាក់ ទៅហ្វឹកហាត់នៅវៀតណាម កីឡាការិនីតេក្វាន់ដូដាប់ប៊ែលយូជី ១នាក់ ទៅហ្វឹកហាត់នៅសហរដ្ឋអាមេរិក កីឡាករហែលទឹក ១នាក់ ទៅហ្វឹកហាត់នៅថៃ និងកីឡាករជិះសេះ ៤នាក់ ស្រី ២នាក់ ទៅហ្វឹកហាត់នៅសាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងថៃ
- បញ្ជូនគ្រូបង្វឹក គ្រូជំនួយក្រុមកីឡាថ្នាល ៧៥នាក់ ស្រី ៦នាក់ ចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការ និងទ្រឹស្តីហាត់ហ្វឹកហ្វឺន
- បញ្ជូនមន្ត្រី ១០នាក់ ស្រី ១នាក់ ចូលរួមវគ្គសិក្សាពិសេសលើការប្រើប្រាស់ឧបករណ៍ហ្វឹកហាត់ជំនួយសាច់ដុំ
- បញ្ជូនគ្រូបង្វឹកជម្រើសជាតិ ៧៥នាក់ ស្រី ៩នាក់ ចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការ និងទ្រឹស្តីហាត់ហ្វឹកហ្វឺន
- បញ្ជូនកីឡាករទ្រើយ៉ាត្តុងថ្នាល និងជម្រើសជាតិ ២០នាក់ ស្រី ៧នាក់ ទៅធ្វើតេស្តបច្ចេកទេស នៅខេត្តកែប។

### *ការងារបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា*

ក្រសួងបាន៖

- ប្រឡងបញ្ចប់ការសិក្សារបស់គរុសិស្សជំនាន់ទី២៨ ចំនួន ១៤៩នាក់ ស្រី ១១នាក់
- ចុះអង្កេតគ្រូបង្រៀនថ្នាក់បរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រឯកទេសអប់រំកាយ
- បង្ហាត់បង្រៀនគរុសិស្ស គរុនិស្សិតតាមប្រព័ន្ធអេឡិចត្រូនិកដោយប្រើប្រាស់កម្មវិធី Zoom និងTelegram
- រៀបចំកម្មវិធីសិក្សាលម្អិត និងចងក្រងឯកសារមេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រសិល្បៈមនុស្សសាស្ត្រឯកទេសអប់រំកាយឆ្នាំទី២ និងឆ្នាំទី៣ ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលបេះដូងមាស។

### *ការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងការពិនិត្យតាមដាន*

ក្រសួងបាន៖

- ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពអប់រំកាយក្នុងម៉ោងសិក្សា នៅខេត្តពោធិ៍សាត់ សៀមរាប ឧត្តរមានជ័យ ព្រៃវែង បាត់ដំបង កំពង់ស្ពឺ កែប កំពត តាកែវ ស្ទឹងត្រែង ក្រចេះ រតនគិរី បន្ទាយមានជ័យ និងប៉ៃលិន
- ពិនិត្យតាមដានសកម្មភាពអប់រំកាយ កម្រិតមធ្យមសិក្សាបឋមភូមិ នៅសាលាគោលដៅ ១០ នៅខេត្តបាត់ដំបង ស្វាយរៀង និងរាជធានី សហប្រតិបត្តិការជាមួយអង្គការបេះដូងមាស

- ចុះពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពហាត់ប្រាណនិងលេងកីឡាដើម្បីសុខភាព ធ្វើតេស្តសូចនាករនៃសុខភាពរាងកាយប្រជាជនអាស៊ាន ស្រង់ទិន្នន័យអ្នកហាត់ប្រាណ និងលេងកីឡា ៥០០នាក់ ស្រី ២៥០នាក់ នៅខេត្តកំពង់ចាម ព្រៃវែង រតនគិរី ព្រះវិហារ និងស្ទឹងត្រែង
- ប្រជុំបូកសរុបការងារអនុវិស័យអប់រំកាយ និងកីឡា ឆ្នាំសិក្សា២០១៨-២០១៩ និងលើកទិសដៅឆ្នាំសិក្សា ២០១៩-២០២០ មានអ្នកចូលរួម ៣១៥នាក់ ស្រី ១៥នាក់ នៅរាជធានី
- ចុះយកព័ត៌មានស្តីពីសកម្មភាពអប់រំកាយនិងកីឡា និងតាមដានការប្រើប្រាស់ទស្សនាវដ្តីកីឡា នៅខេត្តកែប និងសៀមរាប
- ពិនិត្យតាមដាន និងកែលម្អការបង្ហាត់បង្រៀនរបស់គ្រូអប់រំកាយ និងកីឡា តាមគ្រឹះស្ថានមធ្យមសិក្សា នៅខេត្តប៉ៃលិន រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ត្បូងឃ្មុំ និងកំពង់ធំ
- ធ្វើសម្រង់តម្រូវការគ្រូអប់រំកាយ និងកីឡា២៥ ខេត្ត រាជធានី
- ស្រង់ទិន្នន័យព័ត៌មានគ្រូអប់រំកាយ និងកីឡា នៅខេត្តកំពត ពោធិ៍សាត់ កំពង់ធំ បាត់ដំបង កោះកុង ក្រចេះ កំពង់ចាម តាកែវ សៀមរាប រតនគិរី មណ្ឌលគិរី ប៉ៃលិន និងព្រះវិហារ
- ពិនិត្យតាមដានការចុះធ្វើកម្មសិក្សារបស់គរុសិស្សជំនាន់ទី២៨ នៅរាជធានី និងធ្វើរបាយការណ៍ឆ្លើយតប
- ពិនិត្យតាមដានការបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញ និងធ្វើរបាយការណ៍វត្តមាន
- វាយតម្លៃការចុះកម្មសិក្សារបស់គរុនិស្សិតឯកទេសអប់រំកាយ និងកីឡា ១០នាក់ ស្រី ១នាក់ មកពីវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

### ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច

| | សូចនាករ | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ៖ បង្កើនលទ្ធភាពទទួលបានការអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍ | | | | | | |
| ១. | ទីលានកីឡា៥កន្លែងត្រូវបានកែលម្អ | | | | | |
| | *សៀមរាប* | % | ០ | ៦០,០ | ០ | ↓ |
| | *កំពត* | % | ០ | ៦០,០ | ០ | ↓ |
| | *កំពង់ចាម* | % | ០ | ៦០,០ | ០ | ↓ |
| | *បាត់ដំបង* | % | ០ | ៦០,០ | ០ | ↓ |
| | *ភ្នំពេញ* | % | ៧០,០ | ៨០,០ | ០ | ↓ |
| ២. | សាលាបឋមសិក្សាអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | % | ៧៩,០ | ៨៦,០ | ៨០ | → |
| ៣. | សាលាមធ្យមសិក្សាអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | % | ៥០,០ | ៥៤,០ | ៥២ | → |
| ៤. | មេដាយក្នុងការប្រកួតអន្តរជាតិក្នុងមួយឆ្នាំ | ចំនួន | ១៤៦ | ៤៩២ | ០ | ↓ |
| ៥. | ប្រជាជនចូលរួមសកម្មភាពអប់រំកាយ និងកីឡា | % | ២១,០ | ១៦,៦ | ១៥,៩ | → |
| វត្ថុបំណងអនុវិស័យទី២ ៖ លើកកម្ពស់គុណផលក្រុមកីឡាជម្រើសជាតិ ដើម្បីដណ្តើមមេដាយមាសឱ្យបានច្រើននៅឆ្នាំ២០២៣ | | | | | | |
| ៦. | ចំណាត់ថ្នាក់ស៊ីហ្គេមនៅក្នុងប្រទេសអាស៊ាន | ចំណាត់ថ្នាក់ | ៨ | | ០ | ↓ |
| ៧. | មេដាយមាសស៊ីហ្គេម ២០២៣ | ចំនួន | ៤៦ * | ២៨ | ០ | ↓ |
| គោលនយោបាយទី ២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | |

| សូចនាករ | | ឯកតា | ជាក់ស្តែង ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ជាក់ស្តែង ២០២០-២១ | ស្ថានភាព |
|---|---|---|---|---|---|---|
| វត្ថុបំណងអនុវិស័យទី ៣៖ អភិវឌ្ឍស្ថាប័ន អ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡាប្រកបដោយប្រសិទ្ធភាព និងគុណភាព | | | | | | |
| ៨. | កីឡាករ កីឡាការិនីបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ (រយៈពេលវែង) | ចំនួន | ៥០០ | ៩៣ | ៥០៩ | ↑ |
| ៩. | គរុសិស្សបានទទួលការបណ្តុះបណ្តាលអប់រំកាយ និងកីឡាក្នុងមួយឆ្នាំ | ចំនួន | ១៥០ | ១៣០ | ០ | ↓ |
| ១០. | គ្រូបង្វឹកបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ១ ១៧៨ | ១ ២០៦ | ៤១៤ | ↓ |
| ១១. | ចៅក្រមនិងអាជ្ញាកណ្តាលបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៥៩៩ | ១ ២៤០ | ៤៩៧ | ↓ |
| ១២. | គ្រូបង្វឹកបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកីឡា ផែនការយុទ្ធសាស្ត្រ និងការគ្រប់គ្រង | ចំនួន | ១៦៥ | ២៣៣ | ១៦៨ | → |
| ១៣. | គ្រូអប់រំកាយនិងកីឡាបានទទួលការបណ្តុះបណ្តាល(វគ្គខ្លី/វិក្រឹត្យការ) | ចំនួន | ២១០ | ២៨៨ | ៨០ | ↓ |
| ១៤. | មន្ត្រីកីឡាបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ១០ | ២៨៨ | ២៧០ | → |
| ១៥. | អត្តពលិកកម្រិតខ្ពស់ | ចំនួន | ៥០៤ | ៨៨៣ | ៥០៩ | → |

<u>សម្គាល់</u>៖ ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ សម្រេចមិនបានតាមចំណុចដៅ

*មេដាយការប្រកួតកីឡាស៊ីហ្គេមលើកទី៣០ ឆ្នាំ២០១៩

## គ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា ៖

- ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាអប់រំកាយ នៅតាមគ្រឹះស្ថានសិក្សាមួយចំនួនពុំទាន់បានពេញលេញ២ម៉ោង/១សប្តាហ៍
- កង្វះមន្ត្រីបច្ចេកទេសជំនាញតាមប្រភេទកីឡាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលកម្រិតអន្តរជាតិ
- ប្រជាជនចូលរួមហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពនៅមានកម្រិត
- ខ្វះមន្ត្រីវេជ្ជសាស្ត្រកីឡា ក្នុងការថែទាំ សុខភាព ព្យាបាល របបអាហារ និងប្រយុទ្ធប្រឆាំងសារធាតុដូប៉ាក្នុងវិស័យកីឡា
- ខ្វះមន្ត្រីជំនាញបច្ចេកទេសកីឡា សម្រាប់សិក្សាស្រាវជ្រាវ តាមដាន និងវិភាគគុណផលនៃការហាត់ហ្វឹកហ្វឺន
- ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់បង្រៀន និងបង្ហាត់មិនទាន់ឆ្លើយតប
- ធនធានមនុស្សក្នុងអង្គភាពមិនទាន់ឆ្លើយតបទៅនឹងតម្រូវការក្នុងការបំពេញការងារតាមជំនាញ។

## ៣. ទិសដៅឆ្នាំសិក្សា ២០២០-២០២១

ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ទាំងបញ្ហាប្រឈមតាមអនុវិស័យ និងបញ្ហាប្រឈមជាលក្ខណៈអន្តរអនុវិស័យ និងផ្អែកលើបទពិសោធកន្លងមក ក្រសួងអប់រំ យុវជន និងកីឡា នឹងជំរុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនតាមទិសដៅដូចខាងក្រោម ៖

### ៣.១ ទិសដៅតាមអនុវិស័យ

#### *៣.១.១ អនុវិស័យ ការអប់រំកុមារតូច*

- កំណត់គោលនយោបាយ គោលការណ៍ និងទិសដៅក្នុងការគ្រប់គ្រងតាមសាលារៀនសម្រាប់មត្តេយ្យសិក្សាឱ្យបានច្បាស់លាស់
- រៀចំយន្តការគាំទ្រសម្រាប់ការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ជាឧបសម្ព័ន្ធគ្រឹះស្ថានសិក្សាសាធារណៈ
- វិនិយោគសេវាអប់រំកុមារតូចប្រកបដោយសមធម៌ និងបរិយាបន្ន
- ពង្រឹងកិច្ចសហការ និងសម្របសម្រួលអន្តរវិស័យស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- សិក្សារៀបចំក្របខណ្ឌយុទ្ធសាស្ត្រកំណែទម្រង់សម្រាប់អនុវិស័យអប់រំកុមារតូចស្របតាមបរិបទនិងនិន្នាការសកល
- ពង្រឹងការអនុវត្តកម្មវិធីសិក្សាបង្រួញនិងការអបរំតាមគន្លងថ្មីសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សានិងសេវាអប់រំកុមារតូច
- ពង្រឹងការអនុវត្តគោលការណ៍ណែនាំលក្ខខណ្ឌអប្បរមារស្តីពីទឹកស្អាត និងអនាម័យនៅតាមសាលាមត្តេយ្យសិក្សាគ្រប់រូបភាព។

#### *៣.១.២ អនុវិស័យ ការអប់រំបឋមសិក្សា*

- ពង្រីកវិសាលភាពនៃការអនុវត្ត ការគ្រប់គ្រងតាមសាលារៀនឱ្យបានទូលំទូលាយ
- ផ្គត់ផ្គង់គ្រូបង្រៀននៅតាមសាលារៀនដាច់ស្រយាលនិងជួបការលំបាក
- ពង្រាយគ្រូបង្រៀនពីសាលារៀនលើស ទៅសាលារៀនខ្វះគ្រូបង្រៀនតាមស្ថានភាពជាក់ស្តែង
- ពង្រឹងការប្រើប្រាស់គ្រូបង្រៀនថ្នាក់ទី១និងទី២ និងបណ្ណារក្ស
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើចំណេះដឹង វិធីសាស្រ្តបង្រៀន បទពិសោធ ការគ្រប់គ្រងថ្នាក់រៀន
- ពង្រឹងការគ្រប់គ្រងស្ថិតិ និងទិន្នន័យសិស្សអាហារូបករណ៍
- ផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធនិងឧបករណ៍អេឡិចត្រូនិក
- ផ្គត់ផ្គង់ទឹកស្អាត បង្គន់អនាម័យ ការប្រើប្រាស់និងថែទាំបង្គន់អនាម័យ សម្ភារៈអនាម័យ ជាពិសេសសម្ភារៈដែលបម្រើឱ្យការលាងសម្អាតដៃ សម្ភារៈម្ងាប់មេរោគ និងឯកសារអប់រំសុខភាពនៅតាមសាលារៀន
- អនុវត្តកម្មវិធីទន់ភ្លន់ បត់បែន ដោយប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងវិធីចម្រុះ
- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តវង្វាយតម្លៃថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀនឱ្យឆ្លើយតបនឹងប្រធានបទតេស្តវង្វាយតម្លៃសិស្សកម្មវិធីតំបន់ អន្តរជាតិ ទាំងវង្វាយតម្លៃតាមដំណាក់កាល និងវង្វាយតម្លៃសរុប
- បញ្ចូលការអនុវត្តវង្វាយតម្លៃថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន ឱ្យឆ្លើយតបនឹងប្រធានបទតេស្តវង្វាយតម្លៃសិស្សកម្មវិធីតំបន់ អន្តរជាតិ ទាំងវង្វាយតម្លៃតាមដំណាក់កាល និងវង្វាយតម្លៃសរុប ទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅតាមសាលាគរុកោសល្យ
- បញ្ចូលកម្មវិធីភាសាខ្មែរ (អាន-សរសេរ) និងគណិតវិទ្យាថ្នាក់ដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន នៅតាមសាលាគរុកោសល្យ

- បង្កើតកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនថ្នាក់អប់រំពហុភាសានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង
- ពង្រឹងនិងពង្រីកការអនុវត្តវិធីសាស្ត្របង្រៀនអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង
- ពង្រឹងវិធីសាស្ត្របង្រៀននិងរៀនតាមគោលវិធីស្វែម លើមុខវិជ្ជាគណិវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម
- ពង្រឹងសមត្ថភាពការបង្រៀននិងរៀនភាសាអង់គ្លេសថ្នាក់ទី៤ដល់ទី៦
- អភិវឌ្ឍសមត្ថភាពមន្ត្រី ភាពជាអ្នកដឹកនាំសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ ដល់គណៈគ្រប់គ្រងសាលារៀន។

## ៣.១.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

- អភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រងសាលារៀនឱ្យមានសមត្ថភាពពេញលេញ
- ជំរុញ និងគាំទ្រសាលារៀនមួយចំនួនឱ្យមានលទ្ធភាពអនុវត្តកម្មវិធីអប់រំគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិស្វកម្ម
- ពង្រីកវិសាលភាពគាំទ្រតម្រូវការមូលដ្ឋានដល់ការអប់រំបរិយាបន្ន
- រៀបចំបុរេលក្ខខណ្ឌឱ្យបានពេញលេញក្នុងការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- បំប៉នសមត្ថភាពបរិច្ចការីក្នុងការគ្រប់គ្រងបន្ទប់ពិសោធន៍
- ជំរុញកិច្ចសហការជិតស្និទ្ធជាមួយផ្នែកឯកជនដើម្បីអាចផ្ដល់ការគាំទ្រតាមតម្រូវការជាក់ស្ដែងរបស់សាលារៀនក្នុងការរៀបចំកម្មវិធីសិក្សា ការចុះកម្មសិក្សា និងទស្សនកិច្ចសិក្សា
- ពង្រឹងកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីអប់រំបំណិនជីវិតឱ្យបានល្អ
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ឧបករណ៍ពិសោធន៍ គរុកោសល្យ និងវិធីសាស្ត្របង្រៀនថ្មី
- អភិវឌ្ឍសមត្ថភាពមន្ត្រីបច្ចេកទេសផ្នែកបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ដើម្បីធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបុគ្គលិក និងគរុសិស្សនៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន
- ផ្ដល់មន្ត្រីជំនាញបច្ចេកទេសផ្នែកប្រព័ន្ធគ្រប់គ្រងការរៀនពីចម្ងាយ
- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ សម្រាប់ដំណើរការកិច្ចការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- រៀបចំរចនាសម្ព័ន្ធ និងមន្ត្រីទទួលបន្ទុកសុខភាពសិក្សានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យឆ្លើយតបទៅនឹងតម្រូវការការងារជាក់ស្ដែង។

## ៣.១.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

- រៀបចំគោលនយោបាយថ្មីស្ដីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងអនុវិស័យឧត្តមសិក្សា និងផែនការយុទ្ធសាស្ត្រថវិកាគ្រប់ជ្រុងជ្រោយ តាមរយៈការបង្កើតមូលនិធិស្រាវជ្រាវសម្រាប់ឧត្តមសិក្សា និងគោលការណ៍អនុវត្ត
- ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យបែបឌីជីថលលើស្នាដៃស្រាវជ្រាវ និងការបណ្ដុះបណ្ដាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- អភិវឌ្ឍសមត្ថភាពនិងបទពិសោធក្នុងការសរសេរអត្ថបទស្រាវជ្រាវសម្រាប់បោះពុម្ពក្នុងទស្សនាវដ្ដីស្រាវជ្រាវ
- ជំរុញដំណើរការផ្ដល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស
- រៀបចំប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សាឱ្យដំណើរការបានល្អប្រសើរ។

### ៣.១.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

- អនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យបានទូលំទូលាយ
- រៀបចំឯកសារបណ្តុះបណ្តាលគ្រូបង្រៀនកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធតាមប្រព័ន្ធក្រេឌីត
- រៀបចំមន្ត្រីដឹកនាំ និងគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដាច់ដោយឡែក
- ជំរុញដំណើរការប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- អនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលនៅទូទាំងប្រទេស
- បណ្តុះបណ្តាលមន្ត្រីអប់រំក្រៅប្រព័ន្ធលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ
- អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនៅកម្រិតក្រុង ស្រុក ខណ្ឌ
- អភិវឌ្ឍផែនការសកម្មភាពជាតិ និង លើកកម្ពស់ការយល់ដឹងស្តីពីការសិក្សាពេញមួយជីវិត
- អភិវឌ្ឍកម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិអប់រំក្រៅប្រព័ន្ធ
- លើកកម្ពស់ការសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់កម្មវិធីអក្ខរកម្ម កម្មវិធីសមមូលបឋមសិក្សា និងសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ។

### ៣.១.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

- បន្តធ្វើទំនើបកម្មផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីជំរុញកម្មវិធីអភិវឌ្ឍយុវជនបែបឌីជីថល ឱ្យឆ្លើយតបទៅនឹងការអប់រំបែបឌីជីថល និងការសិក្សាក្នុងបរិបទថ្មី
- ធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំ និងសៀវភៅក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ជាពិសេសសេចក្តីណែនាំស្តីពីការបង្កើតក្លឹបជដែកជេញដោលនៅតាមសាលារៀនក្នុងរាជធានី និងការពង្រឹងក្លឹបសិក្សានៅតាមសាលារៀនរាជធានី ខេត្ត
- ពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃ តាមរយៈការធ្វើបញ្ចប់សេចក្តីព្រាងក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃអនុវិស័យការអភិវឌ្ឍយុវជន
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូ និងវិស័យឯកជន ដើម្បីកៀរគរការគាំទ្រកម្មវិធីបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលយុវជន
- បង្កើនកិច្ចសហប្រត្តិបត្តិការជាមួយអង្គការពិភពលោកនៃចលនាកាយរឹទ្ធិ អង្គការដៃគូ សហគមន៍ និងវិស័យឯកជនដើម្បីកៀរគរការគាំទ្រការពង្រីកសមាជិកភាពកាយរឹទ្ធិ
- បន្តពង្រឹង និងអភិវឌ្ឍសមត្ថភាពមន្ត្រី តាមរយៈការបង្កើតកម្មវិធីសិក្សា និងការបណ្តុះបណ្តាលផ្ទៃក្នុងតាមបែបឌីជីថល ដោយប្រើប្រាស់បន្ទប់រៀនអនឡាញលើមុខជំនាញមួយចំនួនដូចជា ១-រៀបចំផែនការ និងអភិវឌ្ឍកម្មវិធី ២-អភិវឌ្ឍកម្មវិធីយុវជននិងគ្រប់គ្រងព្រឹត្តិការណ៍ ៣-កិច្ចការរដ្ឋបាលនិងរបាយការណ៍៤-កុំព្យូទ័ររដ្ឋបាល និងការិយាល័យ ៥-ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ៦-ភាពជាអ្នកដឹកនាំនិងឥរិយាបថគ្រប់គ្រង ៧-កិច្ចការហិរញ្ញវត្ថុសាធារណៈ។

### ៣.១.៧ អនុវិស័យការអប់រំកាយ និងកីឡា

- ពង្រឹងការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាអប់រំកាយនៅគ្រប់គ្រឹះស្ថានសិក្សាឱ្យបានពេញលេញ២ម៉ោង/១សប្តាហ៍
- បំផុស និងជំរុញប្រជាជនឱ្យចូលរួមហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាព
- បណ្តុះបណ្តាលមន្ត្រីបច្ចេកទេស វេជ្ជសាស្ត្រកីឡា និងការប្រយុទ្ធប្រឆាំងសារធាតុដូប៉ាក្នុងវិស័យកីឡា

- ពង្រឹងការប្រមូលផ្តុំក្រុមជម្រើសជាតិក្នុងការចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣១ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងការប្រកួតលក្ខណៈអន្តរជាតិនានា
- បន្តការជួសជុល កែលម្អ ថែទាំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា
- បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា និងអភិវឌ្ឍសមត្ថភាពមន្ត្រី
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ពង្រឹងគុណភាពនៃការរៀបចំប្រកួតកីឡាជាតិ និងអន្តរជាតិ
- រៀបចំសិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយទិន្នន័យព័ត៌មានកីឡា។

## ៣.២ បញ្ហាប្រឈម និងទិសដៅកំណែទម្រង់ឆ្លងអនុវិស័យ

### *៣.២.១ ការពង្រឹងការងារគោលនយោបាយ ផែនការ ស្ថិតិ និងការពិនិត្យតាមដាននិងវាយតម្លៃ*

*បញ្ហាប្រឈម*

- កង្វះទិន្នន័យ និងសូចនាករអប់រំពាក់ព័ន្ធនឹងសមធម៌ បរិយាបន្ន ដែលជាទិន្នន័យបែបគុណវិស័យសម្រាប់រៀបចំគោលនយោបាយ និងផែនការអប់រំ
- កង្វះការសិក្សាស្រាវជ្រាវពីបញ្ញត្តិ និងគោលការណ៍ថ្មីៗនៃកំណែទម្រង់អប់រំក្នុងតំបន់ និងពិភពលោកដែលជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយអប់រំ
- លទ្ធផលស្រាវជ្រាវ និងទិន្នន័យអប់រំ មិនទាន់ត្រូវបានប្រើក្នុងការរៀបចំគោលនយោបាយ និងផែនការអប់រំ
- មិនទាន់មានក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តគោលនយោបាយ និងកំណែទម្រង់អប់រំ
- ការអនុវត្តគោលនយោបាយអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមានកម្រិត
- កង្វះឧបករណ៍ និងសម្ភារបច្ចេកទេសព័ត៌មានវិទ្យាទាំងផ្នែកទន់ និងផ្នែករឹងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- គម្លាតរវាងគោលនយោបាយ និងថវិកាគាំទ្រការអនុវត្តគោលនយោបាយអប់រំ។

*ទិសដៅ*

- បង្កើនការប្រមូលទិន្នន័យ និងសូចនាករអប់រំពាក់ព័ន្ធនឹងសមធម៌ បរិយាបន្ន ដែលជាទិន្នន័យបែបគុណវិស័យសម្រាប់រៀបចំគោលនយោបាយ និងផែនការអប់រំ
- លើកកម្ពស់ការសិក្សាស្រាវជ្រាវពីបញ្ញត្តិ និងគោលការណ៍ថ្មីៗនៃកំណែទម្រង់អប់រំក្នុងតំបន់ និងពិភពលោកដែលជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយអប់រំ
- ជំរុញការប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងទិន្នន័យអប់រំ ក្នុងការរៀបចំគោលនយោបាយ និងផែនការអប់រំ
- អភិវឌ្ឍក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ការអនុវត្តគោលនយោបាយ និងកំណែទម្រង់អប់រំ
- ពង្រីកវិសាលភាពការអនុវត្តគោលនយោបាយអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យបានទូលំទូលាយ
- បំពាក់ឧបករណ៍ និងសម្ភារបច្ចេកទេសព័ត៌មានវិទ្យាទាំងផ្នែកទន់ និងផ្នែករឹងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បន្សុីថវិកាផ្សារភ្ជាប់ទៅនឹងការអនុវត្តគោលនយោបាយអប់រំ
- អភិវឌ្ឍសមត្ថភាពអង្គភាពឱ្យសមស្របតាមតួនាទី និងភារកិច្ច។

### *៣.២.២ ការងារវិមជ្ឈការ និងវិសហមជ្ឈការ*

*បញ្ហាប្រឈម*

- លិខិតបទដ្ឋានដែលបានគ្រោងរៀបចំនៅក្នុងផែនការកសាងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៩-២០២៣) មិនទាន់បានសម្រេចតាមការគ្រោងទុក

- ការអនុវត្តសកម្មភាពមិនស្របតាមផែនការគ្រោងទុកដោយសារស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩
- កង្វះធនធានសម្រាប់គាំទ្រកិច្ចដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

*ទិសដៅ*

- ជំរុញការរៀបចំលិខិតបទដ្ឋានដែលបានគ្រោងរៀបចំនៅក្នុងផែនការកសាងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៩-២០២៣) ឱ្យបានសម្រេចតាមការគ្រោងទុក
- រៀបចំផែនការសកម្មភាពដែលបានគ្រោងទុកដោយភាពទន់ភ្លន់បត់បែន
- ផ្តល់ធនធានសម្រាប់គាំទ្រកិច្ចដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

### *៣.២.៣ ការងារគ្រប់គ្រងបុគ្គលិក*

ទិសដៅ

- បន្តសិក្សាអំពីការរៀបចំយន្តការដើម្បីពិនិត្យនិងកំណត់ឡើងវិញអង្គភាព និងសាលារៀនស្ថិតនៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក
- បន្តចូលរួមនិងជំរុញការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា លើសកម្មភាពពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស
- ចូលរួមអនុវត្តសាកល្បងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន និងគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ពិនិត្យឡើងវិញ និងបន្តជំរុញការអនុវត្តគោលការណ៍ស្តីពីរង្វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ
- ពង្រីកសមត្ថភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ដើម្បីកត់ត្រាទិន្នន័យបុគ្គលិកឱ្យបានគ្រប់គ្រាន់ ព្រមទាំងផ្តល់លទ្ធភាពឱ្យបុគ្គលិកអប់រំអាចចូលមើលទិន្នន័យរបស់ខ្លួនបាន
- ពង្រឹងការបែងចែកផែនការក្របខណ្ឌឆ្នាំ២០២១ និងបញ្ជូនគ្រូបង្រៀនចេញថ្មីឱ្យទៅដល់សាលារៀនគោលដៅ។

### *៣.២.៤ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

*បញ្ហាប្រឈម*

- ការធ្វើវិចារណកម្មចំណាយ និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តថវិកាតាមសារាចរលេខ ០០១ និង ០០៣ បានកាត់បន្ថយឥណទានថវិកាឆ្នាំ២០២០ និងតម្រូវឱ្យកែសម្រួលតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន និងផែនការលទ្ធកម្ម ព្រមទាំងត្រូវលុបចោលគោលការណ៍ជានាចំណាយមួយចំនួនដែលបានរៀបចំ ស្នើសុំរួចជាហេតុធ្វើឱ្យប៉ះពាល់ខ្លាំងដល់ការអនុវត្តសកម្មភាពអាទិភាពរបស់ក្រសួង
- ការផ្តល់សិទ្ធិអំណាចឱ្យមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡានៅមានកម្រិតដែលជះឥទ្ធិពលដល់ពេលវេលាក្នុងការអនុវត្តផែនការសកម្មភាព និងការទូទាត់ថវិកា
- ការចូលរួមអនុវត្តថវិការបស់ប្រធានកម្មវិធី និងប្រធានអនុកម្មវិធីនៅមានកម្រិតដោយត្រូវពង្រឹងការពិនិត្យតាមដាន និងការអនុវត្តទៅតាមកម្មវិធីចំណាយ និងសូចនាករគោលដៅ
- ចំណេះដឹង សមត្ថភាពពាក់ព័ន្ធនឹងការគ្រោងថវិកា ការប្រើប្រាស់កុំព្យូទ័រ នីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យារបស់មន្ត្រីនៅតាមអង្គភាព និងសាលារៀននៅមានកម្រិត
- ការអនុវត្តថវិកានៅអង្គភាពថ្នាក់កណ្តាលមិនទាន់សម្រេចបានតាមគោលដៅសូចនាករដែលបានកំណត់
- ការយល់ដឹង និងអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈរបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុតាមសាលារៀននៅមានកម្រិត

- មិនទាន់មានប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- អង្គភាពមួយចំនួនមិនទាន់បានសម្រួចសកម្មភាពឱ្យបន្សុីទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ឥណទានថវិកាប្រចាំឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា មិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅ ២០ភាគរយ ធៀបចំណាយចរន្តជាតិ
- អង្គភាពដែលស្ថិតក្នុងកម្មវិធីទី៥ ជាកម្មវិធីការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ ភាគច្រើនមានការលំបាកក្នុងការវិភាជថវិកាតាមអនុវិស័យ។

## ទិសដៅ

- កសាងភាពធន់ និងភាពទន់ភ្លន់បត់បែនតាមសភាពការណ៍ជាក់ស្តែងដោយសហការជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- ពិនិត្យឡើងវិញសិទ្ធិអំណាចមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡាក្នុងការអនុវត្តផែនការសកម្មភាព និងការទូទាត់ថវិកា
- ពង្រឹងការពិនិត្យតាមដាន និងការអនុវត្តតាមកម្មវិធីចំណាយ និងសូចនាករគោលដៅក្នុងការអនុវត្តថវិការបស់ប្រធានកម្មវិធី និងប្រធានអនុកម្មវិធី
- អភិវឌ្ឍចំណេះដឹង សមត្ថភាពពាក់ព័ន្ធនឹងការគ្រោងថវិកា ការប្រើប្រាស់កុំព្យូទ័រ នីតិវិធីហិរញ្ញវត្ថុ និងការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា របស់មន្ត្រីនៅតាមអង្គភាព និងសាលារៀនសាធារណៈ
- ជំរុញការអនុវត្តថវិកានៅអង្គភាពថ្នាក់កណ្តាលឱ្យសម្រេចបានតាមគោលដៅសូចនាករដែលបានកំណត់
- ពង្រឹងការយល់ដឹងនិងអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈរបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុតាមសាលារៀន
- អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- សម្រួចសកម្មភាព និងសូចនាករតាមអង្គភាពឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- សម្រួចសកម្មភាពអាទិភាពឆ្លើយតបនឹងកំណែទម្រង់ និងបរិបទអប់រំឌីជីថល ដើម្បីកៀរគរនិងបង្កើនថវិកាប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបនឹងសូចនាករគោលដៅ ២០ភាគរយធៀបចំណាយចរន្តជាតិ
- អភិវឌ្ឍសមត្ថភាពសិក្សា និងវិភាគការវិភាជថវិកាតាមអនុវិស័យក្នុងអង្គភាពដែលស្ថិតក្នុងកម្មវិធីទី៥
- រៀបចំនីតិវិធីបើកផ្តល់អាហារូបករណ៍គរុសិស្ស គរុនិស្សិតតាមប្រព័ន្ធធនាគារ
- ផ្សព្វផ្សាយច្បាប់ស្តីពីថវិកាប្រចាំឆ្នាំរបស់អង្គភាពថវិកា និងគ្រឹះស្ថានសិក្សាសាធារណៈ
- អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា។

## *៣.២.៥ ការងារកិច្ចលទ្ធកម្ម*

### *បញ្ហាប្រឈម*

- ការអនុវត្តនីតិវិធីលទ្ធកម្មប្រើប្រាស់ពេលវេលាយូរ ធ្វើឱ្យយឺតយ៉ាវដល់ការអនុវត្តកិច្ចសន្យាការប្រគល់-ទទួល ការទូទាត់ និងការប្រើប្រាស់
- អង្គភាពថវិកាមានចំនួនច្រើន និងមានតម្រូវការប្រើប្រាស់សម្ភារៈប្រភេទខុសៗគ្នា ធ្វើឱ្យលំបាកក្នុងការវេចខ្ចប់ចូលក្នុងកញ្ចប់ផែនការលទ្ធកម្ម

- ការយល់ដឹងរបស់អង្គភាពថវិកាប្រើប្រាស់នៅមានកម្រិតក្នុងការរៀបចំឯកសារលក្ខណៈបច្ចេកទេសតម្លៃទីផ្សារ និងតម្រូវការ ធ្វើឱ្យការអនុវត្តកិច្ចលទ្ធកម្មមានការលំបាកក្នុងការរៀបចំផែនការលទ្ធកម្ម
- អង្គភាពថវិកាដែលមានតម្រូវការការងារជួសជុល/សាងសង់ផ្តល់ឯកសារពាក់ព័ន្ធ សម្រាប់ធ្វើផែនការ និងស្នើសុំគោលការណ៍ជានាចំណាយមិនទាន់មានលក្ខណៈសមស្រប។

**ទិសដៅ**

- ជំរុញការផ្តល់ជានាចំណាយ ទិដ្ឋាការឯកសារដេញថ្លៃ និងការយល់ព្រមចុះកិច្ចសន្យា ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីអនុវត្តនីតិវិធីកិច្ចលទ្ធកម្មឱ្យបានទាន់ពេលវេលាក្នុងឆ្នាំអនុវត្តផែនការ
- បន្តរៀបចំកែសម្រួល និងចងក្រងឯកសារកិច្ចលទ្ធកម្មឱ្យបានត្រឹមត្រូវស្របទៅតាមឯកសារគតិយុត្តនានា
- សហការជាមួយអង្គភាពថវិកាប្រើប្រាស់ ដើម្បីឱ្យមានភាពច្បាស់លាស់អំពីមាតិកាចំណាត់ថ្នាក់សេដ្ឋកិច្ច តាមសៀវភៅគ្រប់គ្រងថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានដាក់ឱ្យប្រើប្រាស់ងាយស្រួលក្នុងការបញ្ចូលទិន្នន័យជានាចំណាយទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំធ្វើផែនការ និងស្នើសុំគោលការណ៍ចំណាយរបស់អង្គភាពថវិកាសម្រាប់ការងារជួសជុល សាងសង់ ឱ្យមានលក្ខណៈសមស្រប។

### *៣.២.៦ ការងារបណ្តុះបណ្តាល និងវិក្រឹតការ*

*បញ្ហាប្រឈម*

- ផ្អាកវគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា បឋមសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី១៣ វេនទី២ និងជំនាន់ទី១៤ វេនទី១
- ខ្វះធនធានថវិកាក្នុងការបំប៉ននាយកសាលាបឋមសិក្សាស្តីពី ការគ្រប់គ្រងតាមសាលារៀន
- ខ្វះធនធានគ្រូឧទ្ទេសតាមមុខវិជ្ជាឯកទេសនៅវិទ្យាស្ថានគរុកោសល្យ។

**ទិសដៅ**

- ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់ភូមិសិក្សា ៣ ៦០០នាក់
- ពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យស្របតាមស្តង់ដា និងបច្ចេកវិទ្យាជំនាន់ថ្មីនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍសមត្ថភាពបុគ្គលិក គ្រូឧទ្ទេស និងគណៈគ្រប់គ្រងសាលាគរុកោសល្យឱ្យមានគុណសម្បទាសតវត្សរ៍ទី២១
- លើកកម្ពស់គុណវុឌ្ឍិបុគ្គលិក គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៅតាមសាលាគរុកោសល្យ
- កែលម្អកម្មវិធីបណ្តុះបណ្តាលឱ្យទៅប្រព័ន្ធក្រេឌីត និងវិធីសាស្ត្របង្រៀនថ្មីតាមបែបចម្រុះឱ្យមានភាពស៊ីគ្នានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត និងឆ្លើយតបទៅនឹងជំនាញសតវត្សរ៍ទី២១
- បន្តសហការជាមួយអង្គការ JICA អភិវឌ្ឍវិទ្យាស្ថានគរុកោសល្យ ជ្រើសរើស និងបញ្ជូនគ្រូឧទ្ទេស និងមន្ត្រីអប់រំទៅបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន ដើម្បីបម្រើការនៅវិទ្យាស្ថានគរុកោសល្យ
- បន្តបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា គ្រូបឋមសិក្សាដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី១៣ វេនទី២ ចំនួន ១ ៥០០នាក់ និងជំនាន់ទី១៤ វេនទី១ ចំនួន១ ៥០០នាក់
- កៀរគរធនធានថវិកា ដើម្បីពង្រឹងសមត្ថភាពជូននាយក នាយករងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅស្តីពី "ការគ្រប់គ្រងតាមសាលារៀន"
- បង្កើនសមត្ថភាពគ្រូឧទ្ទេស និងគ្រូបង្រៀនផ្នែកវិធីសាស្ត្របង្រៀនលើមុខវិជ្ជាវិទ្យាសាស្ត្រ និង គណិតវិទ្យា

- សាកល្បងអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀនដល់សាលាបឋមសិក្សាគោលដៅ ១០០។

### ៣.២.៧ ការងារអភិវឌ្ឍកម្មវិធីសិក្សា

បញ្ហាប្រឈម

- ការធ្វើតម្រូវការសៀវភៅសិក្សាគោលមិនទាន់ពេលវេលា
- ការផ្លាស់ប្តូរបណ្ណារក្សញឹកញាប់ នាយកសាលាមួយចំនួនជាអ្នកទទួលបន្ទុកសៀវភៅសិក្សាគោល
- ការផ្សព្វផ្សាយវិធីសាស្ត្របង្រៀនតាមគោលវិធីស្វែមមិនទាន់បានទូលំទូលាយ
- មិនទាន់បានផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅឱ្យបានទូលំទូលាយ។

ទិសដៅ

- ជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងផ្គត់ផ្គង់សៀវភៅសិក្សាគោលជូនសាលារៀន(TnT)ធ្វើឱ្យបានគ្រប់សាលារៀន
- រៀបចំផែនការបន្តវេនរយៈពេលមធ្យម និងរយៈពេលវែងសម្រាប់ការប្រើប្រាស់បណ្ណារក្ស និងនាយកសាលាដែលទទួលបន្ទុកសៀវភៅសិក្សាគោល
- ផ្សព្វផ្សាយវិធីសាស្ត្របង្រៀនតាមគោលវិធីស្វែមឱ្យបានទូលំទូលាយ
- ផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅឱ្យបានទូលំទូលាយ
- សរសេរបញ្ចប់សៀវភៅសិក្សាគោលសម្រាប់សិស្ស និងគ្រូបង្រៀនមុខវិជ្ជាសិល្បៈកម្រិតបឋមសិក្សា
- កសាងសមត្ថភាពមន្ត្រីនាយកដ្ឋានពីការអភិវឌ្ឍកម្មវិធីសិក្សាបែបបញ្ញត្តិ និងកម្រិតសមត្ថភាពសិស្សតាមថ្នាក់ជាពិសេសថ្នាក់ទី៩ និងគំរូវិញ្ញាសាប្រឡង
- អភិវឌ្ឍក្របខណ្ឌវិធីសាស្ត្របង្រៀនបែបបញ្ញត្តិ និងគំរូមេរៀនបែបបញ្ញត្តិសម្រាប់បង្រៀនតាមមុខវិជ្ជានីមួយៗ
- អភិវឌ្ឍវីដេអូពីការបង្រៀន និងរៀនតាមបែបបញ្ញត្តិតាមមុខវិជ្ជានីមួយៗ។

### ៣.២.៨ ការងាររដ្ឋបាល

បញ្ហាប្រឈម

- ការផ្តល់សំណើសុំគ្រឿងឥស្សរិយយសថ្នាក់ក្រោមជាតិយឺតយ៉ាវ។

ទិសដៅ

- ពន្លឿនការផ្តល់សំណើសុំគ្រឿងឥស្សរិយយសថ្នាក់ក្រោមជាតិ
- បន្តពង្រឹងការគ្រប់គ្រងលិខិតរដ្ឋបាល ពិសេសចរាចរលិខិត
- ជំរុញការផ្តល់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាលអប់រំ ពិធីការ របាយការណ៍ និងបណ្ណសារ
- គ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធទិន្នន័យឯកសារ និងបណ្ណសារក្រសួង
- ចុះពិនិត្យតាមដានការងារគ្រប់គ្រងរដ្ឋបាលអប់រំ បណ្ណសារ និងការងារប្រឡងប្រណាំង។

### ៣.២.៩ ការងារសំណង់សិក្សា

បញ្ហាប្រឈម

- សំណើសាងសង់ ជួសជុលកែលម្អពីបណ្តារាជធានី ខេត្ត មានច្រើនតែដំណោះស្រាយនៅមានកម្រិត
- ការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំនៅតាមសាលារៀននៅពុំទាន់បានល្អប្រសើរនៅឡើយ

- ខ្វះមន្ត្រីជំនាញ រដ្ឋបាល ផែនការ វិស្វករសំណង់ ស្ថាបត្យករ និងព័ត៌មានវិទ្យា ដើម្បីជំរុញការងារឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។

**ទិសដៅ**

- សិក្សានិងដោះស្រាយតាមកន្សោមអាទិភាព លើសំណើសាងសង់ ជួសជុលកែលម្អពីបណ្តារាជធានី ខេត្ត
- កែលម្អការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំនៅតាមសាលារៀនឱ្យបានល្អប្រសើរ
- ផ្តល់មន្ត្រីជំនាញ រដ្ឋបាល ផែនការ វិស្វករសំណង់ ស្ថាបត្យករ និងព័ត៌មានវិទ្យា ដើម្បីជំរុញការងារឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- បន្តពង្រឹងសមត្ថភាពគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំដល់នាយក នាយករងសាលា និងមន្ត្រីអប់រំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ៣.២.១០ ការងារបោះពុម្ព និងចែកផ្សាយ

**ទិសដៅ**

- កែលម្អសៀវភៅសិក្សាគោល ២៣ចំណងជើង សៀវភៅហ្វឹកហាត់ ២ចំណងជើង សៀវភៅអំណានបន្ថែម ២ចំណងជើង និងសម្ភារឧបទេស ២មុខ
- បោះពុម្ពសៀវភៅសិក្សាគោល សៀវភៅហ្វឹកហាត់ និងសៀវភៅអំណានបន្ថែមសរុប ៣ ៣៥០ ៧៥០ច្បាប់
- ដឹកជញ្ជូនសៀវភៅសិក្សាគោលជូនសាលារៀនទូទាំងប្រទេស ១ ៦២៦ ០០០ក្បាល
- ពង្រីកការលក់សៀវភៅសិក្សា សម្ភារឧបទេស សម្ភារពិសោធន៍ និងសម្ភារៈការិយាល័យជូនអតិថិជនទូទៅ។

### ៣.២.១១ ការងារអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**បញ្ហាប្រឈម**

- ការដាក់ពាក្យបណ្តឹងតវ៉ាភាគច្រើនមិនតាមឋានានុក្រម
- កង្វះការបណ្តុះបណ្តាលមន្ត្រីជំនាញអធិការកិច្ចទាំងថ្នាក់ជាតិ និងអន្តរជាតិ។

**ទិសដៅ**

- បញ្ជ្រាបយន្តការនៃការដាក់ពាក្យបណ្តឹងតវ៉ាតាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជំនាញអធិការកិច្ចផ្សារភ្ជាប់ការអនុវត្តជាក់ស្តែង។

### ៣.២.១២ ការងារសវនកម្មផ្ទៃក្នុង

**បញ្ហាប្រឈម**

- កង្វះធនធាន និងបច្ចេកទេសសម្រាប់គាំទ្រក្នុងការធ្វើសវនកម្មសមិទ្ធកម្ម សវនកម្មបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មគម្រោង
- មន្ត្រីសវនកម្មផ្ទៃក្នុងម្នាក់ៗ នៅមិនទាន់មានជំនាញពាក់ព័ន្ធច្បាស់លាស់ដែលគាំទ្រការអនុវត្តសវនកម្ម។

**ទិសដៅ**

- អភិវឌ្ឍធនធានមនុស្ស និងបំពាក់ឧបករណ៍បច្ចេកទេសសម្រាប់គាំទ្រការធ្វើសវនកម្មសមិទ្ធកម្ម សវនកម្មបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មគម្រោង
- អភិវឌ្ឍសមត្ថភាពមន្ត្រីសវនកម្មផ្ទៃក្នុងឱ្យមាន ជំនាញពាក់ព័ន្ធច្បាស់លាស់សម្រាប់គាំទ្រការអនុវត្តសវនកម្ម
- រៀបចំសៀវភៅណែនាំសវនកម្មផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា

- ផែនការយុទ្ធសាស្ត្រសវនកម្ម ២០២១-២០២៣ ត្រូវបានរៀបចំ
- ធ្វើសវនកម្មសាកល្បង (On the job audit training) លើសមិទ្ធកម្ម បច្ចេកវិទ្យាព័ត៌មាន និងគម្រោង
- បន្តពង្រឹងសមត្ថភាពសវនករផ្ទៃក្នុង លើជំនាញពាក់ព័ន្ធ និងការអនុវត្តការងារជាក់ស្តែង
- បន្តពង្រឹងគុណភាពស្តង់ដារបាយការណ៍សវនកម្មផ្ទៃក្នុង។

### *៣.២.១៣ ការងារធានាគុណភាពអប់រំ*

**បញ្ហាប្រឈម**

- ការរីករាលដាលជំងឺកូវីដ-១៩ នៅកម្ពុជា បានធ្វើឱ្យមានការអាក់ខានក្នុងការធ្វើសកម្មភាពស្ទើរទាំងស្រុងរបស់តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៦ សម្រាប់ឆ្នាំសិក្សា២០១៩-២០២០
- ការរៀបចំ និងអនុវត្តតេស្តវង្វាយតម្លៃអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ថ្នាក់ជាតិ ដោយប្រើប្រាស់កុំព្យូទ័របន្ទះ ស្ថិតនៅក្រោមជំនួយបច្ចេកទេសទាំងស្រុងពីវិទ្យាស្ថានស្រាវជ្រាវត្រីកោណ (RTI) ព្រោះជាលើកដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលទាមទារឱ្យក្រុមការងារបច្ចេកទេសតេស្តនៃនាយកដ្ឋានធានាគុណភាពអប់រំធ្វើការស្រាវជ្រាវនិងអភិវឌ្ឍសមត្ថភាពជាប្រចាំ
- ការសរសេរបញ្ចប់របាយការណ៍វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សាតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) ថ្នាក់ជាតិសង្ខេប និងពិស្តារ នៅមិនទាន់បានរួចរាល់ឡើយ ដោយសារទិន្នន័យចាំបាច់មួយចំនួនមិនមានគ្រប់គ្រាន់ ដែលក្រុមការងារត្រូវការស្នើសុំ និងបញ្ជាក់បន្ថែមពីជំនួយការ បច្ចេកទេសថ្នាក់តំបន់ ព្រមទាំងត្រូវការពេលវេលាដើម្បីពិនិត្យឡើងវិញលើខ្លឹមសារ និងអក្ខរាវិរុទ្ធដែលបានបកប្រែពីភាសាអង់គ្លេសមកជាភាសាជាតិ
- អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍ (OECD) និងប្រទេសជាសមាជិក បានសម្រេចចិត្តរំកិលវដ្តទី៨នៃកម្មវិធី PISA ដោយសារការរីករាលដាសកលនៃជំងឺកូវីដ-១៩ ដូចនេះផែនការសកម្មភាព និងថវិកាសម្រាប់ការអនុវត្តកម្មវិធីតេស្តអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA) សាកល្បងនៅឆ្នាំ២០២០ ត្រូវបានរំកិលទៅឆ្នាំ២០២១ ចំពោះការអនុវត្តតេស្តផ្លូវការនៃកម្មវិធីតេស្តអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ២០២១ ក៏នឹងត្រូវបានរំកិលទៅឆ្នាំ២០២២ ផងដែរ
- ការអនុវត្តវង្វាយតម្លៃលទ្ធផលសិក្សានៅថ្នាក់ក្រោមជាតិ មិនទាន់អាចឆ្លើយតបនឹងក្របខណ្ឌវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅឡើយដោយសារសមត្ថភាពរបស់មន្ត្រីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀននៅមានកម្រិត។

**ទិសដៅ**

- ពិនិត្យឡើងវិញឧបករណ៍តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៦ ឱ្យឆ្លើយតបនឹងការសិក្សាក្នុងបរិបទជំងឺកូវីដ-១៩ និងស្តង់ដាតេស្តថ្នាក់តំបន់កម្រិតបឋមសិក្សា និងអនុវត្តតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ដែលមានសាលារៀនសំណាកចំនួន ២៣០ នៅ ២៥ ខេត្ត រាជធានី
- ពង្រឹងសមត្ថភាពក្រុមការងារតេស្ត ដើម្បីអាចរៀបចំអនុវត្ត និងគ្រប់គ្រងដំណើរការតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូង និងវង្វាយតម្លៃគណិតវិទ្យាថ្នាក់ដំបូងព្រមទាំងការវិភាគទិន្នន័យ និងសរសេររបាយការណ៍ ពិសេសពិនិត្យលទ្ធភាពក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយក្រសួងអប់រំ យុវជន និងកីឡា និងអនុវត្តតេស្តវង្វាយតម្លៃចុងគ្រា EGRA & EGMA នៃគម្រោងមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំទី៣ ពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជាដែលមានសាលារៀនសំណាកចំនួន ៣៤០ នៅ ៩ ខេត្តគោលដៅ

- បញ្ចប់របាយការណ៍វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សាតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) ថ្នាក់ជាតិសង្ខេប និងពិស្ដារ ឱ្យបានរួចរាល់ជាស្ថាពរដើម្បីត្រៀមធ្វើការផ្សព្វផ្សាយជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី និងបន្តផ្សព្វផ្សាយជូនដល់គ្រប់អ្នកពាក់ព័ន្ធ ជាពិសេសកម្រិតសាលារៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សាឱ្យឆ្លើយតបនឹងគុណភាពអប់រំថ្នាក់តំបន់អាស៊ីអាគ្នេយ៍
- ពិនិត្យកែសម្រួលដើម្បីរំកិលផែនការសកម្មភាព និងថវិការយៈពេល ៥ឆ្នាំ (២០១៩-២០២៣) របស់កម្មវិធីតេស្តអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សទៅឆ្នាំ ២០២០-២០២៤ និងអនុវត្តសាកល្បងតេស្តអន្តរជាតិ ស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស-២០២២ ដែលមានសាលារៀនសំណាក ២៥ នៅ ១៤ ខេត្ត រាជធានី គោលដៅ។

### *៣.២.១៤ ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ*

*បញ្ហាប្រឈម*

- អង្គភាពមូលដ្ឋានមួយចំនួនពុំបានបញ្ចប់ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩
- អង្គភាពមួយចំនួនពុំបានយកចិត្តទុកដាក់លើការពិនិត្យតាមដានសេចក្ដីណែនាំលេខ ៥៤ អយក.សណន ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រង និងផ្គត់ផ្គង់សម្ភារបរិក្ខារ ការងារជម្រះបញ្ជី និងការដោះស្រាយវិវាទដីធ្លី
- អង្គភាពមួយចំនួនពុំទាន់បានធ្វើបច្ចុប្បន្នកម្មទិន្នន័យទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០ ច្បាស់លាស់
- សម្ភារបរិក្ខាររដ្ឋបាលគ្រឹះស្ថានសិក្សា និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនមួយចំនួននៅមានកម្រិត។

**ទិសដៅ**

- បំប៉ន និងពិនិត្យវាយតម្លៃការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលកណ្ដាល និងរាជធានី ខេត្ត
- ពង្រឹងការពិនិត្យតាមដានសម្ភារបរិក្ខារមួយឆ្នាំ២ដង តាមសេចក្ដីណែនាំរបស់ក្រសួង និងជំរុញការរៀបចំគម្រោង និងការអនុវត្តនីតិវិធីនៃការជម្រះទ្រព្យសម្បត្តិរដ្ឋ
- រៀបចំគម្រោង និងជំរុញការអនុវត្តនីតិវិធីនៃការជម្រះទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌ
- ធ្វើបច្ចុប្បន្នកម្មទិន្នន័យទ្រព្យសម្បត្តិរដ្ឋ និងបង់ពន្ធលើមធ្យោបាយធ្វើដំណើរសម្រាប់ឆ្នាំ២០២១
- សម្របសម្រួលការបញ្ចេញបញ្ចូលសម្ភារទំនិញ និងការនាំចូលដោយការបង់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ
- ពិនិត្យវាយតម្លៃជ្រើសរើស និងផ្គត់ផ្គង់សម្ភារបរិក្ខាររដ្ឋបាលដល់គ្រឹះស្ថានសិក្សានិងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ។

## ៤. សេចក្ដីសន្និដ្ឋាន

ឆ្នាំសិក្សា២០១៩-២០២០ កន្លងទៅនេះ បានឆ្លុះបញ្ចាំងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ស្មារតីស្រឡាញ់ជាតិ មាតុភូមិ ស្មារតីយកឈ្នះលើរាល់បញ្ហាប្រឈមទាំងឡាយចំពោះមុខ ពិសេសផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ដោយកសាងបានភាពធន់ និងភាពទន់ភ្លន់បត់បែនតាមគ្រឹះស្ថានសិក្សាក្នុងការអនុវត្តគន្លងជីវិតថ្មីវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តដោះស្រាយបញ្ហានៅសេសសល់ ព្រមទាំងដាក់ចេញនូវវិធានការសំខាន់ចាំបាច់នានា រួមទាំងការឆ្លើយតបនឹងអភិក្រមជីវិតធម្មតាតាមគន្លងថ្មី ដោយរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍបន្តខិតខំយកអស់កម្លាំងកាយចិត្ត ដើម្បីបំពេញភារកិច្ចដ៏វិសេសវិសាល និងឧត្តុង្គឧត្តម ប្រកបដោយស្មារតីទទួលខុសត្រូវនិងវិជ្ជាជីវៈខ្ពស់។

# ផ្នែកទី ២

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ៖ ចំនួនសកម្មភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ ថ្នាក់ជាតិ

| ល.រ | អង្គភាព | សកម្មភាពសរុប | បានបញ្ចប់ | កំពុងអនុវត្ត | មិនទាន់អនុវត្ត |
|---|---|---|---|---|---|
| ១ | នាយកដ្ឋានអប់រំកុមារតូច | ២៤ | ២០ | ៤ | ០ |
| ២ | នាយកដ្ឋានបឋមសិក្សា | ៤០ | ១៣ | ១២ | ១៥ |
| ៣ | នាយកដ្ឋានមធ្យមសិក្សា | ៣៣ | ១៥ | ១៦ | ២ |
| ៤ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ២៤ | ១៤ | ៨ | ២ |
| ៥ | នាយកដ្ឋានសុខភាពសិក្សា | ២៩ | ២៧ | ២ | ០ |
| ៦ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | ៣២ | ២១ | ០ | ១១ |
| ៧ | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ | ៣៨ | ៣១ | ២ | ៥ |
| ៨ | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | ១៦ | ១០ | ៥ | ១ |
| ៩ | នាយកដ្ឋានអប់រំពិសេស | ២១ | ១៥ | ២ | ៤ |
| ១០ | នាយកដ្ឋានឧត្តមសិក្សា | ៤១ | ១៦ | ១៨ | ៧ |
| ១១ | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | ១៣ | ៩ | ១ | ៣ |
| ១២ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ២៩ | ២៤ | ០ | ៥ |
| ១៣ | សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ | ២២ | ២២ | ០ | ០ |
| ១៤ | សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ | ២១ | ៧ | ៩ | ៥ |
| ១៥ | សាកលវិទ្យាល័យស្វាយរៀង | ២៨ | ២៥ | ១ | ២ |
| ១៦ | សាកលវិទ្យាល័យ មានជ័យ | ៤៤ | ៣៨ | ៥ | ១ |
| ១៧ | សាកលវិទ្យាល័យ បាត់ដំបង | ១៨ | ៩ | ៦ | ៣ |
| ១៨ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | ៦ | ៥ | ១ | ០ |
| ១៩ | សាកលវិទ្យាល័យនីតិសាស្ត្រ-សេដ្ឋកិច្ច | ១០ | ៩ | ១ | ០ |
| ២០ | សាកលវិទ្យាល័យវិទ្យាល័យក្រចេះ | ១៣ | ១០ | ០ | ៣ |
| ២១ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ | ១៧ | ៥ | ៤ | ៨ |
| ២២ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ១២ | ១២ | ០ | ០ |
| ២៣ | វិទ្យាស្ថានជាតិអប់រំ | ៣០ | ១០ | ១២ | ៨ |
| ២៤ | វិទ្យាស្ថានកំពង់ឈើទាល | ១៦ | ៦ | ៤ | ៦ |
| ២៥ | វិទ្យាស្ថានកំពង់ស្ពឺ | ២៧ | ១៦ | ៨ | ៣ |
| ២៦ | នាយកដ្ឋានអប់រំកាយ និងកីឡា | ២៥ | ១៤ | ៥ | ៦ |
| ២៧ | នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស និស្សិត | ១៧ | ៩ | ១ | ៧ |
| ២៨ | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ២៤ | ១៤ | ៦ | ៤ |
| ២៩ | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ១៩ | ១៤ | ២ | ៣ |
| ៣០ | នាយកដ្ឋានយុវជន | ១៦ | ៧ | ០ | ៩ |
| ៣១ | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន | ២០ | ១០ | ២ | ៨ |
| ៣២ | នាយកដ្ឋានសហប្រតិបត្តិបត្តិការកាយរឹទ្ធិ | ៩ | ៨ | ០ | ១ |
| ៣៣ | នាយកដ្ឋានផែនការ | ២៥ | ២០ | ០ | ៥ |
| ៣៤ | នាយកដ្ឋានបុគ្គលិក | ៣៥ | ១៨ | ៥ | ១២ |
| ៣៥ | នាយកដ្ឋានហិរញ្ញវត្ថុ | ៣៦ | ២៤ | ៨ | ៤ |
| ៣៦ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ១១ | ៦ | ១ | ៤ |
| ៣៧ | នាយកដ្ឋានធានាគុណភាពអប់រំ | ៣២ | ១២ | ៧ | ១៣ |

| ល.រ | អង្គភាព | សកម្មភាពសរុប | បានបញ្ចប់ | កំពុងអនុវត្ត | មិនទាន់អនុវត្ត |
|---|---|---|---|---|---|
| ៣៨ | អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | ៧ | ៥ | ០ | ២ |
| ៣៩ | នាយកដ្ឋានពត៌មាន និងកិច្ចការអាស៊ាន | ១៦ | ៤ | ៦ | ៦ |
| ៤០ | នាយកដ្ឋាននីតិកម្ម | ២៨ | ៥ | ១៤ | ៩ |
| ៤១ | នាយកដ្ឋានសំណង់ | ៧ | ៥ | ២ | ០ |
| ៤២ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ៦ | ៥ | ១ | ០ |
| ៤៣ | នាយកដ្ឋានរដ្ឋបាល | ១៧ | ១០ | ៤ | ៣ |
| ៤៤ | នា.ទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | ១៧ | ៩ | ៥ | ៣ |
| ៤៥ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ២៩ | ៨ | ១០ | ១១ |
| ៤៦ | នាយកដ្ឋានគោលនយោបាយ | ២៧ | ២២ | ៤ | ១ |
| ៤៧ | នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ | ១៦ | ១០ | ១ | ៥ |
| ៤៨ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | ២៤ | ២២ | ២ | ០ |
| ៤៩ | នាយកដ្ឋានការងារប្រឡង | ១៩ | ១១ | ០ | ៨ |
| ៥០ | វិទ្យាស្ថានជាតិអប់រំពិសេស | ២០ | ១៥ | ៤ | ១ |
| ៥១ | មជ្ឈ.តំបន់អាស៊ីអាគ្នេយ៍ SEAMEO TED | ១៧ | ០ | ១៣ | ៤ |
| ៥២ | វិទ្យាស្ថានគរុកោសល្យភ្នំពេញ | ៦ | ៣ | ២ | ១ |
| ៥៣ | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | ១១ | ៤ | ៥ | ២ |
| ៥៤ | អគ្គាធិការដ្ឋាន | ៨ | ៦ | ០ | ២ |
| ៥៥ | អង្គភាពលទ្ធកម្ម | ១០ | ២ | ៦ | ២ |
| ៥៦ | អគ្គរដ្ឋបាលនិងហិរញ្ញវត្ថុ | ៥ | ៥ | ០ | ០ |
| ៥៧ | ការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ | ១ | ១ | ០ | ០ |
| ៥៨ | ការងារពិនិត្យតាមដានវាយតម្លៃ និងគ្រប់គ្រង | ២ | ២ | ០ | ០ |
| ៥៩ | ការងារកំណែទម្រង់វិស័យអប់រំ | ១ | ១ | ០ | ០ |
| សរុបរួម | | ១ ១៦៧ | ៧០០ | ២៣៧ | ២៣០ |

## ឧបសម្ព័ន្ធទី២ ៖ ចំនួនសកម្មភាពនៃទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៩-២០២០ ថ្នាក់ជាតិ

| ល.រ | ផ្នែកសំខាន់ៗ | សកម្មភាពសរុប | បានបញ្ចប់ | កំពុងអនុវត្ត | មិនបានអនុវត្ត |
|---|---|---|---|---|---|
| **ក. ទិសដៅកំណែទម្រង់សំខាន់ៗ** | | | | | |
| ១ | ការពង្រឹងប្រព័ន្ធផែនការ | ៧ | ៦ | ១ | ០ |
| ២ | ការងារវិមជ្ឈការ និងវិសហមជ្ឈការ | ៦ | ០ | ៥ | ១ |
| ៣ | ការគ្រប់គ្រងបុគ្គលិក | ៧ | ៦ | ១ | ០ |
| ៤ | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ២០ | ៩ | ៩ | ២ |
| ៥ | ការងារបណ្ដុះបណ្ដាល និងវិក្រឹតការ | ១១ | ៤ | ៥ | ២ |
| សរុប | | ៥១ | ២៥ | ២១ | ៥ |
| **ខ .ទិសដៅតាមអនុវិស័យ** | | | | | |
| ១ | អនុវិស័យ ការអប់រំកុមារតូច | ៩ | ៣ | ៦ | ០ |
| ២ | អនុវិស័យ ការអប់រំបឋមសិក្សា | ១៣ | ៤ | ៨ | ១ |
| ៣ | អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ១៣ | ៨ | ៤ | ១ |
| ៤ | អនុវិស័យ ការអប់រំឧត្តមសិក្សា | ១២ | ៤ | ៥ | ៣ |
| ៥ | អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៨ | ៣ | ៤ | ១ |
| ៦ | អនុវិស័យ ការអភិវឌ្ឍយុវជន | ១១ | ១ | ៩ | ១ |
| ៧ | អនុវិស័យ ការអប់រំកាយ និងកីឡា | ១០ | ៤ | ៦ | ០ |
| សរុប | | ៧៦ | ២៧ | ៤២ | ៧ |
| **គ. ទិសដៅឆ្លងអនុវិស័យ** | | | | | |
| ១ | ការងារអភិវឌ្ឍកម្មវិធីសិក្សា | ១៣ | ២ | ៦ | ៥ |
| ២ | ការងាររដ្ឋបាល | ៥ | ៤ | ១ | ០ |
| ៣ | ការងារសំណង់សិក្សា | ៣ | ៣ | ០ | ០ |
| ៤ | ការងារបោះពុម្ព និងចែកផ្សាយ | ៥ | ៥ | ០ | ០ |
| ៥ | ការងារអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ៧ | ៦ | ១ | ០ |
| ៦ | ការងារសវនកម្មផ្ទៃក្នុង | ៧ | ២ | ៣ | ២ |
| ៧ | ការងារធានាគុណភាពអប់រំ | ៤ | ៤ | ០ | ០ |
| ៨ | ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ៦ | ៣ | ៣ | ០ |
| ៩ | ការងារលទ្ធផលកម្ម | ៥ | ៥ | ០ | ០ |
| សរុប | | ៥៥ | ៣៤ | ១៤ | ៧ |
| សរុបរួម | | ១៨២ | ៨៦ | ៧៧ | ១៩ |

## ឧបសម្ព័ន្ធទី៣ ៖ ចំនួនសកម្មភាពនៃផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ រាជធានី ខេត្ត

| ល.រ | រាជធានី ខេត្ត | សកម្មភាពសរុប | បានអនុវត្តចប់ | កំពុងអនុវត្ត | មិនបានអនុវត្ត |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | ៩០ | ៨៨ | ០ | ២ |
| ២ | បន្ទាយមានជ័យ | ១៨៧ | ១៦៤ | ០ | ២៣ |
| ៣ | តាកែវ | ៨៦ | ៨៥ | ០ | ១ |
| ៤ | កំពត | ៩០ | ៩០ | ០ | ០ |
| ៥ | ពោធិ៍សាត់ | ៣៧៥ | ៣០៥ | ២៣ | ៤៧ |
| ៦ | កែប | ១០១ | ៨៣ | ០ | ១៨ |
| ៧ | កំពង់ចាម | ១៣៩ | ១៣០ | ១ | ៨ |
| ៨ | កណ្តាល | ២៤៤ | ២១៥ | ០ | ២៩ |
| ៩ | ព្រះសីហនុ | ៧៥ | ៦៨ | ១ | ៦ |
| ១០ | មណ្ឌលគិរី | ១៩៧ | ១៧៧ | ០ | ២០ |
| ១១ | ស្វាយរៀង | ១៩៣ | ១៦៦ | ០ | ២៧ |
| ១២ | ព្រៃវែង | ១០៩ | ១០៩ | ០ | ០ |
| ១៣ | កំពង់ឆ្នាំង | ២៦៥ | ១៩៩ | ១៩ | ៤៧ |
| ១៤ | បាត់ដំបង | ២១២ | ១៥៥ | ១៥ | ៤២ |
| ១៥ | កំពង់ធំ | ១៤៦ | ១១៩ | ០ | ២៧ |
| ១៦ | រតនគិរី | ១២៩ | ១០៤ | ១ | ២៤ |
| ១៧ | ប៉ៃលិន | ១២៧ | ១២១ | ២ | ៤ |
| ១៨ | ស្ទឹងត្រែង | ១២៤ | ៩១ | ៧ | ២៦ |
| ១៩ | សៀមរាប | ៨២ | ៧៩ | ០ | ៣ |
| ២០ | ឧត្តរមានជ័យ | ១០៦ | ៧៤ | ១០ | ២២ |
| ២១ | កំពង់ស្ពឺ | ១៥៤ | ១៣៦ | ៧ | ១១ |
| ២២ | ត្បូងឃ្មុំ | ២៧៩ | ២១៥ | ១១ | ៥៣ |
| ២៣ | ក្រចេះ | ៣២៧ | ២៤៣ | ២០ | ៦៤ |
| ២៤ | ព្រះវិហារ | ៨៣ | ៨៣ | ០ | ០ |
| ២៥ | កោះកុង | ១៥៣ | ១០១ | ០ | ៥២ |
| | សរុបរួម | ៤ ០៧៣ | ៣ ៤០០ | ១១៧ | ៥៥៦ |

## ឧបសម្ព័ន្ធទី៤ ៖ ចំនួនសកម្មភាពនៃទិសដៅសន្និបាតអប់រំឆ្នាំសិក្សា ២០១៩-២០២០ រាជធានី ខេត្ត

| ល.រ | រាជធានី ខេត្ត | សកម្មភាពសរុប | បានអនុវត្តចប់ | កំពុងអនុវត្ត | មិនបានអនុវត្ត |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | ៤៥ | ៤៤ | ០ | ១ |
| ២ | បន្ទាយមានជ័យ | ៦២ | ៥៤ | ០ | ៨ |
| ៣ | តាកែវ | ៦២ | ៤៩ | ១២ | ១ |
| ៤ | កំពត | ៧៤ | ៦១ | ១០ | ៣ |
| ៥ | ពោធិ៍សាត់ | ៦៩ | ៤១ | ១៦ | ១២ |
| ៦ | កែប | ៨៩ | ៦៣ | ០ | ២៦ |
| ៧ | កំពង់ចាម | ១៧៦ | ១៥០ | ១៦ | ១០ |
| ៨ | កណ្តាល | ១២៨ | ១០៦ | ១៤ | ៨ |
| ៩ | ព្រះសីហនុ | ៧៤ | ៦៨ | ១ | ៥ |
| ១០ | មណ្ឌលគិរី | ១២៧ | ១០៧ | ០ | ២០ |
| ១១ | ស្វាយរៀង | ៨០ | ៦៥ | ៩ | ៦ |
| ១២ | ព្រៃវែង | ៦៧ | ៥៣ | ១១ | ៣ |
| ១៣ | កំពង់ឆ្នាំង | ៦៤ | ៥៣ | ៦ | ៥ |
| ១៤ | បាត់ដំបង | ៦២ | ៣៤ | ១៧ | ១១ |
| ១៥ | កំពង់ធំ | ៩២ | ៨៤ | ០ | ៨ |
| ១៦ | រតនគិរី | ៨៥ | ៦៣ | ៨ | ១៤ |
| ១៧ | ស្ទឹងត្រែង | ៦០ | ៤៣ | ៦ | ១១ |
| ១៨ | សៀមរាប | ៥០ | ៤៣ | ៥ | ២ |
| ១៩ | ឧត្តរមានជ័យ | ៥៧ | ៥១ | ១ | ៥ |
| ២០ | កំពង់ស្ពឺ | ៧៦ | ៥៩ | ១៣ | ៤ |
| ២១ | ត្បូងឃ្មុំ | ១០២ | ៦៣ | ៤ | ៣៥ |
| ២២ | ក្រចេះ | ១១២ | ៨៦ | ០ | ២៦ |
| ២៣ | ព្រះវិហារ | ១២២ | ៩៨ | ១៨ | ៦ |
| ២៤ | ប៉ៃលិន | ៥៩ | ៤៦ | ១២ | ១ |
| ២៥ | កោះកុង | ១៤៩ | ១២១ | ០ | ២៨ |
| | សរុបរួម | ២ ១៤៣ | ១ ៧០៥ | ១៧៩ | ២៥៩ |

## ឧបសម្ព័ន្ធទី៥ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៩-២០២០
## កំណែទម្រង់សំខាន់ៗ និងឆ្លងអនុវិស័យ

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| **១. ការពង្រឹងប្រព័ន្ធផែនការ** | | |
| - ពង្រឹងសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP AOP BSP) ផែនការយុទ្ធសាស្ត្រថវិកា តាមរយៈការរៀបចំការធ្វើផែនការផ្តោតលើលទ្ធផល (RBM) | ១ | - ពង្រឹងការរៀបចំផែនការផ្អែកលើលទ្ធផល និងសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រថវិកា២០២១-២០២៣ និងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២១<br>- ធ្វើសុខដុមនីយកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់និងថ្នាក់រាជធានី ខេត្ត<br>- ធ្វើសុខដុមនីយកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ជាស្តង់ដាររួមមួយសម្រាប់កសាងប្រព័ន្ធគ្រោងថវិកាផ្សារភ្ជាប់នឹងគោលនយោបាយ |
| - ធ្វើវិភាគមុខងារនៃអង្គភាពនិងនាយកដ្ឋានក្រោមឱវាទក្រសួង និងរៀបចំផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន | ១ | - រៀបចំផែនការគោលស្តីពី ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំឆ្នាំ ២០២០-២០២៤<br>- កំពុងបន្តរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋានផែនការ |
| - កែលម្អការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំឱ្យឆ្លើយតបទៅនឹងសូចនាករដែលបានដាក់ចេញនិងជានាការអនុវត្តថវិកាទៅតាមអាទិភាពនិងគោលនយោបាយអប់រំ | ១ | - ពង្រឹងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំតាមអនុវិស័យឱ្យកាន់តែល្អប្រសើរ ដោយកំណត់លេខកូដផ្សារភ្ជាប់រវាងសកម្មភាពនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ទាំងនៅថ្នាក់ជាតិ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| - កែលម្អនិងធ្វើបច្ចុប្បន្នកម្មសូចនាករអប់រំទៅតាមគោលដៅ SDG | ១ | - ពិនិត្យនិងកែសម្រួលសូចនាករអប់រំមួយចំនួនដែលមិនមានប្រភពទិន្នន័យច្បាស់លាស់សម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ក្រោមការសម្របសម្រួលរបស់ក្រសួងផែនការ |
| - ពង្រឹងសមត្ថភាពស្ថាប័នក្នុងការវិភាគស្ថិតិ និងពង្រឹងការស្រាវជ្រាវផ្នែកគោលនយោបាយ | ១ | - បណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានគោលនយោបាយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នក្នុងការវិភាគស្ថិតិនិងការស្រាវជ្រាវផ្នែកគោលនយោបាយ |
| - រៀបចំផែនការទំនើបកម្មខាងផ្នែកព័ត៌មានវិទ្យា | ១ | - រៀបចំ និងដាក់ឱ្យអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំតាមអនុវិស័យ តាមប្រព័ន្ធ Software នៅថ្នាក់ជាតិថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដោយផ្សារភ្ជាប់នឹង ESP, BSP, PB និង AOP |
| - ជ្រើសរើសមន្ត្រីជំនាញផ្នែក ICT និងរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីដែលមានស្រាប់។ | ២ | - បំប៉នសមត្ថភាពមន្ត្រីលើជំនាញ ICT នៅនឹងកន្លែង តាមរយៈការបំពេញការងារ<br>- មិនមានមន្ត្រីជំនាញផ្នែក ICT ផ្តល់ដោយក្រសួង ដោយសារការរីករាលនៃជំងឺកូវីដ-១៩ |
| **២. ការធានាវិមជ្ឈការ និងវិសហមជ្ឈការ** | | |
| - រៀបចំនីតិវិធីស្តង់ដានៃការអនុវត្តមុខងារវិស័យអប់រំ និងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារផ្តល់សេវាអប់រំ | ២ | - រៀបចំនីតិវិធីស្តង់ដាអនុវត្តមុខងារវិស័យអប់រំ<br>- រៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធី បែបបទក្នុងការគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ផ្សព្វផ្សាយអនុក្រឹត្យលេខ១៨២, ១៨៣, ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធក្រុងស្រុកខណ្ឌ |
| - ពង្រឹងការផ្តល់សេវាអប់រំស្របតាមគោលការណ៍អភិបាលកិច្ចល្អ និងក្របខណ្ឌគណនេយ្យភាពសង្គម | ២ | - កែសម្រួលឡើងវិញលើឯកសារតម្រង់ទិសការងារគ្រប់គ្រងតាមគោលការអភិបាលកិច្ចល្អ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| | | - កែសម្រួលសូចនាករអាយហ្វយស៊ី វិស័យអប់រំ<br>- ផ្តល់អាជ្ញាបណ្ណបើគ្រឹះស្ថានសិក្សាចំណេះទូទៅ ១១៤ ឧត្តមសិក្សា ០៥<br>- ផ្តល់សេវាស្នើសុំបន្តសុពលភាព ប្តូរឈ្មោះនាយក ប្តូរទីតាំងសាលា ២៧ |
| - រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងអប់រំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | ៣ | - ប្រឈមស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ |
| - ពង្រឹងការគ្រប់គ្រង និងដោះស្រាយវិវាទបុគ្គលិកអប់រំ | ២ | - សម្របសម្រួលដោះស្រាយវិវាទបុគ្គលិកអប់រំបាន ១៥ ករណី |
| - រៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រតាមអនុវិស័យឱ្យឆ្លើយតបការចង្អុលក្នុងច្បាប់ស្តីពីការអប់រំ និងកំណែទម្រង់វិស័យអប់រំ | ២ | - រៀបចំលិខិតបទដ្ឋានគតិយុត្តសរុបចំនួន២៤ |
| - ពង្រឹងសមត្ថភាពលើក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអប់រំ និងសិក្សាប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌច្បាប់។ | ២ | - រៀបចំសិក្ខាសាលាក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តវិស័យអប់រំ សិក្ខាកាម ៩៦ នាក់ ស្រី១២ នាក់<br>- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពីការកំណត់តួនាទី និងភារកិច្ចរបស់មន្ទីរអយក នៅខេត្តសៀមរាប សិក្ខាកាម ៣៧ នាក់ ស្រី ៥ នាក់<br>- រៀបចំសៀវភៅស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស |
| **៣. ការគ្រប់គ្រងបុគ្គលិក** | | |
| - ពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ជាពិសេសការជ្រើសរើសគ្រូបង្រៀនពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនជាប់កិច្ចសន្យា | ១ | - បែងចែកតួលេខគ្រូបង្រៀន ២វេន ១០ ២២៩ នាក់ សម្រាប់ ២២ រាជធានី ខេត្ត<br>- គ្រូបង្រៀនថ្នាក់គួប ២ ៧៦៦ នាក់ សម្រាប់ ១៨ ខេត្ត<br>- គ្រូបង្រៀនជាប់កិច្ចសន្យា ១១ ២៩០ នាក់ សម្រាប់ ២២ រាជធានី ខេត្ត<br>- មន្ត្រីជាប់កិច្ចសន្យា ៧០៤ នាក់ សម្រាប់អង្គភាពថ្នាក់កណ្តាល ៤៥០ នាក់ និងរាជធានី ខេត្ត ២៥៤ នាក់។ |
| - បន្តពង្រឹងការពង្រាយគ្រូបង្រៀន និងការផ្ទេរបុគ្គលិកអប់រំ | ១ | - ពង្រាយគ្រូបង្រៀនពីសាលាលើសទៅសាលាខ្វះគ្រូបង្រៀន ១៨ នាក់ ស្រី ៣ នាក់  និងពង្រាយគ្រូកម្រិតឧត្តម(ចេញថ្មី) ៩៩៤ នាក់ ស្រី ៤៥៨ នាក់ ឱ្យទៅដល់សាលារៀនដែលសាមីខ្លួនបានជ្រើសរើសមុនពេលដាក់ពាក្យប្រឡង<br>- ចេញលិខិតលេខ ២៤៨២ អយក.បល ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការផ្អាកការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំក្នុងឆ្នាំ២០២០<br>- ចេញលិខិតលេខ ២០៨១ អយក.បល ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ស្តីពីការផ្អាកបណ្តោះអាសន្ននៃការផ្ទេរក្របខណ្ឌមន្ត្រីរាជការនិងគ្រូបង្រៀនក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅក្រសួង ស្ថាប័ននានា |
| - សិក្សាឡើងវិញ និងរៀបចំប្រកាសស្តីពីការកំណត់អង្គភាព និងសាលារៀនស្ថិតក្នុងតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក | ១ | - បង្កើតគណៈកម្មការអន្តរក្រសួង<br>- រៀបចំសេចក្តីប្រកាសកំណត់លក្ខណៈវិនិច្ឆ័យតំបន់ |
| - បន្តជំរុញការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា គោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ១ | - រៀបចំសិក្ខាសាលាស្តីពីការពង្រឹងការបែងចែកក្របខណ្ឌថ្មី(សម្រាប់ឆ្នាំ២០២១)<br>- បង្កើតការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយគន្លងអាជីព |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - បន្តពង្រឹងការគ្រប់គ្រងនិងការធ្វើបច្ចុប្បន្នកម្មទិន្នន័យបុគ្គលិកអប់រំក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស(HRMIS) | ១ | - បំប៉នមន្ត្រីទទួលបន្ទុក HRMIS នៅតាមមន្ទីរ អយក រាជធានី ខេត្ត<br>- បញ្ចប់ការរៀបចំផែនការមេ HRMIS<br>- ធ្វើបច្ចុប្បន្នប្រអប់ទិន្នន័យក្នុងប្រព័ន្ធដើម្បីកត់ត្រាទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គលិកឱ្យបានគ្រប់ជ្រុងជ្រោយ<br>- រៀបចំ និងដាក់ឱ្យអង្គភាពសាមីនីមួយៗអាចចូលមើលសំណុំមន្ត្រីរាជការរបស់ខ្លួនក្នុងប្រព័ន្ធ HRMIS |
| - បន្តជំរុញការអនុវត្តរង្វាយតំលៃគុណផលរបស់បុគ្គលិកអប់រំដើម្បីផ្សារភ្ជាប់ទៅនឹងលាភការផ្សេងៗ | ២ | - ពិនិត្យវឌ្ឍនភាពនៃការអនុវត្តសាកល្បង និងពិភាក្សាអំពីយុទ្ធសាស្ត្រដើម្បីអនុវត្តឆ្នាំ២០២១ ឱ្យបានជោគជ័យ និងបន្តពង្រីកការអនុវត្តឱ្យទៅដល់អង្គភាពនានា |
| - បន្តពិនិត្យតាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលការណ៍ និងសេចក្តីណែនាំពាក់ព័ន្ធ និងការគ្រប់គ្រងធនធានមនុស្ស។ | ១ | - ផ្សព្វផ្សាយគោលការណ៍ស្តីពីការបែងចែកក្របខណ្ឌឆ្នាំ ២០២០<br>- ចុះពិនិត្យនិងជំរុញការរៀបចំតាំងស៊ប់ក្នុងក្របខណ្ឌ ការដំឡើងថ្នាក់ និងការគ្រប់គ្រងមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា<br>- រៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ |
| **៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** | | |
| - ពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើនសិទ្ធិអំណាចបន្ថែមទៀត ឱ្យមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ឱ្យស្របតាមលិខិតបទដ្ឋានជាធរមាន | ១ | - លិខិតលេខ ១៩៨២ អយក.ហវ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០<br>- លិខិតលេខ ៥៤៦៩ អយក.ហវ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ |
| - ស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកំណត់កាលបរិច្ឆេទទម្លាក់ថវិកាអាហារូបករណ៍ជូនសិស្សក្រីក្រជួបការលំបាក | ១ | - លិខិតលេខ ៥៥៥៩ សហវ.អថ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២០ |
| - ពង្រឹងការអនុវត្តថវិការបស់ប្រធានកម្មវិធី អនុប្រធានកម្មវិធី និងអង្គភាពថវិកាដើម្បីឆ្លើយតបនឹងកម្មវិធីចំណាយ សូចនាករគោលដៅ និងផែនការប្រតិបត្តិប្រចាំឆ្នាំ | ១ | - លិខិតលេខ ៣១៣ អយក.ហវ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០២១<br>- លិខិតលេខ ៧៦៣ អយក.ហវ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ២០២០<br>- លិខិតលេខ ៤២៤៧ អយក.ហវ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០២០ |
| - បន្តពិនិត្យ និងតាមដានការគ្រប់គ្រង និងអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋរបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុតាមសាលារៀនរដ្ឋ | ២ | - ប្រមូលរបាយការណ៍អនុវត្តថវិកាមូលនិធិដំណើរការសាលារៀនរដ្ឋប្រចាំត្រីមាស និងប្រចាំឆ្នាំតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា<br>- បណ្តុះបណ្តាលនាយកសាលា និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុតាមគ្រឹះស្ថានសិក្សាសាធារណៈស្តីពីនីតិវិធី និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋ |
| - បន្តពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុលើការគ្រោងថវិកា ការអនុវត្តកិច្ចបញ្ជិកា និងប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា | ២ | - សហការជាមួយនាយកដ្ឋានផែនការដើម្បីធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ ដោយកែសម្រួលកម្មវិធី និងចង្កោមសកម្មភាពរបស់អង្គភាពថវិកាមួយចំនួន<br>- ប្រជុំណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំដោយគោរពតាមសារាចរណែនាំលេខ សារាចរណែនាំលេខ០៣ សរណន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ និងសារាចរណែនាំលេខ០៤ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| | | សរណោន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា<br>- កំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា EFMS មុខងារគ្រប់គ្រងថវិកាផ្ទេរទេយ្យបុរេប្រទាន នឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅត្រីមាសទី១ ឆ្នាំ២០២១<br>- កំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យា EFMS មុខងារគ្រប់គ្រងបេសកកម្មក្នុង និងក្រៅប្រទេស |
| - រៀបចំនីតិវិធីក្នុងការផ្តល់ប្រាក់ឧបត្ថម្ភជូនដល់មន្ត្រីអប់រំ ចុះពិនិត្យតាមដានការអប់រំក្នុងក្រុង ស្រុក ខណ្ឌសាមីដែលមានចម្ងាយផ្លូវពីការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌទៅសាលារៀនដែលជួបការលំបាកក្រោម ៥០គីឡូម៉ែត្រ ចុះ និងចាប់ពី ៥០គីឡូម៉ែត្រឡើងទៅ | ៣ | - ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បានផ្ទេរទៅថ្នាក់ក្រោមជាតិ |
| - សិក្សា និងវាយតម្លៃបញ្ហាប្រឈមក្នុងការរៀបចំរបាយការណ៍អនុវត្តថវិកាប្រចាំខែរបស់អង្គភាពថវិកា | ២ | - ចុះជួយសម្របសម្រួលការរៀបចំរបាយការណ៍នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត មួយចំនួនដែលជួបបញ្ហាប្រឈម<br>- បណ្តុះបណ្តាលតាមប្រព័ន្ធ Online នៅតាមអង្គភាពថវិការដ្ឋបាលកណ្តាលមួយចំនួនដែលជួបបញ្ហាប្រឈម |
| - ពង្រឹងការតាមដាន និងការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋ ដើម្បីជួយមន្ទីររាជធានី ខេត្តក្នុងការបែងចែកគម្រោងថវិកាប្រចាំឆ្នាំទៅកាន់សាលារៀន | ១ | - ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋឱ្យស្របតាមលិខិតលេខ ៨០១៥ សហវ.អថ និងលេខ ៥៥៥៩ សហវ.អថ |
| - បង្កើតប្រព័ន្ធរបាយការណ៍តាមប្រព័ន្ធព័ត៌មានវិទ្យាលើអនុវិស័យសម្រាប់អង្គភាពរដ្ឋបាលកណ្តាល | ១ | - អង្គភាពថវិកានៅរដ្ឋបាលកណ្តាល បានប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការរៀបចំរបាយការណ៍ទៅតាមអនុវិស័យ ក្នុងឆ្នាំ២០២០ |
| - ប្រជុំពិភាក្សាលើការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា ផែនការអនុវត្តថវិកាប្រចាំឆ្នាំ ទៅកាន់ផែនការថវិកាប្រចាំឆ្នាំ និងបង្កើតប្រព័ន្ធរបាយការណ៍តាមអនុវិស័យតាមមន្ទីររាជធានីខេត្ត | ២ | - បានសហការជាមួយនាយកដ្ឋានផែនការក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការអភិវឌ្ឍប្រព័ន្ធថវិកាផ្សារភ្ជាប់នឹង ESP, BSP, AOP និង ABP<br>- កំពុងរៀបចំប្រព័ន្ធរបាយការណ៍តាមអនុវិស័យសម្រាប់មន្ទីររាជធានី ខេត្ត |
| - បន្តរៀបចំយន្តការ និងនីតិវិធីនៃការផ្ទេរថវិកាបេសកកម្មតាមប្រព័ន្ធធនាគារសម្រាប់ថ្នាក់កណ្តាល | ២ | - បើកគណនីបៀវត្ស និងបើកប្រាក់បៀវត្សនៅធនាគារអេស៊ីលីដាសម្រាប់មន្ត្រីអប់រំថ្នាក់រដ្ឋបាលកណ្តាល<br>- កំពុងរៀបចំនីតិវិធីបើកប្រាក់បេសសកម្ម ចូលគណនីបៀវត្សរបស់មន្ត្រីអប់រំ |
| - ពង្រឹងការរៀបចំផែនការសកម្មភាពរបស់គ្រប់អង្គភាពថ្នាក់កណ្តាលឱ្យឆ្លើយតបផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP)តាមប្រព័ន្ធព័ត៌មានវិទ្យា | ២ | - កំពុងធ្វើបច្ចុប្បន្នកម្មផែនការសម្មភាពរបស់អង្គភាពថ្នាក់កណ្តាលឱ្យឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP)តាមប្រព័ន្ធព័ត៌មានវិទ្យា |
| - រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកាប្រឡងគ្រប់កម្រិត | ៣ | - មិនមានធនធានគ្រប់គ្រាន់ក្នុងការរៀបចំ |
| - ធ្វើបច្ចុប្បន្នកម្មនិងដោះស្រាយបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងថវិកា SOF របស់សាលារៀនរដ្ឋ | ១ | - ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋ<br>- បណ្តុះបណ្តាលពីនីតិវិធីហិរញ្ញវត្ថុ មូលដ្ឋានគ្រឹះនៃការប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋ<br>- បង្កើតវីដេអូឃ្លីបមេរៀនស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋ<br>- មានក្រុមការងារជួយសម្របសម្រួលដោះស្រាយបញ្ហា |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
| --- | --- | --- |
| | | ប្រឈមក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងថវិកា SOF |
| - ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានវិទ្យាគ្រប់ប្រភេទ | ១ | - ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) ប្រព័ន្ធគ្រោងថវិកាទូទៅ ប្រព័ន្ធគ្រោងថវិកាជំពូក៦៤ មូលនិធិដំណើរការសាលារៀនរដ្ឋ និងរបាយការណ៍អនុវត្តថវិកាប្រចាំខែ ត្រីមាស និងឆ្នាំ |
| - រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកាសាលាគរុកោសល្យនិងវិក្រឹតការនិងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ២ | - កំពុងរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកា និងរបាយការណ៍របស់សាលាគរុកោសល្យនិងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| - រៀបចំប្រព័ន្ធគ្រោងប្រាក់បំណាច់ម៉ោងបន្ថែម (មន្ទីរ.អយក ការិ.អយក និង សាលារៀន) | ១ | - ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រោងថវិកាជំពូក ៦៤ លើការគ្រោងប្រាក់ម៉ោងបន្ថែម ថ្នាក់គួប និងពីរវេន |
| - រៀបចំប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងថវិកាដៃគូអភិវឌ្ឍគ្រប់ប្រភេទ | ២ | - កំពុងសិក្សា និងប្រមូលទិន្នន័យ តាមគ្រឹះស្ថានឧត្តមសិក្សាដែលពាក់ព័ន្ធថវិកាដៃគូអភិវឌ្ឍគ្រប់ប្រភេទ |
| - បន្តបង្កើនស្វ័យភាពជូនសាលារៀនរដ្ឋលើការគ្រប់គ្រងហិរញ្ញវត្ថុ និងបង្កើនថវិកាសាលារៀន | ១ | - ផ្តល់ស្វ័យភាពជូនសាលារៀនរដ្ឋក្នុងការគ្រោងថវិកា<br>- បង្កើនថវិកា ១លានរៀល/សាលា បន្ថែមលើលិខិតលេខ ៨០១៥ សហវ.អថ សម្រាប់ឆ្នាំ២០២១ |
| - រៀបចំនីតិវិធីហិរញ្ញវត្ថុលម្អិតសម្រាប់អង្គភាពថ្នាក់កណ្តាល។ | ២ | - មានសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់អង្គភាពរដ្ឋបាលកណ្តាល |
| **៥. ការងារកិច្ចលទ្ធកម្ម** | | |
| - ជំរុញការអនុវត្តកិច្ចលទ្ធកម្មស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ | ១ | - លទ្ធកម្មទំនិញ (ជំពូក៦០) ២១ គម្រោងមានទឹកប្រាក់ ៣៦ ២៩៧.៥៧ លានរៀល<br>- លទ្ធកម្មសំណង់ (ជំពូក៦១) ០៥ គម្រោងមានទឹកប្រាក់ ២ ៧៧៥.៧០ លានរៀល<br>- លទ្ធកម្មសំណង់ (ជំពូក២១) ០២ គម្រោងមានទឹកប្រាក់ ៨ ៩៥៩.០៩ លានរៀល |
| - បន្តកិច្ចសហការជួយផ្នែកបច្ចេកទេសជូនក្រុមលទ្ធកម្មមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងសកលវិទ្យាល័យ វិទ្យាស្ថាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ ០៨ សរុប ៣៣ ក្រុមលទ្ធកម្ម | ១ | - |
| - ជំរុញការស្នើសុំគោលការណ៍ជានាចំណាយលទ្ធកម្មទំនិញ និងសំណង់ ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ | - |
| - ពិនិត្យផ្ទៀងផ្ទាត់តម្រូវការប្រើប្រាស់របស់អង្គភាពដែលត្រូវវេចខ្ចប់ចូលគ្នាក្នុងគម្រោងតែមួយឱ្យមានលក្ខណៈត្រឹមត្រូវ និងសមស្រប | ១ | - |
| - ជំរុញការអនុវត្តកិច្ចលទ្ធកម្មជូនអង្គភាពថវិការដ្ឋបាលកណ្តាលឱ្យទទួលបានតាមតម្រូវការ និងទាន់ពេលវេលា។ | ១ | - |
| **៦. ការងារបណ្តុះបណ្តាល និងវិក្រឹតការ** | | |
| - ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់ភូមិសិក្សា ៣ ៦០០នាក់ | ៣ | - អនុវត្តតាមស្មារតីសម្រេចរបស់រាជរដ្ឋាភិបាលក្នុង ការផ្អាកជាបណ្តោះអាសន្ននូវការជ្រើសរើសក្របខណ្ឌថ្មីសម្រាប់ឆ្នាំ២០២០ (លិខិតលេខ ១៩២៧ មស.ក្រឧ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ) |
| - បញ្ចូល និងអនុវត្តកញ្ចប់អំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូងក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា | ១ | - សហការជាមួយនាយកដ្ឋានបឋមសិក្សាបន្ថែម ១ក្រេឌីតក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សាមុខវិជ្ជា |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| | | ភាសាខ្មែរ តាមប្រព័ន្ធ គ្រេឌីត១២+២ និងឯកភាពពីថ្នាក់ដឹកនាំក្រសួងនាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០<br>- ដាក់បញ្ចូលកញ្ចប់សម្ភារៈបង្រៀន និងរៀនគណិតវិទ្យាថ្នាក់ដំបូងក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន (១២+២) និងឯកភាពពីថ្នាក់ដឹកនាំក្រសួងនាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០។ ក្រសួងបានសុំការគាំទ្រពីអង្គការ UNESCO ដើម្បីជ្រើសរើសអ្នកពិគ្រោះការ ឬអង្គការ ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល សម្រាប់ជួយផ្នែកបច្ចេកទេស ក្នុងការដាក់បញ្ចូលកញ្ចប់សម្ភារៈបង្រៀន និងរៀនគណិតវិទ្យាថ្នាក់ដំបូងក្នុងកម្មវិធីសិក្សាលម្អិតគណិតវិទ្យា(១២+២) និងបំប៉នសមត្ថភាពគ្រូឧទ្ទេសនៅតាមសាលា គរុកោសល្យ |
| - ពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ | ២ | - អនុវត្តតាមអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការផ្ទេរការ គ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសាននៅ ខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលា អនុវត្តមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា |
| - សហការជាមួយអង្គការ JICA ជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ជ្រើសរើស និងបញ្ជូនគ្រូឧទ្ទេស បុគ្គលិកអប់រំ នៅវិទ្យាស្ថានគរុកោសល្យឱ្យទៅទទួលការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ នៅជប៉ុន | ១ | - សំណង់ និងការបំពាក់សម្ភារបរិក្ខារ និងឧបករពិសោធន៍នៅវិទ្យាស្ថានគរុកោសល្យទាំងពីរ ១០០ភាគរយ<br>- គ្រូឧទ្ទេស ៥នាក់ ស្រី ១នាក់ ទៅបណ្តុះបណ្តាលថ្នាក់បរិញ្ញាជាន់ខ្ពស់នៅប្រទេសជប៉ុន |
| - បន្តបំប៉នគ្រូមត្តេយ្យសិក្សាបឋមសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី១៣ វេនទី២ ចំនួន ១ ៥០០នាក់ និងជំនាន់ទី១៤ វេនទី១ ចំនួន ១ ៥០០នាក់ | ៣ | - អនុវត្តតាមលិខិតលេខ ១៩៥៣ មស.ក្រខ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការផ្អាកជាបណ្តោះអាសន្នសម្រាប់ការផ្តល់ប្រាក់កម្រៃគ្រូបង្រៀនរបបម៉ោងបន្ថែម<br>- អនុវត្តតាមលិខិតលេខ ៣៧១៣ អយក.បវ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ស្តីពីការផ្អាកបើកវគ្គបំប៉នគ្រូបង្រៀនកម្រិតបឋមដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានជំនាន់ទី១៣ វេនទី២ និងជំនាន់ទី១៤ វេនទី១ |
| - បន្តពង្រឹងសមត្ថភាពជូននាយក នាយករងសាលាគរុកោសល្យ សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅស្តីពី " ការគ្រប់គ្រងតាមសាលារៀន " | ២ | - បំប៉ននាយកសាលាមធ្យមសិក្សា ១០០នាក់ ស្រី ៥នាក់<br>- នាយកសាលាមត្តេយ្យ និងបឋមសិក្សាមិនបានបំប៉នដោយសារខ្វះខាតថវិកា |
| - អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យស្របតាមស្តង់ដា និងបច្ចេកវិទ្យាជំនាន់ថ្មី | ២ | - បំពាក់កុំព្យូទ័រ ព្រីនធ័រ និងម៉ាស៊ីនថតចម្លងនៅតាមសាលាគរុកោសល្យ |
| - អភិវឌ្ឍសមត្ថភាព បុគ្គលិក គ្រូឧទ្ទេស គណៈគ្រប់គ្រងសាលាគរុកោសល្យ ឱ្យមានគុណសម្បទាសតវត្សរ៍ទី២១ | ២ | - គណៈគ្រប់គ្រង គ្រូឧទ្ទេសបានបំប៉នស្តីពីការគ្រប់គ្រងការងារបង្រៀន និងរៀនតាមប្រព័ន្ធអេឡិចត្រូនិក |
| - បង្កើនសមត្ថភាពផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា | ២ | - ដាក់ឱ្យប្រើប្រាស់ឯកសារណែនាំលម្អិតនៅសាលាគរុកោសល្យ |
| - បង្កើនសមត្ថភាពប្រើប្រាស់សៀវភៅភាសាអង់គ្លេសថ្នាក់ទី៧-៩ | ១ | - ប្រធានក្រុមបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេសថ្នាក់ទី៧-៩ ចំនួន ២៧៦នាក់ ស្រី ៦២នាក់ ទទួលការ បំប៉នស្តីពីការណែនាំកម្មវិធីភាសាអង់គ្លេសថ្នាក់ទី៧ ដល់ថ្នាក់ទី៩ |
| - លើកកម្ពស់គុណវុឌ្ឍិ និងសមត្ថភាពគ្រូឧទ្ទេសនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ | ១ | - គ្រូឧទ្ទេស ៦៨នាក់ ស្រី ៣៨នាក់ បានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រអប់រំ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| **៧. ការងារអភិវឌ្ឍកម្មវិធីសិក្សា** | | |
| - អនុវត្តឱ្យបានម៉ឺងម៉ាត់នូវដំណើរការធ្វើលទ្ធកម្ម និងការផ្គត់ផ្គង់សៀវភៅសិក្សាគោលទៅតាមកម្មវិធីដែលបានដាក់ចេញ និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ | ១ | - ធ្វើលទ្ធកម្មសម្រាប់ ២០១៩-២០២០ |
| - កែលម្អការធ្វើផែនការផ្គត់ផ្គង់សៀវភៅសិក្សាគោល និងការប្រើប្រាស់លទ្ធផលអធិការកិច្ច ដើម្បីដោះស្រាយការលើស ខ្វះ សៀវភៅសិក្សាគោល | ២ | - សាលារៀនបានធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ TnT តែពុំទាន់បានប្រើប្រាស់ទូទាំងប្រទេសទេ<br>- ចុះពិនិត្យតាមដានបាន២ខេត្ត |
| - អភិវឌ្ឍសមត្ថភាព លើការគ្រប់គ្រង សៀវភៅសិក្សាគោលដល់ថ្នាក់ក្រោមជាតិ | ២ | - បណ្តុះបណ្តាល២ ដង ចំនួន ៦២ នាក់ស្រី១២នាក់ |
| - ផ្គត់ផ្គង់សៀវភៅសិក្សាគោលប្រើប្រាស់នៅតាមគ្រឹះស្ថានសិក្សារដ្ឋ ទៅតាមផលធៀប ១/១ ពីថ្នាក់ទី១ដល់ថ្នាក់ទី៩ និងផលធៀប ២/១ នៅថ្នាក់ទី១០ ដល់ថ្នាក់ទី១២ | ១ | - ផ្គត់ផ្គង់សៀវភៅសិក្សាគោល ២០១៩-២០២០<br>- បឋមសិក្សា ៣ ៣៨០ ៥៤៤ ច្បាប់<br>- មធ្យមបឋមភូមិ ៩២២ ២២៤ ច្បាប់<br>- មធ្យមទុតិយភូមិ ៧៧៤ ០៦២ ច្បាប់<br>- អត្ថបទអក្សរសិល្ប៍ ៥១២ ច្បាប់<br>- សរុបរួម ៥ ០៧៧ ៣៤៤ ច្បាប់ (បានសៀវភៅគ្រប់ចំនួនតាមតម្រូវការសាលារៀន) |
| - ពង្រឹងសមត្ថភាពស្ថាប័នក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងធានាសុខដុមនីយកម្មក្នុងការអនុវត្តកម្មវិធីសិក្សា | ២ | - |
| - រៀបចំវិធីសាស្ត្របង្រៀនថ្មីតាមមុខវិជ្ជានៅកម្រិតមធ្យមសិក្សាដើម្បីអនុវត្តកម្មវិធីសិក្សាតាមបែបបញ្ញត្តិ និងពិនិត្យឡើងវិញកម្មវិធីសិក្សាតាមមុខវិជ្ជានីមួយៗ | ២ | - អភិវឌ្ឍឯកសារជំនួយការរៀន និងបង្រៀនតាមបែបបញ្ញត្តិ<br>- កម្មវិធីអប់រំសិល្បៈ ថ្នាក់ទី១-៣<br>- ឯកសារ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ក្នុងកម្មវិធីសិក្សាបឋមសិក្សាថ្នាក់ទី៤ ទី៥និងទី៦<br>- អភិវឌ្ឍឯកសារជំនួយការរៀននិងបង្រៀនមុខវិជ្ជាសិក្សាសង្គមកម្រិតបឋមសិក្សា ថ្នាក់ទី៣-៦<br>- សេចក្តីណែនាំការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន<br>- ឯកសារណែនាំបង្រៀនបំណិនជីវិតតាមមូលដ្ឋាន |
| - រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មី | ៣ | - ជំងឺកូវិត -១៩ |
| - រៀបចំវគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនថ្មីនៅតាមសាលាគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំ | ៣ | - ជំងឺកូវិត -១៩ |
| - អភិវឌ្ឍឯកសារជំនួយវិធីសាស្ត្រនៃការបង្រៀន និងរៀនភាសាខ្មែរ សម្រាប់បឋមសិក្សាថ្នាក់ទី១-២ និងឯកសារជំនួយអក្សរសិល្ប៍បរទេស | ៣ | - ធ្វើបន្តអក្សរសិល្ប៍ចំនួន ៣អត្ថបទ និងសិល្បៈ៣ |
| - អភិវឌ្ឍឯកសារជំនួយវិធីសាស្ត្រនៃការបង្រៀនតាមបែបគោលវិធីស្វែម និងសៀវភៅណែនាំផលិតសម្ភារឧបទេសមុខវិជ្ជាសិក្សាសង្គម និងឯកសារជំនួយស្តីពី ការប្រែប្រួលអាកាសធាតុបឋមសិក្សា | ២ | - ឯកសារ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ក្នុងកម្មវិធីសិក្សាបឋមសិក្សាថ្នាក់ទី៤ ទី៥និងទី៦<br>- ការអភិវឌ្ឍឯកសារជំនួយការរៀននិងបង្រៀនមុខវិជ្ជាសិក្សាសង្គមកម្រិតបឋមសិក្សា ថ្នាក់ទី៣-៦<br>- កែលម្អកម្មវិធីសិក្សាលម្អិតផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ ភាសាខ្មែរ និងសិក្សាសង្គម ដោយផ្អែកលើយោបល់របស់អ្នកជំនាញសិង្ហបុរី និងបច្ចុប្បន្នកម្ម<br>- សេចក្តីណែនាំការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន<br>- ឯកសារណែនាំបង្រៀនបំណិនជីវិតតាមមូលដ្ឋាន |
| - ពិនិត្យតាមដាននិងគាំទ្រការអនុវត្តកម្មវិធីសិក្សា ភាសាអង់គ្លេស ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ បណ្ណាល័យ និងសៀវភៅសិក្សាគោល | ៣ | - ជំងឺកូវិត -១៩ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - ផ្សព្វផ្សាយឯកសារជំនួយការបង្រៀន និងរៀនភាសាអង់គ្លេសថ្នាក់ទី៤-៦ ស្តង់ដាបណ្ណាល័យបឋមសិក្សា ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន អប់រំកុមារពីការបង្ការគ្រោះថ្នាក់ផ្សេងៗ និងគ្រាប់មីន និងផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ EPRP | ៣ | - សិក្ខាសាលា ១០លើកទាក់ទងនឹងវិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សាលម្អិត ៥២០នាក់ស្រី ១៣៦នាក់<br>- ផ្សព្វផ្សាយស្តង់ដាបណ្ណាល័យ ២២៤នាក់ ស្រី ៥៣នាក់<br>- អប់រំអំពីមីននិងកូវិត-១៩ ចំនួន ៦ ៦៣៦នាក់ ស្រី ២ ៧៣២ នាក់ |
| - រៀបចំទិវាជាតិអំណាន និងវេទិកាអំណាន។ | ២ | - រៀបចំទិវាអំណានមានអ្នកចូលរួមប្រមាណ ២០០ នាក់ |
| **៨. ការងាររដ្ឋបាល** | | |
| - បន្តពង្រឹងការគ្រប់គ្រងលិខិតរដ្ឋបាល ពិសេសចរាចរលិខិត | ១ | - ការងារចេរាចរលិខិតមានភាពរលូន |
| - ជំរុញការផ្តល់គ្រឿងឥស្សរិយយសការងារជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងក្រោមជាតិ | ១ | - ទទួលអនុក្រឹត្យ ២៨ច្បាប់ មានបុគ្គលិកអប់រំ ៩ ១៤៥ នាក់ ស្រី ៣ ៥៨៤ នាក់ ស្មើ ៣៩,១៩ ភាគរយ |
| - អភិវឌ្ឍសមត្ថភាពការងារគ្រប់គ្រងរដ្ឋបាលអប់រំ ពិធីការ របាយការណ៍ និងបណ្ណសារ | ២ | - បំប៉នបុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីការគ្រប់គ្រងរដ្ឋបាលអប់រំ ៥៦ នាក់ ស្រី ១៤ នាក់ |
| - គ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធទិន្នន័យឯកសារ និងបណ្ណសារដ្ឋាន | ១ | - ចងក្រងសំណុំលិខិត ចំនួន ៣១៥ សំណុំ<br>- ស្កេនឯកសារ ឆ្នាំ២០១៩ ចំនួន ២១ ៥៤២ ច្បាប់<br>- បញ្ចូលទិន្នន័យ ឯកសារក្នុងប្រព័ន្ធគ្រប់គ្រងបណ្ណសារ Admindms.com ឆ្នាំ២០០១១៩ ចំនួន ២១ ៤៨២ និងប្រកាសឆ្នាំ២០១៦ និង២០១៧ ចំនួន ២ ២៥៥ ច្បាប់ |
| - ពិនិត្យតាមដានការងារគ្រប់គ្រងរដ្ឋបាលអប់រំ បណ្ណសារ និងការងារប្រឡងប្រណាំង។ | ១ | - |
| **៩. ការងារសំណង់សិក្សា** | | |
| - ធ្វើវិចារណកម្មដោះស្រាយសំណូមពរអាទិភាពនិងបន្ទាន់ដោយខិតខំឱ្យអស់លទ្ធភាពកៀរគរធនធានពីគ្រប់ប្រភព | ១ | - មានអគារសិក្សាប្រើប្រាស់គ្រប់គ្រាន់ សមរម្យ កាត់បន្ថយបាននូវសំណូមពរ និងតម្រូវការពីគ្រប់ប្រភព |
| - ពង្រឹងយកចិត្តទុកដាក់លើការងារគ្រប់គ្រង ថែទាំ ជួសជុលហេដ្ឋារចនាសម្ព័ន្ធអប់រំ តាមរយៈសិក្ខាសាលាស្តីពីការងារនេះដល់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងគណៈកម្មការគ្រប់គ្រងសាលា | ១ | - នាយក នាយិកា មានចំណេះដឹងគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធតាមមូលដ្ឋានប្រកបដោយប្រសិទ្ធភាព |
| - ជ្រើសរើសមន្ត្រីជំនាញ រដ្ឋបាល ផែនការ វិស្វករសំណង់ ស្ថាបត្យករ និងព័ត៌មានវិទ្យា និងរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីដែលមានស្រាប់។ | ១ | - មានមន្ត្រីជំនាញគ្រប់គ្រាន់ដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផលលើការងារចេរន្ត ។ |
| **១០. ការងារបោះពុម្ព និងចែកផ្សាយ** | | |
| - អភិវឌ្ឍសៀវភៅសិក្សាគោល ហ្វឹកហាត់ អំណានបន្ថែម និងសម្ភារឧបទេសផ្សេងៗ | ១ | - មានមន្ត្រីជំនាញ ធនធានថវិកា និងសម្ភារគ្រប់គ្រាន់ |
| - បោះពុម្ពសៀវភៅសិក្សាគោល ហ្វឹកហាត់ និងអំណានបន្ថែម | ១ | - មានមន្ត្រីជំនាញ និងម៉ាស៊ីនបោះពុម្ពគ្រប់គ្រាន់ |
| - ប្រមូលតម្រូវការនិងបែងចែកសៀវភៅសិក្សាគោលឱ្យដល់សាលារៀន | ១ | - មានមន្ត្រីជំនាញ ធនធានថវិកា និងសម្ភារគ្រប់គ្រាន់ |
| - ដឹកជញ្ជូនសៀវភៅសិក្សាគោលជូនសាលារៀនទូទាំងប្រទេស | ១ | - មានមន្ត្រីជំនាញ និងរថយន្តដឹកជញ្ជូនគ្រប់គ្រាន់ |
| - ពង្រីកការលក់សៀវភៅសិក្សា សម្ភារឧបទេស និងសម្ភារៈការិយាល័យជូនអតិថិជនទូទៅ។ | ១ | - មានមន្ត្រីជំនាញ និងបណ្ណាគារផ្ទាល់ខ្លួន |
| **១១. ការងារអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** | | |
| - អភិវឌ្ឍស្តង់ដាអធិការកិច្ចថ្នាក់ជាតិ | ១ | - សៀវភៅណែនាំស្តីពីនីតិវិធីអធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរដ្ឋ ដោយមានការទទួលស្គាល់ពី ឯកឧត្តមបណ្ឌិត្យសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| - ជំរុញនិងលើកទឹកចិត្តឱ្យដាក់ពាក្យបណ្តឹងតវ៉ាតាមឋានានុក្រម | ២ | - ទទួលពាក្យបណ្តឹងតវ៉ាមក អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុប្រមាណជា ៣០ ភាគរយ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - បំប៉នសមត្ថភាពមន្ត្រីអធិការកិច្ចស្តីពីកម្មវិធីអធិការកិច្ចផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែង | ១ | - បំប៉នសមត្ថភាពមន្ត្រីអធិការកិច្ចស្តីពីកម្មវិធីអធិការកិច្ចផ្សារភ្ជាប់ការអនុវត្តជាក់ស្តែង ១ ខេត្ត សិក្ខាកាមចូលរួម ៣២ នាក់ |
| - ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋកម្រិតភូមិភាគ | ១ | - ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ច ការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ១ ភូមិភាគ អ្នកចូលរួម ១៣៨ នាក់ |
| - ធ្វើអធិការកិច្ចការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១ | - ធ្វើនៅអង្គភាពថ្នាក់ជាតិ និង ក្រោមជាតិ ២៣៨ (សាកលវិទ្យាល័យ ០២ មន្ទីរអប់រំ យុវជន និងកីឡា ០៩ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុង ខណ្ឌ៤០ វិទ្យាល័យ ៦០ អនុវិទ្យាល័យ ៣៣ និង សាលាបឋមសិក្សា ៩៤) |
| - ត្រួតពិនិត្យវឌ្ឍនភាពលើការកែលម្អតាមអនុសាសន៍ នៅអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១ | - ពិនិត្យវឌ្ឍនភាពលើការកែលម្អតាមអនុសាសន៍នៅអង្គភាពថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សារដ្ឋ ៨៩ អង្គភាព (មន្ទីរអប់រំ យុវជន និងកីឡា០៤ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ក្រុង/ខណ្ឌ១៧ វិទ្យាល័យ ២០ អនុវិទ្យាល័យ ១៦ និង សាលាបឋមសិក្សា ៣២) |
| - ចុះស្រាវជ្រាវពាក្យបណ្តឹង និង/ឬបាតុភាពមិនប្រក្រតីពាក់ព័ន្ធវិស័យអប់រំ។ | ១ | - ស្រាវជ្រាវពាក្យបណ្តឹង ឬបាតុភាពមិនប្រក្រតីពាក់ព័ន្ធវិស័យអប់រំ០៨ ករណី តាមរយៈពាក្យបណ្តឹង និង ការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង |
| **១២. ការងារសវនកម្មផ្ទៃក្នុង** | | |
| - ជ្រើសរើសមន្ត្រីផ្នែកសវនកម្មផ្ទៃក្នុង ផ្នែកប្រព័ន្ធព័ត៌មានវិទ្យា និងរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីដែលមានស្រាប់ | ១ | - រៀបចំលិខិតសំណើសុំមន្ត្រីក្របខណ្ឌមានជំនាញពាក់ព័ន្ធ ៦រូប<br>- មន្ត្រីសវនកម្មផ្ទៃក្នុង ៨នាក់ បានបណ្តុះបណ្តាលស្តីពីសវនកម្មបច្ចេកវិទ្យាព័ត៌មាន ដោយជោគជ័យ |
| - បំប៉នសមត្ថភាពមន្ត្រីសវនកម្ម | ១ | - មន្ត្រីសវនកម្មផ្ទៃក្នុង ៩នាក់ ចូលរួមសវនកម្មសាកល្បងផ្ទាល់ជាមួយទីប្រឹក្សាបច្ចេកទេសក្នុងស្រុកនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ និងវិទ្យាល័យជប់វារី<br>- ធ្វើសវនកម្មសាកល្បង ដោយប្រើប្រាស់ឧបករណ៍សវនកម្មដែលរៀបចំដោយទីប្រឹក្សាបច្ចេកទេសក្នុងស្រុក នៅសាលាចំណេះទូទៅ ០៥<br>- ចូលរួមធ្វើសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បងលើប្រព័ន្ធ Mission Management System ជាមួយទីប្រឹក្សាបច្ចេកទេសក្នុងស្រុក ប្រចាំអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- កំពុងធ្វើសវនកម្មសាកល្បងលើសមិទ្ធកម្ម និងគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាមួយទីប្រឹក្សាបច្ចេកទេសក្នុងស្រុក ប្រចាំអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - រៀបចំផែនការទំនើបកម្មផ្នែកសវនកម្មតាមប្រព័ន្ធបច្ចេកវិទ្យា | ៣ | - សមត្ថភាពមន្ត្រីមិនទាន់អាចអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មានបាន |
| - អនុម័តសៀវភៅណែនាំសវនកម្មផ្ទៃក្នុង | ២ | - បញ្ចប់សេចក្តីព្រាង និងរៀបចំសំណើសុំអនុម័ត |
| - អនុម័តផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល | ២ | - បញ្ចប់សេចក្តីព្រាងនិងរៀបចំសំណើសុំអនុម័ត |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| - ផ្សព្វផ្សាយដំណើរការគ្រប់គ្រងហានិភ័យដល់ប្រធានសវនដ្ឋានដែលមិនដែលរងសវនកម្ម ឬរងសវនកម្មតិចតួចតាមខេត្តគោលដៅ | ៣ | - ការរីករាលដាលនៃជំងឺកូវីដ-១៩ |
| - ពង្រឹងគុណភាពស្តង់ដារបាយការណ៍សវនកម្មផ្ទៃក្នុង។ | ២ | - ពង្រឹងនីតិវិធីសវនកម្មផ្ទៃក្នុង ដោយអនុវត្តតាមឧបករណ៍សវនកម្មផ្ទៃក្នុង |
| **១៣. ការងារធានាគុណភាពអប់រំ** | | |
| - ផ្តល់សម្ភារបរិក្ខារបច្ចេកទេសមួយចំនួនដល់ថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈទំនើបនិងទាន់សម័យ | ១ | - ផ្តល់កុំព្យូទ័រលើតុ ២៥ គ្រឿង និងម៉ាស៊ីនព្រីន ២៥ គ្រឿងទៅការិយាល័យអធិការកិច្ចគ្រប់រាជធានីខេត្ត<br>- ផ្តល់កុំព្យូទ័រលើតុ ២៥គ្រឿងទៅទៅការិយាល័យអធិការកិច្ចទាំង២៥ រាជធានីខេត្ត សម្រាប់ការធ្វើតេស្តថ្នាក់តំបន់(SEA-PLM) សហការជាមួយអង្គការយូនីសេហ្វ |
| - ជ្រើសរើសមន្ត្រីមានសមត្ថភាពផ្នែកវិភាគទិន្នន័យតេស្តកម្រិតខ្ពស់ និងរៀបចំបើកវគ្គបណ្តុះបណ្តាលមន្ត្រីដែលមានស្រាប់ | ១ | - ជ្រើសរើសមន្ត្រីកិច្ចសន្យាជំនាញផ្នែកវិភាគទិន្នន័យតេស្តកម្រិតខ្ពស់ ១ រូប<br>- បើកវគ្គបណ្តុះបណ្តាលមន្ត្រីអំពីការងារអធិការកិច្ច និងតេស្តវង្វាយតម្លៃដល់មន្ត្រីមិនមែនអធិការ |
| - បំប៉នសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាដើម្បីរៀបចំដំណើរការអនុវត្តតេស្តថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដល់មន្ត្រីការិយាល័យអធិការកិច្ចថ្នាក់ក្រោមជាតិ និងកម្រិតសាលារៀន | ១ | - បំប៉នសមត្ថភាពមន្ត្រីនាយកដ្ឋានដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាតាមរយៈថេប្លេតលើការវាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង សហការជាមួយអង្គការខេប<br>- បំប៉នសមត្ថភាពនាយកនិងគ្រូបង្រៀនស្តីពីការអនុវត្តតេស្តតាមរយៈថេប្លេត |
| - បំប៉នសមត្ថភាពសរសេរបាយការណ៍អធិការកិច្ច | ១ | - បំប៉នមន្ត្រីការិយាល័យអធិការកិច្ច ២៥ រាជធានី ខេត្តអំពីការសរសេរបាយការណ៍ |
| **១៤. ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ** | | |
| - បញ្ចប់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ ២០១៨ ចំពោះអង្គភាព ស្ថាប័នដែលនៅសេសសល់ | ២ | - ផ្ទៀងផ្ទាត់ទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់សាលារៀន ២២៥ |
| - ជំរុញ និងលើកទឹកចិត្តអង្គភាពមួយចំនួនឱ្យអនុវត្តតាមសេចក្តីណែនាំលេខ ៥៤ អយក.សណន ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងផ្គត់ផ្គង់សម្ភារបរិក្ខារ | ២ | - បង្កើតក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ថ្នាក់កណ្តាល |
| - រៀបចំស្តង់ដារបរិក្ខាររដ្ឋបាលគ្រឹះស្ថានបណ្តុះបណ្តាល និងផ្គត់ផ្គង់សម្ភារបរិក្ខារសម្រាប់ការងាររដ្ឋបាល និងកុំព្យូទ័រសម្រាប់ការរៀននិងបង្រៀនដល់គ្រឹះស្ថានសិក្សា | ២ | - ផ្គត់ផ្គង់សម្ភារបរិក្ខារសម្រាប់ការងាររដ្ឋបាលសាលារៀន ១៤២សាលា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ២៦ និងកុំព្យូទ័រសម្រាប់សិស្សរៀន ៩សាលា |
| - បំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុកការងារទ្រព្យសម្បត្តិរដ្ឋលើការប្រើប្រាស់ វាយតម្លៃការងារគ្រប់គ្រង និងធ្វើបច្ចុប្បន្នកម្មទិន្នន័យទ្រព្យសម្បត្តិរដ្ឋ | ១ | - បំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុកការងារទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត ២៣៧ នាក់ ស្រី ៤៣នាក |
| - ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០១៩ (បញ្ជីគោល) អនុវត្តនិតិវិធីជម្រះទ្រព្យសម្បត្តិរដ្ឋ និងបញ្ចូលទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ SARMIS | ១ | - បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ រួចរាល់ ៣១អង្គភាព (ថ្នាក់កណ្តាល ២៦ និងរាជធានី ខេត្ត ០៥) |
| - ជំរុញការធ្វើវិញ្ញាបនបត្រអចលនវត្ថុ និងការប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ។ | ១ | - ប្រមូលចំណូលបង់ចូលថវិការដ្ឋបាន ៣១៦ ៥៨៤ ដុល្លារអាមេរិក និង ១៥ ៩៦៤ ៧០០រៀល |

បញ្ជាក់៖ ១- អនុវត្តរួចរាល់ ២- កំពុងអនុវត្ត ៣- មិនទាន់បានចាប់ផ្តើមអនុវត្ត

## ឧបសម្ព័ន្ធទី៦ ៖ វឌ្ឍនភាពការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៩-២០២០ អនុវិស័យ

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| **១. អនុវិស័យ ការអប់រំកុមារតូច** | | |
| - បន្តកែលម្អ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធមត្តេយ្យសិក្សាគ្រប់រូបភាព | ២ | - ជួសជុល និងកែលម្អ រៀបចំថ្នាក់រៀន ១៤សាលា នៅខេត្តតាកែវ បន្ទាយមានជ័យ កំពង់ចាម ស្ទឹងត្រែង បាត់ដំបង ស្វាយរៀង ព្រៃវែង សៀមរាប កំពត និងខេត្តរតនគិរី<br>- បំពាក់បានបំពាក់ទូរទស្សន៍វៃឆ្លាត ៣១គ្រឿងតាមសាលាគោលដៅនីមួយៗ |
| - ពង្រឹងការអនុវត្តកម្មវិធីសិក្សាលម្អិត និងវិធីសាស្ត្របង្រៀនថ្មីសម្រាប់មត្តេយ្យសិក្សា | ១ | - ដាក់ឱ្យអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាជាផ្លូវការនៅទូទាំងប្រទេស និងឯកសារ " សិក្សាចិត្តសាស្ត្រសង្គមនៅមត្តេយ្យសិក្សា" នៅខេត្តរតនគិរី ក្រចេះ និងខេត្តព្រៃវែង |
| - បន្តរៀបចំកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍ និងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា | ១ | - អភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាផ្នែកមត្តេយ្យសិក្សា និងពិនិត្យនិងកែសម្រួលកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសហគមន៍ |
| - ពង្រឹងការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច | ២ | - រៀបចំពង្រាងការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យអប់រំកុមារតូច |
| - បន្តអនុវត្តកំណែទម្រង់ការគ្រប់គ្រងតាមសាលារៀនសម្រាប់មត្តេយ្យសិក្សាសាធារណៈ | ២ | - រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការអនុវត្តកំណែទម្រង់ការគ្រប់គ្រងតាមសាលារៀនសម្រាប់មត្តេយ្យសិក្សា |
| - រៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃស្ថានភាពអាហារូបត្ថម្ភកុមារនៅមត្តេយ្យសិក្សា | ២ | - រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការវាយតម្លៃស្ថានភាពអាហារូបត្ថម្ភកុមារនៅកម្រិតមត្តេយ្យ សិក្សា។ |
| - បន្តរៀបចំយន្តការ និងលិខិតបទដ្ឋានគាំទ្រការបង្កើតទារកដ្ឋានតាមរោងចក្រ សហគ្រាស និងសហគមន៍ | ២ | - សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងគ្រប់គ្រងទារកដ្ឋាន នៅតាមរោងចក្រសហគ្រាស និងគ្រឹះស្ថានសាធារណៈ |
| - ពិនិត្យកែលម្អយន្តការគាំទ្រពហុវិស័យ ក្របខណ្ឌគតិយុត្ត និងធនធានមនុស្សក្នុងអនុវិស័យអប់រំកុមារតូច | ២ | - កំពុងសិក្សាស្រាវជ្រាវលើយន្តការអនុវត្តអន្តរវិស័យស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច |
| - អនុម័ត និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៩ -២០២៣ | ២ | - ប្រជុំពេញអង្គនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូចអាណត្តិទី២ ដើម្បីអនុម័ត និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៩-២៣ |
| **២. អនុវិស័យ ការអប់រំបឋមសិក្សា** | | |
| - បញ្ចូលកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្ត | ២ | - បណ្តុះបណ្តាលគ្រូឧទ្ទេសសាលាគរុកោសល្យលើការអនុវត្តកញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ដំបូង<br>- ត្រូវពង្រីកនៅឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់ |
| - បង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំពហុភាសានៅសាលាគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ២ | - បំប៉នសមត្ថភាពស្តីពី វិធីសាស្ត្របង្រៀនថ្នាក់អប់រំពហុភាសា ដល់គ្រូនិងអ្នកពាក់ព័ន្ធ |
| - ពង្រឹងនិងពង្រីកការគ្រប់គ្រងតាមសាលារៀន | ២ | - អភិវឌ្ឍសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន សម្រាប់ដំណាក់កាលដំបូង និងបណ្តុះបណ្តាលដល់គ្រូឧទ្ទេសថ្នាក់ជាតិ និងថ្នាក់ |

| សកម្មភាព | ស្ថានភាព | មូលហេតុ |
|---|---|---|
| | | ក្រោមជាតិ<br>- អនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ នៅសាលាបឋមសិក្សាគោលដៅ ១៦០ លើសកម្មភាព ១)បង្កើតនិងបំប៉នគណៈកម្មការគ្រប់គ្រងសាលារៀន ២)ហ្វឹកហាត់ការលើដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ៣)ហ្វឹកហាត់ការលើការធ្វើតេស្តវាយតម្លៃការសិក្សា<br>- បន្តរៀបចំសេចក្ដីណែនាំប្រតិបត្តិស្ដីពីការគ្រប់គ្រងតាមសាលារៀនសម្រាប់ដំណាក់កាលបន្ត ដើម្បីពង្រីកការអនុវត្តនៅសាលារៀនគោលដៅ ១ ៥០០ បន្ថែមនៅទូទាំងប្រទេស |
